


ព.ស. ២៥៥៧ គ.ស. ២០១៤



# សមណនិស្សិត

## ភិក្ខុ ចង្កមាចិណ្ណោ ពេជ្រ សំណាង

ព.ស. ២៥៥៧ គ.ស. ២០១៤

# ជីវប្រវត្តិសង្ខេប

**-ភិក្ខុ ចង្គមាចិណ្ណោ ពេជ្រ សំណាង** ជនជាតិ ខ្មែរ សញ្ជាតិ ខ្មែរ

-ទីកន្លែងកំណើត ភូមិទឹកក្រហម ឃុំកណ្តោល ស្រុកកំពត ខេត្តកំពត

-កើតថ្ងៃសុក្រ ១២កើត ខែកត្តិក ឆ្នាំថោះ ព.ស. ២៥២៩

-បួសសាមណេរ នៅថ្ងៃទី០៩ ខែមេសា ព.ស.២៥៤៣ / គ.ស.២០០០ ស្ថិតក្នុងពទ្ធសីមាវត្ត កំពូលមាស (ហៅវត្តប្រឡាយ) ឃុំកណ្តោល ស្រុកកំពត ខេត្តកំពត។

-ឧបសម្បទាជាភិក្ខុ នៅថ្ងៃទី០៩ ខែមេសា ឆ្នាំ ព.ស.២៥៥១ / គ.ស.២០០៦ ក្នុងវត្តដដែលហើយ ព្រះឧបជ្ឈាយ៍ដូចគ្នា ព្រះគ្រូអនុគណ ព្រះនាម **ខៀវ ហង់** ខេត្តកំពត។

## ប្រវត្តិ និងការសិក្សា

-១៩៩៥-២០០១ សិក្សាពុទ្ធិកបឋមសិក្សា វត្តពិជ័យឧត្តុង្គ

-២០០២-២០០៥ សិក្សានៅសាលាវិទ្យាល័យពីរជាន់ (បឋមភូមិ)

-២០០៦-២០០៩ សិក្សាសាលាវិទ្យាល័យពីរជាន់ (ទុតិយភូមិ)

-២០០៩-បច្ចុប្បន្ន សិក្សានៅសាកលវិទ្យាល័យបៀលប្រាយ(ប.ជ)ផ្នែកគ្រប់គ្រងទូទៅ (ឆ្នាំទី៣) និងសាកលវិទ្យាល័យគ្រប់គ្រងនិងសេដ្ឋកិច្ច Marketing (ឆ្នាំទី៣) ថ្នាក់បរិញ្ញាបត្រ។

-សព្វថ្ងៃជាសមាជិកសមាគមអ្នកនិពន្ធខ្មែរ (វត្តបទុមវតី រាជធានីភ្នំពេញ)

-អាសយដ្ឋានបច្ចុប្បន្ន វត្តសូរិយារាម(វត្តថ្មី) ភូមិ បាលិលេយ្យ សង្កាត់ ប៉ោយប៉ែត ក្រុង ប៉ោយប៉ែត ខេត្ត បន្ទាយមានជ័យ។

Website:samnang24.blogspot.com

Email: monk_buddhism007@yahoo.com/ Tel:012222905/066999967

# អារម្ភកថា

បុព្វហេតុដែលធ្វើឱ្យខ្ញុំផ្ដើមរៀបរៀងសៀវភៅ "ចំណេះដឹងនានាក្នុងពុទ្ធសាស-នាខ្មែរ "មួយក្បាលនេះ ដែលអស់លោកអ្នកទាំងឡាយកំពុងកាន់អាននៅនឹងដៃ គឺកើតឡើងដោយសារខ្ញុំយល់ឃើញថា ក្នុងវិស័យពុទ្ធសាសនាយើង ខាងក្បួនច្បាប់សម្រាប់សិក្សាតែងមានការខ្វះខាត ម្យ៉ាងក្បួនច្បាប់ផ្សេងៗទាក់ទងនឹងពុទ្ធសាសនា ដែលបានបោះពុម្ពផ្សាយមិនបានពិនិត្យល្អិតល្អន់ពីស្ថាប័នជំនាញបណ្ដាលឱ្យមានកំហុសឆ្គងនាំឱ្យអ្នកសិក្សាយល់ដឹងខុសៗគ្នា ធ្វើឱ្យការប្រតិបត្តិក៏ចេះតែខុសៗគ្នាដែរ ។ឆ្លើយតបទៅនឹងតម្រូវការនៃពុទ្ធសាសនិកជនគ្រប់រូបនោះខ្ញុំបានព្យាយាមខិតខំស្រាវជ្រាវប្រមូលពីសៀវភៅជាច្រើនក្បាល យកមករៀបរៀងសៀវភៅនេះឡើងផ្ដុំចូលគ្នាតែមួយក្បាលប៉ុណ្ណោះរួចបញ្ជូនទៅស្ថាប័នជំនាញក្រសួងនៅរាជធានីភ្នំពេញ ដើម្បីត្រួតពិនិត្យមុននឹងធ្វើការបោះពុម្ពផ្សាយចែកជូនជាធម្មទាននោះ ។

ខ្ញុំគិតថាសៀវភៅនេះ មានអត្ថប្រយោជន៍យ៉ាងច្រើន ចំពោះលោកអ្នកដែលចូលចិត្តស្វែងយល់ចង់ដឹង ចង់រៀនព្រះធម៌ក្នុងពុទ្ធសាសនា។ ម្យ៉ាងទៀតទុកជាកេរ្តិ៍មរតកសម្រាប់កូនចៅក្មេងគ្រប់ជំនាន់ក្រោយៗបានសិក្សារៀនសូត្រនូវព្រះធម៌ថែមទាំងរបៀបធ្វើបុណ្យក្នុងពុទ្ធសានាផង ។

ដោយអំណាចអានិសង្សនៃការព្យាយាមប្រមូលចងក្រង សៀវភៅធម៌នេះសូមឱ្យព្រះពុទ្ធសាសនារុងរឿងចម្រើនរហូតដល់គ្រប់៥000ព្រះវស្សា និងឱ្យសព្វសត្វទាំងឡាយបាននូវសេចក្ដីសុខតាំងពីបច្ចុប្បន្ននេះរហូតដល់អនាគតជាតិកុំបីអាក់ខានឡើយ ។

បន្ទាយមានជ័យ,ថ្ងៃ១៥កើត ខែ ភទ្របទ ឆ្នាំ ព.ស. ២៥៥៥ / គ.ស. ២០១១

**ភិក្ខុចង្កមាចិណ្ណោ ពេជ្រ សំណាង**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងធម្មការនិងសាសនា**

## ចំណាប់អារម្មណ៍

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះភិក្ខុ **ពេជ្រ សំណាង** ដែលបានខិតខំព្យាយាមប្រឹងប្រែង ស្រាវជ្រាវ រៀបរៀងនូវសៀវភៅ "**ចំណេះដឹងនានាក្នុងពុទ្ធសាសនាខ្មែរ**" ដែលបានដកស្រង់ចេញពីសៀវភៅផ្សេងៗ ដើម្បីចងក្រងជាសៀវភៅនេះឡើង ក្នុងគោលបំណងបោះពុម្ពផ្សព្វផ្សាយជាធម្មទាន ក្នុងនាមខ្លួនខ្ញុំផ្ទាល់យល់ឃើញថា អាចផ្សព្វផ្សាយបាន ដើម្បីជាប្រយោជន៍ដល់ប្រជាជន ពុទ្ធបរិស័ទទូទៅបានសិក្សាស្រាវជ្រាវ។ ខ្ញុំសូមបញ្ជាក់ថា អនុញ្ញាតឲ្យផ្សព្វផ្សាយសៀវភៅនេះទៅតាមអ្វីដែលបានពិនិត្យចុងក្រោយរួចហើយ ។

រាជធានីភ្នំពេញ, ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១១

**រដ្ឋមន្ត្រី**

**មិន.ឃិន**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សមាគមអ្នកនិពន្ធខ្មែរ

## ចំណាប់អារម្មណ៍

អក្សរសាស្ត្រខ្មែរ មាននៅគ្រប់ទីកន្លែងទាំងអស់ ដែលកវីនិពន្ធបានសរសេរចងក្រងទុកសំរាប់ការអានរបស់ប្រជាពលរដ្ឋតាមតម្រូវការ។

នៅក្នុងដៃនេះ គឺជាសៀវភៅផ្នែកព្រះពុទ្ធសាសនាប្រសូតចេញពីអ្នកនិពន្ធជាបុព្វជិតមួយព្រះអង្គ ហើយព្រះអង្គ គឺជាសមាជិកអ្នកនិពន្ធមួយដែរ ដែលខំសំរិតសំរាំងអស់រយៈកាលជាងមួយឆ្នាំ ទើបបដិសន្ធិឡើងក្រោមចំណងជើងថា «**ចំណេះដឹងនានាក្នុងពុទ្ធសាសនាខ្មែរ**»

ខ្ញុំបាទក្នុងនាមប្រធានការិយាល័យរដ្ឋបាលនៃសមាគមអ្នកនិពន្ធខ្មែរសុំថ្លែងអំណរព្រះគុណចំពោះព្រះអង្គភិក្ខុ **ពេជ្រ សំណាង** ដែលជាម្ចាស់ស្នាដៃសៀវភៅនេះនិងស្រាវជ្រាវសំរាប់លើកស្ទួយវិស័យព្រះពុទ្ធសាសនា។

ភ្នំពេញ,ថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ២០១១

ប្រធានការិយាល័យរដ្ឋបាល

ស.អ.ខ.
KHMER WRITER'S ASSOCIATION

បណ្ឌិត.ខៀវ-កុសល

ចំណាប់អារម្មណ៍

ខ្ញុំព្រះករុណា បានអាន និងពិនិត្យសៀវភៅ
“ចំណេះដឹងនានាក្នុងពុទ្ធសាសនាខ្មែរ” របស់ព្រះតេជគុណ
ពេជ្រ សំណាង ដែលបាន [illegible] ជាពិសេស
[illegible] សៀវភៅនេះ [illegible]
[illegible] ពុទ្ធបរិស័ទ [illegible]
ទាក់ទងនឹងព្រះពុទ្ធសាសនា ។ សៀវភៅនេះ [illegible]
ខ្ញុំព្រះករុណា យល់ឃើញថា [illegible]
[illegible]
[illegible]
[illegible]
[illegible] ខ្ញុំព្រះករុណា [illegible]
[illegible]
ព្រះតេជគុណ [illegible]
[illegible]

[illegible] ថ្ងៃទី ២៧.១២.[illegible]

[signature]

[illegible]

ចំណាប់អារម្មណ៍

ថ្វាយព្រះករុណា ខ្ញុំបាទ បានទទួលសៀវភៅឈ្មោះ ចំណេះដឹងនានាក្នុងព្រះពុទ្ធសាសនាខ្មែរ ដែលរៀបរៀងដោយព្រះភិក្ខុ ពេជ្រ សំណាង បានឲ្យថ្វាយព្រះករុណា ខ្ញុំបាទ បានយកមកត្រួតពិនិត្យ និងពិសោធអានខ្លឹមសារ, សង្កេតឃើញ រួចហើយ ឃើញថា សេចក្ដីបកស្រាយលម្អិតនឹង ព្រះពុទ្ធ [illegible] និង [illegible] របស់ពុទ្ធបរិស័ទទៅ ឲ្យបានយល់ពីខ្លឹមសារជាក់ស្ដែង ងាយស្រួលក្នុងការ ប្រតិបត្តិ ឲ្យកាន់តែងាយស្រួលឡើង ជៀសវាងយល់ខុសពីការគោរព ពិត និងការប្រតិបត្តិខុស។

ធ្វើនៅភ្នំពេញ, ថ្ងៃទី២១ ខែ [illegible] 2011

[illegible]

# ចំណាប់អារម្មណ៍

សៀវភៅ ចំណេះដឹងនានាក្នុងពុទ្ធសាសនាខ្មែរ នេះដែលជាការប្រមូលចងក្រងពីសៀវភៅនានារបស់ អ្នកប្រាជ្ញ បណ្ឌិត អត្ថកោវិទខ្មែរ ដែលបានចេះចាំនូវពុទ្ធោវាទ របស់ព្រះបរមគ្រូជាម្ចាស់នៃយើង ដើម្បីរក្សាទុកសម្រាប់ឱ្យ កុលបុត្រ កុលធីតា ឧបាសក ឧបាសិកា បានចេះដឹង និងយល់បុណ្យកុសល ក្នុងផ្លូវព្រះពុទ្ធសាសនា។

សូមថ្លែងអំណរគុណចំពោះ **ភិក្ខុចង្កមាចិណ្ណោ ពេជ្រ សំណាង** ដែលបានខិតខំប្រឹងប្រែងអស់កម្លាំងកាយចិត្តនិងពេលវេលាក្នុងការចងក្រងសៀវភៅនេះដើម្បីជាប្រយោជន៍នៅក្នុងព្រះពុទ្ធសាសនាយូរអង្វែងតទៅ។

វត្តស្ទឹងបត់, ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ព.ស. ២៥៥៥ / គ.ស.២០១១

**ព្រះគ្រូអនុគណ**

និរមល្លោ ង៉ុក ចំរើន

# ចំណាប់អារម្មណ៍

សៀវភៅ ចំណេះដឹងនានាក្នុងពុទ្ធសាសនាខ្មែរ នេះដែលជាការប្រមូលចងក្រងពីសៀវភៅនានា របស់អ្នកប្រាជ្ញ បណ្ឌិតខ្មែរ ដែលបានចេះចាំនូវពុទ្ធឱវាទ របស់ព្រះបរមគ្រូជាម្ចាស់នៃយើង ដើម្បីតម្កល់ទុកឱ្យកុលបុត្រ កុលធីតា ឧបាសក ឧបាសិកា បានចេះដឹងសម្រាប់ធ្វើបុណ្យក្នុងផ្លូវព្រះពុទ្ធសាសនា។

ក្នុងនាម ខ្ញុំព្រះករុណាខ្ញុំបាទ ជាប្រធានការិយាល័យធម្មការ និងសាសនា ក្រុងប៉ោយប៉ែត សូមថ្លែងអំណរគុណចំពោះ **ភិក្ខុចង្កមាចិណ្ណោ ពេជ្រ សំណាង** ដែលបានខិតខំយកអស់កម្លាំងកាយចិត្ត និងពេលវេលាក្នុងការចងក្រងសៀវភៅនេះដើម្បីជាប្រយោជន៍ក្នុងព្រះពុទ្ធសាសនាតទៅ។

ប៉ោយប៉ែត, ថ្ងៃទី១៩ ខែតុលា ឆ្នាំ ព.ស.២៥៥៥ / គ.ស. ២០១១

ប្រធានការិយាល័យធម្មការ និងសាសនាក្រុង

ស៊ាង_សេងហុក

# ឧទ្ទិសកថា

ដោយអំណាចមហាកុសលដ៏ធំធេងនេះ ដែលកើតចេញពីការខិតខំប្រឹងប្រែងអស់ទាំងកម្លាំងកាយចិត្តនិងពេលវេលារបស់ខ្ញុំ សូមលើកជូនចំ-ពោះលោកអ្នកដ៏មានគុណទាំងពីរ សូមឧទ្ទិសមហាកុសលនេះថ្វាយ ប្រគេនជូនចំពោះលោកអ្នកប្រាជ្ញទាំងឡាយ មានសម្តេច ព្រះមហាសង្ឃរាជាធិបតី **ជួន ណាត** (ជោតញ្ញាណោ) ដែលបានចូលទិវង្គត កន្លងទៅនេះជាដើម ព្រមទាំងបុព្វបុរសទាំងឡាយ ដែលបានធ្វើពលិកម្ម បុព្វហេតុការពារបូរណ-ភាពទឹកដី និងសាសនា ឱ្យបានសុខសន្តិភាពដូចសព្វថ្ងៃនេះ រួមទាំងញាតិក្នុងវដ្តសង្សារទាំងអស់សូមឱ្យលោកអ្នកទាំងឡាយនោះបានរួចចាកពីទុគតិភពកុំបីអាក់ខានឡើយ ។

ថែមទាំងសូមថ្លែងអំណរព្រះគុណយ៉ាងជ្រាលជ្រៅចំពោះ ឯកឧត្តម **មិន ឃិន** រដ្ឋមន្ត្រី នៃក្រសួងធម្មការ និងសាសនាក្រុងភ្នំពេញ, បណ្ឌិត **ខៀវ កុសល**ជាបណ្ឌិតអក្សរសាស្ត្រខ្មែរនិងជាប្រធានរដ្ឋបាលក្នុងសមា-គមអ្នកនិពន្ធខ្មែរ ក្រុងភ្នំពេញ, លោក **សាន សម្ផស្ស** ទីប្រឹក្សារដ្ឋមន្ត្រី **មិន ឃិន** ភ្នំពេញ, លោក **យ៉ាន ហឿន** អតីតជាសមាជិកជំនុំព្រះត្រៃបិដកនៃពុទ្ធសាសនបណ្ឌិត្យភ្នំពេញ, ព្រះគ្រូបច្ឆិមសីមាវាសី **ប៊ុក ចំរើន** ជាព្រះគ្រូអនុគណ ក្រុងប៉ោយប៉ែត, លោក **ស៊ាន សេខហុក** ប្រធានការិយាល័យធម្មការ និងសាសនាក្រុងប៉ោយប៉ែត, ព្រមទាំងសហធម្មិកគ្រប់រូបគ្រប់ព្រះអង្គ ដែលបានផ្តល់យោបល់ និងចំណាយពេលវេលា ជួយត្រួតពិនិត្យសៀវភៅនេះ ។ម្យ៉ាងវិញទៀតសូមជូនបុណ្យកុសលចំពោះលោកអ្នកដ៏មានគុណទាំងឡាយ និងសប្បុរសជនគ្រប់ទិសទី ដែលបានចំណាយថវិកាជួយបោះពុម្ពសៀវភៅនេះ សូមបានទទួលនូវចំណែកនៃបុណ្យកុសល និងអានិសង្សស្មើនឹងខ្ញុំ កុំបីឃ្លៀងឃ្លាតឡើយ ។

*សូមអនុមោទនា !*

## នាមអ្នកដែលមានឧបការៈក្នុងការជួយពិនិត្យ អក្ខរាវិរុទ្ធ ខ្លឹមសារ វេយ្យាករណ៍ ចំពោះសៀវភៅនេះ

១-ឯកឧត្តម **មិន ឃិន** រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនារាជធានីភ្នំពេញ
២-លោក **ខៀវ កុសល** បណ្ឌិតអក្សរសាស្ត្រខ្មែរ និងជាប្រធានសមាគមអ្នកនិពន្ធខ្មែរផ្នែករដ្ឋបាល រាជធានីភ្នំពេញ
៣-លោក **សាន សម្ផស្ស** ទីប្រឹក្សាផ្ទាល់រដ្ឋមន្ត្រី**មិនឃិន** ក្រសួងធម្មការនិងសាសនា រាជធានីភ្នំពេញ
៤-លោក **យ៉ាន ហៀន** អតីតសមាជិកជំនុំព្រះត្រៃបិដកនៃពុទ្ធសាសនបណ្ឌិត្យ រាជធានីភ្នំពេញ

## ព្រះនាមនិងនាមអ្នកដែលមានឧបការៈក្នុងការជួយផ្តល់យោបល់និងគំនិតល្អៗចំពោះសៀវភៅនេះ

១-ព្រះគ្រូបច្ឆិមសីមាវាសី **ប៉ុក ចំរើន** ព្រះគ្រូអនុគណក្រុងប៉ោយប៉ែត
២-លោក**ស៊ាង សេងហុក** ប្រធានការិយាល័យធម្មការនិងសាសនាក្រុង
៣-គ្រូឧទ្ទេសាចារ្យ បញ្ញោបទីបោ **ញ៉ៀម សឿន** ចៅអធិការវត្តទួលពង្រ
៤-ភិក្ខុ **ជួង រដ្ឋា** ព្រះគ្រូចៅអធិការវត្តសូរិយារាម (វត្តថ្មី)
៥-ភិក្ខុ **អ៊ុំ សំអាត** គ្រូសូត្រឆ្វេងវត្តសូរិយារាម(វត្តថ្មី)
៦-គ្រូធម្មាចារ្យ ធម្មបាលោ **សោម សុភី** មេកុដិសាលាឆាន់វត្តថ្មី
៧-ភិក្ខុ **ឈិន ណារិទ្ធិ** មេកុដិឈើ វត្តថ្មី
៨-សាស្ត្រាចារ្យ **គីម ស្រួយ** ជានាយកវិទ្យាល័យសម្តេចឪ សិរីសោភ័ណ
៩-សាស្ត្រាចារ្យ **ថ័រ ឋុន្ធី** បង្រៀនសាកលវិទ្យាល័យបៀលប្រាយ
១០-សាស្ត្រាចារ្យ**ជួន សំណាង** បង្រៀនសាកលវិទ្យាល័យបៀលប្រាយ
១១-ព្រមទាំងសាស្ត្រាចារ្យ ញាតិញោម គុណម្ចាស់មួយចំនួនទៀតផងដែរ

# មាតិកា

**ឈ្មោះអត្ថបទ** **ទំព័រ**


អារម្ភកថា.......................................................................

ឧទ្ទិសកថា.......................................................................

## ពិធីបុណ្យនានា

កំណើតបុណ្យដារទក្ខិណានុប្បទាន..................................................១

កំណើតនៃសុរាមានក្នុងលោក..........................................................៤

កំណើតបុណ្យពូនភ្នំខ្សាច់...............................................................៧

កំណើតបុណ្យផ្កាប្រាក់.................................................................១១

កំណើតបុណ្យចូលឆ្នាំថ្មី................................................................១៤

កំណើតបុណ្យកតញ្ញូកតវេទី..........................................................២២

កំណើតបុណ្យកឋិន.....................................................................២៨

អានិសង្សកសាងបង្គន់.................................................................៣២

កំណើតបុណ្យបូជាព្រះច័ន្ទសំពះព្រះខែ............................................៣៥

ធម៌រំលឹកគុណព្រះរតនត្រ័យ...........................................................៣៧

## ពិធីការផ្សេងៗ

សាមណេរបព្វជ្ជាវិធី....................................................................៤៣

បាលីសុំទណ្ឌកម្ម.......................................................................៥១

បាលីចូលវស្សា....................................................................................៥២
បាលីលើកសត្តាហៈ................................................................................៥២
បាលីចេញវស្សា...................................................................................៥៣
ការលាចាកសិក្ខាបទ............................................................................៥៤
បាលីសម្តែងអាបត្តិ...............................................................................៥៨
ពាក្យសូមអារាធនាព្រះសង្ឃសម្តែងធម៌ទេសនា..................................៦០

## របៀបធ្វើពុទ្ធាភិសេក

របៀបធ្វើទាំង៩សង្កាត់........................................................................៦១
ធម៌សម្រាប់សូត្រពុទ្ធាភិសេក...............................................................៦២
បាលីស្រែកជយឃោស..........................................................................៦៣
នមោ៨បទ...........................................................................................៦៤
វិធីសមាទានឧបោសថសីល..................................................................៦៦
ឈ្មោះទីសេនាសនៈទាំងឡាយ..............................................................៦៩
វេរសង្ឃទាន........................................................................................៧០
វេរកឋិន..............................................................................................៧១
វេរផ្កាប្រាក់ប្រគេនព្រះសង្ឃ..................................................................៧២
វេរអង្ករ..............................................................................................៧៣
បាលីពូត និងបោះបាយបិណ្ឌ...............................................................៧៤
ពាក្យសម្រាប់ក្រើនកឋិន១-២.............................................................៧៥
បាលីសម្រាប់សូត្រកឋិន.......................................................................៧៧
ពិធីក្រុងពាលី......................................................................................៨២
អញ្ជើញព្រះភូមិទាំង៨ទិស....................................................................៩០

## ព្រះរាជជីវប្រវត្តិសម្តេចព្រះសង្ឃរាជ

ខាងគណៈមហានិកាយ.....................................................................៩១
និល ទៀង..........................................................................................៩១
កែ អ៊ុក..............................................................................................៩៤
ប្រាក់ ហ៊ិន.........................................................................................៩៦
ជួន ណាត...........................................................................................៩៨
ហួត តាត..........................................................................................១១៥
ទេព វង្ស...........................................................................................១១៧
ខាងគណៈធម្មយុត្តិកនិកាយ.........................................................១១៩
ប៉ាន................................................................................................១១៩
អៀម.................................................................................................១២០
ស៊ុក................................................................................................១២១
អ៊ុង ស្រី.........................................................................................១២២
ភុល ទេស.........................................................................................១២៣
ទេព លឿង.........................................................................................១២៤
ហ៊ី ជា..............................................................................................១២៤
ប៊ួរ គ្រី............................................................................................១២៥

## ធម៌សូត្ររំដោះគ្រោះ និងលើករាសី

ធមិចម្លងគ្រោះ.............................................................................១២៨
ធមិមហាមេឃ..............................................................................១២៩
ធមិលើករាសី..............................................................................១៣៩

## កងធម៌

## ធម៌ពួក២

ធម៌មួយមានឧបការច្រើន២យ៉ាង............................................១៤៦
ធម៌ជាលោកបាលធម៌២យ៉ាង..................................................១៤៦
ធម៌ធ្វើឱ្យល្អ២យ៉ាង..............................................................១៤៦
បុគ្គលរកបានដោយកម្រ២យ៉ាង................................................១៤៦
ទេសនា២យ៉ាង.....................................................................១៤៦
និព្វាន២យ៉ាង.......................................................................១៤៧
បូជា២យ៉ាង..........................................................................១៤៧
បដិសណ្ឋារៈ២យ៉ាង..............................................................១៤៧
មរណៈ២យ៉ាង.....................................................................១៤៧
សទ្ធា២យ៉ាង........................................................................១៤៧
សង្ខារ២យ៉ាង......................................................................១៤៨
សេចក្តីសុខ២យ៉ាង................................................................១៤៨
ធម៌ធ្វើឱ្យកើតសីល២យ៉ាង.......................................................១៤៩
សម្បត្តិឧបាសក២យ៉ាង..........................................................១៤៩
ពលៈធម៌ជាកម្លាំង២យ៉ាង........................................................១៤៩
ពហុស្សុតមាន២យ៉ាង.............................................................១៤៩
សាសនា២យ៉ាង.....................................................................១៤៩
ធម៌ធ្វើឱ្យកើតសីល២យ៉ាង.......................................................១៤៩

បង្គោល ឬ ចន្ទល់របស់សីល២ យ៉ាង..........១៤៩

**ធម៌ពួក៣**

រតនៈ៣យ៉ាង..........១៥០
គុណរបស់ព្រះរតនៈ៣យ៉ាង..........១៥០
អាការៈដែលព្រះពុទ្ធទ្រង់ប្រដៅ៣យ៉ាង..........១៥១
ឱវាទរបស់ព្រះពុទ្ធ៣យ៉ាង..........១៥១
ទុច្ចរិត៣យ៉ាង..........១៥១
សុចរិត៣យ៉ាង..........១៥២
អកុសលមូល៣យ៉ាង..........១៥៣
កុសលមូល៣យ៉ាង..........១៥៤
បញ្ញត្តិរបស់សប្បុរស៣យ៉ាង..........១៥៤
បុញ្ញកិរិយាវត្ថុ៣យ៉ាង..........១៥៥
សាមញ្ញលក្ខណៈ៣យ៉ាង..........១៥៥
ភ្លើង៣យ៉ាង..........១៥៥
កម្ម៣យ៉ាង..........១៥៥
ទ្វារ៣យ៉ាង..........១៥៦
អាសវៈ៣យ៉ាង..........១៥៦
អត្ថប្រយោជន៍៣យ៉ាង..........១៥៦
ធម្មនិយាម៣យ៉ាង..........១៥៦
បិដក៣យ៉ាង..........១៥៧

លោក៣យ៉ាង..........១៥៧
ញាណ៣យ៉ាង..........១៥៧
ព្រះសទ្ធម្ម៣យ៉ាង..........១៥៧
សម្បត្តិ៣យ៉ាង..........១៥៨
អភិសេកព្រះ៣យ៉ាង..........១៥៨
បុត្រ៣យ៉ាង..........១៥៨
សុខ៣យ៉ាង..........១៥៨
មូលហេតុកើតសរណគមន៍៣យ៉ាង..........១៥៩
សីលរបស់គ្រហស្ថមាន៣យ៉ាង..........១៥៩
កិច្ចដែលត្រូវចម្រើនថ្ងៃឧបោសថ៣យ៉ាង..........១៥៩
បង្អែកសាសនា៣យ៉ាង..........១៥៩
ម្លប់សាសនា៣យ៉ាង..........១៦០
មែកសាសនា..........១៦០
ចំណង៣យ៉ាង..........១៦០
ឫសគល់របស់ព្រះសូត្រ៣យ៉ាង..........១៦០
ឫសគល់របស់ព្រះវិន័យ៣យ៉ាង..........១៦០
ឫសគល់របស់ព្រះអភិធម្ម៣យ៉ាង..........១៦០
វត្ថុបរិភោគមិនឆ្អែត៣យ៉ាង..........១៦១
ស្រវឹង៣យ៉ាង..........១៦១
ទិដ្ឋិមានទោស៣យ៉ាង..........១៦១

ចែកមហាកុសល៨ប្រកបដោយចេតនា៣យ៉ាង............................១៦១
សមាធិ៣យ៉ាង......................................................................១៦២
អសុរ៣យ៉ាង.........................................................................១៦២
និព្វាន៣យ៉ាង......................................................................១៦២
ហេតុឱ្យកើតបុណ្យ៣យ៉ាង..................................................១៦២
បុណ្យចម្រើនព្រះជន្មមានន័យ៣យ៉ាង......................................១៦៣

## ធម៌ពួក៤

ធម៌ជាសេចក្ដីចម្រើន៤យ៉ាង..................................................១៦៣
កម្មដ្ឋានគួរចម្រើន៤យ៉ាង......................................................១៦៤
ព្រហ្មវិហារធម៌៤យ៉ាង..........................................................១៦៤
សតិប្បដ្ឋាន៤យ៉ាង...............................................................១៦៥
អបាយមុខ៤យ៉ាង..................................................................១៦៥
ប្រយោជន៍បច្ចុប្បន្ន៤យ៉ាង......................................................១៦៦
ប្រយោជន៍ខាងមុខ៤យ៉ាង.......................................................១៦៦
ការបែងចែកទ្រព្យជា៤ចំណែក................................................១៦៧
សុខរបស់គ្រហស្ថ៤យ៉ាង.......................................................១៦៧
សេចក្ដីប្រាថ្នាកម្រក្នុងលោក៤យ៉ាង.........................................១៦៧
ត្រកូលស្ដុកស្ដម្ភតាំងនៅ មិនបានយូរដោយហេតុ៤យ៉ាង................១៦៧
ធម៌របស់ឃរាវាស៤យ៉ាង.......................................................១៦៨
អបាយភូមិ៤យ៉ាង..................................................................១៦៨

ឱឃៈ៤យ៉ាង..........................................................................១៦៨
បរិស័ទ៤យ៉ាង......................................................................១៦៨
យោនិ កំណើត៤យ៉ាង..........................................................១៦៩
សទ្ធា៤យ៉ាង.........................................................................១៦៩
កូន៤ពួក...............................................................................១៦៩
ហេតុនាំឱ្យកើតសុខ៤យ៉ាង...................................................១៧០
លោកិយសរណគមន៍៤យ៉ាង..................................................១៧០
អត្ថរបស់សីល៤យ៉ាង...........................................................១៧០
ប្រាជ្ញ៤យ៉ាង.........................................................................១៧១
បុគ្គល៤ពួក..........................................................................១៧១
អានិសង្សកតញ្ញូ៤យ៉ាង.........................................................១៧១
ប្រេត៤ពួក............................................................................១៧១
ច្រូចទឹក៤យ៉ាង.....................................................................១៧២
អន្លង់ទាំង៤យ៉ាង..................................................................១៧២
អាចឆ្លងអន្លង់បានដោយធម៌៤យ៉ាង.........................................១៧២
ធម៌ធ្វើឱ្យជួបជុំគ្នា៤យ៉ាង........................................................១៧៣
សករាជ៤យ៉ាង......................................................................១៧៣
ព្រះពុទ្ធមាន៤យ៉ាង...............................................................១៧៥
ហេតុកើតលោភសោមនស្ស៤យ៉ាង.........................................១៧៥
ហេតុកើតឧបេក្ខា៤យ៉ាង......................................................១៧៦

ហេតុឱ្យកើតទោសមូលចិត្ត៤យ៉ាង..........................................១៧៦
អបាយភូមិ៤យ៉ាង..........................................................១៧៦
សត្វតិរច្ឆានចែកជា៤យ៉ាង..................................................១៧៧
មនុស្សក្នុងទ្វីបទាំង៤......................................................១៧៧
អសង្ខេយ្យកប្ប៤យ៉ាង......................................................១៧៨
ការប្រៀបធៀបអាយុកប្ប....................................................១៧៨
អាយុរបស់អរូបព្រហ្ម៤.....................................................១៧៩
រសមាន៤យ៉ាង.............................................................១៧៩
មាតា បិតាមានឈ្មោះ៤យ៉ាង...............................................១៨០

## ធម៌ពួក៥

អនន្តរិយកម្ម៥យ៉ាង........................................................១៨០
អាយុកាលនៃមហានរកនីមួយៗ..............................................១៨០
អភិណ្ហប្បច្ចវេក្ខណៈ៥យ៉ាង..................................................១៨១
ធម៌ធ្វើឱ្យក្លាហាន៥យ៉ាង......................................................១៨១
អង្គអ្នកសំដែងធម៌៥យ៉ាង....................................................១៨២
អានិសង្សស្តាប់ធម៌៥យ៉ាង....................................................១៨២
ធម៌ជាកម្លាំង៥យ៉ាង.........................................................១៨៣
ស្វាមីគប្បីទំនុកបម្រុងភរិយាដោយស្ថាន៥យ៉ាង..........................១៨៣
ភរិយាគប្បីទំនុកបម្រុងស្វាមីដោយស្ថាន៥យ៉ាង..........................១៨៣
មច្ឆរិយៈ៥យ៉ាង..............................................................១៨៤

មារ៥យ៉ាង........................................................................១៨៤
សម្បទា៥យ៉ាង....................................................................១៨៤
ស្ត្រីប្រកបដោយកល្យាណធម៌៥យ៉ាង..........................................១៨៥
វត្ថុតាងសម្រាប់ពុទ្ធសាសនា៥យ៉ាង.............................................១៨៥
ថ្ងៃ-ខែ-ឆ្នាំនៃព្រះពុទ្ធ.............................................................១៨៦
ក្នុងភទ្ទកប្បនេះព្រះពុទ្ធបានត្រាស់ដឹង.........................................១៨៧
ប្រតិទិនឆ្នាំនៃព្រះពុទ្ធ............................................................១៨៨
ចេតិយ៥យ៉ាង....................................................................១៨៨
ចំណងធំ១០ប្រការ...............................................................១៨៨
ភស្តុតាងលំអិត៥យ៉ាង...........................................................១៨៩
ពុទ្ធកិច្ចទាំង៥យ៉ាង...............................................................១៨៩
បុគ្គលដែលធរណីស្រូបជំនាន់ព្រះពុទ្ធគង់នៅ..................................១៩០
ពាក្យដែលត្រូវសួរ៥យ៉ាង........................................................១៩០
ព្យសនៈការវិនាស៥យ៉ាង.........................................................១៩១
ហេតុឱ្យកើតទិដ្ឋិកតសម្បយុត្តៈ៥យ៉ាង.........................................១៩១
សង្ស័យក្នុងអនាគត៥យ៉ាង......................................................១៩១
លោកិយអភិញ្ញា៥យ៉ាង..........................................................១៩២
បញ្ញាចក្ខុ៥យ៉ាង..................................................................១៩២
បុណ្យមានអានិសង្ស៥យ៉ាង.....................................................១៩៣
តួនាទីមាតាបិតា៥យ៉ាង..........................................................១៩៣
តួនាទីបុត្រ៥យ៉ាង.................................................................១៩៤

មហាបរិច្ចាគ៥យ៉ាង..........................................................................១៩៤

## ធម៌ពួក៦

ខ្ជិលធ្វើការងារមានទោស៦យ៉ាង..........................................................១៩៥
ហេតុឱ្យកើតអសង្ខារិកចិត្ត៦យ៉ាង.......................................................១៩៥
ហេតុឱ្យកើតសសង្ខារិកចិត្ត៦យ៉ាង.......................................................១៩៦
ធម៌ដែលជាហេតុលះទោសៈ៦យ៉ាង......................................................១៩៦
សង្ស័យក្នុងបច្ចុប្បន្ន៦យ៉ាង.................................................................១៩៧
ធម៌ជាហេតុកើតកុសលឧបេក្ខា៦យ៉ាង..................................................១៩៧
រស្មី៦ពណ៌...........................................................................................១៩៨

## ធម៌ពួក៧

អរិយទ្រព្យ៧យ៉ាង..............................................................................១៩៩
កុសលកម្មឱ្យផលផ្សេងៗគ្នា៧យ៉ាង.........................................................១៩៩
មាឃមាណពសមាទានវត្តបទ៧យ៉ាង........................................................២០០
ដើមឈើប្រចាំកប្ប៧យ៉ាង...................................................................២០០

## ធម៌ពួក៨

លោកធម៌៨យ៉ាង..................................................................................២០១
កម្លាំងមនុស្ស៨ប្រការ........................................................................២០១
ស្ត្រីមើលងាយប្តីដោយហេតុ៨យ៉ាង......................................................២០២
អានន្ទសូមពរ៨ប្រការពីព្រះពុទ្ធ.........................................................២០៣
សេចក្តីសង្ស័យ៨យ៉ាង........................................................................២០៣
សំឡេងរបស់ព្រហ្មប្រកបដោយអង្គ៨.....................................................២០៤

មហានរកជាវរណ្ដៅ.....................................................២០៤

**បកិណ្ណកធម៌**

ប្រេត១២ពួក.....................................................២០៥
ប្រេត២១ពួក.....................................................២០៦
អាយុនៅក្នុងទេវលោកនិងព្រហ្មលោក.....................................................២០៧
ស្ត្រីនឹងក្បត់ប្ដីដោយហេតុ៩យ៉ាង.....................................................២១១
បារមី១០យ៉ាង.....................................................២១២
ឱវាទធនញ្ជ័យសេដ្ឋី១០យ៉ាង.....................................................២១២
នាថករណៈធម៌១០យ៉ាង.....................................................២១៣
កថាវត្ថុ ពាក្យគួរពោល១០យ៉ាង.....................................................២១៣
អាឃាតវត្ថុ១០យ៉ាង.....................................................២១៤
បុញ្ញកិរិយាវត្ថុ១០យ៉ាង.....................................................២១៥
សម្មាទិដ្ឋិទស្សនៈ១០យ៉ាង.....................................................២១៦
សាកសព១០យ៉ាង.....................................................២១៧
ធម៌មួយមានឧបការៈច្រើន.....................................................២១៨
ធម៌មួយគួរកំណត់ដឹង.....................................................២១៨
ធម៌មួយជាចំណែកនៃសេចក្ដីវិនាស.....................................................២១៩
ធម៌មួយដឹងច្បាស់.....................................................២១៩
កម្ម១២យ៉ាង.....................................................២១៩
ឈាបនកិច្ច.....................................................២២០
ទសជាតក.....................................................២២០
មហាវេស្សន្តរជាតក១៣កណ្ឌ.....................................................២២២
នាមនៃអ្នកពោលនមោ.....................................................២២៣
ប្រយោជន៍ពោលនមោ.....................................................២២៣
សិក្ខាបទនៃអានិសង្ស.....................................................២២៤

អានិសង្សរបស់សីល១២យ៉ាង..................................២២៤
សិក្ខាបទផ្សេងៗនៃសីល..........................................២២៥
អង្គសីលនៃសិក្ខាបទនីមួយៗ.....................................២២៦
ធម៌ដែលស្ត្រីអាចប្រាថ្នាកើតជាប្រុស.............................២២៩
ពោធិបក្ខិយធម៌៣៧ប្រការ.......................................២២៩
សង្ស័យក្នុងព្រះសូត្រ១៦យ៉ាង....................................២៣០
តិរច្ឆានកថា..........................................................២៣១
គាថាផ្សេងៗ..........................................................២៣២
អានិសង្សផ្សេងៗ....................................................២៥១
ដំណើរនៃការត្រាស់ដឹងជាព្រះពុទ្ធ...............................២៦១
ស្ងួនកំណាព្យកម្សាន្តអារម្មណ៏.....................................២៦៥
អានិសង្សជួយបោះពុម្ពសៀវភៅធម៌ជាធម្មទាន១០ប្រការ...............៣១៨
ផ្សាយមេត្តាចិត្តដល់ពួកសត្វ........................................៣១៩
បរាភវសូត្រ............................................................៣២០
ធម៌ឱ្យពរជូនពរមនុស្សគ្រប់វ័យ.....................................៣២៧
ក្បួនហោរាសាស្ត្រ ទស្សន៍ទាយជោគជតារាសី ខ្ពស់-ទាប ..............៣៣១
អវសានកថា............................................................៣៣៧
ឯកសារយោង.......................................................៣៣៩
នាមសប្បុរសជនបានបរិច្ចាគបច្ច័យបោះពុម្ពសៀវភៅ.................៣៤១

# ពិធីបុណ្យនានា

## កំណើតបុណ្យ៧ថ្ងៃ

## ពរទាំងឡាយ៤ប្រការគឺ

**អាយុ** សូមឱ្យមានជន្មាវស្សាយឺនយូរ

**វណ្ណៈ** សូមឱ្យមានសម្បុរកាយរូបឆោមល្អ

**សុខៈ** សូមឱ្យបានសុខកាយសប្បាយចិត្ត

**ពលៈ** សូមឱ្យមានកម្លាំងកាយនិងកម្លាំងសទ្ធា

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស (៣ដង)**

ខ្ញុំព្រះករុណា សូមនមស្ការចំពោះគុណកែវព្រះរតនត្រ័យទាំងបី ដោយសេចក្ដីគោរពជ្រះថ្លាយ៉ាងក្រៃលែង។

ពិធីបុណ្យ៧ថ្ងៃនេះ ជាតិខ្មែរយើងតែងតែប្រារព្ធធ្វើមិនសូវខានពិសេសពេលក្រុមគ្រួសារណាមួយមានសមាជិកណាម្នាក់ស្លាប់ គឺមិនសូវចៀសរួចពីការប្រារព្ធធ្វើបុណ្យ៧ថ្ងៃនេះឡើយ។ យើងដឹងថា ព្រះពុទ្ធសាសនាមាននិយាយពីកម្មផលដែលបុគ្គលអ្នកស្លាប់ តែងស្ពាយទៅដោយអំពើជាកុសលនិងអកុសលជាប់ជាមួយប្រៀបនឹងស្រមោលអន្ទោលតាមប្រាណអ៊ីចឹង។ ដូច្នេះតើបុគ្គលអ្នកប្រព្រឹត្តនោះទីបំផុតនឹងបានទទួលទុក្ខឬសុខយ៉ាងណា? ព្រោះហេតុនេះទើបយើងឃើញថា ពិធីបុណ្យ៧ថ្ងៃ ញាតិមិត្តតែងធ្វើសឹងគ្រប់កន្លែង ដោយយោងតាមការបញ្ជាក់ទាក់ទងនឹងរឿងមានដូចតទៅ÷

# រឿងភិក្ខុតិស្សត្ថេរ

កាលព្រះសម្មាសម្ពុទ្ធបរមគ្រូគង់ក្នុងវត្តជេតពនជាអារាមរបស់អនាថ-បិណ្ឌិកសេដ្ឋីសាងថ្វាយព្រះអង្គ ក្នុងគ្រានោះ មានភិក្ខុសង្ឃជាច្រើនដែលបានបួសក្នុងសាសនាតាមមាគ៌ាព្រះអង្គ។ ក្នុងនោះគឺមានត្រកូលជាច្រើនចូលមកបួស មានទាំងត្រកូលអ្នកក្រ អ្នកមាន សេដ្ឋី គហបតី គ្រប់ស្រទាប់វណ្ណៈទាំងអស់ ដែលលះបង់ផ្ទះចូលមកសាងផ្នួស បួសជាបព្វជិតក្នុងវត្តជេតពន ពោលគឺពួកគេទម្លាក់វណ្ណៈទាំងនោះចោល ក្នុងនោះមានភិក្ខុមួយអង្គព្រះនាម **តិស្សត្ថេរ** ចេញពីត្រកូលក្រីក្រលំបាកតែមានសទ្ធាបួសក្នុងព្រះពុទ្ធសាសនាដោយស្មោះពីចិត្ត។ លោកតែងតែតូចចិត្តខ្លួនឯងដែលកើតក្នុងត្រកូលក្រីក្រហើយមិនមានស្បង់ចីវរថ្មីដូចសង្ឃដទៃទៀត។ ក្នុងសម័យថ្ងៃមួយ មានញាតិញោមអ្នកមានសទ្ធាជ្រះថ្លាចំពោះព្រះរតនត្រ័យ ឃើញព្រះអង្គតិស្សត្ថេរ ប្រើចីវរចាស់គាត់ក៏បានជាវចីវរថ្មីមួយសម្រាប់ ប្រគេនដល់ព្រះអង្គ។ និយាយពីភិក្ខុតិស្សត្ថេរក្រោយពីបានទទួលស្បង់ចីវរថ្មីហើយលោកមានចិត្តត្រេកអររីករាយសប្បាយដោយគិតថារបស់ថ្មីដូចនេះកុំអាលស្លៀកពាក់ប្រើប្រាស់អីចាំពេលមានពិធីបុណ្យណាធំៗម្តងទើបប្រើ។

ព្រះពុទ្ធអង្គទ្រង់ត្រាស់ថា សត្វលោកមិនអាចកំណត់អាយុខ្លួនឯងថា ត្រូវស្លាប់អាយុប៉ុណ្ណោះប៉ុណ្ណោះបាននោះទេ វាមិនទៀងទាត់ទេ ដែលលោកសម្តែងថាអនិច្ចំនេះឯង ភិក្ខុតិស្សត្ថេរក៏ដូចគ្នាក្រោយពីព្រះអង្គបានទទួលចីវរថ្មី មិនទាន់បានប៉ុន្មានផងស្រាប់តែសុគតបាត់ទៅ ដោយចិត្តស្រឡាញ់ចីវរនោះដួងវិញ្ញាណរបស់លោកក៏ជាប់នឹងចីវរ បណ្តាលឱ្យចិត្តភ្នកបានកើតជាសត្វចៃធំមួយលើចីវរនោះទៅ។ និយាយពីពួកភិក្ខុទាំងឡាយដែល

គង់ក្នុងវត្តបាត់មិនឃើញអង្គតិស្សត្ថេរនោះយូរថ្ងៃ មានការឆ្ងល់បានទៅមើលកន្លែងសិង ទើបដឹងថា ភិក្ខុតិស្សត្ថេរនោះបានសុគតបាត់ទៅហើយ ខណៈនោះ ភិក្ខុទាំងអស់ឃើញចីវរនៅក្បែរនោះបម្រុងយកមកចែកគ្នាប្រើប្រាស់ស្រាប់តែឃើញសត្វចៃមួយធំកំពុងតែវារចុះវារឡើងហាក់ដូចជាការ-ពារ មិនចង់ឱ្យអ្នកណាយកចីវរនោះទេ ភិក្ខុទាំងឡាយមើលឃើញហេតុគួរឆ្ងល់យ៉ាងនោះ ទើបនាំគ្នាទៅចូលគាល់ព្រះដ៏មានព្រះភាគ ដែលគង់ក្នុងវត្តជេតពន ពេលនោះព្រះអង្គបានត្រាស់សម្តែងព្រះធម៌ទេសនាប្រារព្ធពីរឿងភិក្ខុតិស្សត្ថេរនោះ ប្រាប់ដល់ភិក្ខុទាំងឡាយថា ម្នាលអ្នកទាំងឡាយ សត្វលោកទាំងអស់នៅពេលជិតស្លាប់ កាលបើជននោះរឭកយកអ្វីជាអារម្មណ៍ ហើយអាចធ្វើឱ្យវិញ្ញាណជននោះទៅជាប់នឹងរបស់នោះបាន ដូចយ៉ាងភិក្ខុតិស្សត្ថេរអង្គនេះដែរ ដោយហេតុតែ ស្រឡាញ់ពេញចិត្តនឹងចីវររបស់ខ្លួន ដែលមិនទាន់បានប្រើប្រាស់ផងស្រាប់តែសុគតទៅទើបបានកើតជាសត្វចៃមួយ ដូចដែលភិក្ខុទាំងឡាយបានឃើញនោះឯង ។

**កូនខុសហើយម៉ែ!**

ស្នេហ៍អើយស្នេហ៍ស្នោះ លះបង់ទាំងអស់ មិនស្រណោះអ្វី
ស្គាល់ចិត្តស្គាល់ថ្លើម នាំគ្នាចូលឆី Hotelល្បាញល្បី
នារាត្រីស្ងាត់ ។
នេះហើយស្នេហា ឥតបានពិចារណ៏ ធ្វើឱ្យបង់បាត់
កេរ្តិ៍ឈ្មោះដ៏ល្អ បវរពេកក្កាត់ បែរជារសាត់
បាត់គ្មានសល់អី ! (នៅមានត ១)

សៀវភៅនានាធម្មសង្គហ ដោយ ចក់ កន ឬសៀវភៅដារទក្ខិណានុប្បទាន (ចង់ដឹងកាន់តែច្បាស់ជាពិស្តារ)

# កំណើតនៃសុរាមានក្នុងលោក

តើសុរានេះមានតាំងពីពេលណាមក? ទើបមានរហូតមកទល់បច្ចុប្បន្ននេះ យើងគ្រប់គ្នាត្រូវគិតថាកម្លាំងសុរានេះខ្លាំងយ៉ាងណា? នៅពេលដែលបុគ្គលណាម្នាក់បានផឹកតើផ្តល់គុណសម្បត្តិឬគុណវិបត្តិយ៉ាងណាដែរ? ទោះបីយ៉ាងណាក៏ដោយតាមសាច់រឿងបានបញ្ជាក់ថាកាលណាមនុស្សបានផឹកសុរាហើយ សុរានោះវានឹងផ្តល់ផលមិនល្អដល់អ្នកផឹកវិញ ពិសេសមានការប្រមាទច្រើនដូចមានរឿងតំណាលថា

## រឿងធ្វើរព្រៃឈ្មោះសុរៈ

កាលដែលកន្លងទៅហើយព្រះបាទព្រហ្មទត្តសោយរាជ្យសម្បត្តិក្នុងក្រុងពារាណសី ។ សម័យកាលនោះមានធ្វើរព្រៃម្នាក់ឈ្មោះ**សុរៈ**គាត់បានទៅព្រៃហេមពាន្តដើម្បីប្រកបកិច្ចការផ្សេងៗ ។នៅព្រៃហេមពាន្តនោះមានឈើមួយដើមកម្ពស់មួយជំហរ បែកមែកជាបី ក្នុងប្រឡោះប្រគាបឈើនោះមានរណ្តៅធំប៉ុនពាង ។លុះដល់ធ្លាក់ភ្លៀងមកទឹកដក់នៅក្នុងរណ្តៅធំៗនោះថែមទាំងមានដើមសម៉ កន្ទួតព្រៃ និងម្រេចជាដើមដុះក្បែរដើមឈើនោះហើយផ្លែទាំងនោះតែងជ្រុះទៅក្នុងរណ្តៅនោះ ។ មិនតែប៉ុណ្ណោះសត្វបក្សីទាំងឡាយតែងពាំស្រូវសាលីទៅទំស៊ីហើយជ្រុះទៅក្នុងរណ្តៅនោះទៀត ។ ទឹកក្នុងរណ្តៅនោះ ក៏មានពណ៌ក្រហម មានរសជាតិខ្លាំងដល់រដូវក្តៅសត្វបក្សីទាំងឡាយ មានសេចក្តីស្រេកឃ្លានបានផឹកទឹកនោះក៏ស្រវឹង បម្រះនទៀលដួលជ្រប់នៅទៀបគល់ឈើនោះ បន្តិចក៏ស្រែកកញ្ជ្រៀវខ្សៀវខ្វារ

ហើរចេញទៅសូម្បីសត្វកំប្រុកស្វាកង្ហែនជាដើម ដែលបានផឹកទឹកនោះក៏មានទំនងដូចគ្នាដែរ ។ថ្មើរព្រៃបានឃើញហើយក៏គិតថាទឹកនេះមិនមែនពុលទេបើជាទឹកពុលសត្វ ដែលផឹកទាំងប៉ុន្មានមុខជាស្លាប់អស់ឥតសល់ហើយក៏ដងទឹកផឹកដរាបដល់ស្រវឹង ហើយបង្កាត់ភ្លើងចាប់សត្វដែលដួលជ្រប់ក្រាបក្បែរគល់ឈើសម្លាប់បោកអាំងស៊ីផឹកទឹកនោះអស់ពីរបីថ្ងៃ។ សម័យនោះមានតាបសមួយរូបឈ្មោះ **វរុណៈ**នៅក្នុងទីជិតនោះ ថ្មើរព្រៃដងយកទឹកនោះមួយបំពង់ឫស្សី និងដុំសាច់ដែលចម្អិនស្រេចនោះ ដើរទៅកាន់សំណាក់ **វរុណៈ** តាបសហើយបាននិយាយថា សូមលោកម្ចាស់ឆាន់ទឹកនោះចុះ! លុះឆាន់អស់កាលជាយូរថ្ងៃទើបទឹកនោះមានឈ្មោះ វរុណៈ ដោយហេតុតាបសនោះបានផឹកមុនគេ។ អ្នកទាំងពីរគិតគ្នាថាទឹកនោះវាសំខាន់ណាស់ក៏ដងចាក់ពេញបំពង់ឫស្សីជាច្រើន រួចរែកទៅស្រុកបច្ចន្តគ្រាមឱ្យអ្នកស្រុកក្រាបបង្គំទូលព្រះមហាក្សត្រថាមានអ្នកចេះធ្វើទឹកស្រវឹងយ៉ាងវិសេសទើបនឹងមកដល់ ។ព្រះមហាក្សត្រទ្រង់ត្រាស់បង្គាប់ ឱ្យអ្នកទាំងពីរចូលទៅគាល់ អ្នកទាំងពីរនាក់ក៏យកទឹកនោះទៅថ្វាយព្រះរាជា។ ទ្រង់សោយក៏ស្រវឹងស្រួលមែន លុះអស់ទឹកនោះទៅបានត្រាស់បង្គាប់ឱ្យដងយកទៅ ថ្វាយទៀត។ ជនទាំងពីរនាក់ទៅនាំទឹកសុរានោះបានពីរបីថ្ងៃទើបបបួលគ្នាថាយើងមិនអាចទៅយកជានិច្ចបានទេហើយក៏បានកំណត់យកគ្រឿងផ្សំគ្រប់មុខមកផ្សំធ្វើសុរាក្នុងនគរនោះ។ អ្នកនគរនាំគ្នាផឹកសុរាតែរាល់ៗគ្នាក៏ទៅជាអ្នកមានសេចក្ដីប្រមាទក្នុងការងារ ធ្លាក់ខ្លួនទៅជាជនកំសត់ទុគ៌តនគរ

នោះក៏សាបសូន្យ ចាកសេចក្ដីចម្រើនគ្រប់យ៉ាង អ្នកធ្វើសុរាក៏នាំគ្នារត់ទៅក្នុងនគរពារាណសី ឱ្យអ្នកនគរក្រាបទូលព្រះបាទពារាណសី ហើយទ្រង់បង្គាប់ឱ្យហៅមកទ្រង់ព្រះរាជទានស្បៀងអាហារឱ្យធ្វើសុរាថ្វាយ ។ នគរនោះក៏វិនាសដូចមុនទៀតអ្នកធ្វើសុរារត់ចេញពីទីនោះទៅនៅក្នុងនគរសាកេត ចេញពីនគរសាកេតទៅនៅនគរសាវត្ថី ។ គ្រានោះព្រះចៅក្រុងសាវត្ថីទ្រង់ព្រះនាមព្រះបាទ **សព្វមិត្រ** ព្រះអង្គបានធ្វើសេចក្ដីសង្គ្រោះដល់អ្នកដែលធ្វើសុរាទាំងពីរនាក់នោះ ទ្រង់ព្រះរាជទានទេយ្យវត្ថុផ្សេងៗ ដល់អ្នកទាំងពីរៗ ក៏បានធ្វើសុរានៅក្នុងនគរសាវត្ថីនោះអស់កាលជាយូរឆ្នាំ ការធ្វើសុរាក៏ចេះតែកើតបន្តៗពីត្រឹមនោះមក ។[១]

| | | |
|---|---|---|
| ស្រួលតែមួយភ្លែត | ភ្នែកបើកក្រឡែត | ចាំប្រុសសង្ហា |
| ក្រេបចន្ទទឹកឃ្មុំ | ហាក់ធំអស្ចារ្យ | បានប្រាណកាលណា |
| | ប្រុសប្រែដោះដៃ ។ | |
| ជ្រុលចិត្តជ្រុលកាយ | ខុសហើយទើបស្ដាយ | អាឡោះអាល័យ |
| ស្ដាយកេរ្ដិ៍ស្រីខ្មែរ | ក្បត់ទាំងប្រពៃណី | ធ្លាប់តែមានន័យ |
| | តាំងពីបូរាណ ។ | |
| | នៅមានត(២) | |

១-ឃិន-វ៉ន់ ប្រជុំបុញ្ញប្រវត្តិផ្សាយចេញដោយបណ្ណាគារ គីម-គី ព.ស. ២៥១៥ គ.ស.១៩៧២

# កំណើតបុណ្យពូនភ្នំខ្សាច់

បើតាមក្នុងគម្ពីរមហាសំការសូត្របានបញ្ជាក់ថាពេលសង្ក្រាន្តថ្មីជិតមកដល់ព្រះបាទ**បសេនទិកោសល**បានទូលសួរព្រះអង្គថាក្រោយពេលព្រះអង្គបរិនិព្វានទៅ កាលបើដល់សង្ក្រាន្តចូលឆ្នាំម្តងៗ តើខ្ញុំព្រះអង្គគួរបំពេញកុសលអ្វីខ្លះ? ព្រះពុទ្ធទ្រង់ត្រាស់សម្តែងថា គួរសាងវាលុកចេតិយនៅឆ្នេរស្ទឹងទន្លេហើយនាំយកគ្រឿងសក្ការៈ ទៀន ធូប គ្រឿងក្រអូប ផ្កាជាដើមមកបូជាចុះ ព្រះអង្គបានវិសេសណាស់ ដូចគ្នានឹងស្រង់ទឹកព្រះសង្ឃដែរ។ ដោយមានសេចក្តីអនុញ្ញាតយ៉ាងនេះហើយទើបបុណ្យពូនភ្នំខ្សាច់នេះបានបុណ្យកុសលច្រើនអនេក ដោយអាចសង្ឃឹម និងញញឹមទុកទៀតថា បុញ្ញកម្មដែលខ្លួនបានបំពេញនោះអាចសម្រាលបាបកម្មរបស់ខ្លួនម្នាក់ៗបាននេះចំពោះកាលដែលព្រះពុទ្ធអង្គគង់ធរមានទើបបុណ្យកុសលដែលជននោះបានធ្វើ គឺអាចទទួលបានផលភ្លាមៗដូចមានរឿងមួយបញ្ជាក់ថា បន្ទាប់ពីមាណពបានប្រគេនបាយមួយដុំដល់ព្រះបច្ចេកពុទ្ធមាណពនោះបានទៅកាន់ឋានសួគ៌៧ថ្ងៃ គឺដោយសារតែព្រះបច្ចេកពុទ្ធនោះ ទើបចាកចេញពីនិរោធសមាបត្តិថ្មីៗផងដូច្នេះទើបបុណ្យកុសលនោះ អាចផ្តល់ឱ្យភ្លាមៗយ៉ាងនេះ។ ផ្ទុយទៅវិញនៅពេលបច្ចុប្បន្ននេះយើងមិនអាចប្រៀបធៀបទៅនឹងសម័យព្រះពុទ្ធគង់នៅបានឡើយ ព្រោះយើងបានទាន់ត្រឹមតែសាសនាព្រះអង្គប៉ុណ្ណោះ។ ដូច្នេះនិទានទាក់ទងនឹងការពូនភ្នំខ្សាច់នេះមានដូចតទៅ

# រឿងអន្លំលោភកំនេទបុត្រ

កាលដែលកន្លងទៅហើយមានមាណពម្នាក់មិនចេះធ្វើបុណ្យ ដាក់ទានដល់សមណព្រាហ្មណ៍ណាមួយឡើយ ព្រោះមិនជឿទៅលើបុណ្យកុសល អ្នកធ្វើល្អបានល្អអ្នកធ្វើអាក្រក់បានផលអាក្រក់នោះទេហើយមាណពនោះជាមនុស្សចូលចិត្តធ្វើអំពើកាប់សម្លាប់សត្វផ្សេងៗដើម្បីចិញ្ចឹមជីវិតរបស់ខ្លួនជារៀងរាល់ថ្ងៃតាំងពីព្រឹកទល់ព្រលប់ ។ សម័យថ្ងៃមួយមាណពនោះបានក្រោកពីព្រលឹមរៀបចំខ្លួនប្រាណកាន់ស្នា និងបណ្តើរឆ្កែសំដៅទៅក្នុងព្រៃជ្រៅដើម្បីបរបាញ់សត្វនៅថ្ងៃនោះ ។ មាណពនោះ បាញ់សត្វមិនបានសោះ មូលហេតុមកពីមានព្រះបច្ចេកពុទ្ធមួយព្រះអង្គ ដែលទើបតែចេញពីនិរោធសមាបត្តិថ្មីៗ បាននិមន្តកាត់ជិតមាណព ធ្វើឱ្យសត្វទាំងអស់ភិតភ័យហើយរត់បាត់ទៅហើយព្រះបច្ចេកពុទ្ធនោះចេះតែនិមន្តតាមមាណពនោះ ។ រហូតទល់វេលាបាយថ្ងៃត្រង់ អស់កម្លាំងហេវហត់ មាណពក៏ចាប់ផ្តើមរៀបបាយកញ្ចប់បម្រុង នឹងបរិភោគ ស្រាប់តែព្រះបច្ចេកពុទ្ធនោះ មក-ដល់ខាងមុខមិនព្រមនិមន្តទៅណាសោះ ខណៈនោះមាណពនោះកាន់តែខឹងទៅៗតែក្នុងចិត្តគិតថាបើអាត្មាអញឱ្យបាយទៅសមណៈ នេះបន្តិចប្រហែលជាគាត់មិននៅរំខានអញបរបាញ់ទៀតទេ ។ក្សិណនោះក៏បានយកបាយមួយដុំមកដាក់បាត្រ ប្រគេនដល់ព្រះបច្ចេកពុទ្ធនោះ ព្រះពុទ្ធអង្គទ្រង់ត្រាស់សម្តែងថាសព្វសត្វទាំងឡាយ ឱ្យតែកើតមកហើយលើលោកិយនេះតែងតែដល់នូវសេចក្តីស្លាប់ជាទីបំផុតដូចៗគ្នា គ្រាន់តែមុន ឬក្រោយយូរឆាប់

តែប៉ុណ្ណោះ ។តែការស្លាប់នេះគឺមានគ្រប់សត្វទាំងឡាយត្រូវតែវិលកើតវិលស្លាប់ក្នុងវដ្តសង្សារមិនមានពេលស្រាកឡើយ ។ កាលបើបុគ្គលនោះបានប្រព្រឹត្តតែអំពើល្អគ្រប់យ៉ាងសន្សំបុណ្យកុសលច្រើនពេលស្លាប់អាចជួយបុគ្គលនោះឯងទៅកើតឋានសួគ៌ទេវលោក សោយសម្បត្តិទិព្វ មានស្រីទេពអប្សរមកចោមរោមជាបរិវារប្រកបសុខសប្បាយគ្រប់ពេលវេលា ។ តែផ្ទុយទៅវិញ បើបុគ្គលនោះបានធ្វើអាក្រក់ច្រើន នឹងទទួលរងទុក្ខវេទនាដោយមានទីកន្លែងមួយសម្រាប់រង់ចាំគឺឋាន **នរក ប្រេត សត្វតិរច្ឆាន** និង**អសុរកាយ** ។ ដូច្នេះជីវិតរបស់មាណពនោះ ក៏ដូចគ្នាដែរទិបំផុត ត្រូវមច្ចុរាជមកផ្តាច់អាយុរបស់មាណពនោះទៅដោយកម្មអកុសលដែលខ្លួនឯងបានកាប់សម្លាប់សត្វតូចធំរាប់មិនអស់ត្រូវធ្លាក់ទៅឋាន នរក សោយទុក្ខវេទនា ព្រោះកម្មរបស់ខ្លួនបានសាងកាលពីនៅរស់ ។ តែដោយបុណ្យកុសលអានិសង្ស ដែលបានប្រគេនបាយមួយដុំដល់ព្រះបច្ចេកពុទ្ធនោះអានិសង្សនោះគឺមិនបាត់ទៅណាឡើយ ។ ហេតុដូច្នេះ គាត់បានទៅសោយសុខក្នុងឋានសួគ៌ចំនួន៧ថ្ងៃដែលជាឋានមានលម្អដោយរតនសម្បត្តិផ្សេងៗ មានស្រីទេពអប្សរ កំដរចោមរោមជាបរិវារយ៉ាងច្រើន ដោយអំណាចអានិសង្សបុណ្យដែលមាណពនោះបានបំពេញធ្វើពេលនោះទើបមាណពនោះមានឈ្មោះថា **អន្នំលោកំ-ទេវបុត្រ**ពោលគឺបានប្រគេនបាយមួយដុំដល់ព្រះបច្ចេកពុទ្ធនោះឯង ។ ផលបុណ្យទាំងឡាយអាចឱ្យផលនាបច្ចុប្បន្នកាលក៏មាន ឱ្យផលនាបរលោកក៏មានដោយទិដ្ឋធម្មិកត្ថប្រយោជន៍និងសម្បរាយិកត្ថប្រយោជន៍ឱ្យផលភ្លាមៗ

ក្រោយពីបុគ្គលណាម្នាក់បានបំពេញធ្វើបុណ្យឱ្យទានរក្សាសីលចម្រើនមេត្តាភាវនាជាដើម ។ ព្រោះហេតុនេះហើយ ទើបមាណពនោះបានទៅសោយសម្បត្តិទិព្វចំនួនប្រាំពីរថ្ងៃតែប៉ុណ្ណោះ ។មាណពបានជាស្វាមីនៃនាង**សុវណ្ណ-ឱរ៉ៃ**ជាទេពធីតាដែលមានប្រាជ្ញាឆ្លាតលើសស្រីនានាក្នុងឋានសួគ៌នោះ ។នៅពេលដែល "**អន្លំលោកំឆេទបុត្រ**" បានជាស្វាមីនាងនោះហើយការសន្យាការពិភាក្សារវាងគ្នានឹងគ្នា រហូតដល់នាងធីតាបានដឹងហេតុ ដែលស្វាមីនាងបានមកកើតក្នុងឋានសួគ៌នេះដោយហេតុថាស្រឡាញ់ស្វាមីមិនចង់ឱ្យបែកពីនាងក៏រកវិធីជួយស្វាមីគឺធ្វើពិធីពូនភ្នំខ្សាច់រួចអធិដ្ឋានជា**វាលុកចេតិយ** ដល់ថ្ងៃកំណត់ពួកយមរាជយមបាលនាំគ្នាមកដើម្បីនាំមាណពទៅវិញ ពេលនោះ នាងដែលជាភរិយាបានប្រាប់ថា បើអ្នកចង់យកប្ដីខ្ញុំទៅចូរអ្នករាប់គ្រាប់ខ្សាច់នេះឱ្យអស់បើរាប់មិនអស់ទេកុំយកប្ដីខ្ញុំអីបើរាប់អស់ចាំយកទៅចុះ!បន្ទាប់មកពួកយមរាជយមបាលទាំងអស់បាននាំគ្នារាប់គ្រាប់ខ្សាច់ដែលនាងបានអធិដ្ឋានរួចនោះទោះបីអ្នកទាំងអស់នោះព្យាយាមយ៉ាងណាក៏រាប់មិនអស់ចេះតែកើនឡើងៗ ។ ទីបំផុតអ្នកទាំងនោះក៏ព្រមចុះចាញ់រួចនាំគ្នាត្រឡប់ទៅវិញអស់ទៅ ។ រឿងនេះចង់បញ្ជាក់អំពី ពិធីបុណ្យពូនភ្នំខ្សាច់ គឺមានចាប់តាំងពីពេលនោះមក ទើបអ្នកកាន់ព្រះពុទ្ធសាសនា ខិតខំរក្សារហូតមកទល់បច្ចុប្បន្ននេះ ។[២]

---

២-លោក ញាណ ភឿន និង ម៉ម ឆៃ លំអានទំនៀមទម្លាប់ខ្មែរបុរាណទំព័រ១៤៦ ផ្សាយដោយបណ្ណាគារ ស៊ីវ ស្រីម៉ៅ ព.ស២៥៤៨ ។

# កំណើតបុណ្យផ្កាប្រាក់សាមគ្គី

បុណ្យផ្កាដែលធ្វើដោយមានផ្កាជាសក្ការៈនោះមានពីរបែបគឺ

១-**បុណ្យផ្ការុក្ខជាតិ** និង**ផ្កាវារីជាតិ** គឺគេបេះតែផ្កាឈើ និងផ្កាឈូកថ្វាយព្រះពុទ្ធរូប ។

២-**បុណ្យផ្កាប្រាក់** គឺគេសន្មតប្រាក់ថាជាផ្កាបវារណាចំពោះព្រះដើម្បីសាងថាវរវត្ថុអ្វីមួយ ។

ប្រទេសកម្ពុជាយើង សម័យបុរាណពុទ្ធបរិស័ទទាំងឡាយទាំងព្រះរាជាទាំងប្រជារាស្ត្រ ទ្រង់តែងតែប្រារព្ធធ្វើបុណ្យរុក្ខជាតិ និងផ្កាវារីជាតិដោយយកផ្កាចងក្រងហើយ ហែយកទៅថ្វាយព្រះពុទ្ធនៅព្រះវិហារវត្តណាមួយដែលនៅជិត។ ព្រះរាជាតែងទ្រង់ធ្វើនៅខែវស្សា គឺនៅថ្ងៃ១៥កើតខែស្រាពណ៍ដោយទ្រង់ស្ដេចយាងទៅក្រសាលតាមបឹងតាមព្រះទីន័ង នាវាទ្រង់ព្រះរាជបញ្ជាឱ្យបេះ**ផ្កាឈូកស ឈូកក្រហម ព្រលិត លំចង់ ស្បង្ក័ជ** យកមកថ្វាយព្រះក្នុងព្រះរាជមន្ទីរហើយទ្រង់ចាត់ឱ្យហែហមដោយក្បួនហែដ៏មហោឡារិក យកទៅថ្វាយព្រះពុទ្ធរូបគ្រប់វត្តអារាម ដែលនៅជិតព្រះបរមរាជវាំង។ តែសព្វថ្ងៃដោយគេយល់ថា វត្តអារាមនីមួយៗតែងកសាងទីសេនាសនៈ ដូច្នេះទើបនិយមយកលុយមកចងក្រងជាផ្កា រួចបានវេរប្រគេនដល់ព្រះសង្ឃ ហើយបុណ្យផ្កាប្រាក់នេះគេទុកថា ជាបុណ្យធំមួយព្រោះគេបានរួមបច្ច័យ កសាងថាវរវត្ថុផ្សេងៗ ទាំងខាងពុទ្ធចក្រ និងអាណាចក្រអាចធ្វើជាប្រយោជន៏ដ៏ធំធេងសម្រាប់ធ្វើជាទីសេនាសនៈផ្សេងៗបានឈ្មោះថាធ្វើឱ្យសាសនារុងរឿងតទៅផង ។

# រឿងព្រះបទុមត្ថេរ

(គម្ពីរបាលីព្រះវិន័យ)

ត្រង់ភេសជ្ជករណាទិវិនិច្ឆ័យកថា ចែងពីប្រភពនៃបុណ្យផ្កាបានឮថាព្រះ **មហាបទុមត្ថេរ**នៅលង្កាទ្វីបកាលដែលរោគកើតឡើងដល់ព្រះរាជទេពី នៃព្រះមហាក្សត្រ ដែលស្និទ្ធស្នាលនឹងព្រះអង្គ ព្រះរាជាទ្រង់ចាត់ឱ្យស្រ្តីបម្រើម្នាក់មកសួរថ្នាំលោក ដោយសារលោកជាអ្នកកាន់វិន័យត្រឹមត្រូវមិនប្រាប់ថាចេះ ឬមិនចេះទេលោកធ្វើជាបែរទៅសួរពួកភិក្ខុថា ម្នាលអាវុសោ កាលដែលរោគដូច្នេះកើតឡើងដល់ភិក្ខុគេផ្សំថ្នាំនេះមួយៗ ។ស្រ្តីបម្រើបានឮក៏នាំដំណឹងនោះទៅទូលព្រះរាជា ព្រះរាជាបានជ្រាបក៏ចាត់ការឱ្យព្យាបាលរោគនោះដោយប្រើថ្នាំដូច្នោះក៏បានជាសះស្បើយទៅ។ កាលជាសះស្បើយហើយព្រះរាជាទ្រង់យកចីវរ១ត្រៃ និងរូបិយវត្ថុ៣០០កហាបណៈ ដាក់ក្នុងប្រអប់១ទៅតម្កល់ទុកជិតព្រះបាទាព្រះមហាបទុមត្ថេរ ហើយបវារណាថា **ភន្តេ បុប្ផ បូជំ ករោថ**បពិត្រព្រះករុណាម្ចាស់ដ៏ចម្រើន! ផ្កាទាំងអស់សូមព្រះកុរណាម្ចាស់ចាត់ចែងផ្កាបូជាព្រះពុទ្ធរូបចុះ។ ព្រះមហាបទុមត្ថេរទទួលដោយតុណ្ហីភាពហើយគិតថា រូបិយវត្ថុមួយចំណែកនេះ ជាចំណែកអាចារ្យ លុះគិតហើយក៏ឱ្យអាចារ្យនោះទទួលយក ចំណែកនោះដោយកប្បិយវោហារសល់ពីនោះលោកចាត់ ចែងបូជាព្រះពុទ្ធរូប។ សម័យបុរាណប្រហែលជាពុទ្ធសាសនិកជនយកតម្រាប់តាមរឿងនេះហើយ បានជាគេធ្វើបុណ្យផ្ការុក្ខជាតិ និងផ្កាប្រាក់ ជាពុទ្ធបូជារួមជាមួយគ្នាជាប់ជាប្រពៃណីនៅ

ក្នុងព្រះពុទ្ធសាសនាហើយសម័យតៗមកអ្នកមានសទ្ធាជ្រះថ្លាដែលត្រូវការកសាងថាវរវត្ថុផ្សេងៗ មានកុដិ ព្រះវិហារ សាលាបុណ្យ សាលារៀន ស្ពាន ស្រះជាដើមជារបស់ត្រូវចាយប្រាក់ច្រើនតែបើគេមានធនធានតិចមិនអាចសាងម្នាក់ឯងបានក៏ផ្តើមធ្វើជាបុណ្យផ្កាឡើង រួចរៃអង្គាសញ្ញាតិមិត្តឱ្យចូលប្រាក់ជួយកសាងថាវរវត្ថុនោះតាមកម្លាំងសទ្ធា។ តែតាមទម្លាប់ស្រុកខ្មែរនាសម័យបច្ចុប្បន្ន ទោះបីមានធនធានច្រើន ដែលអាចកសាងម្នាក់ឯងបានក៏ដោយតែមុននឹងធ្វើបុណ្យផ្កាគេផ្សាយដំណឹងបុណ្យនោះដល់ញាតិមិត្តជិតឆ្ងាយឱ្យជួយឧបត្ថម្ភគ្នាផង។ ជនអ្នកមានសទ្ធាជឿជាក់មុតមាំខ្លាំងក្លាប្រកបដោយអសង្ខារិកជ្រះថ្លាក៏តែងជួយចូលរួមកុសលជាច្រើន ទើបបានកំណត់បុណ្យនេះទៅ។[៣]

មិនគួរខ្លួនធ្លាក់ នៅក្នុងអន្ទាក់ ចាញ់ដៃប្រុសព្រាន
ភ្លេចអស់បណ្តាំ អ្នកម្តាយទូន្មាន ថាកូនគ្រប់ប្រាណ
ត្រូវចេះថែធួន។

កូនខុសហើយម៉ែ កូនមិនបានថែ ឱ្យល្អខ្ជាប់ខ្លួន
ផ្ទុកទាំងរោគអេដស៍ មាននៅក្នុងខ្លួន ព្រោះមិនស្តាប់ក្បួន
ពាក្យម៉ែធ្លាប់ស្តី។

នៅមានត(៣)

៣-ប្រជុំពិធីបុណ្យទំព័រ៩៣-៩៨ រៀបរៀងដោយឧត្តមប្រឹជា ចាប-ពិន ផ្សាយដោយបណ្ណាគារ សេង ងួន ហួត។

# កំណើតបុណ្យចូលឆ្នាំថ្មី

បុណ្យចូលឆ្នាំថ្មីជាប្រពៃណីជាតិយើង ដែលតែងតែធ្វើជារៀងរាល់ឆ្នាំ បើតាមទម្លាប់ខ្មែរ តែងប្រារព្ធនៅក្នុងខែចេត្រ ជាខែដែលប្រជាកសិករ ប្រមូលផលស្រូវរួចរាល់។ រីឯពិធីបុណ្យនេះដែលមាននិទានជាលំដាប់ ដូចតទៅ÷

## ១‧ពេលវេលាចូលឆ្នាំខ្មែរ

កាលដើមឡើយខ្មែរយើងប្រារព្ធធ្វើបុណ្យចូលឆ្នាំក្នុងខែមិគសិរ ព្រោះគេកំណត់យកខែនេះជាដើមឆ្នាំ។នាសម័យពីព្រេងនាយឆ្នាំនីមួយៗចែកជាបីរដូវគឺហេមន្តរដូវគិម្ហរដូវនិងវស្សានរដូវ។ បុរាណលោកគិតខែហេមន្តរដូវ រដូវត្រជាក់ចាត់ទុកជារដូវដើមឆ្នាំប្រៀបបាននឹងពេលព្រឹកដែលផុតពីរាត្រីគឺជាដើមថ្ងៃ។ គិម្ហរដូវ រដូវក្តៅត្រូវសន្មតទុកជាកណ្តាលឆ្នាំប្រៀបដូចជាពេលថ្ងៃត្រង់វស្សានរដូវជារដូវដែលមេឃមីរងងឹតមានភ្លៀងផ្គរត្រូវទុកជាចុងឆ្នាំប្រៀបបាន នឹងពេលព្រលប់។ ចំណេរកាលក្រោយមក គ្រាដែលបុព្វបុរសខ្មែរយើង អនុលោមប្រើចុល្លសករាជជាសំខាន់នោះមិនដឹងជាប្រើនៅក្នុងរដូវកាលនៃព្រះរាជាអង្គណាទេទើបការចូលឆ្នាំថ្មីមានការប្រែប្រួល ហើយកំណត់យកខែចេត្រជាខែដើមឆ្នាំវិញ ព្រោះបុព្វបុរសយើងយល់ថា ស្ថិតនៅក្នុងខែមិគសិរនេះប្រជានុរាស្រ្តកសិករខ្មែរយើងជាប់រវល់មមាញឹកក្នុងបេសកកម្មមានការរៀបចំធ្វើស្រែចម្ការជាដើម។ទើបលោកកំណត់យកពេលចូលឆ្នាំមកធ្វើនៅក្នុងកំលុងខែចេត្រវិញ ពីព្រោះថាខែចេត្រកិច្ចការ

ច្រូតកាត់បោកបែនរបស់ប្រជាកសិករបានចប់សព្វគ្រប់ហើយ បណ្ដាប្រជាពលរដ្ឋខ្មែរយើងមានពេលទំនេរមានឱកាស ដើម្បីធ្វើបុណ្យទានតាមធនធានរបស់ខ្លួនមាន។ ម្យ៉ាងទៀតបានកម្សាន្តសប្បាយតាមសេចក្ដីប្រាថ្នាការកំណត់នេះក៏ជាប់ជាប្រពៃណីរហូតមកដល់សព្វថ្ងៃនេះ ។ចំណែកថ្ងៃ,ខែ, ឆ្នាំខ្មែរ តែងប្រព្រឹត្តទៅមិនមុនថ្ងៃ៤កើតខែចេត្រ និងមិនក្រោយថ្ងៃ៤កើតខែ ពិសាខ ។

## ២-ទិដ្ឋភាពបុណ្យចូលឆ្នាំខ្មែរ

បុណ្យចូលឆ្នាំខ្មែរជាព្រឹត្តិការណ៍យ៉ាងធំមួយក្នុងទឹកចិត្តនិងជីវភាពខ្មែរ មុនពេលបុណ្យចូលឆ្នាំមកដល់ គេនាំគ្នារៀបចំបោសសម្អាត តុបតែងផ្ទះសំបែងសម្អាតទីធ្លាវត្តអារាម ផ្លូវថ្នល់ ចេតិយ រមណីយដ្ឋាន សង់រានទេវតា បុកអង្ករកខុសដងទឹក ត្រៀម សម្លៀកបំពាក់ថ្មីៗ។ល។ ឱ្យហើយស្រេច។ ពេលចូលឆ្នាំ ជាពេលជម្រះឧបទ្រពចង្រៃនៃឆ្នាំចាស់ ឱ្យជ្រះស្រឡះដើម្បីទទួលឆ្នាំថ្មីទេវតាថ្មីក្នុងក្ដីសោមនស្សក្សេមក្សាន្តនិងសុភមង្គល។ ឆ្នាំថ្មីមកដល់ ស្នូរស្គររគាំងសំឡេងធមិពរជ័យ លាន់ឮ រន្ទឺអឺងកង ចេញពីវត្តអារាម និងពីភូមិប្រជាជន ព្រោះវត្តខ្លះនៅឆ្ងាយពីភូមិគេរៀបចំកន្លែងមួយក្នុងភូមិរបស់គេ រួចនិមន្តព្រះសង្ឃមកភ្លើងទៀនឆេះព្រោងព្រាត ផ្សែងធូបហុយចេញពីគ្រប់រានទេវតាតាមដងផ្លូវមុខផ្ទះសំបែងវត្តអារាម។ ចាស់ទុំ ក្រមុំ កំលោះក្មេងក្មាងតូចធំប្រដាប់ប្រដាដោយសម្លៀកបំពាក់ស្អាតៗ ចេញមកទទួលទេវតាឆ្នាំថ្មី ។ម្នាក់ៗមានទឹកមុខរីករាយស្រស់ស្រាយ រំភើបក្រៃលែង

ក្រមុំ កំលោះ ក្មេងៗសប្បាយក្អាកក្អាយជាងគេ ព្រោះជាឱកាសដ៏ពិសេសបំផុតសម្រាប់ពួកគេចូលឆ្នាំថ្មីកម្សាន្តលេងល្បែងប្រជាប្រិយជាមួយគ្នាដោយគ្មានចាស់ទុំណាម្នាក់ឃាំងឃាត់អ្វីឡើយ ។ពេលព្រលប់គេនាំគ្នាទៅស្តាប់ធម៌អាថិជាការផ្តុំនូវកុសលសម្រាប់ជីវិតជាតិនេះនិងជាតិខាងមុខរួចក៏មកប្រមូលផ្តុំគ្នាលេងល្បែងប្រជាប្រិយផ្សេងៗតាមចំណង់ចំណូលចិត្ត ។

គេនាំគ្នាលេងល្បែង ចាប់កូនខ្លែង លាក់កន្សែង ក្រុងកូនមាន់ ទាញព្រ័ត្រ ឬច្រៀង ចម្រៀងប្រពៃណី ឬលេងស្តេចចង់ ចោលឈូងបោះអង្គញ់ លោតអន្ទាក់រាំវង់ ។ល ។យ៉ាងសប្បាយរីករាយ ។ ទោះបីយ៉ាងណាគេពុំភ្លេចរៀបចំចង្ហាន់ទៅប្រគេនដល់ព្រះសង្ឃ ដើម្បីបង្សុកូលឧទ្ទិសកុសលជូនបុព្វការីជនញាតិសន្តាន ដែលបានចែកឋានទៅកាន់បរលោកហើយនោះទេ ។ គេនាំគ្នាជញ្ជូនដីដាក់វត្តពូនភ្នំខ្សាច់ រែកទឹកស្រង់ព្រះពុទ្ធរូបព្រះសង្ឃចាស់ៗព្រឹទ្ធាចារ្យ ពេលត្រឡប់ដល់ផ្ទះវិញគេអញ្ជើញ មាតាបិតា ចាស់ទុំមកផ្ងូតទឹកហើយជូនសម្លៀកបំពាក់ថ្មីៗនំចំណីដើម្បីជាកិច្ចតបស្នងសងគុណចំពោះបុព្វការីជនរបស់គេជាទម្លាប់ដល់ថ្ងៃឆ្លងបុណ្យ គេពិនិត្យឃើញតាមក្រោមម្លប់ឈើធំៗ មានល្បែងប្រជាប្រិយផ្សេងៗ តាមចំណង់ចំណូលចិត្តរៀងៗខ្លួន អ្នកខ្លះទៀតគេនាំគ្នាទៅទស្សនាកម្សាន្ត ប្រាសាទបុរាណ និងរមណីយដ្ឋាន គោរពបូជាវត្ថុស័ក្តិសិទ្ធិភ្ជាប់បរិយាកាសរីករាយនេះទៅ នឹងបរិយាកាសសម័យពីព្រេងនាយដ៏រុងរឿង តាមតំបន់ជាច្រើនយ៉ាងសន្ធឹកសន្ធាប់ ។ នៅក្នុងប្រទេសពេលចូលឆ្នាំម្តងៗពួកគេមិនមែនសប្បាយត្រឹមតែ

រយៈពេល៣ថ្ងៃប៉ុណ្ណោះទេគេចាប់លេងសប្បាយរបៀបនេះមុននិងក្រោយថ្ងៃចូលឆ្នាំ ប៉ុន្មានថ្ងៃទៀតផង ហើយគេនាំគ្នាធ្វើបុណ្យកុសល ឱ្យអស់ចិត្តសប្បាយដើម្បីអបអរសាទរចំពោះជីវិតថ្មីរបស់គេ ដែលបានហៃលឆ្លងកាត់ឧបសគ្គទទួលជោគជ័យក្នុងរយៈពេលឆ្នាំចាស់កន្លងទៅ និងដើម្បីត្រៀមចាំទទួលភារកិច្ចថ្មី ត្រៀមចាំរដូវសាបព្រោះ ដកស្ទូង ត្រៀមចាំទឹកភ្លៀងដែលនឹងបង្អុរចុះមក នា ដើមវស្សានរដូវនៃឆ្នាំថ្មីដ៏ខ្លីខាងមុខ។

## ៣~ជំនឿទេវតាឆ្នាំថ្មី

ក្នុងសង្ក្រាន្តសូត្រនិទានថា ក្នុងដើមភទ្ទកប្បនេះមានបុរសម្នាក់ឈ្មោះ **ធម្មបាល**ជាអ្នកប្រាជ្ញចេះចប់ត្រៃវេទ ព្រមទាំងចេះភាសាសត្វទៀតផង។ ធម្មបាលតែងសម្តែងមង្គលដល់មនុស្សផងទាំងពួង ។សម័យនោះគេគោរពបូជាមហាព្រហ្ម។ **មហាព្រហ្ម**បានជ្រាបថា ធម្មបាលកុមារ ជាអ្នកប្រាជ្ញក៏មកសួរប្រស្នា៣ខហើយសន្យាថា ប្រសិនបើធម្មបាលដោះស្រាយប្រស្នានេះរួច កបិលមហាព្រហ្មនឹងកាត់ព្រះសិរខ្លួនបូជាធម្មបាល តែបើធម្មបាលដោះស្រាយប្រស្នាមិនរួចទេត្រូវកាត់ក្បាលបូជាមហាព្រហ្មវិញ។ ធម្មបាលសុំបង្អង់៧ថ្ងៃសិន ដើម្បីគិតប្រស្នាប៉ុន្តែ៦ថ្ងៃកន្លងផុតទៅ ហើយនៅតែគិតមិនឃើញសោះ ។ធម្មបាលក៏ភៀសខ្លួនទៅពួនក្រោមដើមត្នោតមួយគូដែលជាលំនៅនៃសត្វឥន្ទ្រី ។ជាភ័ព្វសំណាងល្អយប់នេះធម្មបាលក៏បានឮសត្វឥន្ទ្រី--ញី-ឈ្មោល និយាយគ្នាថា

-ញីៈ ព្រឹកនេះបានសាច់ពីណាស៊ី?

**-ឈ្មោលៈ** យើងនឹងបានស៊ីសាច់ធម្មបាល ដែលត្រូវកបិលមហាព្រហ្ម សម្លាប់ព្រោះដោះប្រស្នាមិនរួច។

**-ញីៈ** ប្រស្នានោះដូចម្ដេច?

**-ឈ្មោលៈ** ខទី១ វេលាព្រឹកសិរីនៅទីណា? ត្រូវឆ្លើយថានៅមុខហេតុនេះមនុស្សទាំងឡាយត្រូវយកទឹកលាងមុខ។

-ខទី២ ថ្ងៃត្រង់សិរីស្ថិតនៅត្រង់ណា? ត្រូវឆ្លើយថាស្ថិតនៅទ្រូងមនុស្សត្រូវលាងទ្រូងឬយកទឹកមកស្រឡាបលើទ្រូង។

-ខទី៣ ពេលយប់សិរីនៅទីណា? ឆ្លើយថានៅជើងដូច្នេះមនុស្សត្រូវលាងជើង។

ហេតុនេះពាក្យពេចន៍ទាំងប៉ុន្មានរបស់សត្វឥន្ទ្រីទាំងពីរក៏បានជាពន្លឺដល់ធម្មបាល ក្នុងការដោះស្រាយប្រស្នាកបិលមហាព្រហ្ម រួចចៀសផុតពីមរណៈ។ កបិលមហាព្រហ្ម សុខចិត្តចុះចាញ់កាត់ព្រះសិរបូជាធម្មបាល។ មុននឹងកាត់ព្រះសិរកបិលមហាព្រហ្មហៅទេពធីតា៧អង្គ ដែលជាបុត្រីរបស់ខ្លួនឱ្យយកពានមកទ្រព្រះសិរ ព្រោះបើដាក់ព្រះសិរនេះធ្លាក់លើផែនដីនឹងកើតជាអណ្ដាតភ្លើងឆេះអស់ ត្រឹមតែ៦០នាទី ទើបដង្ហែព្រះសិរនោះ ទៅប្រតិស្ឋានទុកនៅក្នុងមណ្ឌលភ្នំកៃលាស។ លុះដល់គម្រប់មួយឆ្នាំសង្ក្រាន្តថ្មីចូលមកដល់ ទើបនាងធីតាទាំង៧អង្គ ផ្លាស់វេនគ្នាមកដង្ហែព្រះសិរ កបិលមហាព្រហ្មប្រទក្សិណភ្នំព្រះសុមេរុជារៀងរាល់ឆ្នាំ។

**បុត្រទាំង៧អង្គនោះគឺ**

១-បើសង្ក្រាន្តចំថ្ងៃអាទិត្យ វេននាង **ទុង្សា**

២-បើសង្ក្រាន្តចំថ្ងៃចន្ទ ត្រូវនាង **គោរាគ**

៣-បើសង្ក្រាន្តចំថ្ងៃអង្គារត្រូវវេននាង **រាក្សសា**

៤-បើសង្ក្រាន្តចំថ្ងៃពុធ ត្រូវវេននាង **មន្ទា**

៥-បើសង្ក្រាន្តចំថ្ងៃព្រហស្បតិ៍ ត្រូវនាង **កិរិណី**

៦-បើសង្ក្រាន្តចំថ្ងៃសុក្រ ត្រូវវេននាង **កិមិរា**

៧-បើសង្ក្រាន្តចំថ្ងៃសៅរ៍ត្រូវវេននាង **មហោទរា**។

ដោយមានជំនឿបែបនេះទើបខ្មែរយើងបានរៀបចំពិធីបូជាទេវតាដែលត្រូវវេនដង្ហែព្រះសិរកបិលមហាព្រហ្ម និងត្រូវអភិបាលពិភពលោករៀងរាល់ឆ្នាំចូលមកដល់មិនដែលអាក់ខានឡើយ។

**៤-ជំនឿពិធីស្រង់ព្រះ**

មហាសំការសូត្រដែលមានមកក្នុងគម្ពីរជាតក ជាមគធភាសា បាននិទានថា ថ្ងៃសង្ក្រាន្តថ្មីជិតមកដល់ព្រះបាទ**បសេនទិកោសល** បានរៀបចំជារបាំយ៉ាងកុះករនៅឆ្នេរស្ទឹងមួយហើយក៏បាននិមន្តព្រះពុទ្ធ និងព្រះភិក្ខុសង្ឃស្រង់ទឹក រួចសមាទានសីល ហើយប្រគេនភត្តាហារចំពោះព្រះពុទ្ធព្រមទាំងភិក្ខុសង្ឃនៅទីនោះ។ គម្ពីរនេះដដែលបញ្ជាក់ទៀតថា អ្នកដែលបានស្រង់ទឹក **ព្រះសង្ឃ មាតាបិតា គ្រូ ឧបជ្ឈាយ៍** មានអានិសង្សច្រើនណាស់ អនាគតជាតិនឹងបានទៅកើតក្នុងទេវលោកបានសេចក្តីសុខគ្រប់យ៉ាង។ គម្ពីរបញ្ជាស

ជាតក ត្រង់ជាតកទី៣១បានបញ្ជាក់អានិសង្សនៃ ការស្រង់ទឹកព្រះសង្ឃ ដូចមហាសំការសូត្រដែរ គ្រាន់តែខុសគ្នាដោយមិនបានបញ្ជាក់ថា គឺនៅឱកាសចូលឆ្នាំឬនៅពេលណាប៉ុណ្ណោះ។ លោកលើកឧទាហរណ៍ ដូចជាព្រះ **បាទបុល្លរាជ** ដែលបាននិមន្ត**ព្រះឧសភត្ថេរ** ក្នុងសាសនាព្រះពុទ្ធសរណង្ករឱ្យស្រង់ទឹក ។លុះអនាគតជាតិទៅបានទៅកើតនៅទេវលោកមានបុណ្យបារមីច្រើនហើយ ទីបំផុតបានទៅជាស្តេចចក្រពត្តិក្នុងជម្ពូទ្វីបនេះ ។ ក្នុងរជ្ជកាលព្រះបាទជយវរ្ម័នទី៧ពេលចូលឆ្នាំម្តងៗគេតែងតែធ្វើពិធីដោយនិមន្តព្រះពុទ្ធរូបមានមហិទ្ធានុភាព២៥អង្គ ដែលតំណាងអាណាខេត្តទាំងឡាយ ក្នុងព្រះរាជាណាចក្រកម្ពុជា មកធ្វើជាពិធីស្រង់ទឹកនៅប្រាសាទ ជ័យស្រី (ប្រាសាទព្រះខ័ន) រួចដង្ហែព្រះពុទ្ធរូបទាំងនោះជាក្បួនយ៉ាងមហោឡារិកមុននឹងយកទៅតម្កល់នៅកន្លែងដើមវិញ ។ដោយមានជំនឿនិងមានទំនៀមទម្លាប់របស់ដូនតាយើងដូចពោលខាងលើនេះហើយ ទើបមានទម្លាប់ជាប្រពៃណី រហូតមកដល់សព្វថ្ងៃនេះហើយ ឱ្យតែដល់ពេលចូលឆ្នាំម្តងៗគេតែងតែធ្វើពិធីស្រង់ទឹកព្រះពុទ្ធរូប ព្រះសង្ឃ មាតាបិតា ជីដូនជីតា បុព្វការីជនតាមវត្តអារាម និងតាមភូមិស្រុក។ ពេលដែលធ្វើពិធីស្រង់ទឹកយើងគួរធ្វើតាមវិធីមួយដូចជាកូនចៅស្រង់ទឹកជូន មាតាបិតា ជីដូនជីតា ។ល ។យើងគប្បីរៀបកន្លែងមានគ្រែចងជាបុស្បុក មានពាងទឹក៤តាមជ្រុងគ្រែរួចកូនចៅលុតជង្គង់សូមខមាទោសមាតាបិតាជីដូនជីតាអំពីកំហុសខុសឆ្គង ដែលកូនចៅអនុវត្តខុសកន្លងមកជាសម្តីក្តី ឬកូនចៅមានទំនាស់

ទាស់ទែងជាមួយនឹងបងប្អូនខ្លួនប្រកាន់ពាក្យសម្ដីគ្នា ដែលធ្វើឱ្យ មាតាបិតាជីដូនជីតាព្រួយបារម្ភ និងសូមពរជ័យពីគាត់។ រួចបន្ទាប់មកថ្វាយបង្គំគាត់សុំអញ្ជើញទៅស្រង់ទឹក (តែគួរធ្វើពេលថ្ងៃក្ដៅជៀសវាងរងាញាក់នាំមានផលលំបាកខ្លាំងព្រោះគាត់ចាស់ៗ)។ បន្ទាប់មកអញ្ជើញគាត់ផ្លាស់សម្លៀកបំពាក់ថ្មីៗដែលកូនចៅបានជូនទៅគាត់នោះ។ រីឯពិធីស្រង់ព្រះនិងភិក្ខុសង្ឃលោកអាចារ្យណែនាំធ្វើតាមធម្មតាដែលធ្លាប់ធ្វើទៅចុះ[៤]។

| | | |
|---|---|---|
| រោគអេដស៏ស៊ីដា | កើតមានកាលណា | លើប្រាណប្រុសស្រី |
| មិនយូរមិនឆាប់ | តែងអាយុខ្លី | មច្ចុរាជប្រល័យ |
| | ឱ្យក្ស័យសង្ខារ។ | |
| ធ្លាប់តែសប្បាយ | មិត្តភក្ដិក្អាកក្អាយ | ល្បែងស្រីល្បែងស្រា |
| ភ្លេចស្រោមការពារ | ស្រើបស្រាលតណ្ហា | នាំគ្នាចូលបារ |
| | ទាំងចិត្តទោរទន់។ | |
| | នៅមានត(៤) | |

៤-លោក ញាណ ភឿន និង ម៉ម ឆៃ លំអានទំនៀមទម្លាប់ខ្មែរបុរាណទំព័រ១៤១-១៤៥ ផ្សាយដោយបណ្ណាគារ ស៊ីវ ស្រីម៉ៅ ព.ស. ២៥៤៨។

# កំណើតបុណ្យកតញ្ញូកតវេទី

ពិធីនេះភាគច្រើនគេនិយមធ្វើត្រឹមតែមួយយប់ និងមួយព្រឹកប៉ុណ្ណោះ ដោយមានការនិមន្តព្រះសង្ឃយ៉ាងតិច៤អង្គឡើងទៅ។ អត្ថន័យដែលធ្វើ គឺដើម្បីគោរពចំពោះលោកអ្នកជា មាតាបិតា ជីដូនជីតា និងសូមពរជ័យពីលោកមានគុណទាំងឡាយ។ របៀបធ្វើគេពិភាក្សាគ្នាជាមួយបងប្អូន សុំការឯកភាព តាមលទ្ធភាព អ្នកមានធូរធារ ក្រ និង មធ្យម ដើម្បីទិញសាដក និងវត្ថុផ្សេងៗសម្រាប់ធ្វើបុណ្យ។ព្រលឹមឡើងថ្ងៃកំណត់គេនិមន្តព្រះសង្ឃមកឆាន់ទាំងព្រឹកទាំង-ថ្ងៃត្រង់ឬថ្ងៃត្រង់តែម្តងក៏បានតាមលទ្ធភាព។ បើព្រះសង្ឃវត្តជិតផ្ទះ លោកនិមន្តទៅវត្តវិញជាធម្មតា រីឯពិធីនេះដំបូងអាចារ្យចាប់ពិធីបួងសួងទេវតាប្រកាសពិធីដែលកូនចៅមាននាមជាអាទិ៍គឺ .....មានកតញ្ញូចំពោះ.....ប្រារព្ធធ្វើពិធីនេះឡើង។

បន្ទាប់មកអាចារ្យនិយាយចំពោះសាមីខ្លួនកូនចៅណាមួយអាចនិយាយផ្ទាល់ពីការសុំខមាទោសនូវរាល់ទោសកំហុស ដែលកូនចៅបានប្រព្រឹត្តមិនសមហេតុផលចំពោះលោកមានគុណក្នុងកាលជាកន្លងនិង សូមប្តេជ្ញាគោរពរាប់អានស្រលាញ់បងប្អូន មិនធ្វើអំពើអាក្រក់ណាមួយឱ្យ មាតាបិតា ជីដូនជីតា ព្រួយបារម្ភឡើយ។ រួចលុតជង្គង់ គោរពជូនវត្ថុទាំងអស់នោះទៅលោកអ្នកដែលយើងបម្រុងជូន។ពេលកូនចៅជូនអ្នកមានគុណត្រូវជូនពរ ជ័យដល់កូនចៅផ្ទាល់មាត់បន្ទាប់មកអញ្ជើញគាត់ទៅផ្ងូតទឹក។

(ពិធីនេះមាននៅក្នុងពិធីស្រង់ព្រះ) បញ្ជាក់: ការធ្វើនេះមិនប្រកាន់ថាបងប្អូនមាមីងទេ។ ដោយការធ្វើកតញ្ញូកតវេទិនេះទោះបី បុរស- ស្ត្រី- គ្រហស្ថ បព្វជិតណាមួយក៏ដោយ ដែលបានទទួលផលប្រយោជន៍ និងសេចក្ដីសុខ ចម្រើនជាដើម អំពីអ្នកដទៃដែលគេបានទំនុកបម្រុងដល់ខ្លួនឱ្យបានប្រយោជន៍ណាមួយហើយ យើងមិនគួរបំភ្លេចគុណបំណាច់គឺសេចក្ដីល្អ ដែលអ្នកទាំងនោះបានធ្វើនោះទេគួរធ្វើកតវេទិតបស្នងសងគុណគាត់វិញ។ ម្យ៉ាងទៀត អានិសង្សកតញ្ញូកតវេទីនេះមានកម្លាំងធំធេងណាស់ដូចមាននិទានក្នុងរឿងសុវណ្ណសាមស្រាប់។

## រឿងព្រះសុវណ្ណសាម

ក្នុងកាលដ៏កន្លងទៅហើយនៅនគរមួយមាន អ្នកនេសាទពីរត្រកូលមានលំនៅឋានឆ្ងាយពីគ្នាម្នាក់នៅស្ទឹងម្ខាង ចំណែកម្នាក់ទៀតនៅស្ទឹងម្ខាងទៀតហើយអ្នកនេសាទទាំងពីរបានសន្យាគ្នាថា កាលបើយើងទាំងពីរបានកូនស្រីនិងកូនស្រីឱ្យធ្វើជាមិត្តបើកូនប្រុសមួយនិងស្រីមួយយើងធ្វើជាដន្លងនឹងគ្នាមិនយូរប៉ុន្មានត្រកូលទាំងពីរក៏បានកូនស្រីមួយនិងប្រុសមួយ។ លុះធំពេញវ័យម្ដាយឪពុក ក៏បានផ្សំអ្នកទាំងពីរជាគូភរិយា។ ទោះបីគេបានជាភរិយានឹងគ្នាក៏ដោយតែគេមិនប្រាថ្នាក្នុងកាមនោះទេ គឺចង់តែទៅបួសដើម្បីរួចចាកកាមទាំងឡាយ។ សេចក្ដីប្រាថ្នារបស់ជនទាំងពីរនោះ រឹតតែកើតមានខ្លាំងឡើងៗ រាល់ថ្ងៃទ្រាំមិនបានក៏នាំគ្នាសុំលាម្ដាយឪពុកទាំងសងខាងចេញទៅបួស។

ទោះបីម្ដាយឪពុកទាំងសងខាង យំសោកស្ដាយមិនបើកឱ្យបួសក៏ចេះតែទទូចលារឿយៗទាល់តែបាន។ លុះបានហើយម្ដាយឪពុក ក៏បានរៀបចំបរិក្ខារគ្រប់ប្រដាប់សម្រាប់ស្លៀកពាក់ជាឥសី ឱ្យកូនទាំងពីរដោយបំណងរៀងៗខ្លួនបានសម្រេចពេលអ្នកទាំងពីរបានបរិក្ខារគ្រប់គ្រាន់ហើយក៏ស្លៀកពាក់ជាឥសីលាម្ដាយឪពុក ធ្វើដំណើរចូលទៅក្នុងព្រៃហេមពាន្ត ដ៏ជាទីសែនស្ងាត់ចម្រើនមេត្តាភាវនាជាសុខសាន្ត។

វេលាមួយ **ព្រះអមរិន្ទ្រាធិរាជ**ស្ដេចបើកទិព្វចក្ខុមើលស្រាប់តែឃើញឥសីទាំងពីរនាក់ប្ដីប្រពន្ធត្រូវខ្វាក់ភ្នែកទាំងអស់គ្នានៅពេលខាងមុខ ដូច្នេះត្រូវតែមានកូនម្នាក់សម្រាប់បម្រើ។ពេលនោះព្រះឥន្ទក៏និម្មិតខ្លួនមកប្រាប់ដល់ឥសីទាំងពីរថា ម្នាលឥសីទាំងពីរ មិនយូរប៉ុន្មានទៀតទេអ្នកត្រូវខ្វាក់ភ្នែក។ ដូច្នេះចូលអ្នករួមសំវាសទៅទើបយើង នឹងនិមន្តទេវបុត្រមួយអង្គមកបម្រើអ្នក ខណៈនោះឥសីប្ដីប្រពន្ធមិនព្រមសោះបន្ទាប់មកព្រះឥន្ទក៏ប្រាប់បន្តទៀតថាបើអ៊ីចឹង ចូលអ្នកយកដៃទៅស្ទាប អង្អែល លើផ្ចិតតាបសីនៅពេលអធ្រាត្រណា! តាបសទាំងពីរថា បើគ្រាន់ប៉ុណ្ណោះបាន។ លុះឥសីទាំងពីរទទួលព្រម ដូច្នោះហើយព្រះឥន្ទក៏អារាធនា **សុវណ្ណសាមទេវបុត្រពោធិសត្វ** ឱ្យស្ដេចចុះចាប់បដិសន្ធិក្នុងផ្ទៃនាងបារិកាជាឥសី ដូចសេចក្ដីប្រាថ្នា។ សុវណ្ណសាមកុមារ វ័យធំឡើងម្ដាយឪពុកតែងទៅបេះផ្លែឈើជីកមើមឈើមកចិញ្ចឹមជារាល់ថ្ងៃ។ ថ្ងៃមួយជារដូវភ្លៀងមហាមេឃ បង្អុរភ្លៀង១មេយ៉ាងធំ តាបសទាំងពីររត់ជ្រកក្រោមដើមឈើមួយ ក្នុងដំបូក

ដែលមានពស់១ធំនៅក្នុងរូង។ តាបសទាំងពីរមិនដឹងថា មានពស់ក៏អង្គុយពីលើរូងនោះហើយញើសក្អែលស្រក់ទៅលើរូងនោះ។ ពស់នោះក៏បង្ហុយផ្សែងពិសវាមកត្រូវចំភ្នែក ហើយតាបសទាំងពីរនោះងងឹតភ្នែកទាំងពីរសូន្យឈឹងមើលគ្នាពុំឃើញអង្គុយយំនៅក្រោមដើមឈើនោះ រកផ្លូវទៅអាស្រមពុំរួច។ ព្រះសុវណ្ណសាមកុមារ ចាំម្តាយឪពុកនៅអាស្រមបាត់ពុំឃើញមកតាមកំណត់ពេលដូចសព្វដងក៏រត់រកសព្វច្រកល្ហក។ លុះឃើញម្តាយឪពុកងងឹតភ្នែកទាំងពីរនាក់ក៏ទួញយំហើយ ទ្រង់ដឹកដៃម្តាយឪពុកចេញទៅកាន់អាស្រមហើយសុវណ្ណសាមកុមារ កាប់បំពង់កូនឈើមកចងខ្វាត់ខ្វែងពីអាស្រមទៅបង្គន់ពីបង្គន់ទៅកាន់កន្លែងសម្រាកជាដើម។ ខ្លួនតែងតែទៅក្នុងព្រៃដងទឹក និងបេះផ្លែឈើមកជូនម្តាយឪពុករាល់ថ្ងៃ ក្នុងដំណើរទៅនោះ គឺតែងមានសត្វផ្សេងៗដើរអមហែទៅជាមួយ។ ថ្ងៃមួយពេលដែលសុវណ្ណសាមកុមារ ទៅដងទឹកដើម្បីលាងជម្រះកាយម្តាយឪពុកដោយមានសត្វក្តាន់ជាដើមបានដើរហែហាមអមសឹងតែមើល សុវណ្ណសាមមិនឃើញឡើយ ។ថ្ងៃនោះចំពេលដែល**កបិលយក្ស**មានបំណងចូលព្រៃបាញ់សត្វលេងកម្សាន្តព្រះទ័យ ទ្រង់ទតពីចម្ងាយទៅមិនឃើញព្រះពោធិសត្វឃើញតែក្តាន់ដើរទន្ទឹមគ្នា ទ្រង់ក៏យឹតធ្នូបាញ់តម្រង់ទៅមិនត្រូវក្តាន់បែរជាត្រូវព្រះពោធិសត្វទៅវិញ ចំកណ្តៀតក្អមដួលទៅលើផែនដី។ ពេលនោះសុវណ្ណសាម សែនចុកចាប់ឈឺយ៉ាងខ្លាំងបានរៀបរាប់ថា អ្នកអើយបាញ់នេះមិនស្លាប់តែរូបខ្ញុំម្នាក់ទេ ស្លាប់ទាំងម្តាយឪពុក ខ្ញុំទាំងពីររូបទៀតផង

ឱ! ខ្ញុំអាសូរម្ដាយឪពុកខ្ញុំណាស់ពីថ្ងៃនេះទៅ ឥតមាននរណាបម្រើអ្នកឡើយ។ ស្ដេចកបិលយក្សស្ដាប់ឮពាក្យនោះហើយក៏មានចិត្តអាណិតមេត្តាជាខ្លាំងចូលទៅសួរថា សូមអ្នកអត់ទោសឱ្យខ្ញុំផង! ខ្ញុំធានាទៅបម្រើម្ដាយឪពុកអ្នកជំនួសអ្នកអស់មួយជីវិត។ ទូលហើយក៏លាព្រះពោធិសត្វទៅរកអាស្រមរបស់តាបសទាំងពីរ លុះទៅដល់ហើយ ស្ដេចកបិលយក្ស ឡើងកាន់អាស្រមដោយស្នូរព្រះបាទាខ្លាំងៗ។ តាបសទាំងពីរសួរថា នរណាដើរអីក៏ឮសូរខ្លាំងម្ល៉េះអ្នកមកពីណា? ស្ដេចកបិលយក្សជម្រាបថា ខ្ញុំឈ្មោះកបិលយក្ស បានបាញ់ក្ដាន់ដែលអមព្រះសុវណ្ណសាមកុមារ ជាកូនរបស់អ្នកទាំងពីរកំពុងបណ្ដើរទៅដងទឹកស្រះតែមិនត្រូវក្ដាន់បែរជាត្រូវ ព្រះសុវណ្ណសាមទៅវិញ ឥឡូវកូនអ្នកក្ស័យជីវិតទៅហើយ ខ្ញុំមកនេះមកបម្រើលោកទាំងពីរជំនួសសុវណ្ណសាម ។និមិត្តតែឮសូរពាក្យទាំងនេះភ្លាមតាបសីទាំងពីររូបក៏បានយំសោកខ្សឹកខ្សួលគួរឱ្យអាណិតអាសូរពេក។ ថ្លែងឯនាងមណីមេខលាទេពធីតា ដែលជាអ្នករក្សានៅព្រៃនោះទាំងប៉ុន្មាន មកធ្វើសច្ចាប្រណិធានជុំវិញព្រះពោធិសត្វក្នុងគម្ពីរបានបញ្ជាក់ថា កាលបើមើលឃើញដូច្នេះហើយ មិនជួយនោះប្រាកដជាបែកក្បាលជាបំណែកមិនខាន។ ពេលនោះក៏ធ្វើការប្រណិធាននៅជុំវិញពោធិសត្វ ដែលទ្រង់សន្លប់បាត់ស្មារតីឯតាបសទាំងពីររូបដែលជាម្ដាយឪពុកឱ្យស្ដេចកបិលយក្ស ក៏បាននាំមកជួបសុវណ្ណសាម ជាកូនដល់ហើយតាបសទាំងពីរ និងស្ដេចកបិលយក្សយំសោកសង្រេងហើយធ្វើសច្ចាប្រណិធានទាំងអស់គ្នានៅជុំវិញព្រះពោធិសត្វ

ដោយអានុភាពនៃសច្ចវាចានោះផងដោយ អានិសង្សកតញ្ញូកតវេទិតាធម៌របស់ព្រះពោធិសត្វសុវណ្ណសាមក៏មានស្មារតីឡើងវិញបន្ទាប់មកក្រាបថ្វាយបង្គំតាបសទាំងពីរជាម្តាយឪពុក ដោយគោរពហើយនាំម្តាយឪពុកទៅកាន់អាស្រមវិញដោយសុវត្ថិភាព។ឯស្តេចកបិលយក្សនោះ ក៏ទទួលបញ្ចសីលតាមព្រះឱវាទព្រះសុវណ្ណសាមពោធិសត្វ ហើយត្រឡប់ទៅកាន់នគរវិញហោង។ នៅទីបំផុតជាតកនេះ ព្រះបរមសាស្តាទ្រង់សម្តែងថាកតញ្ញូគឺជនអ្នកដឹងឧបការគុណ និងធ្វើតបចំពោះលោកមានគុណ គឺកតវេទិតាធម៌ដែលមានអានិសង្សដូចពោលមកនេះហើយដែលតថាគតបានត្រាស់ជាព្រះពុទ្ធមកុដត្រៃភពក៏ដោយសារកតញ្ញូកតវេទិតាធម៌នោះឯង។[៥]

| | | |
|---|---|---|
| អាយុក៏ខ្លី | ចំណេះអ្វីៗ | មានពីកាលមុន |
| កេរ្តិ៍ឈ្មោះគ្រួសារ | ពីរោះពេកពន់ | ឱ្យអ្នកមានគុណ |
| | ចិត្តសែនសោកា។ | |
| ធ្លាប់តែឧត្តម | កាលវ័យក្រមុំ | ក្រពុំដូចផ្កា |
| មានប្រុសកំលោះ | ចោមរោមស្នេហា | មានអេដស៍កាលណា |
| | គេឈប់ស្នើសុំ។ | |
| | នៅមានត(៥) | |

៥-ឧត្តមប្រីជា អានិសង្សសាមសិប ទំព័រ១១៦-១២៤ផ្សាយដោយពុទ្ធសាសនបណ្ឌិត្យ ព.ស.២៥៤៣។

# កំណើតនៃការធ្វើកឋិនទាន

បុណ្យដែលទាយកទាយិកាធ្វើដោយនាំចីវរទៅប្រគេនចំពោះភិក្ខុសង្ឃ ដែលបានគង់ចាំវស្សាអស់រយៈវេលា៣ខែ ក្នុងអាវាសវត្តណាមួយហើយ ដើម្បីឱ្យលោកក្រាលគ្រងនោះហៅថាបុណ្យកឋិន ឬកឋិនទានចីវរដូចជាចីវរទានទាំងពួងដែរតែមានឈ្មោះវិសេសប្លែកជាងទានដទៃ ដែលធ្វើហៅថាកាលទាន ជាទានមានផលច្រើនជាងចីវរទានទាំងពួង ព្រោះប្លែកពីចីវរ-ទានឯទៀតដោយលក្ខណៈ៥យ៉ាងគឺ

**១. ប្លែកដោយកាល** ព្រោះមានពុទ្ធានុញ្ញាតថាកឋិនកាលមានតែ២៩ថ្ងៃ គឺខែអស្សុជ១៤ថ្ងៃ ពីត្រឹម១រោច ដល់១៤រោច(ខែដាច់)ខែកត្តិក១៥ថ្ងៃពីត្រឹម១កើតដល់១៥កើត(ពេញបូណ៌មី)។ រយៈកាលនេះ ពាក្យសាមញ្ញហៅថារដូវកឋិន ក្នុងរដូវនេះទាយកចង់ធ្វើថ្ងៃណាមួយក៏បានឱ្យតែស្ថិតក្នុងថ្ងៃ ទាំង២៩នេះហើយវត្តមួយធ្វើបានតែម្តងប៉ុណ្ណោះ។

**២. ប្លែកដោយវត្ថុ** គឺសំពត់ដែលក្រាលកឋិននោះ បានតែស្បង់ឬចីពរឬក៏សង្ឃាដី ដែលគេធ្វើត្រឹមត្រូវតាម**ពុទ្ធប្បញ្ញត្តិ**សំពត់ក្រៅពីនេះធ្វើពុំបាន ហើយសំពត់ទាំង៣មុខទៀតសោតនឹងយកទាំងអស់ជាអង្គកឋិនក៏ពុំបានគឺបានតែ១មុខ ទោះបីទាយកយកចីវរ១ត្រៃគឺ **ចីពរ១ ស្បង់១ សង្ឃាដី១** ជាសំពត់កឋិនមកវេរប្រគេនក៏ភិក្ខុអ្នកក្រាលគ្រងលោករើសយកតែវត្ថុណាមួយធ្វើជាអង្គកឋិន គឺលោកចង់យកស្បង់ក៏បានចីពរក៏បាន សង្ឃាដីក៏បានស្រេចលើព្រះទ័យលោក ឱ្យតែវត្ថុនោះត្រឹមត្រូវតាម**វិនយប្បញ្ញត្តិ**តែតាម

ធម្មតាលោកអ្នកក្រាលគ្រងច្រើនយក**សង្ឃាដី** ជាអង្គកឋិនដោយលោកយល់ថាបណ្ដាចីវរ ១ត្រៃ សង្ឃាដីជាចីវរធំជាងគេ ។

**៣-ប្លែកដោយអំពើ** គឺបុគ្គលអ្នកធ្វើគប្បីធ្វើឱ្យត្រូវរបៀបតាមព្រះវិន័យ ។

**៤-ប្លែកដោយបដិគ្គាហកៈ**គឺអ្នកទទួលសំពត់កឋិនបានតែភិក្ខុក្រៅពីភិក្ខុពុំបានឡើយហើយភិក្ខុនោះទៀត លុះតែបាននៅចាំវស្សាគ្រប់៣ខែក្នុងវត្តណាមួយទើបទទួលក្រាលគ្រងនិងអនុមោទនា កឋិនក្នុងវត្តនោះបានភិក្ខុដែលមិនបានចាំវស្សាឬបាននៅចាំវស្សាដែរតែឱ្យដាច់ក៏ទទួលពុំបាន ។

**៥-ប្លែកដោយអានិសង្ស**គឺទាយកអ្នកធ្វើក៏បានអានិសង្សច្រើនភិក្ខុសង្ឃអ្នកទទួលក្រាលគ្រង និងអនុមោទនា ក៏បានអានិសង្ស៥យ៉ាងក្នុងរវាង៥ខែដូចមានក្នុងវិន័យបិដកភាគ៨ត្រង់កឋិនក្ខន្ធកៈថា

១-**អនាមន្តចារោ** ត្រាច់ទៅកាន់ទីដទៃ ដោយមិនបាច់លាភិក្ខុផងគ្នាបានដោយមិនមានទោស ។

២-**អសមាទានចារោ** ត្រាច់ទៅដោយមិនបាច់យកត្រៃចីវរគ្រប់ប្រដាប់ទៅជាមួយបាន ។

៣-**គណភោជនំ** ឆាន់ភោជនបាន ។

៤-**យាវទត្ថចីវរំ** ទុកដាក់អតិរេកចីវរបានតាមត្រូវការ ។

៥-**យោ ច តត្ថ ចីវរុប្បាទោ សោ នេសំ ភវិស្សតិ** ចីវរដែលកើតឡើងក្នុងអាវាសនោះចីវរនោះនឹងមានដល់ភិក្ខុនោះ ។

ដោយកឋិនទានជាទាននាំឱ្យភិក្ខុសង្ឃជាអ្នកទទួលក្រាលគ្រង និងអនុមោ-ទនា បានអានិសង្ស៥យ៉ាង ដូចពោលមកនេះហើយបានជាទាយកអ្នកធ្វើកឋិនត្រូវបានអានិសង្សច្រើនជាអនេកត្រារាប់ពុំបានឡើយ ព្រោះជាចីវរ

ទានពិសេសប្លែកពីចីវរទាននានាដូចពោលមកនេះឯង។ ចីវរទានឱ្យហើយ បានទទួលផលានិសង្ស៥យ៉ាង ដែលប្រកបដោយសេចក្តីសុខស្រួលដល់ភិក្ខុសង្ឃជាអ្នកទទួលទានផង សមដូចព្រះពុទ្ធដីការថា **សុខស្ស ទាតា មេធាវី សុខំ សោ អធិគច្ឆតិ** ជនអ្នកមានប្រាជ្ញាណាមួយបានឱ្យនូវសេចក្តីសុខស្រួលដល់អ្នកដទៃ ជននោះឯងរមែងបានជួបប្រទះនឹងសេចក្តីសុខស្រួលវិញពិតប្រាកដពុំខានឡើយ។

អធិប្បាយថាជនណាបានធ្វើកឋិនទានដែលនាំឱ្យភិក្ខុសង្ឃបានអានិសង្ស ៥យ៉ាងក្នុងរវាង៥ខែនោះបានឈ្មោះថា ជាអ្នកឱ្យសេចក្តីសុខស្រួលដល់អ្នកដទៃក្នុងបច្ចុប្បន្នជាតិហើយជននោះតែងតែបានសុខក្នុងមនុស្សលោក និងទេវលោកក្នុងអនាគតជាតិ ដោយអំណាចអានិសង្សនៃកឋិនទាននោះក្នុងកាលជាអនាគតជននោះនឹងបានជាឯហិភិក្ខុឬឯហិភិក្ខុនី ដែលមានត្រៃចីវរកើតឯងនេះជាអានិសង្សកឋិនដូចមានរឿងនិទានថា

ប្រទេសឯណាមិនមានគេរាប់អាន មិនមានផ្លូវរកស៊ីចិញ្ចឹមជីវិត មិនមានញាតិសន្តានផៅពង្ស ឬក៏មិនមានវិទ្យាគមចម្រើនចំណេះវិជ្ជា បុគ្គលគប្បីលះបង់ប្រទេសនោះចេញ។

ដកស្រង់ចេញពីសៀវភៅ "ស្រីហិតោបទេស" ព.ស.២៥៣៧
រៀបរៀងដោយ ភិក្ខុ ប៉ាង ខាត់ វីរិយបណ្ឌិតោ (ខ្លឹមសារត)

# រឿងភិក្ខុ៣០រូប

វិន័យបិដកកឋិនក្ខន្ធកៈមានចែងអំពីប្រភពនៃកឋិនចីវរថាក្នុងបឋមពោធិកាលព្រះបរមសាស្តា ទ្រង់ឱ្យភិក្ខុប្រើប្រាស់តែបង្សុកូលចីវរ ពុំទាន់ទ្រង់អនុញ្ញាតឱ្យប្រើគហបតីចីវរនៅឡើយ ។ សម័យមួយកាលដែលទ្រង់គង់ចាំវស្សានៅវត្តជេតពនជិតដល់ថ្ងៃចូលវស្សាភិក្ខុ៣០អង្គទៅស្រុកបាវាគឺប្រាថ្នាចង់មកថ្វាយបង្គំព្រះអង្គមុនថ្ងៃចូលវស្សាតែមកមិនទាន់ក៏ចូលវស្សានៅជនបទមួយត្រង់កណ្តាលផ្លូវដល់ចេញវស្សាហើយ ទើបភិក្ខុទាំង៣០រូបនោះនាំគ្នាមក ។ ស្របពេលដែលនិមន្តនោះមានភ្លៀងធ្លាក់ច្រើនពេក ភិក្ខុទាំងនោះមានត្រៃចីវរទទឹកជោកដោយទឹកភ្លៀង ដោយហេតុតែចង់ឃើញព្រះពុទ្ធឆាប់ក៏នាំគ្នាចូលទៅថ្វាយបង្គំព្រះអង្គទាំងទទឹកនោះ ។ព្រះអង្គទ្រង់បានអនុញ្ញាត ចំពោះជនអ្នកមានសទ្ធាដែលចង់ធ្វើកឋិនទានហើយចាត់ទុកថាជាអ្នកគោរពព្រះពុទ្ធដីកា ដែលទ្រង់អនុញ្ញាតឱ្យភិក្ខុសង្ឃបាន អានិសង្ស៥ប្រការពិតនិងជាអ្នកមានចិត្តអាណិតអាសូរព្រះសង្ឃដែល បានគង់ចាំវស្សាសិក្សាធម៌វិន័យ ចម្រើនមេត្តាភាវនា អស់ត្រីមាសឱ្យលោកបានអានិសង្ស៥ប្រការតាមពុទ្ធានុញ្ញាតនោះផងហើយនិងជាអ្នកបានធ្វើឱ្យពុទ្ធសាសនាបានឋិតនៅយូរបិតថេរចិរកាលរុងរឿងចម្រើនទៅផង ។ ដោយសារកឋិនទានជាកាលទានពិសេសប្លែកអំពីចីវរទាននានាដូច ដែលពិពណ៌នាមកនេះហើយបានជាលោកពោលថាមានអានិសង្សច្រើនលើសចីវរទានទាំងពួង ។[៦]

---

៦-ឧត្តមប្រីជា ចាប ពិន អានិសង្សសាមសិប ទំព័រ ៦៣-៦៦ ផ្សាយដោយពុទ្ធសាសនបណ្ឌិត្យ ព.ស. ២៥៤៣ ។

# អានិសង្សសាងបង្គន់

បង្គន់ជាទីបន្ទោបង់ឧច្ចារៈបស្សាវៈ (មូត្រលាមក) លោករាប់ចូលក្នុងទិសេនាសនប្បច្ច័យដូចកុដិសាលាឬផ្ទះសំបែង និងទីសេនាសនៈឯទៀតដែរ ព្រោះជាទីជ្រកអាស្រ័យដើម្បីបន្ទោបង់ និងដើម្បីការពារត្រជាក់ក្ដៅដូចគ្នា ប្លែកតែកុដិ សាលា ឬផ្ទះសំបែង សម្រាប់ដេកនៅបង្គន់សម្រាប់បន្ទោបង់មូត្រលាមកប៉ុណ្ណោះ។ នរណាៗក៏ត្រូវតែបិទបាំងកេរ្តិ៍ខ្មាសក្នុងពេលបន្ទោ-បង់ជាការចាំបាច់ខានពុំបាន។ ព្រោះហេតុនេះ កាលបើពោលដល់ផលានិសង្សសង់បង្គន់ជាទានក៏ប្រហាក់ប្រហែលនឹងអានិសង្សសង់កុដិ សាលា និងទីសេនាសនៈដូចគ្នា តែបើពោលឱ្យល្អិតទៅ ការសង់បង្គន់មានផលានិសង្ស ប្លែកពីការសង់សេនាសនៈឯទៀតៗ បន្តិចចំពោះការបិទបាំងខ្មាស និងជាការចាំបាច់ត្រូវតែបិទបាំង ត្រូវតែបន្ទោបង់ឱ្យទាន់ពេលខានពុំបាន។ កាលបើបង្គន់ជាទីសំខាន់ ជាការចាំបាច់ដូចពោលមកហើយ ផលានិសង្ស នៃការសង់បង្គន់ក៏ត្រូវតែមានច្រើន ព្រោះជាការសង្គ្រោះដោះទុក្ខអ្នកមានធុរៈដូចមាននិទានបញ្ជាក់ថា

> ក្រមុំកំលោះ គ្រប់ប្រាណទាំងអស់ ចូរស្ដាប់ពាក្យខ្ញុំ
> ខំប្រឹងរៀនសូត្រ ត្រៀមខ្លួនបឋម នោះវិជ្ជាផ្សំ
> ទំពាំងស្នងឱ្យ។
> នៅមានត(៦)

# រឿងព្រះពាក្កុលត្ថេរ

ក្នុងសាសនាព្រះពុទ្ធកស្សប មុនសាសនាព្រះសមណគោតមបរមគ្រូនៃយើងនេះមានគហបតីម្នាក់បានឃើញព្រះអរហន្តមួយអង្គ លោកឈឺបន្ទោ-បង់ឧច្ចារៈខ្លាំងត្រង់ទីកណ្តាលវាលដែលមានមនុស្សច្រើនលោកដើររកបង្គន់ដើម្បីបន្ទោបង់គហបតីនោះបានឃើញបានដឹងរឿងនោះក៏ប្រញាប់ប្រញាល់យកសំពត់ធ្វើជារនាំងបិទបាំងជាបង្គន់ ប្រគេនលោកភ្លាមទាន់ពេលលោកក៏បន្ទោបង់ដោយស្រួលហើយគហបតីនោះទូលលោកថាដោយអំណាចផលដែលខ្ញុំបានធ្វើបង្គន់ប្រគេនលោកម្ចាស់ ដោយរួសរាន់ទាន់ពេលវេលាយ៉ាងនេះបើលោកម្ចាស់បានសម្រេចធម៌ណាក្នុងអត្តភាពនេះសូមឱ្យខ្ញុំព្រះករុណាបានសម្រេចធម៌នោះដូចលោកម្ចាស់ផងក្នុងជាតិខាងមុខកុំខាន ។លោកបានទទួលថាអ្នកប្រាថ្នាយ៉ាងណាសូមឱ្យបានសម្រេចយ៉ាងនោះគហបតីនោះលុះអស់អាយុទៅ បានទៅកើតជាទេវបុត្រឋិតនៅក្នុងឋានទេវលោក អស់១ពុទ្ធន្តរ(ចន្លោះព្រះពុទ្ធ១អង្គ)លុះមកដល់ពុទ្ធកាលនៃព្រះសមណគោតមបរមគ្រូជាម្ចាស់នៃយើងនេះទេវបុត្រនោះ ច្យុតចាកឋានសួគ៌មកកើតក្នុងត្រកូលសេដ្ឋីមួយនៅក្បែរមាត់ទន្លេ នៅក្នុងពេលវេលាដែលប្រសូតម្តាយឪពុក យកទារកនោះទៅធ្វើមង្គលនៅមាត់ទន្លេ ផ្ងូតទឹកក្នុងទន្លេទារកនោះរបូតពីដៃម្តាយ ធ្លាក់ទៅក្នុងទឹកមានត្រីធំ១លេបទៅក្នុងពោះ ហែលតាមទន្លេទៅមានអ្នកនេសាទចាប់ត្រីនោះ យកទៅលក់ឱ្យសេដ្ឋីម្នាក់នៅមាត់ទន្លេជិតនោះដែរ ។សេដ្ឋីនោះបានឱ្យគេវះពោះត្រីនោះក៏ឃើញកូននោះនៅ

ក្នុងពោះ ក៏ត្រេកអរពន់ប្រមាណយកកូននោះទុកជាកូនសំណព្វចិត្ត ដូចកូនបង្កើតរបស់ខ្លួន។ ឯសេដ្ឋីជាម្តាយឪពុកបានដឹងដំណឹងនោះក៏មកសុំកូននោះទៅវិញតែសេដ្ឋីជាម្តាយចិញ្ចឹមពុំព្រមឱ្យហើយត្រកូលសេដ្ឋីទាំងពីរបានដាក់វេនគ្នាចិញ្ចឹមកូននោះ៤ខែម្នាក់។ កូននោះក៏បានឈ្មោះថាពាកុលកុមារ (កុមារដែលមានត្រកូលពីរ) តាំងពីពេលនោះមក។ លុះពាកុលកុមារនោះមានវ័យចម្រើនឡើងបានអាយុ២០ឆ្នាំ បានបួសជាភិក្ខុមាននាមថា ពាកុលត្ថេរ បានជាព្រះអរហន្ត១អង្គ ក្នុងព្រះពុទ្ធសាសនាលោកមាន សុខភាពល្អណាស់ ឥតមានរោគាអ្វីបន្តិចបន្តួចទេ តាំងពីប្រសូតរហូតដល់ចាស់លោកមានព្រះជន្ម១៦០ឆ្នាំទើបចូលនិព្វាន។[៧]

| | | |
|---|---|---|
| ចប់ឃ្លាមានន័យ | ខ្ញុំសូមស្រដី | ផ្តែផ្តាំចុងក្រោយ |
| យុវវ័យស្រីប្រុស | កុំបីបណ្តោយ | ចង់សាកចង់ដោយ |
| | មិនចេះឈប់ឈរ។ | |
| ជាទីបញ្ចប់ | សូមលើកម្រាមដប់ គោរពជូនពរ | |
| គ្រប់គ្នាទាំងអស់ | នាមខ្មែរអង្គរ | ល្អហើយបវរ |
| | អច្ឆរិយៈថ្លៃថ្លា។ | |

ពេជ្រ សំណាង

**ចប់**

---

៧-ឧត្តមប្រិជា ចាប ពិន អានិសង្សសាមសិប ទំព័រ ៤៣-៤៤ ផ្សាយដោយពុទ្ធសាសនបណ្ឌិត្យ ព.ស. ២៥៤៣។

# កំណើតបុណ្យបូជាព្រះចន្ទសំពះព្រះខែ

មានប្រជាពុទ្ធបរិស័ទទាំងឡាយ នាំគ្នាប្រារព្ធរាល់ឆ្នាំដោយមានជំនឿ ឬរំលឹកខួបអង្គនៃព្រះសម្មាសម្ពុទ្ធបរមគ្រូកាលនៅជាពោធិសត្វ។ កាលដែលព្រះអង្គយោនយកកំណើតកើតជាសត្វទន្សាយ ដល់ថ្ងៃពេញបូណ៌មីវេលារាត្រី ព្រះចន្ទពេញវង់មានពន្លឺល្អសោភា ព្រះអង្គក្រលេកមើលព្រះចន្ទ ហើយមានសេចក្ដីជ្រះថ្លាប្រកបដោយករុណាចិត្តព្រះអង្គនឹកគិតដូច្នេះថា បើអ្នកណាត្រូវការសាច់របស់អញ អាត្មាអញ នឹងបំពេញជីវិតជាទានក្នុងកាលឥឡូវនេះ។ អស្ចារ្យណាស់គ្រាន់តែនឹកគិតប៉ុណ្ណោះ ក៏ក្ដៅដល់អាសនៈព្រះឥន្ទ្រស្ដេចទ្រង់អាវជ្ជនាកា ឃើញទន្សាយព្រះពោធិសត្វ មានករុណាជ្រះថ្លាចង់បំពេញទាន ក៏ហោះចុះមកនិម្មិតធ្វើជា ព្រាហ្មណ៍ចាស់ជរាម្នាក់ ហើយមកកាន់សំណាក់ទន្សាយពោធិសត្វរួចបានពោលថាខ្ញុំដើរផ្លូវឆ្ងាយអត់ឃ្លានគ្មានអាហារបរិភោគមកយូរថ្ងៃហើយជីវិតរបស់ខ្ញុំនឹងក្ស័យក្នុងថ្ងៃនេះ ហើយបើមិនបានអ្វីនោះ!ធ្វើដូចម្ដេចនឹងបានអាហារបរិភោគអ្ហេះ?

ព្រះពោធិសត្វឆ្លើយថាបើអ្នកត្រូវការចូររកឧសបង្កាត់ភ្លើងឱ្យឆេះទៅចុះ! ខ្ញុំនឹងលោតចូលក្នុងភ្លើងរួចអ្នកនឹងបានសាច់ខ្ញុំបរិភោគ ។ព្រាហ្មណ៍ចាស់តបថាខ្ញុំអរគុណណាស់ ហើយក៏រកឧសបង្កាត់ភ្លើងជាគំនរយ៉ាងធំរួចហើយ

ទន្សាយពោធិសត្វ រលាស់ខ្លួនយ៉ាងស្អាតលោតចូលទៅក្នុងភ្លើង ស្រាប់តែភ្លើងនោះរលត់អស់ទៅសូម្បីតែរោមមួយសរសៃក៏មិនឆេះផង ។

ហេតុដ៏អស្ចារ្យនេះហើយដែលនាំព្រាហ្មណ៍ចាស់ ស្ងើចសរសើរហើយឥន្ទ្រព្រាហ្មណ៍ ក៏ហោះទៅយកថ្មកែវសិលាមួយដុំទៅគូសវាសភ្ជាប់រូបទន្សាយពោធិសត្វក្នុងវង់ព្រះចន្ទនោះទៅ ។អាស្រ័យហេតុនេះហើយទើបបានជាអ្នកខ្លះយល់ថាមើលទៅឃើញហាក់ដូចជារូបទន្សាយនៅរង្វង់ព្រះចន្ទ ។ ដោយមានហេតុដូចបានពោលមកនេះបានជាអ្នកកាន់ព្រះពុទ្ធសាសនានាំគ្នាគោរពបូជាព្រះចន្ទសំពះព្រះខែជាប់តមកដល់សព្វថ្ងៃនេះ ។[៨]

**តើចំណេះដឹងគឺជាអ្វី?**

| | |
|---|---|
| មានមនុស្សជាច្រើនជញ្ជឹងគិត | តើវិជ្ជាពិតនៅទីណា? |
| ហេតុអ្វីបានជាក្នុងលោកា | ព្យាយាមសិក្សាគ្រប់ៗគ្នា ។ |
| តាំងពីថ្នាក់តូចដល់ថ្នាក់ខ្ពស់ | ធ្វើដំណើរឆ្ពោះអស់ទ្រព្យា |
| តស៊ូរៀនសូត្រឥតគណនា | ខ្លះចាស់ជរាក៏មិនស្តាយ ។ |
| តើនេះដោយសារតែហេតុអ្វី? | ទើបមនុស្សប្រុសស្រីមិនជិនណាយ |
| ហាត់ពត់លត់ដំបន្ទុំកាយ | ខ្នះខ្នែងខ្វល់ខ្វាយរកចំណេះ ។ |
| ជនណាបានរៀនខ្លួនប្រសើរ | ឈានធ្វើដំណើរមិនប្រហែស |
| សិក្សាវិជ្ជាឱ្យបានចេះ | ឆ្លៀតយកតម្រិះទៅថ្ងៃក្រោយ ។ |
| ចំណេះពិតជាក់ខ្ពស់ឧត្តម | វិជ្ជារួមផ្សំនេះស្នងឱ្យ |
| ស្វែងរកការងារណាក៏ដោយ | ល្អណាស់មិនធ្លោយដូចជនល្ងង់ ។ |
| បម្រើការងារប្រាក់ខែខ្ពស់ | មានទាំងកិត្តិយសខ្ពស់ឧត្តុង្គ |
| ក្មេងចាស់ប្រុសស្រីតែងលិចលង់ | ព្រោះតែឆោមយង់ចងគំនិត ។ |

នៅមានត(១)

៨-យិន-វ៉ន់ ប្រជុំបុញ្ញប្រវត្តិ ទំព័រ ៤៧-៤៩ ផ្សាយចេញពីបណ្ណាគារ គីម-គី ព.ស. ២៥១៥ គ.ស ១៩៧២ ។

# ធម៌រំលឹកគុណព្រះរតនត្រ័យ

## ថ្វាយគ្រឿងសក្ការបូជា

ឥមេហិ ទីបធូបាទិ សក្ការេហិ ពុទ្ធំ ធម្មំ សង្ឃំ អភិបូជយាមិ មាតាបិតាទីនំ គុណវន្តានញ្ច មយ្ហញ្ច ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ។

### នមស្ការព្រះពុទ្ធរតនៈ

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស។

(សូត្រ៣ចប់)

យោ សន្និសិន្នោ វរពោធិមូលេ មារំ សសេនំ មហតិំ វិជេយ្យោ សម្ពោធិមាគច្ឆិ អនន្តញ្ញាណោ លោកុត្តមោ តំ បនមាមិ ពុទ្ធំ ។

(ថ្វាយបង្គំម្តង)

យេ ច ពុទ្ធា អតីតា ច យេ ច ពុទ្ធា អនាគតា បច្ចុប្បន្នា ច យេ ពុទ្ធា អហំ វន្ទាមិ សព្វទា។

(ថ្វាយបង្គំម្តង)

ឥតិបិសោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណ-សម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ។

(ថ្វាយបង្គំម្តង)

ត្រូវប្រកាសប្តេជ្ញាខ្លួនចំពោះពុទ្ធគុណថា

**នត្ថិ មេ សរណំ អញ្ញំ ពុទ្ធោ មេ សរណំ វរំ ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ។**

(ថ្វាយបង្គំម្តង)

ត្រូវសូមខមាទោសនឹងពុទ្ធគុណដូច្នេះថា

**ឧត្តមង្គេន វន្ទេហំ បាទបំសុំ វរុត្តមំ ពុទ្ធេ យោ ខលិតោ ទោសោ ពុទ្ធោ ខមតុ តំ មមំ។**

**នមស្ការព្រះធម្មរតនៈ**

**អដ្ឋង្គិកអរិយបថោ ជនានំ មោក្ខប្បវេសាយ ឧជុ ច មគ្គោ ធម្មោ អយំ សន្តិករោ បណីតោ និយ្យានិកោ តំ បនមាមិ ធម្មំ។**

(ថ្វាយបង្គំម្តង)

**យេ ច ធម្មា អតីតា ច យេ ច ធម្មា អនាគតា បច្ចុប្បន្នា ច យេ ធម្មា អហំ វន្ទាមិ សព្វទា។**

(ថ្វាយបង្គំម្តង)

**ស្វាក្ខាតោ ភគវតា ធម្មោ សន្ទិដ្ឋិកោ អកាលិកោ ឯហិបស្សិកោ ឱបនយិកោ បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ។**

(ថ្វាយបង្គំម្តង)

ត្រូវប្រកាសប្ដេជ្ញាខ្លួនចំពោះធម្មគុណថា

**នត្ថិ មេ សរណំ អញ្ញំ ធម្មោ មេ សរណំ វរំ ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ។**

( ថ្វាយបង្គំម្ដង)

ត្រូវសូមខមាទោសនឹងព្រះធម្មគុណថា

**ឧត្តមង្គេន វន្ទេហំ ធម្មញ្ច តិវិធំ វរំ ធម្មេ យោ ខលិតោ ទោសោ ធម្មោ ខមតុ តំ មមំ។**

( ថ្វាយបង្គំម្ដង)

**នមស្ការព្រះសង្ឃរតនៈ**

**សង្ឃោ វិសុទ្ធោ វរទក្ខិណេយ្យោ សន្តិន្ទ្រិយោ សព្វមលប្បហីនោ គុណេហិនេកេហិ សមិទ្ធិបត្តោ អនាសវោ តំ បនមាមិ សង្ឃំ។**

( ថ្វាយបង្គំម្ដង)

**យេ ច សង្ឃា អតីតា ច យេ ច សង្ឃា អនាគតា បច្ចុប្បន្នា ច យេ សង្ឃា អហំ វន្ទាមិ សព្វទា។**

( ថ្វាយបង្គំម្ដង)

**សុបដិបន្នោ ភគវតោ សាវកសង្ឃោ ឧជុបដិបន្នោ ភគវតោ សាវកសង្ឃោ ញាយបដិបន្នោ ភគវតោ**

**សាវកសង្ឃោ សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ យទិទំ ចត្តារិ បុរិសយុគានិ អដ្ឋ បុរិសបុគ្គលា ឯស~ ភគវតោ សាវកសង្ឃោ អាហុនេយ្យោ បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ។** (ថ្វាយបង្គំម្តង)

គប្បីប្រកាសប្តេជ្ញាខ្លួនចំពោះសង្ឃគុណថា

**នត្ថិ មេ សរណំ អញ្ញំ សង្ឃោ មេ សរណំ វរំ ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ។**

ត្រូវសូមខមាទោសនឹងព្រះសង្ឃគុណថា

**ឧត្តមង្គេន វន្ទេហំ សង្ឃញ្ច ទុវិធោត្តមំ សង្ឃេ យោ ខលិតោ ទោសោ សង្ឃោ ខមតុ តំ មមំ។**

(ថ្វាយបង្គំម្តង)

## សុភមង្គលកថា

**ហោតុ សព្វំ សុមង្គលំ រក្ខន្តុ សព្វទេវតា សព្វពុទ្ធានុភាវេន
សោត្ថិ ហោតុ និរន្តរំ។**

**ហោតុ សព្វំ សុមង្គលំ រក្ខន្តុ សព្វទេវតា សព្វធម្មានុភាវេន
សោត្ថិ ហោតុ និរន្តរំ។**

**ហោតុ សព្វំ សុមង្គលំ រក្ខន្តុសព្វទេវតា សព្វសង្ឃានុភាវេន
សោត្ថិ ហោតុ និរន្តរំ។**

(ថ្វាយបង្គំម្តង)

## បណាមគាថា

យោ កប្បកោដីហិបិ អប្បមេយ្យំ កាលំ ករោន្តោ អតិទុក្ករានិ ខេទំ គតោ លោកហិតាយ នាថោ នមោ មហាការុណិកស្ស តស្ស ។ អសម្ពុធំ ពុទ្ធនិសេវិតំ យំ ភវាភវំ គច្ឆតិ ជីវលោកោ នមោ អវិជ្ជាទិកិលេសជាលំ វិទ្ធំសិនោ ធម្មវរស្ស តស្ស ។ គុណេហិ យោ សីលសមាធិបញ្ញា វិមុត្តិញ្ញាណប្បភូតីហិ យុត្តោ ខេត្តញ្ញូនានំ កុសលត្ថិកានំ តមរិយសង្ឃំ សិរសា នមាមិ ។

( ថ្វាយបង្គំម្ដង)

## គាថាសុំសេចក្ដីសុខ

ឥច្ចេវមច្ចន្ត នមស្សនេយ្យំ នមស្សមានោ រតនត្តយំ យំ បុញ្ញាភិសន្ទំ វិបុលំ អលត្ថំ តស្សានុភាវេន ហតន្តរាយោ ។

## អនុមោទនារក្ខាយាចនគាថា

អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា បុញ្ញំ នោ
អនុមោទន្តុ ចិរំ រក្ខន្តុ សាសនំ ។
អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា បុញ្ញំ នោ
អនុមោទន្តុ ចិរំ រក្ខន្តុ រាជានោ ។

អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា បុញ្ញំ នោ
អនុមោទន្តុ ចិរំ រក្ខន្តុ ញាតិយោ ។
អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា បុញ្ញំ នោ
អនុមោទន្តុ ចិរំ រក្ខន្តុ បាណិនោ ។
អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា បុញ្ញំ នោ
អនុមោទន្តុ ចិរំ រក្ខន្តុ នោ សទា ។

## បត្តិទានគាថា

យំ កិញ្ចិ កុសលកម្មំ កត្តព្វំ កិរិយំ មម កាយេន វាចា មនសា តិទសេ សុគតំ កតំ យេ សត្តា សញ្ញិនោ អត្ថិ យេ ច សត្តា អសញ្ញិនោ កតំ បុញ្ញផលំ មយ្ហំ សព្វេ ភាគី ភវន្តុ តេ យេ តំ កតំ សុវិទិតំ ទិន្នំ បុញ្ញផលំ មយា យេ ច តត្ថ ន ជានន្តិ ទេវា គន្ត្វា និវេទយុំ សព្វលោកម្ហិ យេ សត្តា ជីវន្តាហារហេតុកា មនុញ្ញំ ភោជនំ សព្វេ លភន្តុ មម ចេតសាតិ ។

## ចប់ធម៌នមស្ការសង្ខេប

៩-សែម-សូរ ប្រជុំភាណវារៈបាលី-ប្រែពិសេស ទំព័រ ១១៨-ផ្សាយដោយបណ្ណាគារត្រៃរតនី ព.ស. ២៥៤៣ គ.ស. ១៩៩៩។

# ពិធីការផ្សេងៗ

## សាមណេរបព្វជ្ជាវិធី

កុលបុត្រដែលប្រាថ្នានឹងបួសជាសាមណេរគប្បី កោរសក់ ពុកមាត់ ពុកចង្កា កាត់ក្រចក ឱ្យត្រឹមត្រូវតាមវិនយប្បញ្ញត្តិ ហើយស្លៀកពាក់បែប បទយរាវ៉ាស ហើយកាន់យកគ្រឿងសក្ការៈបូជាមានទៀន និងធូបជាដើម ចូលទៅបូជាព្រះពុទ្ធរូបក្នុងខណ្ឌសីមា ធ្វើកាយបណាម វំចីបណាមដោយគោរពរួចហើយកាន់សំពត់កាសាវៈបិទ្រចូលទៅកាន់សំណាក់ព្រះឧបជ្ឈាយ៍ ដាក់សំពត់កាសាវៈចុះក្បែរខ្លួន ហើយថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន រួចហើយក្រោកឈរឡើងប្រណម្យអញ្ចលីសូធ្យថា

**ឱកាស វន្ទាមិ ភន្តេ ភគវា សព្វំ អបរាធំ ខមថ មេ ភន្តេ មយា កតំ បុញ្ញំ សាមិនា អនុមោទិតព្វំ សាមិនា កតំ បុញ្ញំ មយ្ហំ ទាតព្វំ សាធុ សាធុ អនុមោទាមិ៕**

ប្រែថា: សូមទានគោរពបពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំលោកម្ចាស់ បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់អត់នូវទោសគឺសេចក្ដីខុសទាំងពួងដល់ ខ្ញុំព្រះករុណាបុណ្យទាំងឡាយដែលខ្ញុំព្រះករុណាបានធ្វើហើយ សូមលោកម្ចាស់អនុមោទនាត្រេកអរតាមចុះបុណ្យដែលលោកម្ចាស់បានធ្វើហើយ សូមលោកម្ចាស់ចែករំលែកឱ្យដល់ខ្ញុំព្រះករុណាផងនិងបានសេចក្ដីល្អញាំងប្រយោជន៍ឱ្យសម្រេចខ្ញុំព្រះករុណា សូមទទួលអនុមោទនា ( ត្រេកអរតាម) ។

ហើយពោលដូច្នេះតទៅទៀតថា

**ឱកាស ការុញ្ញំ កត្វា បព្វជ្ជំ ទេថ មេ ភន្តេ។**

ប្រែថាៈសូមទានគោរព បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់មេត្តាប្រោសធ្វើនូវសេចក្តីករុណាហើយឱ្យនូវបព្វជ្ជាដល់ខ្ញុំព្រះករុណា។

រួចហើយអង្គុយច្រហោង លើកដៃប្រណម្យពោលដូច្នេះថាៈ

**អហំ ភន្តេ បព្វជ្ជំ យាចាមិ។**

**ទុតិយម្បិ អហំ ភន្តេ បព្វជ្ជំ យាចាមិ។**

**តតិយម្បិ អហំ ភន្តេ បព្វជ្ជំ យាចាមិ។**

ប្រែថាៈ បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណាសូមនូវបព្វជ្ជា! បពិត្រ លោកម្ចាស់ដ៏ចម្រើនខ្ញុំព្រះករុណាសូមនូវបព្វជ្ជា! ជាគម្រប់ពីរដងផង! ជាគម្រប់បីដងផង! ។

ហើយពោលដូច្នេះតទៅទៀត៣ដងថា

**សព្វទុក្ខ និស្សរណ និព្វាន សច្ឆិករណត្ថាយ ឥមំ កាសាវំ គហេត្វា បព្វាជេថ មំ ភន្តេ អនុកម្បំ ឧបាទាយ។**

ប្រែថា បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់មេត្តាប្រោស សូមទទួលយកនូវសំពត់កាសាវៈ ហើយធ្វើនូវសេចក្តីអនុគ្រោះបំបួសខ្ញុំព្រះករុណាដើម្បីប្រយោជន៍ និងធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាន ដែលជាធមិវលាស់ខ្លួនចេញចាកទុក្ខទាំងពួង។

រួចហើយព្រះឧបជ្ឈាយ៏ត្រូវទទួលយកសំពត់កាសាវៈ អំពីអំពីបព្វជ្ជាបេក្ខ-បុគ្គលហើយបព្វជ្ជាបេក្ខបុគ្គលត្រូវពោលដូច្នេះ៣ដងតទៅទៀតថាៈ

**សព្វទុក្ខ និស្សរណ និព្វាន សច្ឆិករណត្ថាយ ឯតំ កាសាវំ គហេត្វា បព្វាជេថ មំ ភន្តេ អនុកម្បំ ឧបាទាយ៕**

ប្រែថាៈ បពិត្រលោកម្ចាស់ដ៏ចម្រើនសូមលោកម្ចាស់មេត្តាប្រោសឱ្យនូវសំពត់កាសាវៈនុ៎ះដល់ខ្ញុំព្រះករុណា ហើយធ្វើនូវសេចក្ដីអនុគ្រោះបំបួស ខ្ញុំព្រះករុណា ដើម្បីប្រយោជន៏ធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាន ដែលជាធមិរលាស់ខ្លួនចេញចាកទុក្ខទាំងពួង។

រួចហើយព្រះឧបជ្ឈាយ៏ត្រូវប្រគល់សំពត់ កាសាវៈនោះឱ្យបព្វជ្ជាបេក្ខវិញ ហើយប្រាប់តបបញ្ចកម្មដ្ឋាន អនុលោមបដិ លោមដោយបាលីថា

**កេសា លោមា នខា ទន្តា តចោ**

**តចោ ទន្តា នខា លោមា កេសា៕**

ប្រែថាៈ សក់ រោម ក្រចក ធ្មេញ ស្បែក ស្បែក ធ្មេញ ក្រចក រោម សក់។លុះរួចកិច្ចនេះហើយបព្វជ្ជាបេក្ខគប្បីថ្វាយបង្គំ៣ដងហើយក្រោកដើរទៅផ្លាស់សម្លៀកបំពាក់យរាវាសចេញទ្រទ្រង់សំពត់កាសាវៈគឺ ស្លៀកស្បង់ គ្រង ចីពរឱ្យត្រឹមត្រូវតាមសេក្ខិយវត្ត។

បន្ទាប់មកបព្វជ្ជាបេក្ខត្រូវកាន់គ្រឿងសក្ការៈមានទៀន ធូបជាដើមចូលទៅរកព្រះឧបជ្ឈាយ៏ ឬបព្វជ្ជាចារ្យប្រគេនគ្រឿងសក្ការៈនោះទៅលោក ហើយក្រោកឈរប្រណម្យអញ្ជលីសូធ្យថា

**ឱកាស វន្ទាមិ ភន្តេ សព្វំ អបរាធំ ខមថ សាធុ សាធុ អនុមោទាមិ ខ**

(ប្រែដូចមុន) រួចហើយពោលដូច្នេះតទៅទៀតថា

**ឱកាស ការុញ្ញំ កត្វា តិសរណេន សហសីលានិ ទេថ មេ ភន្តេ ខ**

សូមទានគោរពបពិត្រលោកម្ចាស់ដ៏ចម្រើនសូមលោកម្ចាស់មេត្តាប្រោសធ្វើនូវសេចក្តីករុណាឱ្យសីលទាំងឡាយព្រមទាំងព្រះត្រៃសរណគមន៏ដល់ខ្ញុំព្រះករុណា ។

ហើយអង្គុយច្រហោងផ្គងអញ្ជលីឡើងពោលដូច្នេះថា

**អហំ ភន្តេ សរណសីលំ យាចាមិ ខ**បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណាសូមនូវព្រះត្រៃសរណគមន៏ និងសីល ។

**ទុតិយម្បិ អហំ ភន្តេ សរណសីលំ យាចាមិ ខ**

**តតិយម្បិ អហំ ភន្តេ សរណសីលំ យាចាមិ ខ**

បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណាសូមនូវព្រះត្រៃសរណគមន៏ និងសីល ។ជាគម្រប់ពីរដងផងជាគម្រប់បីដងផង ។ ហើយបព្វជ្ជាបេក្ខផ្តើមតាំងនមោ៣ដងថា

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ៣ចប់**

ប្រែថាៈ រីកិរិយានមស្ការថ្វាយបង្គំនៃខ្ញុំព្រះករុណា សូមមានដល់ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គជាព្រះអរហន្តដ៏ប្រសើរ ទ្រង់តាស់ដឹងនូវញេយ្យធម៌ទាំងពួងដោយប្រពៃចំពោះព្រះអង្គឯង ឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ ។

ព្រះឧបជ្ឈាយ៍តាំងនមោ៣ដងថា

**យមហំ វទាមិ តំ វទេហិ !**

យើងពោលនូវពាក្យឯណាអ្នកចូរពោលនូវពាក្យនោះ។

បព្វជ្ជាបេក្ខត្រូវទទួលថា

**អាម ភន្តេ** ករុណាលោកម្ចាស់ (ខ្ញុំព្រះករុណានឹងពោលតាម)។

ព្រះឧបជ្ឈាយ៍ ឬបព្វជ្ជាចារ្យ ឱ្យព្រះត្រៃសរណគមន៍ថា

**ពុទ្ធំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណាសូមដល់នូវព្រះពុទ្ធជាទីពឹងទីរលឹក។

**ធម្មំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណាសូមដល់នូវព្រះធមិជាទីពឹងទីរលឹក។

**សង្ឃំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណាសូមដល់នូវព្រះសង្ឃជាទីពឹងទីរលឹក។

**ទុតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ**ខ្ញុំព្រះករុណាសូមដល់នូវព្រះពុទ្ធជាទីពឹងទីរលឹកជា គម្រប់ពីរដងផង។

**ទុតិយម្បិ ធម្មំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណាសូមដល់នូវព្រះធមិជាទីពឹងទីរលឹក ជាគម្រប់ពីរដងផង

**ទុតិយម្បិ សង្ឃំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណាសូមដល់នូវព្រះសង្ឃជាទីពឹងទី រលឹកជាគម្រប់ពីរដងផង។

**តតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណាសូមដល់នូវព្រះពុទ្ធជាទីពឹងទីរលឹក ជាគម្រប់បីដងផង។

**តតិយម្បិ ធម្មំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណាសូមដល់នូវព្រះធមិជាទីពឹងទីរលឹកជាគម្រប់បីដងផង។

**តតិយម្បិ សង្ឃំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណាសូមដល់នូវព្រះសង្ឃជាទីពឹងទីរលឹកជាគម្រប់បីដងផង។

ឯវិធីដែលឱ្យត្រៃសរណគមន៍នេះឱ្យជាអនុនាសិកន្តជាឯកសម្ពន្ធដូច្នេះ ក៏បាននិងឱ្យជាមការន្តក៏បានឬឱ្យទាំងអនុនាសិកន្តនិងមការន្តទាំងពីរយ៉ាង ក៏បានដែរ ។

វិធីឱ្យជាមការន្តនោះត្រូវឱ្យមួយបទម្តង១ដូច្នេះថា

**ពុទ្ធំ សរណំ គច្ឆាមិ**

**ធម្មំ សរណំ គច្ឆាមិ**

**សង្ឃំ សរណំ គច្ឆាមិ**

**ទុតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ**

**ទុតិយម្បិ ធម្មំ សរណំ គច្ឆាមិ**

**ទុតិយម្បិ សង្ឃំ សរណំ គច្ឆាមិ**

**តតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ**

**តតិយម្បិ ធម្មំ សរណំ គច្ឆាមិ**

**តតិយម្បិ សង្ឃំ សរណំ គច្ឆាមិ។**

(ប្រែថាដូចមុន) ហើយលោកពោលថា

**តិសរណគមនំ** បាលីទាំងពីរនេះជាកិច្ចដល់នូវព្រះត្រៃសរណគមន៍ ឬថា **តិសរណគ្គហណំ បរិបុណ្ណំ** កិរិយាកាន់យក គឺទទួលយកនូវព្រះត្រៃសរណគមន៍បរិបូណ៌ហើយ ។

បេក្ខបុគ្គលត្រូវទទួលថា **អាម ភន្តេ** ។

ហើយក្រាបចុះម្តង រួចទទួលសិក្ខាបទ១០តទៅទៀតថា

## សិក្ខាបទ១០

**បាណាតិបាតា វេរមណី សិក្ខាបទំ សមាទិយាមិ ។**

**អទិន្នាទានា វេរមណី សិក្ខាបទំ សមាទិយាមិ ។**

**អព្រហ្មចរិយា វេរមណី សិក្ខាបទំ សមាទិយាមិ ។**

**មុសាវាទា វេរមណី សិក្ខាបទំ សមាទិយាមិ ។**

**សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី សិក្ខាបទំ សមាទិយាមិ ។**

**វិកាលភោជនា វេរមណី សិក្ខាបទំ សមាទិយាមិ ។**

**នច្ចគីតវាទិតវិសូកទស្សនា វេរមណី សិក្ខាបទំ សមាទិយាមិ ។**

**មាលាគន្ធវិលេបនធារណមណ្ឌន វិភូសនដ្ឋានា វេរមណី សិក្ខាបទំ សមាទិយាមិ ។**

**ឧច្ចាសយនមហាសយនា វេរមណី សិក្ខាបទំ សមាទិយាមិ ។**

**ជាតរូបរជតប្បដិគ្គហណា វេរមណី សិក្ខាបទំ សមាទិយាមិ ។**

បន្ទាប់មកសាមណេរត្រូវទទួលតាមលោកទៀតពាដងថា

**ឥមានិ ទស សិក្ខា បទានិ សមាទិយាមិ ។**

ក្រាបបង្គំម្តងក្រោកឈរប្រណម្យអញ្ជលីសូធ្យក្រាបថ្វាយបង្គំពាដងថា

**វន្ទាមិ ភន្តេ សព្វំ អបរាធំខមថ សាធុ សាធុ អនុមោទាមិ ។**

វិធីបំបួសសាមណេរចប់តែប៉ុណ្ណេះ

បន្ទាប់មកគប្បីសុំនិស្ស័យ ឯបាលីសុំនិស្ស័យនោះមានដូចតទៅ

កុលបុត្របានបួសជាសាមណេរលក្ខណៈដូចបានធ្វើរួចមកហើយ នោះតពីនេះទៅ គប្បីសុំនិស្ស័យពីព្រះឧបជ្ឈាយ៍។ រីឯកិច្ចសុំនិស្ស័យ គឺសាមណេរត្រូវមានគ្រឿងសក្ការៈប្រគេនព្រះឧបជ្ឈាយ៍ ប្រណម្យអញ្ជលីសូធ្យថា

**ឱកាស វន្ទាមិ ភន្តេ សព្វំ ឧលឧ សាធុ សាធុអនុមោទាមិ ឧ**

**ឱកាស ការុញ្ញំ កត្វា និស្សយំ ទេថ មេ ភន្តេឧ**

អង្គុយចុះផ្គងអញ្ជលីសូធ្យថា

**អហំ ភន្តេ និស្សយំ យាចាមិ ឧ**

**ទុតិយម្បិ អហំ ភន្តេ និស្សយំ យាចាមិឧ**

**តតិយម្បិ អហំ ភន្តេ និស្សយំ យាចាមិឧ**

ក្រាបសិរសាចុះសូធ្យថា

**ឧបជ្ឈាយោ មេ ភន្តេ ហោហិ** ព្រះឧបជ្ឈាយ៍លោកពោលតបថា **សាធុ** ឬថា **លហុ** ថា **ឱបាយិកំ** ឬថា **បដិរូបំ** ឬក៏ **បាសាទិកេន សម្បាទេហិ** ទាំង៥បទនេះណាមួយ ស្រេចលើព្រះទ័យលោក។

សាមណេរគប្បីទទួលថា

**ឱកាស សម្បដិច្ឆាមិឧ** លោកពោលពីរដងទៀតគប្បីទទួលត្រឹមតែថា **សម្បដិច្ឆាមិ សម្បដិច្ឆាមិឧ**

បន្ទាប់មកសាមណេរ ងើបសិរសាឡើងប្រណម្យអញ្ជលី សូធ្យពីរ ដងឱ្យខ្លាំង៧ថា: **អជ្ជតគ្គេទានិ ថេរោ មយ្ហំ ភារោ អហំ បិ ថេរស្ស ភារោ។**

រួចហើយថ្វាយបង្គំ៣ដងចប់វិធីយកវត្តតែប៉ុណ្ណោះ ។[១០]

## បាលីសុំទណ្ឌកម្ម

**លភេយ្យាហំ ភន្តេ ទណ្ឌកម្មំ អាយតឹ សំវរំ អាបជ្ជិស្សាមិ។**

ប្រែថា:បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណាត្រូវទណ្ឌកម្ម ខ្ញុំព្រះករុណានឹងដល់នូវសេចក្ដីសង្រួមគឺថានឹងប្រព្រឹត្តឱ្យល្អទៅមុខទៀត ។

ព្រះឧបជ្ឈាយ៍ ឬអាចារ្យត្រូវដាក់ទណ្ឌកម្មឱ្យសាមណេរនោះ តាមទោសកំហុស ។បើបានធ្វើទណ្ឌកម្មរួចស្រេចហើយ សាមណេរនោះក៏ឈ្មោះថាបាន តាំងនៅក្នុងសេចក្ដីបរិសុទ្ធដូចប្រក្រតី ។

ក្នុងលោកនេះ បើគេនិយាយឱ្យស្លាប់ចិត្ត ដោយប្រើពាក្យផ្អែមល្ហែមដូចទឹកឃ្មុំ បើគេធ្វើឱ្យលុះក្នុងអំណាច ដោយឧបាយមច្ឆាចារគេមិនបញ្ឆោតបោកបាន ? ឱគួរសង្វេគណាស់ !

ទស្សនៈ ភិក្ខុ ប៉ាង ខាត់ វីរិយបណ្ឌិតោ

---

១០-ទៀន-យន់ និង អ៊ួង-នឿន វិន័យសាមណេរ ទំព័រ ៣-១២ និង ទំព័រ ៥៥ ផ្សាយចេញពីបណ្ណាគារគីម-គី បោះពុម្ពលើកទី៤ ព.ស. ២៥១៦ គ.ស.១៩៧២ ។

# បាលីចូលព្រះវស្សា

**ឱកាស ឥមស្មឹ អាវាសេ ឥមំ តេមាសំ វស្សំ ឧបេមិ ៗ**

**-ទុតិយម្បិ ឱកាស ឥមស្មឹ អាវាសេ ឥមំ តេមាសំ វស្សំ ឧបេមិៗ**

**-តតិយម្បិ ឱកាស ឥមស្មឹ អាវាសេ ឥមំ តេមាសំ វស្សំ ឧបេមិៗ**

បើម្នាក់ឯងថា"មិ "តែបើគ្នាច្រើនថា" ម"។

ប្រែថា យើងទាំងឡាយនៅចាំវស្សាអស់ខែ៣នេះក្នុងអាវាសថា តែត្រឹមបាលី៣ដងមិនបាច់ថាសេចក្តីប្រែទេ។

# បាលីលើកសត្តាហៈ

**សចេ មេ អន្តរាយោ នត្ថិ សត្តាហព្ភន្តរេ យេវ បុន និវត្តិស្សាមិៗ**

**-ទុតិយម្បិ សចេ មេ ៗលៗ និវត្តិស្សាមិៗ**

**-តតិយម្បិ សចេ មេ ៗលៗ និវិត្តិស្សាមិៗ**

បើមិនមានអន្តរាយដល់អាត្មាអញទេ អាត្មាអញនឹងត្រឡប់មកវិញក្នុងចន្លោះសត្តាហៈពុំខាន។

ជាគម្រប់ពីរដងផង ! ជាគម្រប់បីដងផង ។

# បាលីចេញព្រះវស្សា

ឱកាស សង្ឃម្ភន្តេ បវារេមិ ទិដ្ឋេនវា សុត្តេនវា បរិសង្កាយវា វទន្តុមំ អាយស្មតោ អនុកម្បំ ឧបាទាយ បស្សន្តោ បដិក្ករិស្សាមិ

ទុតិយម្បិ }
តតិយម្បិ } សង្ឃម្ភន្តេ បវារេមិ ទិដ្ឋេន វា

សុត្តេន វា បរិសង្កាយវា វទន្តុមំ អាយស្មតោ អនុកម្បំ ឧបាទាយ បស្សន្តោ បដិក្ករិស្សាមិ[១១]

អ្នកប្រាជ្ញ កាលបើស្វែងរក វិជ្ជានិងទ្រព្យ គប្បីគិតថាដូចជាខ្លួនមិនចាស់មិនស្លាប់ កាលបើស្វែងរកធម៌ គប្បីគិតថាខ្លួនត្រូវម្រឹត្យុចាប់ក្របួចសក់បោកសម្លាប់ឥឡូវនេះហើយ ។

បណ្តាទ្រព្យទាំងពួង វិជ្ជាលោកពោលថា ជាទ្រព្យដ៏ឧត្តម ព្រោះវិជ្ជាចោរលួចយកមិនបានផង កាត់ថ្លៃមិនបានផង មិនចេះរេចរឹលអស់ទៅផងសព្វៗកាល ។

ទស្សនៈ ភិក្ខុ ប៉ាង ខាត់ វីរិយបណ្ឌិតោ

១១-ទៀន-យន់ និង អួង-នឿន វិន័យសាមណេរ ទំព័រ១០៦-១០៧ ផ្សាយចេញពីបណ្ណាគារ គីម-គី បោះពុម្ពលើកទី៤ ព.ស.២៥១៦ គ.ស. ១៩៧២ ។

# ការលាចាកសិក្ខាបទ

ភិក្ខុសាមណេរអ្នកនឿយណាយក្នុងការប្រព្រឹត្តព្រហ្មចរិយធម៌មានប្រាថ្នានឹងត្រឡប់មកកាន់ភេទជាគ្រហស្ថ រមែងធ្វើបានដោយការលាសិក្ខា។ ឯការលាសិក្ខាបទនោះក្នុង **គម្ពីរកង្ខាវិតរណី បឋមបារាជិក**សម្តែងថា ត្រូវប្រកបអង្គ៦យ៉ាងគឺ

ចិត្ត១ ខេត្ត១ កាល១ បយោគ១ បុគ្គល១ វិជាននៈ១។

១-**ចិត្ត** អ្នកលាសិក្ខា ត្រូវធ្វើដោយតាំងចិត្តដើម្បីលាសិក្ខាពិត១ បើគ្រាន់តែថាលេង ឬទន្ទេញពាក្យលាពោលដោយការរៀន ឬក៏សម្តែងវិន័យថាមិនរាប់ថាលាទេ។

២-**ខេត្ត** សំដៅយក ខេត្តបទ២២យ៉ាង គឺសម្រាប់ពោលលា ១៤យ៉ាង និងខេត្តបទសម្រាប់ទ្រទ្រង់ភេទជាថ្មី៨យ៉ាង។

ខេត្តបទសម្រាប់ពោលលា១៤យ៉ាងគឺ

**ពុទ្ធំ បច្ចក្ខាមិ** ខ្ញុំសូមលាព្រះពុទ្ធ១

**ធម្មំ បច្ចក្ខាមិ** ខ្ញុំសូមលាព្រះធម៌១

**សង្ឃំ បច្ចក្ខាមិ** ខ្ញុំសូមលាព្រះសង្ឃ១

**សិក្ខំ បច្ចក្ខាមិ** ខ្ញុំសូមលាសិក្ខា១

**វិនយំ បច្ចក្ខាមិ** ខ្ញុំសូមលាវិន័យ១

**បាតិមោក្ខំ បច្ចក្ខាមិ** ខ្ញុំសូមលាបាតិមោក្ខ១

**ឧទ្ទេសំ បច្ចក្ខាមិ** ខ្ញុំសូមលាឧទ្ទេស១

**ឧបជ្ឈាយំ បច្ចក្ខាមិ** ខ្ញុំសូមលាព្រះឧបជ្ឈាយ៍១

**អាចរិយំ បច្ចក្ខាមិ** ខ្ញុំសូមលាអាចារ្យ១

**សទ្ធិវិហារិកំ បច្ចក្ខាមិ** ខ្ញុំសូមលាសទ្ធិវិហារិក១

**អន្តេវាសិកំ បច្ចក្ខាមិ** ខ្ញុំសូមលាអន្តេវាសិក១

**សមានុបជ្ឈាយកំ** ខ្ញុំសូមលាសមានុបជ្ឈាយក៏១

**សមានាចរិយកំ បច្ចក្ខាមិ** ខ្ញុំសូមលាសមានាចរិយក៏

**សព្រហ្មចារឹ បច្ចក្ខាមិ** ខ្ញុំសូមលាសព្រហ្មចារី១

ខេត្តបទសម្រាប់ទ្រទ្រង់ភេទជាថ្មី៨យ៉ាងគឺ

**១-គិហីតិមំធារេថ**សូមលោកម្ចាស់ទាំងឡាយចាំទុកនូវខ្ញុំថាជាគ្រហស្ថ១

**២-ឧបាសកោតិ មំ ធារេថ** សូមលោកម្ចាស់ទាំងឡាយចាំទុកនូវខ្ញុំថាជា ឧបាសក១

**៣-អារាមិកោតិ មំ ធារេថ** សូមលោកម្ចាស់ទាំងឡាយចាំទុកនូវខ្ញុំថាជាអារាមិកជន១

**៤-សាមណេរោតិ មំ ធារេថ** សូមលោកម្ចាស់ទាំងឡាយចាំទុកនូវខ្ញុំថាជាជាសាមណេរ១

**៥-តិត្ថិយោតិ មំ ធារេថ**សូមលោកម្ចាស់ទាំងឡាយចាំទុកនូវខ្ញុំថាជាតិរ្ថិយ១

**៦-តិត្ថិយសាវកោតិ មំ ធារេថ** សូមលោកម្ចាស់ទាំងឡាយចាំទុកនូវខ្ញុំថាជាសាវកតិរ្ថិយ១

**៧-អស្សមណោតិ មំ ធារេថ** សូមលោកម្ចាស់ទាំងឡាយចាំទុកនូវខ្ញុំថាជាបុគ្គលមិនមែនជាសមណៈ១

**៨-អសក្យបុត្តិយោតិ មំ ធារេថ** សូមលោកម្ចាស់ទាំងឡាយចាំទុកនូវខ្ញុំថាជាអសក្យបុត្ត១។ រួមត្រូវជាខេត្តបទ ២២ ប្រការ។

ក្នុងខេត្តបទ២២ប្រការនេះ អ្នកលាសិក្ខាគប្បីពោលលាតែខេត្តបទណាមួយដែលខ្លួនចង់លា ហើយទ្រទ្រង់ខេត្តបទណាមួយដែលខ្លួនស្រឡាញ់។

៣-**កាល** អ្នកលាសិក្ខាត្រូវពោលឱ្យច្បាស់ កុំឱ្យច្រឡំកាល ដូចជាពោលថា ខ្ញុំនឹងលា (បច្ចក្ខិស្សំ) ខ្ញុំព្រះករុណា នឹងជាគ្រហស្ថ (គិហីភវិស្សំ)។ល។ មិនឈ្មោះថាលាសិក្ខាឡើយ ត្រូវលាជាសមាទានកាលថា សិក្ខំ បច្ចក្ខាមិ ខ្ញុំលាសិក្ខា គិហីតិ មំ ធារេថ សូមព្រះករុណាទាំងឡាយចាំទុកខ្ញុំនេះថាជាគ្រហស្ថ។

៤-**បយោគ** បយោគចែកជា២យ៉ាង គឺកាយប្បយោគ១ វចីបយោគ១ ។ កាយប្បយោគគឺអ្នកលាគ្រាន់តែធ្វើកាយវិការ ឬផ្លាស់សំពត់កាសាវៈចេញស្លៀកដណ្តប់ដូចគ្រហស្ថមិនរាប់ថាលាទេលុះណាតែបញ្ចេញវាចា ប្តេជ្ញាខ្លួនឯងជាវចីបយោគ ទើបឈ្មោះថាលា។

៥-**បុគ្គល** បុគ្គលអ្នកលាសិក្ខា មិនមែនជាមនុស្សឆ្កួត មិនក្រឡកចិត្ត មិនមានវេទនាគ្របសង្កត់ទាំងបុគ្គលដទៃជាសាក្សីនោះមិនមែនជាសត្វគឺជាមនុស្សដឹងខុសត្រូវហើយនៅចំពោះមុខគ្នាឯង។

៦-**វិញ្ញាបនៈ** ការឱ្យដឹងច្បាស់អ្នកលាសិក្ខាគប្បីប្រាប់អ្នកដទៃឱ្យដឹងច្បាស់អំពីការអផ្សុកចង់សឹក និងប្រាប់ភេទថ្មីដែលត្រូវផ្លាស់ ។

បើប្រកបដោយអង្គទាំង៦នោះហើយទើបឈ្មោះថាលាសិក្ខា ។

វិជ្ជាយឹតយោងជនដែលនៅថោកទាប ឱ្យបានចូលទៅជិតព្រះនរបតីដែលគេនៅជិតបានដោយក្របំផុត ឬអ្នកមានបុណ្យដ៏ក្រៃលែង ជាងព្រះនរបតីទៅទៀត ។ ដូចស្ទឹងដែលនៅក្នុងទីទាបតែងប្រមូលយកទឹកចូលទៅកាន់សមុទ្រ ។ វិជ្ជាអាចនាំឱ្យមានវិន័យ វិន័យនាំឱ្យបានសេចក្តីថ្លៃថ្នូរ សេចក្តីថ្លៃថ្នូរនាំឱ្យបានទ្រព្យសម្បត្តិ ហើយទ្រព្យសម្បត្តិក៏អាចនាំឱ្យបានធមិ ធមិដឹកនាំឱ្យបានសេចក្តីសុខ ។សស្ត្រវិជ្ជា និងសាស្ត្រវិជ្ជា ទាំងពីរនេះគួរប្រតិបត្តិ សិក្សារៀន ឱ្យចេះដឹង ទាំងអស់វិជ្ជាទី១ខាងដើម(សស្ត្រវិជ្ជា) កើតចម្រើនឡើងដើម្បីសើចលេង ជាត្លុកកំប្លែង វិជ្ជាទី២ខាងចុង (សាស្ត្រវិជ្ជា) បុគ្គលគួរគោរពក្នុងកាល ទាំងពួង ។

ទស្សនៈ ភិក្ខុ ប៉ាង ខាត់ វីរិយបណ្ឌិតោ

១២-ទៀន-យន់ និង អួង-នឿន វិន័យសាមណេរ ទំព័រ១០៨-១១៣ ផ្សាយចេញពីបណ្ណាគារ គីម-គី បោះពុម្ពលើកទី៤ ព.ស. ២៥១៦ គ.ស.១៩៧២ ។

# បាលីសម្ដែងអាបត្តិ

សព្វាតា អាបត្តិយោ អារោចេមិ សព្វាតា អាបត្តិយោ អារោចេមិ សព្វាគរុ លហុកា អាបត្តិយោ អារោចេមិ សព្វាគរុ លហុកា អាបត្តិយោ អារោចេមិ៕

ឧកាស អហំ ភន្តេ សម្ពហុលានានា វត្ថុកាអាបត្តិយោ អបជ្ជឹតា តុម្ហមូលេ បដិទេសេមិ៕

ចាស់: បស្សសិ អាវុសោ តា អាបត្តិយោ៕

ក្មេង: ឧកាស អាម ភន្តេ បស្សាមិ

ចាស់: អាយតឹ ភន្តេ សំវរិយ្យាសិ

ក្មេង: សាធុ សដ្ឋុ ភន្តេ សំវរិស្សាមិ

ទុតិយម្បិ សាធុ សដ្ឋុ ភន្តេ សំវរិស្សាមិ

តតិយម្បិ សាធុ សដ្ឋុ ភន្តេ សំវរិស្សាមិ៕

នបុនេវំ ករិស្សាមិ នបុនេវំ ភាសិស្សាមិ នបុនេវំ ចិន្តយិស្សាមិ៕

ចាស់: សព្វាតា អាបត្តិយោ អារោចេមិ (៣ដង)

សព្វាគរុ លហុកា អាបត្តិយោ អារោចេមិ (៣ដង)

អហំ អាវុសោ សម្ពហុលានានា វត្ថុកា អាបត្តិយោ អបជ្ជឹតា តុយ្ហមូលេ បដិទេសេមិ៕

**ក្មេង: ឱកាសអាម ភន្តេ តាអាបត្តិយោ**

**ចាស់: អាម អាវុសោ បស្សាមិ**

**ក្មេង: អាយតឹ ភន្តេ សំវរិយ្យាថ**

**ចាស់: សាធុ សដ្ឋុ អាវុសោ សំវរិយ្យាមិ**

**ទុតិយម្បិ សាធុ សដ្ឋុ អាវុសោ សំវរិយ្យាមិ**

**តតិយម្បិ សាធុ សដ្ឋុ អាវុសោ សំវរិយ្យាមិ**

**នបុនេវំ ករិស្សាមិ នបុនេវំ ភាសិស្សាមិ នបុនេវំ ចិន្តយិស្សាមិ៥**

(បើចង់សម្តែងបញ្ជាក់អាបត្តិត្រូវថាដូចខាងក្រោមបើថាសរុបមិនបាច់ថាទេ) ត្រង់បាចិត្តិយាយោ អាចបញ្ចូលកងអាបត្តិណាមួយក៏បាន ក្នុងវង់ក្រចក។

**ក្មេង: អហំ ឯកំ អាបត្តឹ អាបន្នោតា (បាចិត្តិយាយោ) តាតុម្ហមូលេ បដិទេសេមិ**

**ចាស់: បស្សសិ អាវុសោ តា អាបត្តិយោ**

**ក្មេង: ឱកាស អាម ភន្តេ បស្សាមិ**

**ចាស់: អយតឹ អាវុសោ សំវរិយ្យាសិ**

**ក្មេង: សាធុ សដ្ឋុ ភន្តេ សំវរិយ្យាថ**

**ទុតិយម្បិ សាធុ សដ្ឋុ ភន្តេ សំវរិយ្យាថ**

**តតិយម្បិ សាធុ សដ្ឋុ ភន្តេ សំវរិយ្យាថ**

**នបុនេវំ ករិស្សាមិ នបុនេវំ ភាសិស្សាមិ នបុនេវំ ចិន្តយិស្សាមិ ៥**

## ពាក្យអារាធនាព្រះធម្មកថិកសម្តែងធម៌ទេសនា

**ព្រហ្មា ច លោកាធិបតី សហម្បតី កតញ្ជលី អន្ធិវរំ អាយាចថ សន្តីធ សត្តាប្បរជក្ខជាតិកា ទេសេស្សុ ធម្មំ អនុកម្បិមំ បជំ ។**

សហម្បតីព្រហ្ម ឱនបង្គំអារាធនា សម្តេចព្រះភគវា ដោយគាថាយ៉ាងនេះឯង។ព្រះពុទ្ធទ្រង់អនុកូល ព្រមទទួលនឹងសម្តែង ដោយតុណ្ហីភាពថ្លែង តាមភារៈគុណករុណា។ ទើបក្រោកចាកទីនោះ ភក្ត្រាឆ្ពោះព្រៃមិគទាយ៍ យាងចេញចរលីលា ពីទីនោះដោយព្រះបាទ។ ញុំាងសត្វចូលពុទ្ធចក្រ មានបញ្ចវគ្គីយ៍ជាអាទិ៍ ឱ្យផឹកអម្រឹតជាតិ រសនិព្វានតាមធម្មតា។ ចាប់ផ្តើមពីនោះឯង ទ្រង់សម្តែងធមិទេសនា ធ្វើពុទ្ធក្រឹត្យា អស់វស្សាសែសិបប្រាំ។ ពុំថយពុំបន្ធូរ ប្រយោជន៍យូរអង្វែងឆ្នាំ សម្រេចបុញ្ញកម្ម ដល់សព្វសត្វទាំងភពត្រ័យ។ ហេតុនោះឥឡូវនេះ យើងខ្ញុំនេះសាទរក្រៃ បពិត្រព្រះគុណថ្លៃ សូមនិមន្តប្រោសទេសនា។ អនុគ្រោះពួកបរិស័ទ ដែលជាប់ខាត់ដោយមោហា ឱ្យកើតមានបញ្ញា ប្រាកដនាទីនេះហោង។[១៣]

ទោះការគិតគួរល្អឥតខ្ចោះ មិនមានចន្លោះច្រាសក្នុងចិត្ត
គិតហើយសឹមគួររក្សាពិត ចាំទុកក្នុងចិត្តមិនភ្លេចថ្ងៃ។
ចំណេះវិជ្ជាមានច្រើនល្អ ផ្លូវលោកផ្លូវធមិល្អពេកក្រៃ
ខំប្រឹងទន្ទេញទាំងយប់ថ្ងៃ លកលៃកែច្នៃទាន់នៅក្មេង។
នៅមានត(២)

១៣-គហិប្បតិបត្តិយរាវាសធមិ ទំព័រ ២៨-៣០ ផ្សាយចេញពីអាស្រមឧត្តម ព.ស. ២៥៤៧។

# របៀបធ្វើពុទ្ធាភិសេក

ការធ្វើពុទ្ធាភិសេកមានរបៀបរៀបរយ៩សង្កាត់គឺ

សង្កាត់ទី១ រៀបចំគ្រឿងសក្ការបូជា មានផ្កាស្រស់ៗ (មានផ្កាម្លិះ-ផ្កាឈូកជាដើម) និងទៀនធូបថ្វាយបដិមាអង្គថ្មី ។

សង្កាត់ទី២ និមន្តព្រះភិក្ខុសង្ឃចម្រើនព្រះបរិត្ត។

សង្កាត់ទី៣ និមន្តព្រះធម្មកថិកមួយព្រះអង្គសម្តែងរឿងបឋមត្រាស់។

សង្កាត់ទី៤ និមន្តព្រះភិក្ខុមួយអង្គ ឬពីរអង្គសូធ្យបាលីពុទ្ធាភិសេក។

សង្កាត់ទី៥ សូធ្យបទធម្មសង្វេគ ដែលធ្លាប់ហៅថាធមិបទ។

សង្កាត់ទី៦ សូធ្យបទផ្ចាញ់មារ។

សង្កាត់ទី៧ និមន្តព្រះសង្ឃសូធ្យបាលីគាថា ពុទ្ធជយមង្គល គឺធមិពាហុំ ។

សង្កាត់ទី៨ ពុទ្ធបរិស័ទបាចផ្កាស្រស់មានផ្កាម្លិះជាដើម ទៅលើព្រះពុទ្ធរូបអង្គថ្មី អ្នកខ្លះមានសុគន្ធវារីប្រោះព្រំ ទឹកក្រអូបនោះថ្វាយព្រះពុទ្ធរូបអង្គថ្មី ដោយស្ងៀមៗឥតបញ្ចេញវាចាថាអ្វី ជួនកាលកំពុងធ្វើពិធីនេះ អាចារ្យម្នាក់បញ្ចេញវាចាខ្លាំងៗឱ្យពុទ្ធបរិស័ទថា តាមទាំងអស់គ្នាថា ព្រះពុទ្ធមានសិរីទ្រង់ឈ្នះហើយ! មារមានចិត្តបាប ចាញ់ព្រះអង្គហើយ! (ថាតាម៣ដង)។

សង្កាត់ទី៩ លុះចប់ពិធីនេះហើយពុទ្ធបរិស័ទជាឧបាសកឧបាសិកាទាំងអស់គ្នា សូធ្យធមិនមស្ការព្រះរតនត្រ័យតាមទម្លាប់ដែលតែងសូធ្យរៀងមក។ រួចហើយសូធ្យធមិឧទ្ទិសកុសល ផលបុណ្យ តាមទម្លាប់ដូចសព្វដង។

# គាថាខ្លះៗសម្រាប់សូធ្យក្នុងពិធីពុទ្ធាភិសេក

## នមោ តស្ស ខ លខ ៣ចប់

**បារមី៣០..................................ខលខ**

**ពាហុំ..................................ខលខ**

**ក្រែសកជយយោស......................ខលខ**

**ជយន្តោ..................................ខលខ**

**អវិជ្ជា..................................ខលខ**

**អនេកជាតិ..............................ខលខ**

**ធម្មចក្រ..................................ខលខ**

**មង្គល៣៨ប្រការ........................ខលខ**

**ឱកាស វន្ទាមិ ភន្តេ ភគវា សព្វំ ..ខលខ**

**យាទេវតា..............................ខលខ**

**យំកិញ្ចិ ស..............................ខលខ**

| | |
|---|---|
| លះបង់គំនិតទិដ្ឋិខុស | ក្នុងនាមកូនប្រុសកុំដើរលេង |
| រៀនច្រើនចម្រើនទាំងវ័យក្មេង | ស័យប្រែជាហេងថ្ងៃអវសាន ។ |
| អ្នកមានចំណេះមានទាំងប្រាក់ | សប្បាយហ៊ីកហ៊ាក់អ្វីក៏បាន |
| រស់នៅមានន័យសុខសាន្តត្រាណ | មានទាំងលុយឡានប្រាក់ហៀរហូរ ។ |

នៅមានត(៣)

# បាលីប្រែជយឃោស

**ជយោ ហិ ពុទ្ធស្ស សិរីមតោ អយំ មារស្ស ច បាបិមតោ បរាជយោ** ។ ប្រែថាព្រះពុទ្ធមានសិរីទ្រង់ឈ្នះហើយ មារមានចិត្តបាបចាញ់ព្រះអង្គហើយ **ជយោហិ ពុទ្ធស្ស សិរីមតោ អយំ** ព្រះពុទ្ធមានសិរីទ្រង់ឈ្នះហើយ **មារស្ស ចបាបិមតោប រាជយោ** មារមានចិត្តបាបចាញ់ព្រះអង្គហើយ ។សូធ្យឱ្យថាតាមព្រម៧គ្នាបីដង សូធ្យធមិនមស្ការព្រះរតនត្រ័យដូចទម្លាប់សព្វដង ។

ចប់ពិធីពុទ្ធាភិសេកសង្ខេបត្រឹមតែប៉ុណ្ណោះ ។

| | |
|---|---|
| មានខ្ញុំកំដរទាំងឆ្វេងស្តាំ | រីករាយប្រចាំឬចង់ដូរ |
| ជ្រើសរើសស្រីល្បីមកបញ្ជូរ | មានអ្នកជំហាររង់ចាំស្រាប់ ។ |
| កវីបណ្ឌិតអ្នកប្រាជ្ញផង | បានរៀបចងក្រងជាច្រើនច្បាប់ |
| ស្នាដៃនិពន្ធយ៉ាងចំណាប់ | រៀបរាប់សាសព្វឆ្លុះបញ្ចាំង ។ |
| សៀវភៅលក់នៅបណ្ណាគារ | មានគ្រប់នានាដាក់ទូតាំង |
| តម្កល់បង្ហាញមិនបិទបាំង | មានទាំងក្នុងឡាំងល្អពេកកូវ ។ |
| ដូច្នេះចូរអ្នកខំឧស្សាហ៍ | រៀនវិជ្ជាណាដែលត្រឹមត្រូវ |
| កិត្តិយសខ្ពស់ថ្លាមិនអាស្រូវ | គ្រាន់បង្ហាញផ្លូវសព្វទីឋាន ។ |

នៅមានត(៤)

# នមោ៨បទ

## បបរិវត្ត

**នមោអរហតោសម្មា សម្ពុទ្ធស្ស មហេសិនោ**

ខ្ញុំសូមបង្គំឆ្ពោះព្រះអរហន្ត សម្ពុទ្ធភគវន្តកាលស្វែងរកធម៌
គឺពោធិញ្ញាណប្រសើរបវរ បានត្រាស់ដឹងធម៌ដោយអរិយមគ្គ ។

**នមោឧត្តមធម្មស្ស ស្វាក្ខាតស្សេវ តេនិធ**

សូមថ្វាយបង្គំព្រះធម៌ឧត្តម ដែលព្រះបរមសម្ពុទ្ធសម្តែង
ដោយប្រពៃពិតប្រាកដជាក់ស្តែង ព្រះធម៌នោះឯងទុកជាសាសនា ។

**នមោមហាសង្ឃស្សាបិ វិសុទ្ធិសីលទិដ្ឋិនោ**

សូមថ្វាយបង្គំព្រះសង្ឃប្រសើរ ដែលលោកបានធ្វើទិដ្ឋិនិងសីល
ឱ្យបានបរិសុទ្ធផុតចាកមន្ទិល គឺទិដ្ឋិសីលលោកស្អាតអស់ហើយ ។

**នមោឱមាត្យារទ្ធស្ស រតនត្តយស្ស សាធុកំ**

សូមថ្វាយបង្គំប្រជុំត្រៃរតន៍ ប្រារព្ធដោយបទមានពីរប្រការ
ព្រះពុទ្ធព្រះធម៌ព្រះសង្ឃនេះណា ប្រសើរថ្លៃថ្លារកថ្លែងពុំបាន ។

**នមោឱមកាតីតស្ស តស្សេវត្ថុត្តយស្សាបិ**

សូមថ្វាយបង្គំភ្នំវត្ថុបី ពិសេសពិសីប្រសើរថ្កើងថ្កាន
ព្រះពុទ្ធព្រះធម៌ព្រះសង្ឃសព្វស្ថាន តេជះកល្យាណដោយគុណគួរគាប់ ។

**នមោ ការប្បភាវេន វិគច្ឆន្តុឧបទ្ទវា**

សូមថ្វាយបង្គំត្រៃរតន៏សោភា ឧបទ្រពនានាចូរវិនាសបាត់
ដោយអានុភាពបុណ្យជួយកម្ចាត់ ធ្វើក្ដីវិបត្តិឱ្យស្ងាត់សូន្យទៅ។

**នមោ ការានុភាវេន សុវត្ថិ ហោតុសព្វទា**

សូមថ្វាយបង្គំត្រៃរតន៏ទាំងបី សូមសុខសួស្ដីកើតសព្វវេលា
ដោយអានុភាពធ្វើការវន្ទា គោរពបូជាព្រះត្រៃរតនៈ។

**នមោ ការស្សតេជេន វិធិម្ហិ ហោមិតេជវា**

សូមថ្វាយបង្គំត្រៃរតន៏សោភា តេជះចេស្ដាចូរមានដល់ខ្ញុំ
ក្នុងពិធីធ្វើការថ្វាយបង្គំ តេជះបុណ្យធំចូរកើតឡើងហោង។[១៤]

រូបគំនូរដែលគេគួរទុកឲ្យដំភាជនៈថ្មី មិនឃ្លាតក្លាយទៅជាប្រការដទៃយ៉ាងណា នីតិវិជ្ជា ដែលគេបង្ហឹក បង្ហាត់ ដល់កូនក្មេង ទាំងឡាយដោយថា ជាគ្រឿងប្រៀបធៀប ក៏ជាប់នៅយ៉ាងនោះ លោកពោលទុកក្នុងទីនេះមិត្តលាភ "ការគប់មិត្ត"។

ទស្សនៈ ភិក្ខុ ប៉ាង ខាត់ វីរិយបណ្ឌិតោ

---

១៤-មាឃបូជា វិសាខបូជា និងពិធីពុទ្ធាភិសេក រៀបចំដោយគណៈកម្មការធម្មវិន័យ ផ្សាយដោយបណ្ណាគារ យាយតា ព.ស. ២៥៣៣ គ.ស. ១៩៨៩។

# វិធីសមាទានឧបោសថសីល

ឱកាស អហំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ អដ្ឋសីលានិ យាចាមិ។

ទុតិយម្បិ អហំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ អដ្ឋសីលានិ យាចាមិ។

តតិយម្បិ.....។ល។.........................................។

## មួយបែបទៀត

ឱកាស អហំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ អដ្ឋង្គសមន្នាគតំ ឧបោសថំ យាចាមិ អនុគ្គហំ កត្វា សីលំ ទេថ មេ ភន្តេ។

ទុតិយម្បិ អហំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ អដ្ឋង្គសមន្នាគតំ ឧបោសថំ យាចាមិ អនុគ្គហំ កត្វា សីលំ ទេថ មេ ភន្តេ។

តតិយម្បិ........................។ល។......................។

បញ្ជាក់

(បើសុំសីលម្នាក់ឯងថា **ទេថ មេ** តែបើសុំសីលច្រើននាក់ ត្រូវថា **ទេថ នោ** វិញ។

**សិក្ខាបទ**

**បាណាតិបាតា វេរមណី សិក្ខាបទំ សមាទិយាមិ ។**

**អទិន្នាទានា វេរមណី សិក្ខាបទំ សមាទិយាមិ ។**

**អព្រហ្មចរិយា វេរមណី សិក្ខាបទំ សមាទិយាមិ ។**

**មុសាវាទា វេរមណី សិក្ខាបទំ សមាទិយាមិ ។**

**សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី សិក្ខាបទំ សមាទិយាមិ ។**

**វិកាលភោជនា វេរមណី សិក្ខាបទំ សមាទិយាមិ ។**

**នច្ចគីតវាទិតវិសូកទស្សន មាលាគន្ធវិលេបនធារណមណ្ឌន វិភូសនដ្ឋានា វេរមណី សិក្ខាបទំ សមាទិយាមិ ។**

**ឧច្ចាសយនមហាសយនា វេរមណី សិក្ខាបទំ សមាទិយាមិ ។**

រួចហើយអ្នកសមាទានត្រូវសូធ្យកំណត់ឧបោសថសីលថា

**ឥមំ អដ្ឋង្គសមន្នាគតំ ពុទ្ធប្បញ្ញត្តំ ឧបោសថំ ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ សម្មទេវ អភិរក្ខិតុំ សមាទិយាមិ ។**

ប្រែថា៖ខ្ញុំព្រះករុណាសូមសមាទាននូវឧបោសថសីលដ៏ប្រកបដោយអង្គប្រាំបីប្រការដែលព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់បញ្ញត្តិទុកហើយនេះដើម្បីនឹងរក្សាឱ្យបរិបូណ៌ ប្រពៃអស់កាលកំណត់ថ្ងៃនេះ និងយប់នេះ សូមកុសលចូរជាឧបនិស្ស័យ ធ្វើឱ្យជ្រាបច្បាស់នូវព្រះនិព្វាន ក្នុងដ៏អនាគតទៅឯជាតិមុខ នោះហោង ។[១៥]

---

១៥-គហិប្បតិបត្តិ យកវាំសធម្ម ទំព័រ២០-២២ ផ្សាយចេញពីអាស្រមឧត្តម ព.ស. ២៥៤៧ ។

# វិធីសមាទាននិច្ចសីល (សីលប្រាំ)

**ឱកាស អហំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ បញ្ចសីលានិ យាចាមិ។**

**ទុតិយម្បិ អហំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ បញ្ចសីលានិ យាចាមិ។**

**តតិយម្បិ.....។ល។........................................។**

បញ្ជាក់៖ បើសុំសីលម្នាក់ឯងថា **ទេថ មេ** តែបើសុំសីលច្រើននាក់ ត្រូវថា **ទេថ នោ** វិញ ។

# ពិធីវេររោងឧបោសថ

**មយំ ភន្តេ ឥមំ ឧបោសថាគារំ ការេត្វា ឧបោសថប្បវារណាទិ សង្ឃកម្មំ ករណត្ថាយ ចាតុទ្ទិសស្ស ភិក្ខុសង្ឃស្ស ទេម សាធុ ភន្តេ ភិក្ខុសង្ឃោ ឥមំ ឧបោសថាគារំ បដិគ្គណ្ហតុ មាតាបិតាទីនំ គុណវន្តានំ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ។**

**ទុតិយម្បិ ..............................................។**

**តតិយម្បិ ..............................................។**

ប្រែថា បពិត្រព្រះគម្ដែងសង្ឃដ៏ចម្រើនយើងខ្ញុំទាំងឡាយបានចាត់ចែងធ្វើនូវរោងសម្រាប់ធ្វើឧបោសថកម្មនេះហើយសូមវេរប្រគេនដល់ព្រះភិក្ខុសង្ឃ

ដែលមកអំពីទិសទាំង៤ដើម្បីជាប្រយោជន៍ដល់កិរិយាធ្វើនូវសង្ឃកម្ម មាន ឧបោសថកម និងបវារណាកម្មជាដើម បពិត្រព្រះគម្ពែងសង្ឃដ៏ចម្រើនសូម ព្រះភិក្ខុសង្ឃទទួលយកនូវរោងសម្រាប់ធ្វើនូវឧបោសថនេះ ដើម្បីសេចក្តី ចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខគ្រប់ប្រការ ដល់លោកអ្នកដ៏ មានគុណទាំងឡាយមានមាតាបិតាជាដើមផង ដល់យើងខ្ញុំទាំងឡាយផង អស់កាលជាអង្វែងទៅហោង ។ អស់វារៈពីរដងផង អស់វារៈបីដងផង ។

## ឈ្មោះសេនាសនៈទាំងឡាយមានដូចជា

**ឥមំ សាលំ** នូវសាលានេះ

**ឥមំ កុដឹ** នូវកុដិតូចនេះ

**ឥមំ ទច្ចកុដឹ** នូវបង្គន់នេះ

**ឥមំ កប្បិយកុដឹ** នូវកប្បិយកុដិនេះ

**ឥមំ វិហារំ** នូវកុដិធំនេះ

**ឥមំ ឧបដ្ឋានសាលំ** នូវសាលាសម្រាប់ប្រជុំគ្នាធ្វើទាននេះ ។

| | |
|---|---|
| ចំណេះចេះពិតមិនបាត់បង់ | ទោះមានគេចង់មករំខាន |
| ចោរប្រឹងយ៉ាងណាទោះក្ស័យប្រាណ | ក៏លួចពុំបានទេលោកអ្ហើយ! |
| ដូចនេះអ្នកអ្ហើយខំសិក្សា | យើងបុត្រខេមរាកុំកន្តើយ |
| វិជ្ជាពិតនេះផ្តល់ចម្លើយ | ប្រាកដតបឆ្លើយថ្ងៃណាមួយ ។ |

នៅមានត(៥)

# បាលីវេរសង្ឃទាន

**នមោ........................៣ចប់**

**អយំ នោ ភន្តេ បិណ្ឌបាតោ ធម្មិកោ ធម្មលទ្ធោ ធម្មេនេវ ឧប្បាទិតោ មាតាបិតុអាទិកេ គុណវន្តេ ឧទ្ទិស្ស ឥមំ សង្ឃភត្តំ សបរិក្ខារំ ពុទ្ធប្បមុខស្ស សង្ឃស្ស ទេម តេ គុណវន្តានយោ ឥមំ សង្ឃភត្តំ សបរិក្ខារំ អត្តនោ សន្តកំវិយ មញ្ញមានា អនុមោទិត្វាន យថិច្ឆិត សម្បត្តីហិ សមិជ្ឈន្តុ សព្វទុក្ខា បមុញ្ចន្តុ ឥមិនា និសន្ទេនៗ**

**ទុតិយម្បិ ..................................................ៗ**

**តតិយម្បិ ..................................................ៗ**

## វេរសង្ឃទាន ( បែបទី២ )

**មយំ ភន្តេ ឥមានិ ខាទនីយ ភោជនីយា ទីនិ សជ្ជេត្វា សង្ឃស្ស ទេម សាធុ ភន្តេ សង្ឃោ ឥមានិ ខាទនីយ ភោជនីយាទីនិ បដិគ្គណ្ហតុ មាតាបិតាទីនំ គុណវន្តានញ្ច អម្ហាកញ្ច ទីឃរត្តំ អត្ថាយ ហិតាយ សុខាយៗ**

**ទុតិយម្បិ ..............................................ៗ**

**តតិយម្បិ ..............................................ៗ**

# វេរកឋិនទាននិងគ្រឿងបរិក្ខារកឋិន

**មយំ ភន្តេ ឥមំ កឋិនចីវរំ សានិសំសំ សង្ឃស្ស ទេម សាធុ ភន្តេ សង្ឃោ ឥមំ កឋិនចីវរំ សានិសំសំ បដិគ្គណ្ហតុ កឋិនំ អត្ថរិតុំ មាតាបិតាទីនំ គុណវន្តានញ្ច អម្ហាកញ្ច ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ៕**

**~ទុតិយម្បិ ...................................៕**

**~តតិយម្បិ ...................................៕**

ប្រែៈ បពិត្រព្រះសង្ឃដ៏ចម្រើន យើងខ្ញុំទាំងឡាយ សូមវេរនូវកឋិនចីវរនេះ ព្រមទាំងអានិសង្សលាភ ប្រគេនដល់ព្រះសង្ឃ។ បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃ មេត្តាទទួលយកនូវកឋិនចីវរនេះ ព្រមទាំងអានិសង្សលាភ ដើម្បីក្រាលគ្រងកឋិននេះ ដើម្បីសេចក្តីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់អ្នកដ៏មានគុណទាំងឡាយ មានមាតាបិតាជាដើមផង ដល់យើងខ្ញុំទាំងឡាយផង អស់កាលជាអង្វែងទៅហោង។

| | |
|---|---|
| ម្យ៉ាងយើងយុវជនយុវវ័យ | កុំយកច្បាប់ព្រៃពន្លកត្រួយ |
| បើអ្នកខុសពិតមិនអាចជួយ | ធ្វើខុសញយៗគង់មានទោស។ |
| កើតមកជាមនុស្សត្រូវស្គាល់ខុស | អ្នកមានកំហុសធ្វើជ្រុលជ្រួស |
| ខំប្រឹងយកឈ្នះត្រដាបដួស | គ្មានទេកិត្តិយសចំពោះខ្លួន។ |

នៅមានត(៦)

# ធម៌វេរផ្កាប្រាក់ប្រគេនព្រះសង្ឃ

**មយំ ភន្តេ សទ្ធាសម្បន្នា ឥធ អារាមេ (......)ករណត្ថាយ ឥមានិ ហិរញ្ញបុប្ផានិ ឥធានេត្វា សង្ឃស្ស បទារេមខ សាធុភន្តេ សង្ឃោ វិនយានុរូបំ កប្បិយការកស្ស ហត្ថេ ឋបិតានិ ឥមានិ ហិរញ្ញបុប្ផានិ បដិជានាតុ មាតាបិតាទីនំ គុណវន្តានញ្ច អម្ហាកញ្ច ទីឃរត្តំ អត្ថាយ ហិតាយ សុខាយខ**

**ទុតិយម្បិ ..........................................ខ**

**តតិយម្បិ ..........................................ខ**

ប្រែថា បពិត្រព្រះគម្ពែងសង្ឃដ៏ចម្រើនអើ្ហយ យើងខ្ញុំទាំងឡាយ មានសទ្ធាជ្រះថ្លាបាននាំមកនូវផ្កាហិរញ្ញវត្ថុទាំងឡាយនេះចំនួន...សូមបវារណាចំពោះព្រះសង្ឃដើម្បីកសាង(......)ក្នុងវត្តនេះ ។

អ្នកប្រាជ្ញចាំចេះប្រសើរគាប់ រស់នៅមានភ័ព្វថែមមាំមួន
គឺលោកខំរៀនពីច្បាប់ក្បួន ដូច្នេះមាសស្ងួនគួរខំថៃ ។
ភ័ព្វព្រេងវាសនាចារជូនអ្នក បានកើតចំជាក់ជាកូនខ្មែរ
រក្សាស្នាដៃដែលពូកែ តាយាយពុកម៉ែបន្សល់មក ។
នៅមានត(៧)

# វេរអង្ករចំពោះព្រះសង្ឃ

**មយំ ភន្តេ ឥមានិ តណ្ឌុលានិ សបរិក្ខារានិ ឥធានេត្វា សង្ឃស្ស ទេម សាធុ ភន្តេ សង្ឃោ ឥមានិ តណ្ឌុលានិ សបរិក្ខារានិ បដិគ្គណ្ហតុ មាតាបិតូនំ គុណវន្តានំ ច ញាតកានំ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ។**

**ទុតិយម្បិ .........................................។**

**តតិយម្បិ .........................................។**

ប្រែថា បពិត្រព្រះគម្ពែងសង្ឃដ៏ចម្រើនអើយ យើងខ្ញុំទាំងឡាយបាននាំនូវអង្ករនិងបរិក្ខារទាំងឡាយនេះមកតម្កល់ទុកក្នុងទីនេះហើយសូមវេរប្រគេនដល់ព្រះសង្ឃ។ បពិត្រព្រះគម្ពែងសង្ឃដ៏ចម្រើន សូមព្រះសង្ឃមេត្តាទទួលយកនូវអង្ករជាបរិក្ខារទាំងឡាយនេះ ដើម្បីសេចក្តីចម្រើនដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខគ្រប់ប្រការ ដល់អ្នកដ៏មានគុណទាំងឡាយមានមាតាបិតាជាដើមផង ដល់គ្រូឧបជ្ឈាយាចារ្យទាំងឡាយផង ដល់ញាតិទាំងឡាយផងដល់យើងខ្ញុំព្រះករុណាទាំងឡាយផងអស់កាលជាអង្វែងទៅហោង។អស់វារៈពីរដងផង! អស់វារៈបីដងផង។

> មានប្រយោជន៍អ្វី ចំពោះកូនដែលកើតហើយល្ងង់ផង មិនប្រកបដោយធមិផង ? ដូចភ្នែកឈើ មានប្រយោជន៍អ្វី ? បានត្រាន់តែឈើ ចាក់ដោតនាំឱ្យរំខានប៉ុណ្ណោះ។
>
> ទស្សនៈ ភិក្ខុ ប៉ាង ខាត់ វិរិយបណ្ឌិតោ

# បាលីពូតនិងបោះបាយបិណ្ឌ

បាលីពូតបាយបិណ្ឌៈពេលពូតឱ្យសូធ្យថា

**ឱកាស ឥមំ អាហារ បិណ្ឌបាតំ អហំ បូជាមិ ។**

**ទុតិយម្បិ ឥមំ អាហារ បិណ្ឌបាតំ អហំ បូជាមិ។**

**តតិយម្បិ ឥមំ អាហារ បិណ្ឌបាតំ អហំ បូជាមិ។**

បាលីបោះបាយបិណ្ឌពេលហៃបោះឱ្យសូធ្យថា

**សព្វេ សត្តា អាហារ បិណ្ឌបាតំ ផលា ផលំ តវន្តុ។**[១៦]

ព្រោះហេតុនេះហើយចូររាល់គ្នា ខំប្រឹងពុះពារមានជ័យជោគ
សែនល្បីរន្ទឺពេញលើលោក ខ្ពស់ដូចពពកលើវេហាស៍ ។
កម្ពុជាប្រទេសអស្ចារ្យណាស់ ភ្ញៀវជាតិក្មេងចាស់មកទស្សនា
កម្សាន្តរីករាយក្នុងកាយា មានទាំងអប្សរារាំស្វាគមន៍ ។

ពេជ្រ សំណាង

**ចប់**

---

១៦-គហិប្បតិបត្តិ ឃរាវាសធម៌ ផ្សាយចេញពីអាស្រមឧត្តម ព.ស. ២៥៤៧។

# ពាក្យសម្រាប់គ្រើនកឋិនទី១

**ភន្តេ** បពិត្រព្រះគម្ពែងសង្ឃដ៏ចម្រើនរីឯអង្គកឋិនទាននេះជារបស់អស់លោកអ្នកពុទ្ធបរិស័ទទាំងឡាយ ............ ជាប្រធានសុទ្ធសឹងតែពុទ្ធមាមិកជន ប្រកបដោយបសាទសទ្ធានិងកុសលចេតនាជាអសង្ខារិកជ្រះថ្លាចំពោះគុណព្រះរតនត្រ័យទាំងបីបានបំពេញនូវបុញ្ញកិរិយាវត្ថុចេះលៃលកយកធនធាន ដែលគ្មានខ្លឹមសារ ធ្វើឱ្យជារបស់មានខ្លឹមសារ កប់ទុកក្នុងព្រះពុទ្ធ-សាសនា ដើម្បីជាទ្រព្យមតិក សម្រាប់ប្រើប្រាស់ទៅក្នុងភពខាងមុខទៀត បានស្រុះស្រួលបបួលគ្នាផ្តួចផ្តើមបង្កើតកឋិនទាននេះឡើង ព្រមទាំងហែហមដ៏ឧឡារិកគគ្រឹកគគ្រេងតាមមាគ៌ា ដើម្បីនឹងយកមកវេរ ថ្វាយព្រះភិក្ខុសង្ឃ ដែលគង់ចាំវស្សាអស់ត្រីមាសក្នុងវត្ត.........នេះហាក់ដូចជាសំពត់កោសេយ្យពស្ត្រអណ្តែតត្រសែតឰដ៏អាកាសវេហានភាល័យ ហើយធ្លាក់ចុះមកក្នុងកណ្តាលជំនុំសង្ឃជាសង្ឃទានស្មោះ ឥតមានចំពោះអង្គណាមួយឡើយ ។ បើអង្គណាមួយ មានត្រៃចីវរទុព្វលភាព ដាច់ដាច មិនអាចប្រើ-ប្រាស់បានហើយចេះនូវ **អានិសង្ស៥ ចាំនូវមាតិកា៨ បលិពោធ២ អនន្តរាភារៈ២៤ អន្តរាភារៈ១៧** អាចញុំាងសង្ឃឱ្យត្រេកអរដោយកឋិនត្ថារកិច្ចបាន ក៏សូមមានព្រះពុទ្ធដីកា ឆ្លើយមកចុះ នោះព្រះសង្ឃនឹងអបលោកសំពត់កឋិននេះ ដល់ព្រះករុណាអង្គនោះ ដោយញត្តិទុតិយកម្មវាចា ក្រាលគ្រងដូច តទៅៈ

(ភិក្ខុទី១) ប្រកាសសង្ឃចប់ហើយត្រូវឈប់បង្អង់ ២-៣នាទីសិន សឹមភិក្ខុទី២ប្រកាសសង្ឃតទៅទៀត។

## ពាក្យសម្រាប់គ្រើនកឋិនទី២

**ភន្តេ** បពិត្រព្រះគម្ដែងសង្ឃដ៏ចម្រើន ខ្ញុំព្រះករុណាជាអ្នកតំណាងសង្ឃគ្រប់ព្រះអង្គក្នុងឱកាសនេះ សូមពិតព្រះថេរដីកាចំពោះព្រះសង្ឃគ្រប់ព្រះអង្គសូមទានជ្រាប។

យើងខ្ញុំទាំងអស់សុទ្ធសឹងតែមានត្រៃចីវរល្មមគ្រប់គ្រាន់នឹងប្រើប្រាស់ហើយប៉ុន្តែតាមយោបល់របស់ខ្ញុំព្រះករុណាយល់ឃើញតែព្រះ...........ទើបសមគួរនឹងក្រាលគ្រងនូវសំពត់កឋិននេះ ដោយហេតុថាលោកអ្នកចេះនូវអានិសង្ស៥ ចាំនូវមាតិកា៨ បលិពោធ២ អនត្ថតាការៈ២៤អត្ថតាការៈ១៧ហើយឆ្លៀវឆ្លាតក្នុងកឋិនត្ថារកិច្ចអាចញ៉ាំងសង្ឃឱ្យត្រេកអរបាន។ហេតុនេះហើយបើព្រះសង្ឃគ្រប់ព្រះអង្គយល់ឃើញថាសមគួរដូចជា បកាសនវាចាដែល ខ្ញុំព្រះករុណាបានថ្លែងមកនេះ ក៏សូមបញ្ចេញនូវសញ្ញាថា សាធុឱ្យព្រម១ គ្រប់អង្គទៅហោង។

ត្រូវស្រឡាញ់វិជ្ជាឱ្យដូចស្រឡាញ់កែវភ្នែកអ្នក!
មានពុទ្ធិ ជីវិតស្រស់ថ្លាបវររុងរឿង!
រៀនច្រើនកើនវិជ្ជា!
ទស្សនៈ សាស្ត្រាចារ្យ វ៉ារ វុទ្ធី

# បាលីសម្រាប់សូត្រកឋិន

**សុណាតុ មេ ភន្តេ សង្ឃោ ឥទំ សង្ឃស្ស កឋិនចីវរំ ឧប្បន្នំ។ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឥមំ កឋិនចីវរំ ឥត្ថន្នាមស្ស ភិក្ខុនោ ទទេយ្យ កឋិនំ អត្ថរិតុំ។ ឯសា ញត្តិ។**

**សុណាតុ មេ ភន្តេ សង្ឃោ ឥទំ សង្ឃស្ស កឋិនចីវរំ ឧប្បន្នំ។ សង្ឃោ ឥមំ កឋិនចីវរំ ឥត្ថន្នាមស្ស ភិក្ខុនោ ទេតិ កឋិនំ អត្ថរិតុំ។ យស្សាយស្មតោ ខមតិ ឥមស្ស កឋិនចីវរស្ស ភិក្ខុនោ ទានំ កឋិនំ អត្ថរិតុំ សោ តុណ្ហស្ស យស្ស-នក្ខមតិ សោ ភាសេយ្យ។ ទិន្នំ ឥទំ សង្ឃេន កឋិនចីវរស្ស ឥត្ថន្នាមស្ស ភិក្ខុនោ កឋិនំ អត្ថរិតុំ ។ ខមតិ សង្ឃស្ស តស្មា តុណ្ហី ឯវមេ តំ ធារយាមិ។**

បពិត្រព្រះគម្តែងសង្ឃដ៏ចម្រើន!សូមព្រះសង្ឃស្តាប់នូវពាក្យខ្ញុំសំពត់កឋិននេះកើតឡើងដល់សង្ឃហើយ។ បើការនេះមានកាលគួរដល់សង្ឃហើយ សង្ឃគួរឱ្យសំពត់កឋិននេះទៅភិក្ខុនេះចុះ (ឈ្មោះនេះ) ដើម្បីក្រាលកឋិន។

បពិត្រព្រះសង្ឃដ៏ចម្រើនសូមព្រះសង្ឃស្តាប់ខ្ញុំសំពត់កឋិននេះ កើតឡើងដល់ព្រះសង្ឃហើយ។

(ឥឡូវ)សង្ឃឱ្យសំពត់នេះទៅភិក្ខុឈ្មោះនេះដើម្បីក្រាលគ្រងកឋិនគួរឱ្យដល់លោកដ៏មានអាយុអង្គណាលោកដ៏មានអាយុអង្គនោះត្រូវស្ងៀមមិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ ត្រូវនិយាយឡើង។ សំពត់កឋិននេះសង្ឃឱ្យទៅភិក្ខុ (ឈ្មោះនេះ) ហើយដើម្បីក្រាលកឋិន។ ការនេះគួរដល់សង្ឃព្រោះហេតុនោះបានជាសង្ឃស្ងៀម ខ្ញុំចាំទុកនូវការនេះដោយភាពដែលសង្ឃស្ងៀមយ៉ាងនេះ។

ការដែលសង្ឃសូធ្យប្រគល់សំពត់កឋិនដោយញត្តិទុតិយកម្មវាចាដូច្នេះហើយ បើសំពត់កឋិននោះទាយក ធ្វើបរិកម្មសម្រេចមកជា ស្បង់ចីពរសង្ឃាដីរួចមកហើយ ភិក្ខុត្រូវក្រាលដោយស្បង់ ឬចីពរ ឬក៏សង្ឃាដី គប្បីបច្ចុទ្ធរា ដកស្បង់ចីពរ សង្ឃាដីចាស់ចេញ ហើយធ្វើកប្បពិន្ទុ អធិដ្ឋាន ស្បង់ចីពរសង្ឃាដីថ្មីឡើង)

## ឯពិធីដកដូច្នេះ

-ពិធីដកសង្ឃាដីថា **ឥមំ សង្ឃាដឹ បច្ចុទ្ធរាមិ** អាត្មាអញដកនូវសង្ឃាដីនេះ។

-ដកឧត្តរាសង្គៈ(ចីពរ)ថា **ឥមំ ឧត្តរាសង្គំ បច្ចុទ្ធរាមិ** អាត្មាអញដកនូវឧត្តរាសង្គៈ(ចីពរ)នេះ។

-ដកអន្តរវាសកៈ(ស្បង់)ថា**ឥមំ អន្តរវាសកំ បច្ចុទ្ធរាមិ** អាត្មាអញដកនូវស្បង់នេះ។

ដកចីពរស្បង់សង្ឃាដីរួចហើយត្រូវធ្វើកប្បពិន្ទុចីពរថ្មីដែលបម្រុងក្រាលកឋិននោះត្រង់ជ្រុង ឬមុំចីពរ ដោយពណ៌ពាយ៉ាង ពណ៌ណាមួយដែលមានសម្ដែងក្នុងសិក្ខាបទស្រាប់។

## ឯពិធីពិន្ទុកប្បដូច្នេះ

**ឥមំ ពិន្ទុកប្បំ ករោមិ** អាត្មាអញធ្វើនូវពិន្ទុកប្បនេះ។

( តពីនេះត្រូវអធិដ្ឋានចីវរថ្មីឡើង) ពិធីអធិដ្ឋាននោះដូច្នេះ

-អធិដ្ឋានសង្ឃាដីថា **ឥមំ សង្ឃាដឹ អធិដ្ឋាមិ**

**ទុតិយម្បិ** .....................

**តតិយម្បិ** .....................

អាត្មាអញអធិដ្ឋាននូវសង្ឃាដីនេះ ជាគម្រប់ពីរដងផង!ជាគម្រប់បីដងផង។

-អធិដ្ឋាន ឧត្តរាសង្គៈថា **ឥមំ ឧត្តរាសង្គំ អធិដ្ឋាមិ**

**ទុតិយម្បិ** .......................

**តតិយម្បិ** .......................

អាត្មាអញ អធិដ្ឋាន នូវឧត្តរាសង្គៈនេះ។

អធិដ្ឋាន អន្តរាវាសកៈ ថា **ឥមំ អន្តរវាសកំ អធិដ្ឋាមិ**

**ទុតិយម្បិ** .........................

**តតិយម្បិ** .........................

អាត្មាអញអធិដ្ឋាននូវអន្តរវាសកៈនេះ កាលធ្វើអធិដ្ឋានរួចហើយត្រូវក្រាលគ្រងកឋិនដោយចីវរណាមួយតាមត្រូវការ ហើយគប្បីបញ្ចេញវាចាឱ្យជំនុំសង្ឃបានឮច្បាស់។

បើចង់ក្រាលដោយសង្ឃដីថា **ឥមាយ សង្ឃាដិយា កឋិនំ អត្ថរាមិ** ប្រែថា ខ្ញុំក្រាលកឋិនដោយសង្ឃាដីនេះ។

បើចង់ក្រាលដោយចីវរនេះថា **ឥមានិ ឧត្តរា សង្គេន កឋិនំ អត្ថរាមិ** ខ្ញុំក្រាលកឋិនដោយឧត្តរាសង្គៈ(ចីពរ)នេះ។

បើចង់ក្រាលដោយអន្តរវាសកៈថា **ឥមិនា អន្តរវាសកេន កឋិនំ អត្ថរាមិ** ខ្ញុំក្រាលកឋិនដោយអន្តរាសកៈ(ស្បង់)។

កាលភិក្ខុ បានក្រាលកឋិនតាមបែបនេះរួចហើយ ត្រូវចូលទៅជិតសង្ឃឬគណៈឬបុគ្គលគ្រងចីពរអង្គុយច្រហោងប្រណម្យអញ្ជលីឡើងពោលប្រាប់លោកទាំងនោះអនុមោទនាថា

**អត្ថតំ អាវុសោ សង្ឃស្ស កឋិនំ ធម្មិកោ កឋិនត្ថារោ អនុមោទថ**

ម្នាលលោកដ៏មានអាយុ កឋិនរបស់សង្ឃ ខ្ញុំក្រាលរួចហើយការក្រាលកឋិននុ៎ះ ប្រកបដោយធមិសូមលោកទាំងឡាយអនុមោទនាចុះ។

ចំណែកភិក្ខុ អ្នកអនុមោទនាវិញ ត្រូវគ្រងចីពរស្នាម្ខាង អង្គុយច្រហោងប្រណម្យអញ្ជលីឡើងពោលអនុមោទនាថា

**អត្ថតំ ភន្តេ សង្ឃស្ស កឋិនំ ធម្មិកោ កឋិនត្ថារោ អនុមោទាម**

បពិត្រលោកម្ចាស់ដ៏ចម្រើន កឋិនរបស់សង្ឃលោកក្រាលរួចហើយ ការក្រាលកឋិន(នុ៎ះ) ប្រកបដោយធម៌យើងសូមអនុមោទនា។ អនុមោទនាមួយបែបទៀតថា **អត្ថតំ ភន្តេ សង្ឃស្ស កឋិនំ ធម្មិកោ កឋិនត្ថារោ អនុមោទាមិ** បពិត្រព្រះករុណាដ៏ចម្រើនកឋិនរបស់សង្ឃដែលសង្ឃបានឱ្យហើយដល់លោក ៗបានក្រាលហើយ កឋិនដែលលោកបានក្រាលហើយ នេះជាធម៌ដ៏សមគួរតាមពុទ្ធានុញ្ញាត ខ្ញុំសូមអនុមោទនាត្រេកអរតាមការគួររបស់កឋិន។ ចុងក្រោយផ្សាយមេត្តាសព្វសត្វ បន្ទាប់មកសូធ្យធម៌ **យំកិញ្ចិ** ចប់ប៉ុណ្ណេះ។[១៧]

មានតែវិជ្ជាទេទើបអាចរំដោះភាពក្រីក្រ
វិជ្ជាជាទ្រព្យសម្បត្តិដែលមិនចេះអស់!
វិជ្ជាជារ៉ែមាសមិនចេះរីងស្ងួត!
រៀនច្រើនកើនទ្រព្យសម្បត្តិ!
សាស្ត្រាចារ្យ វ៉ីរ វុទ្ធី

១៧-សែម-សូរ ប្រជុំភាណវារៈបាលី-ប្រែពិសេស ទំព័រ ២៩៤-២៩៩ ផ្សាយចេញពីបណ្ណាគារត្រៃរតន៍ ព.ស. ២៥៤៣ គ.ស. ១៩៩៩។

# ពិធីក្រុងពលីឬពាលី

ពិធីនេះជាទម្លាប់មកមានពីរបែបគឺ

ក-តាមពិធីព្រហ្មញ្ញសាសនា គឺបូជាចំពោះស្តេចក្រុងពាលី

ខ-តាមរបៀបព្រះពុទ្ធសាសនាពលីនេះមាន៥គឺ

១-**បុព្វបេតពលី** រៀបរណ្តាប់ មានបាយស្លក បង្អែមចម្អាប ទៀន ធូប ឧទ្ទិសជូនបុព្វការីជនដែលបានស្លាប់ ។

២-**អតិថិពលី**បដិសណ្ឋារៈភ្ញៀវដែលបានអញ្ជើញចូលរួមក្នុងកម្មវិធីដើម្បីជាសក្ខីភាព ។

៣-**ញាតិពលី** បដិសណ្ឋារៈញាតិសាច់សាលោហិត ដែលបានជួបជុំទទួលស្គាល់ដឹងឮ ។

៤-**រាជពលី** ធ្វើពិធីគោរពតាមច្បាប់ទម្លាប់របស់ប្រទេសជាតិគឺស្មើសុំដល់រដ្ឋអំណាចគ្រប់លំដាប់ថ្នាក់ដឹងឮនិងអនុញ្ញាត ដែលហៅថាក្រុងពលីនោះឯង ។

៥-**ទេវតាពលី** បូជាដល់ទេព្តាមានពិធីបួងសួង ទេព្តាជាដើម ។[១៨]

(ពិធីនេះឃើញភាគច្រើនក្នុងពិធីមង្គលការ)

---

១៨-ព្រះពោធិវង្ស ហួត-តាត ធម្មសង្គហៈ ទំព័រ៦០ ផ្សាយដោយរោងពុម្ពខេមររដ្ឋ ព.ស. ២៥០១ គ.ស. ១៩៥៨។

## ផ្ដើមសូធ្យថា

**ឱកាស** ខ្ញុំព្រះករុណាសូមគោរពអារាធនាព្រះរតនត្រៃត្រិង្សនិរន្ទទេវាទេព្ដាទាំងឆកាមាទាំងអ្នកតាចាស់ស្រុក ទាំងម្រេញគង្វាល នាងគង្ហីងព្រះធរណីនិងទេពធីតាក្នុងភូមិភពផែនដែននភាល័យត្រៃនេត្រ វេទមុ្កដបរិសុទ្ធមុនីអង្គអសុរិន្ទឥន្ទកោសិយទើបយាងសម្ដេចព្រះស្រីទិព្វា ព្រហ្មលោកមហាសុរង្គឥសីសុទ្ធ ព្រះចិត្តកូដ ព្រះចន្ទកុមារ ព្រះយក្សកុមារ ព្រះវិរុឡ្ហកៈសេនាព្រះរាម ទើបព្រះអង្គបញ្ជាព្រះបារមីសួរ ព្រះចតុលោកបាលព្រះបាទភុជង្គនាគព្រះពិស្ណុការ ព្រះបាទក្រុងពាលី ព្រះវេស្សវណ ព្រះបាទឆត្រពាន់ព្រះបាទកងជុំ ព្រះព្រហ្មមុខបួនព្រះរាមមុខដប់ មូលមកសព្វគ្រប់ទាំងព្រះធមិ៨៤000ធម្មក្ខន្ធទើបលោកហោះឈានចាកឋានវិមានមកគង់ក្នុងទីនេះព្រោះ(យើងខ្ញុំជាអ្នកដើមការទាំង៤សាមីខ្លួនទាំងពីរ) មាននាម......បានរៀបចំប្រដាប់ប្រដាសំពត់ផ្ទត់ប្រេងម្សៅក្រាសកញ្ចក់ ពោត សណ្ដែកល្ងព្រមទាំង ភស្ដុភារ បណ្ណាការ ក្រយាបូជា សូមគោរពអញ្ជើញស្ដេចក្រុងពាលីយាងមកទទួលយកនូវក្រយាបូជានេះហោង។

| |
|---|
| រៀនច្រើនកើនវិជ្ជា វិជ្ជាជាមិត្តដ៏ប្រពៃ!<br>មានពុទ្ធិទើបថ្លៃថ្នូរគាប់ប្រសើរ!<br>សាស្ត្រាចារ្យ វីរ វុទ្ធី |

# វិធីក្រុងពាលីតាមបែបពុទ្ធសាសនា

ឃើញច្រើននៅក្នុងពិធីបញ្ចុះសីមាលើកផ្ទះឡើងផ្ទះ ឆ្លងអណ្តូងឆ្លងរោងរាន ឆ្លងថ្នល់ ឆ្លងស្ពានឆ្លងសាលាឆទាន ឆ្លងស្រះ ឆ្លងដើមពោធិ៍ឆ្លងព្រះត្រៃបិដក និងសមិទ្ធផលផ្សេងៗទៀត ឬពិធីបញ្ចុះ បឋមសិលាជាដើម ។ល។ ដំបូងឃើញគេរៀបចំតុមួយមានកម្រាលមានបង្គោលចងឆត្រ ឬក្លស់បាំងពីលើ និងចងអំពៅខ្មៅមួយដើមលើតុ មានម្ហូបមួយថាស បង្អែមមួយថាស បាយ ទឹកផ្តិល ផ្កា១ថូ សំពត់ស១គូ សំពត់ពណ៌១គូ ទៀនធូបសម្រាប់អុជ និងទៀន៥ធូប៥ ។តែដោយស្ថានភាពគ្រួសារខ្លះក្រីក្រម្ល៉ោះហើយគេដាក់តែក្រមា១ចំនួនប៉ុណ្ណោះ វត្ថុទាំងនេះគេជូនអាចារ្យ ។

# សេចក្តីប្រកាសបួងសួង

អាចារ្យប្រកាសថាវីទេវតាទាំងពួងទាំងឡាយ **តិដ្ឋន្តា** ស្ថិតនៅ **សគ្គេ ការមេច** ពួដ៏ស្ថានសួគ៌ជាកាមភពក្តី **ភុម្មា ច** ពួដ៏ភូមិភពគ្រប់សកលមណ្ឌលដែនផែនដីចន្លោះទួលខ្ពស់ព្រះធរណីគីរីជលសាពួដ៏លើភ្នំក្រំថ្មតូចធំ ប្រជុំអមជ្រោះជ្រង ឈូងឆកក្បាលហ្លួងជង្គង់មូលមកយើងបួងសួងអ្នកទេព្តា **អន្តលិក្ខេ ច** តាំងពីផែនដីផ្ទៃភូមិប្រឹថពីក្រឡារហូតទេព្តានៅអាកាស ពាសពេញមេឃាទេព្តាទិសប្រាំបី អាស្រ័យនៅក្នុងគុហាចូឡាមកជួយជាកសិណសាក្សី **វិមានេ ច** នៅក្នុងវិមានស្ថានតូចធំប្រមូលមកប្រជុំដោយទិសទីក្នុងវិមានស្ថានប៉ុន្មានក្តីអស់ទេពធីតា **នីបេរន្តេ ច** ទេព្តា

នៅព្វដ៏គោកកោះចន្លោះទឹកបឹងស្ទឹងទន្លេក្បែរអូរជង្ហុកថ្លុកត្រពាំងមានទាំងគ្រប់ស្ថាននានាមូលមកប្រជុំព្រមគ្នា **កាមេ ច** ទេព្តារក្សាស្រុកស្រះស្រង់របស់របងក្នុងបន្ទាយទេពធីតាទាំងឡាយមូលមកប្រជុំការ**តរុវនគហនេ គេហវត្ថុម្ហិខេត្តេ ច** ទេព្តានៅព្រៃព្វដ៏ដើមឈើតូចឈើធំពាសពេញក្រមុំលំពស់លំពង់កំលោះស្រោងស្រាវក្នុងរបស់របងដងព្រៃព្រឹក្សានៅក្នុងស្រែចម្ការ ច្បារដំណាំ ទេព្តាប្រចាំភូមិភព គ្រប់សកលជុំចក្រវាល **ជលថលវិសមេ ច** ទេព្តានៅព្វដ៏គោកកោះចន្លោះទឹកបឹងស្ទឹងគង្គាអញ្ជើញមកជាអធិបតីនៃយើង **យក្ខគន្ធព្វនាគា ច** យក្សគន្ធព្វមហារង្គភុជង្គនាគាអញ្ជើញទេវតា **តិដ្ឋន្តា** ស្ថិតសព្វស្ថាន **សន្តិកេ** កាន់សំណាក់ស្នាក់ អាស្រ័យនៃយើងបាន **សុណន្តុ ធម្មំ** តាំងចូលមកស្តាប់ធម៌ **មុនិវរវចនំ** នូវព្រះបន្ទូលព្រះមានបុណ្យដ៏ប្រសើរ **ភោន្តោទេវសង្ឃា យោ** ហៃទេព្តាដ៏មានរិទ្ធានុភាពផងទាំងឡាយអើយ **អយំកាលោ** វិកាលនេះ **ធម្មស្សវនកាលោ** ជាកាលគួរ នឹងស្តាប់នូវព្រះធម៌ ។

បន្ទាប់មកអាចារ្យ នមស្ការជាមួយនឹងពុទ្ធបរិស័ទហើយចុងក្រោយសូធ្យធម៌យោកប្បកោដិបន្ទាប់មកអាចារ្យចាប់ប្រកាសបន្តទៀតថា បពិត្រទេវតាគ្រប់ទាំងគន្ធព្វគ្រុឌនាគាព្រះឥន្ទព្រះព្រហ្មព្រះចតុលោកបាលនៃទោះទាំងទេពធរណីទាំងគិរីទីព្រឹក្សព្រៃទ្វីបកោះជ្រោះជ្រងជ្រលងជល-ស័យសមុទ្រនៃស្ទឹងទីទេព្តាស្ថិតសព្វស្ថានសួគ៌វិមានអាកាសឫទ្ធិបុណ្យបារមីបុព្វេពិតព្យាបាលតេជះ យើងនឹងរលឹកយើងនឹកគិតប្រកាសថា សូមជួយ

ជោគជយោតេជះសីលទានផង ចម្រើនវង្វង់កុសលដ្បិតយើងខ្ញុំមានមេត្រីចិត្តបេតីប្រតិពលឃើញអានិសង្សផលបរិយត្តិធមិដល់បុណ្យទានសូមជួយឱ្យសុខសួស្តី ជយវុឌ្ឍី ក្សេមក្សាន្ត សូមលោកអ្នកម្ចាស់ទានបាននូវបុញ្ញ-សម្បទា មានសម្បត្តិជាបុណ្យសូមស្តេចចតុលោកបាលមានព្រះបាទធតរដ្ឋះកាន់ទិសបូពិ ព្រះបាទវិរូបក្ខះកាន់ទិសបស្ចិម ព្រះបាទវិរុឡ្ហកៈ កាន់ទិសទក្សិណព្រះបាទកុវេរៈកាន់ទិសឧត្តរ។ មហារាជទាំងបួនស្ថិតក្រោមអំណាចព្រះឥន្ទអញ្ជើញមកជាអធិបតីនៃយើងនិងជូនពរជ័យ សិរីមហាប្រសើរចូរមករក្សាពួកយើងថ្កើងសាធុការទៅហោង ។បន្ទាប់មកទៀតក៏ផ្តើមកម្មវិធីតាមសំណូមពរម្ចាស់ទានប្រធានដើមបុណ្យឬតាមកម្មវិធីដែលមានគ្រោងទុក។ ពិធីនេះអាចារ្យរៀបទៀនប្រាំធូបប្រាំស្លាធមិដៃមួយគូ បង្អែមចម្អាបមួយថាសទឹកមួយពែងសុំទឹកដីធ្វើរោងផ្កាស្លាធ្វើចង្ក្រានបាយ ។

**វន្ទាមិ សព្វទេវា គន្ធាយ ទេវិន្ទនំ សារពើទុក្ខ សារពើសោក សារពើរោគ សារពើភ័យ សារពើចង្រៃ សារពើបាបគ្រោះ វិនាសសន្តិ អសេសតោ។ សូមព្រះភូមិឯបូរ៉ា ព្រះចន្ទតារា ព្រះភូមិមានលក្ខិណា ឯហិ ឯហិ គច្ឆន្តុ ស្វាហាយះ។**

យើងខ្ញុំឱនអង្គអភិវាទវរវន្ទា ប្រណម្យវន្ទាសូមព្រះរាជាអ្នកតែងធានា នូវព្រះធរណីផងដ្បិតអ្នកអើយសូមអញ្ជើញមកផ្ទានដល់ស្ថានយើងឆាប់យើងខ្ញុំប្រុងប្រៀបរៀបប្រដាប់រុងរឿងស្រេចស្រាប់អាហារត្រកាលពិសីសូមភូមិ

សូមដីនេះនៃសង់រោងផ្កាស្លាជាថ្មី កុំបីអ្នកមានការឆ្ងល់ បពិត្រសូមអញ្ជើញមកឆាប់ៗ៉ា យើងសូមរៀបក្រយាបូជាអ្នកហោង។

**ឱកាស តោន្តោ ទេវសង្ឃាយោ** បពិត្រអស់ទេវបុត្រទេវតាដែលស្ថិតរក្សាតាំងតែអំពីភពផែនដែនប្រឹថពីគិរី បពិតសមុទ្រខណ្ឌ ព្ធដ៏ហេមវន្តជាន់ព្រះហិមពាន្តជាស្ថានព្រះឥសីតាបស ដោយជ្រោះគុកគុហាមណ្ឌលព្រះប្រាសាទឋានវិមានទោះទិសឆ្ងាយជិត បពិត្រអស់ទេវតា ដែលរក្សាស្វេតច្ឆត្រសម្បត្តិរដ្ឋរាជធានីជាទីសោភិរម្យ ប្រជុំនៅកណ្តាប់ចក្រវាល នូវអស់ទេវតា ដែលស្ថិតរក្សាស្ទឹងបឹងគង្គាខ្ពង់ខ្ពស់ បព្វតាសិលាគិរីជ្រោះជ្រងជ្រលងទូរគមន៏សាខា ល្អាងសិលាទឹកថ្លាយង់ព្រៃត្រង់ទ្រគុំភ្នំស្លោមស្ទឹងបឹងត្រពាំង ស្រះស្រង់នូវអស់ទេវតាដែលរក្សានាងគង្ហីងព្រះធរណីជាទីគោរពប្រសព្វទៅដល់ឆកាមាសួគ៌ទាំង៦ជាន់ព្រហ្មលោកទាំង១៦ជាន់យើងខ្ញុំសូមអញ្ជើញលោកយាងចុះមកជួយថែរក្សាប្រចាំការមានព្រះអាទិត្យមានព្រះចន្ទ មានព្រះអង្គារ មានព្រះសុក្រ មានព្រះសៅរ៍ មានព្រះកាល មានព្រះចតុលោកបាលទាំង៤គឺព្រះបាទធតរដ្ឋព្រះបាទវិរុឡ្ហកៈ ព្រះបាទវិរូបក្ខៈព្រះបាទកុវេរៈ ស្តេចនៅជាន់ចាតុម្មហារាជិកា ព្រះតាបសឥសីសិលាព្រះមហាឥសី ព្រះមាតុលី ព្រះស្រីភូមិរដ្ឋ ព្រះយន្តកុមារ ព្រះកឹករណ៍ទាំងព្រះយមរាជា ព្រះពិស្ណុការព្រះប៉មសូរ ព្រះឥសូរ ព្រះនារាយណ៍ព្រះពាយព្រះអគ្គី ព្រះភិរុណ សម្តេចអម្រិន្ទឥន្ទ្រាធិរាជ ជាធំប្រជុំនៅតាវត្តិង្សានូវអស់ទេវតា ដែលរក្សាភ្នំសត្តបរិភណ្ឌទាំង៧ជាន់ តាំងតែអំពីភ្នំ

យុគន្ធរឥសីសន្ធរករវិសុទស្សនៈនេមិន្ធរវិន្តកៈអស្សកណ្ណនូវអស់ទេវតាដែល
រក្សាព្រះពុទ្ធសាសនាទាំងប្រាំពាន់ព្រះវស្សា នូវអស់ទេវតា ដែលរក្សាព្រះ
នគរវង្សភក្រ្តបុរីស្រីក្រុងកម្ពុជា ទាំងគ្រប់ភ្នំប្រជុំនូវស្តេចចម្បាំង ទាំងអង្គ
ព្រះសុមេរុរាជា ទន់ស្ងួនគ្រងសម្តេចព្រះអសង្ខេយ្យសម្តេចកងចក្រលាយ
លក្ខណ៍កងជុំបទុមកុមារដែលស្ថិតរក្សាគ្រប់ភ្នំគ្រប់ភូមិគ្រប់ស្រុក យើងខ្ញុំ
សូមអញ្ជើញលោកចុះមកជួយដោះទុក្ខភ័យឱ្យស្អាតកុំឱ្យមានឧត្បាតនឹងធ្វើ
មង្គលការ គឺលោកធ្វើបុណ្យថ្វាយគ្រឿងសក្ការៈ និងតង្វាយដល់ទេវតា
បពិត្រទេវតាសព្វឋាន យើងខ្ញុំសូមទានបង្គំវន្ទា និមន្តសម្តេចព្រះឥន្ទ្រានិមន្ត
ព្រះយមរាជា សូមស្តេចមកគង់រាន ថ្មី ខ្ញុំថ្វាយស្លាធមិ បាយសី ថ្វាយស្លាបារី
ទៀនធូប ប្រទីបជ្វាលា ខ្ញុំថ្វាយទឹកអប់ ភ្ញីផ្កា ថ្វាយគ្រឿងបូជា
សម្រាប់ម្ចាស់ថ្លៃថ្វាយរានទិសទាំង៨ ទាំងរានម្ចាស់ថ្លៃរៀបចំជាថ្មីប្រសើរ
ស្អាងស្អាត ខ្ញុំថ្វាយខ្នល់ខ្នើយកម្រាលជាខ្នាតសឹងថ្មីពិចិត្របរិសុទ្ធ ទើប
អញ្ជើញព្រះមាតុលី មកគង់រានថ្មីយើងខ្ញុំបម្រុងស្រេចស្រាប់ ទើបអញ្ជើញ
ព្រះយាងមកឆាប់ៗខ្ញុំថ្វាយរណ្តាប់សូមពរជ័យអំពីអ្នកហោងបានថ្វាយភ្លេង
តូរ្យតន្ត្រីផងថ្វាយគ្រប់ប្រការផងទាំងអស់ឥតឱ្យមានសល់ខ្ញុំថ្វាយសូមបាន
មគ្គនិងផលសូមឱ្យបានដល់ព្រះសាសនាជាថ្មី បពិត្រទេវតាទិសទាំង៨ជួយ
ជាសាក្សីនៃលោក....បាននិមន្តព្រះសង្ឃ ដារស្មូធ្យមន្ត ទេសនា ចម្រើនឱ្យ
បានមគ្គផល សូមលាអស់ទាំងទោសទុក្ខលាបាប នរក កម្មពៀរវេរាគ្រប់គ្នា
សូមឆុតដូចពាក្យប្រាថ្នាកើតជាតិកាលឯណាកុំឱ្យវង្វេងវិលវល់យើងខ្ញុំសូម

លាគ្រប់គ្នាទោះយើងខ្ញុំសង់កុដិសាលា សាងព្រះវិហារតម្កល់តម្កើងសាសនា ធ្វើផ្លូវសង់ស្ពានបង្គន់ក្តីណា ជីកដីដាំផ្កា បម្រុងធ្វើទានសព្វគ្រប់ទោះយើងខ្ញុំដាំព្រះពោធិ៍លើព្រះធរណីស្អាងពូនជាព្រះចេតិយ បពិត្រអ្នកអើយយើងខ្ញុំនេះនៃពំនាក់អាស្រ័យជីវិតលើព្រះគុណធ្ងន់ខ្ញុំសូមជីវិតជីពជន្មវែងយឺនយូរណាបានទាន់ឃើញព្រះមហាបពិត្រជាថ្មី វន្ទាមិ ពុទ្ធំ បត្តា ណន្តំ បុញ្ញំ មយ្ហំ ទាតព្វំ សាធុ សាធុ អនុមោទាមិ ។

បពិត្រអស់ទេវតា សូមអ្នកហោះមកជួយជាសាក្សី ជ្រោមជ្រែងក្រវើនចម្រើនពរសុខសួស្តីបំពេញបារមីបុណ្យយើងសព្វថ្ងៃ យើងខ្ញុំនេះណាសង្វាតឧស្សាហ៍ ព្យាយាមបំពេញសីលទាន ភាវនាសព្វថ្ងៃ សូមគុណព្រះរតនត្រៃទាំងបីឱ្យពរ ព្រះពុទ្ធរក្សា ព្រះធម៌ ធានា ព្រះសង្ឃសាទរព្រះឥន្ទលោកជួយជ័យ ព្រហ្មថ្លៃឱ្យពរអស់ទេពនិករអរឱ្យសុខា ទោះទាំងទេពព្រក្ស ស្ថិតស្ថានសំណាក់ក្នុងព្រៃព្រឹក្សាស្ថិតលើគិរីក្នុងទីគ្រីហាក្នុងថ្នាក់ជ្រោះថ្លា ស្ថានសន្ទប់ព្រះចេតិយ សូមអ្នកឈានមកអំពីឈូងឆកជ្រុងជ្រោយគិរីស្ថិតលើភពផែនព្រះធរណីបំពេញបារមីបុណ្យយើងនៃឱ្យបានសម្រេចដរាបទៅហោង ។

**តើសព្វាបត្រគឺជាអ្វី?**

ហេតុអ្វីមនុស្សយើងខំសិក្សា ចង់បានបរិញ្ញាគ្រប់ៗគ្នា
លំបាកយ៉ាងណាខំម្ចីម្នា ខំប្រឹងពុះពាររាល់យប់ថ្ងៃ ។
ទោះធ្វើដំណើរទៅសែនឆ្ងាយ ឃ្លាតណាស់ឪពុកម្តាយទាំងអាល័យ
មិនថាទៅនោះវាអស់ថ្លៃ ក៏មិនអាល័យទេលុយហ្នឹង ។ ត(១)

# ពិធីសែនព្រេន

សែនបង់បាយព្រះពិស្ណុការបពិត្រយើងខ្ញុំលើកដៃប្រណម្យបង្គំអញ្ជើញព្រះពិស្ណុការព្រះបារមីសួរ្យអ្នកចុះមកអំពីត្រៃត្រិង្សវិមានស្ថានគីរី ព្រះជនកព្រះជននី អ្នកមកជួយបង្វែរការឱ្យដល់យើងខ្ញុំផង អស់ទាំងប្រដាប់ស្រេចស្រាប់បរិបូណ៌ហើយហោងមិនឱ្យមានឆ្គងបណ្តាំ ។( ធ្វើ៣ដង)

ទើបអញ្ជើញព្រះភូមិរាជា អ្នកតែងធានាព្រះធរណីបាន បពិត្រអ្នកអើ្ហយខ្ញុំស្មោះស្មានសូមអ្នកយាត្រាហោះថ្កានដល់ស្ថានយើងខ្ញុំឆាប់រ៉ា យើងខ្ញុំបម្រុងប្រដាប់ស្រេចស្រាប់មានទាំងអាហារចំណើដ្សិតលោក....រៀបមង្គលធ្វើនូវ.....នេះនៃសូមភូមិសូមដីកុំបីអ្នកខានយាត្រាបពិត្រអ្នកប្រាកដហោង ។

## អញ្ជើញព្រះភូមិទិសទាំង៨

ទើបអញ្ជើញព្រះភូមិទិស..............រាជាសព្វាយ

ទើបអញ្ជើញព្រះភូមិទិស..............រាជាព្រះចន្ទតារា

ទើបអញ្ជើញព្រះភូមិទិស.............រាជាអ្នកមានលក្ខិណា

ឯហិ ឯហិ មម អាគច្ឆន្តុ ភុញ្ជន្តុ ស្វាហាយៈ ។

បញ្ជាក់ៈ ត្រង់ចន្លោះ............ ខាងលើនេះត្រូវដាក់ឈ្មោះទិសមានដូចជា បូពិ អាគ្នេយ៍ ទក្សិណ និរតី បស្ចិម ពាយព្យ ឧត្តរ ឦសាន បន្តទីនេះសូមអញ្ជើញសូធ្យតាមចេះទៅចុះ ។ អាចជាអាកាសដ្ឋាមង្គលចក្កវាឡ សព្វេ បុរត្ថិមា -ឥមិនា -យំកិញ្ចិ ......... ។ល ។

# ព្រះរាជជីវប្រវត្តិសម្តេចព្រះសង្ឃរាជ
# សម្តេចព្រះមហាសង្ឃរាជ
# ព្រះនាម និល ទៀង
# គណៈមហានិកាយ

ព.ស.២៤០១-២៤៥៧

គ.ស.១៨៥៧-១៩១៣

ព្រះអង្គប្រសូតនៅថ្ងៃសៅរ៍ ៧កើត ខែអាសាឍ ឆ្នាំវក ឆស័ក ព.ស. ២៣៦៨ គ.ស.១៨២៤ ក្នុងស្រុកពោធិព្រះបាទ ខេត្តកៀនស្វាយ (ស្រុកកៀនស្វាយខេត្តកណ្តាលបច្ចុប្បន្ន) ព្រះអង្គជាបុត្រនៃបិតានាម និល មាតានាម ឡឹក ។

ក្នុងគ.ស១៨៣១ កាលនោះកុមារទៀង ទើបតែអាយុបាន៨ឆ្នាំ ទ័ពយួន និងសៀម បានពើបប្រយុទ្ធគ្នាយ៉ាងខ្លាំងក្លានៅតំបន់កៀនស្វាយ ដើម្បី ដណ្តើមយកស្រុកខ្មែរ ។ គ្រួសារសម្តេចទៀងទាំងប៉ុន្មាន ត្រូវទ័ពសៀមចាប់ កែនកៀរយកទៅស្រុកសៀម ទុកធ្វើជាទាសាទាសី ។ កុមារទៀង និងជីដូន ត្រូវគេបញ្ជូនឱ្យទៅរស់នៅឯទីក្រុងបាងកក ។

នៅទីនោះកុមារទៀងបានជួបនឹងមាម្នាក់ឈ្មោះពៅជាអាមាត្យរបស់ព្រះ បាទសម្តេចព្រះអង្គឌួង កាលព្រះអង្គនៅជាព្រះអង្គម្ចាស់ដែលសៀមកែន កៀរយកទៅធ្វើជាឈ្លើយដែរ ។ ចំណែកគ្រួសារសម្តេចមួយផ្នែកទៀត ត្រូវ សៀមបញ្ជូនទុកឱ្យរស់នៅ ស្រុកមង្គលបុរីក្នុងខេត្តបាត់ដំបង ។

ព្រះអង្គមានព្រះជន្មាយុបាន១១ឆ្នាំ ក្នុងឆ្នាំមមី ឆស័ក ព.ស.២៣៧៨ គ.ស.១៨៣៤បានបំពេញផ្នួសជាសាមណេរ នាវត្តមួយ នៅទីក្រុងបាងកក។

ព្រះជន្មាយុបាន២១វស្សា ក្នុងឆ្នាំរោង ព.ស.២៣៨៨ គ.ស.១៨៤៤ សម្តេចព្រះណាំក្លាវ ព្រះចៅក្រុងសៀមទ្រង់រាជានុញ្ញាតឱ្យសាមណេរទៀង ចូលបំពេញឧបសម្បទាក្នុងនាគខ្វាន់ព្រះរាជទ្រព្យនៅវត្តព្រះស្រីរតនសាស្តារាម គឺវត្តព្រះកែវមរកត ក្រុងបាងកក។

ព្រះជន្មាយុបាន២៦វស្សា ក្នុងឆ្នាំរកា ឯកស័ក ព.ស.២៣៩៣ គ.ស.-១៨៤៩ព្រះអង្គបានទៅថ្វាយព្រះពរលាសម្តេចព្រះណាំក្លាវត្រឡប់មកប្រ-ទេសកម្ពុជាវិញ។នៅពេលមកដល់ប្រទេសកម្ពុជាហើយព្រះបាទហរិរក្សរា-មាឥស្សរាធិបតីព្រះអង្គឌួង ទ្រង់សូមនិមន្តឱ្យគង់នៅប្រទេសកម្ពុជា ហើយទ្រង់បានធ្វើព្រះរាជចុតហ្មាយថ្វាយសម្តេចព្រះណាំក្លាវ។ ព្រះជន្មាយុបាន ៣៤វស្សាក្នុងឆ្នាំម្សាញ់ នព្វស័ក ព.ស.២៤០១ គ.ស.១៨៧៥ ព្រះបាទសម្តេច ព្រះហរិរក្សរាមាឥស្សរាធិបតីព្រះអង្គឌួងទ្រង់បានលើកឱ្យអង្គព្រះព្រហ្មមុនីនិល ទៀង ឱ្យគ្រងទីសម្តេចព្រះមហាសង្ឃរាជាក្រុងកម្ពុជា។

លុះរំលងពីនោះមកបានមួយឆ្នាំ ព.ស.២៤០២ គ.ស.១៨៥៨ ព្រះបាទសម្តេចព្រះហរិរក្សរាមាឥស្សរាធិបតីព្រះអង្គឌួងបានតាំងសម្តេចព្រះសង្ឃ-រាជនិល ទៀង ជាស្តេចសង្ឃពេញទី ហើយបានរៀបចំពិធីថ្វាយទឹកក្លស់ទឹកស័ង្ខនៅក្រុងឧត្តុង្គមានជ័យមានគោរម្យងារជា"សម្តេចព្រះមហាសង្ឃរាជា

គណាធិបតីសិរីបរមបពិត្រជាសង្ឃនាយកតិលកលោកាចរិយោត្តមបរមមេ-ធ សង្ឃជេដ្ឋា មហាសង្ឃរាជាធម្មិកវរោត្តមបរមបពិត្រ ដ៏ជាអធិបតីព្វដ៏គណៈសង្ឃក្នុងក្រុងកម្ពុជា ជេដ្ឋារដ្ឋាមហាឥន្ទបត្តនគរបវរបុរីរម្យឧត្តមរាជបនិជាមហាមគ្គនាយក សម្រេចកិច្ចអស់ទ្រទ្រង់សង្ឃព្រះរាជាគណៈទាំង៤សម្រាប់។ សម្តេចព្រះមហាសង្ឃរាជ និល ទៀង ព្រះអង្គមានឋានន្តរសក្តិជាមហាសង្ឃរាជនៅក្នុងរាជ្យ៣គឺ

១-ព្រះបាទសម្តេច ព្រះហរិរក្សរាមាឥស្សរាធិបតីព្រះ **អង្គឌួង**

២-ព្រះបាទសម្តេច **ព្រះនរោត្តម** ព្រះចៅក្រុងកម្ពុជាធិបតី

៣-ព្រះបាទសម្តេច **ព្រះស៊ីសុវត្ថិ** ព្រះចៅក្រុងកម្ពុជាធិបតី។

ព្រះជន្មាយុបាន៩០វស្សាគត់ នៅក្នុងឆ្នាំឆ្លូវ ព្រះអង្គទ្រង់ សោយទិវង្គត នៅថ្ងៃព្រហស្បតិ៍ ២កើត ខែអស្សុជ ឆ្នាំឆ្លូវបញ្ចស័ក ព.ស.២៤៥៧ ត្រូវនឹងថ្ងៃទី២ខែតុលា គ.ស.១៩១៣ វេលាម៉ោង១២និង៤០នាទីអធ្រាត្រ ដោយព្រះរោគជរាពាធ នៅព្រះរាជដំណាក់វត្តឧណ្ណាលោមក្រុងភ្នំពេញ។

| | |
|---|---|
| ប្អូនឆ្នាំសិក្សាសែនយូរម្លេះ | ទ្រូងអើយរលេះហើយឬដឹង |
| ចង់បានចំណេះទើបខំប្រឹង | ទោះឆ្លងព្រៃកស្ទឹងក៏តស៊ូ។ |
| មានលុយតិចតួចមិនហ៊ានចាយ | មិនហ៊ានចំណាយព្រោះគិតគូរ |
| និស្សិតក្រីក្រជាគំរូ | បានចេះរអ៊ូតែម្នាក់ឯង។ |
| តើនេះដោយសារតែហេតុអ្វី? | ទើបមនុស្សប្រុសស្រីខំប្រឹងប្រែង |
| ខ្លះខំសិក្សាមិនរអែង | រៀបរាប់ថ្លាថ្លែងតខ្លឹមសារ។(ត)២ |

# សម្តេចព្រះធម្មលិខិត សិរីមហាសង្ឃកិច្ច

# ឥន្ទត្ថេរោ កែ អ៊ុក ព្រះសង្ឃនាយក

# គណៈមហានិកាយ

# ព.ស.២៤៥៨-២៤៨០

# គ.ស.១៩១៤-១៩៣៦

ព្រះអង្គប្រសូតនៅ ថ្ងៃព្រហស្បតិ៍ (បាត់រនោច.ខ្មីត) ខែកត្តិក ឆ្នាំកុរ ត្រីស័ក ព.ស.២៣៩៥ គ.ស.១៨៥១ នៅភូមិក្រោលខ្សែវ ស្រុកពញាឮ ខេត្ត កណ្ដាល។ បិតានាម កែវ មាតានាម មា ហើយត្រូវជាចៅសម្ដេច ជហ្វា ប៉ុក។

មានព្រះជន្មាយុបាន១០ឆ្នាំនៅឆ្នាំវកត្រីស័កព.ស.២៤០៤ គ.ស.១៨៦០ មាតា បិតា នាំយកទៅរៀនសូត្រនៅវត្តរំដួល ស្រុកឧត្តុង្គ ខេត្តកំពង់ស្ពឺ នៅក្នុងសំណាក់ព្រះពោធិវង្ស ប្រាក់។

មានព្រះជន្មាយុ១៥ឆ្នាំ ក្នុងឆ្នាំឆ្លូវសប្តស័ក ព.ស.២៤០៩ គ.ស.១៨៦៥ បានបួសជាសាមណេរនៅវត្តរំដួល ស្រុកឧត្តុង្គ ខេត្តកំពង់ស្ពឺ។

មានព្រះជន្មាយុ២២វស្សា នៅក្នុងឆ្នាំវកចត្វាស័ក ព.ស.២៤១៦ គ.ស. ១៨៧២បានបំពេញឧបសម្បទាជាភិក្ខុ នៅវត្តឧណ្ណាលោម ដែលសម្ដេចព្រះសង្ឃរាជ និល ទៀង ជាព្រះឧបជ្ឈាយ៍។

ព្រះជន្មាយុ៦៤វស្សា នៅក្នុងឆ្នាំខាលឆស័ក ព.ស.២៤៥៨ គ.ស.១៩១៤ ព្រះអង្គបានទទួលសមណសក្តិជាព្រះសង្ឃនាយកស្តីទី។

ព្រះជន្មាយុ៧៥វស្សា នៅក្នុងឆ្នាំរោង សំរឹទ្ធិស័ក ព.ស.២៤៧២ គ.ស. ១៩២៨ព្រះអង្គបានទទួលបានសមណសក្តិជាសម្តេចព្រះធម្មលិខិត សង្ឃនាយកសិរីមហាសង្ឃកិច្ចគណមហានិកាយព្រះសង្ឃនាយកស្តីទីចំនួន១៥ឆ្នាំ។

ព្រះជន្មាយុ៨៦វស្សានៅក្នុងឆ្នាំជូតអដ្ឋស័កព.ស.២៤៨០ គ.ស.១៩៣៦ ព្រះអង្គបានចូលទិវង្គត នៅថ្ងៃសៅរ៍ ២រោចខែជេស្ឋឆ្នាំជូត នៅវេលាម៉ោង ២០និង៣០នាទី នៅវត្តឧណ្ណាលោមក្រុងភ្នំពេញ។

| | |
|---|---|
| តើសញ្ញាបត្រនេះគឺជាអ្វី? | ហើយមានតម្លៃថ្លៃយ៉ាងណា |
| ដូច្នេះអ្នកបានបរិញ្ញា | សញ្ញាបត្រថ្លាសម្គាល់ខ្លួន។ |
| សារប្រយោជន៏នៃសញ្ញាបត្រ | បវរពេកក្តាត់ណាស់បងប្អូន |
| សញ្ញាបត្រនេះតដល់កូន | ត្រាប់តាមច្បាប់ក្បួនឆ្លងផុតត្រើយ។ |
| បើអ្នកដាក់ឈ្មោះចូលធ្វើការ | អ្នកមានបរិញ្ញាបត្ររួចហើយ |
| បំពេញស៊ីវីរួចអាប់ផ្លាយ | អ្នកកុំព្រួយឡើយការងារនោះ។ |
| ប្រាកដជាបានក្តីសម្រេច | គេរង់ចាំស្រេចនៅទីនោះ |
| រីប្រាក់បៀវត្សក៏បានខ្ពស់ | និងមានកិត្តិយសឧត្តមក្រៃ។ |
| ការងារក៏ស្រួលនៅក្នុងម្លប់ | មិនមានឈរឈប់ហាត់រាល់ថ្ងៃ |
| ដោយមានចំណេះប្រៀបពេជ្រថ្មៃ | ផ្លាស់រូបកែខែផ្ទុយជនល្ងង់។ |
| មួយថ្ងៃ៧ខំធ្វើការ | ហាត់នឿយកាយាដូចក្នុងទ្រុង |
| ចង់បានអ្វីមួយក្នុងចិត្តស្លុង | ខាតដើមខាតចុងគ្រប់វេលា។ |

(ត)៣

# សម្តេចព្រះមហាសុមេធាធិបតី

# ប្រាក់ ហ៊ិន

# ព្រះសង្ឃនាយក គណៈមហានិកាយ

ព.ស.២៤១៨-២៤៩១

គ.ស.១៩៣៧-១៩៤៧

ព្រះអង្គប្រសូតនៅថ្ងៃអាទិត្យ ៨កើត ខែបុស្ស ឆ្នាំកុរបញ្ចស័ក ព.ស. ២៤០៤ គ.ស.១៨៦៣ នៅភូមិចាក់អង្ករ ស្រុកកំពង់សៀម ខេត្តកំពង់ចាម តែពេលទម្ងន់នៅភូមិពោធិជំទាវមាន់ ខេត្តព្រៃវែង ដោយស្រុកមានវិបត្តិភ័ន្ត ប្រែសម័យរាមាកំហែងក៏បានរត់ទៅនៅ ភូមិចាក់អង្ករវិញ។ បិតានាមប្រាក់ជាជំទប់លេខ១មាតានាមដែងក្រោយមកមាតាបិតាបានមករស់នៅឃុំ លេខ៦ ជ្រោយចង្វារ ភ្នំពេញមានរបរជាអ្នកជំនួញឬស្សី។

ព្រះជន្មាយុបាន១២ឆ្នាំបានបួសជាសាមណេរនៅ វត្តសាំងសាមី ក្រុងព្រៃ វែង ពីឆ្នាំច ឆស័ក ព.ស.២៤១៨ គ.ស.១៨៧៤។

ព្រះជន្មាយុបាន២១វស្សាបានឧបសម្បទាជាភិក្ខុ នៅក្នុងវត្តសាំងសាមី ឆ្នាំមមែចត្វាស័ក ព.ស.២៤២៧គ.ស.១៨៨៣ព្រះឧបជ្ឈាយ៍ឱ្យនាមបញ្ញត្តិថា សុធម្មត្ថេរ។

ព្រះអង្គបានឡើងជាចៅអធិការវត្តសារាវ័នតេជោ ឃុំលេខ៣ ក្រុងភ្នំ-ពេញ ពីឆ្នាំចត្រីស័ក ព.ស.២៤៥៤ គ.ស.១៩១០។

ព្រះជន្មាយុ៧៥វស្សានៅក្នុងឆ្នាំឆ្លូវ ព.ស.២៤៨១ ព្រះអង្គបានឡើងជាព្រះសង្ឃនាយកស្តីទីគណៈមហានិកាយ ព្រះរាជក្រឹត្យលេខ៦ ចុះថ្ងៃទី០១ ខែហ្វេវ្រីយេឆ្នាំ១៩៣៧ ។

ព្រះជន្មាយុ៧៧វស្សា ព្រះអង្គបានទទួលនូវឋានន្តរសក្តិជាព្រះសង្ឃនាយក ព្រះរាជក្រឹត្យលេខ ២២ ចុះថ្ងៃទី១៧ ខែដេសមប្រ៊ី ឆ្នាំ១៩៤០។

ព្រះជន្មាយុ៨០វស្សាព្រះអង្គបានឡើងសមណសក្តិជាន់ខ្ពស់ជាទីសម្តេចព្រះពោធិវង្សព្រះសង្ឃនាយក គណៈមហានិកាយ នៅថ្ងៃសុក្រ ៣កើត ខែពិសាខ ឆ្នាំមមីចត្វាស័ក ព.ស.២៤៧៤ គ.ស.១៩៣០។

មានព្រះជន្មាយុ៨១វស្សាព្រះអង្គបានឡើងសមណស័ក្តិខ្ពស់បំផុត ជាទីសម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយកគណៈមហានិកាយនៅ ថ្ងៃ១រោច ខែអស្សុជ ឆ្នាំមមែបញ្ចស័ក ព.ស.២៤៧៥ ត្រូវនឹងថ្ងៃទី១៩ ឧកតូប្រ៊ី ឆ្នាំ១៩៣១។

មានព្រះជន្មាយុ៨៥វស្សា ព្រះអង្គបានចូលទិវង្គត នៅថ្ងៃព្រហស្បតិ៍ ៨កើត ខែកត្តិក ឆ្នាំកុរ ព.ស.២៤៩១ត្រូវនឹងថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៤៧ វេលាពាក់កណ្តាលអធ្រាត្រ។

# សម្តេចព្រះសង្ឃរាជ គណៈមហានិកាយ

# ជួន ណាត ជោតញ្ញាណោ

## ១-ជាតិបរិច្ឆេទកំណត់អំពីជាតិ

សម្តេចព្រះសង្ឃរាជទ្រង់ប្រសូតនៅ ថ្ងៃអង្គារ ១១រោច ខែផល្គុន ឆ្នាំវកឆស័កព.ស.២៤២៧គឺថ្ងៃទី១១ ខែមីនា គ.ស.១៨៨៣នៅភូមិកំរៀង សង្កាត់រកាកោះស្រុកគងពិសី ខេត្តកំពង់ស្ពឺ សម្តេចមានព្រះជាតិក្នុងត្រកូល កសិករព្រះមាតាសម្តេចនាម **យក់**ព្រះបិតានាម **ព្រហ្ម ជួន**។ គ្រួសារនេះ មានបុត្រតែពីរនាក់ គឺអង្គសម្តេចព្រះសង្ឃរាជ និងលោកអ្នកឧកញ៉ា សោ-ភ័ណមន្ត្រី **ជួន នូត** ជាព្រះអនុជនៃសម្តេចព្រះសង្ឃរាជ។

## ២-កុមារបរិច្ឆេទកំណត់អំពីនៃកុមារភាព

សម្តេចកាលនៅកុមារភាពមានព្រះជន្មាយុរវាង ១២ឆ្នាំ ព្រះមាតាបិតា បាននាំយកទៅផ្ញើផ្ញាក់ ឱ្យរៀនសូត្រអក្សរសាស្ត្ររបស់ជាតិ ក្នុងសំណាក់ លោកគ្រូសូត្រស្តាំនាម **កែ ម៉ម** វត្តពោធិ៍ព្រឹក្ស ហៅវត្តពោធិល្វំ សង្កាត់ រលាំងកែន ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល។

## ៣-បព្វជ្ជាបរិច្ឆេទកំណត់អំពីបព្វជ្ជា

លុះសម្តេចមានព្រះជន្មាយុ១៤ឆ្នាំបានបួសជាសាមណេរក្នុងថ្ងៃ១៥កើត ខែពិសាខឆ្នាំចសំរឹទ្ធិស័ក ព.ស.២៤៤១ គ.ស.១៨៩៧ នៅបំពេញកិច្ចសិក្សា នាវត្តពោធិព្រឹក្ស អស់រយៈកាល២ឆ្នាំ ទើបចេញពីវត្តពោធិព្រឹក្ស ទៅរៀន សូត្រព្រះបរិយត្តិធម៌ឯ វត្តឧណ្ណាលោមក្រុងភ្នំពេញ ក្នុងសំណាក់ព្រះគ្រូ

**ទេព សោ** នាកុដិថៃវ ប្រេបកំពែងខាងជើងក្នុងកាលព.ស.២៤៤៣គ.ស. ១៨៩៩។

## ៤.ឧបសម្បទាបរិច្ឆេទកំណត់អំពីឧបសម្បទា

លុះសម្តេចបានព្រះជន្មាយុ គម្រប់២១វស្សា បាននិមន្តត្រឡប់ទៅ សូម ឧបសម្បទាជាភិក្ខុ ក្នុងវត្តពោធិព្រឹក្ស ដែលជាវត្តដើមវិញ ដោយមានព្រះ តេជព្រះគុណព្រះពុទ្ធឃោសាចារ្យ**ម៉ាកេត** សុវណ្ណប្បញ្ញោជាព្រះឧបជ្ឈាយ៍ កាលលោកនៅជាចៅអធិការវត្តពោធិព្រឹក្ស មានព្រះតេជព្រះគុណ **កែ ម៉ម** មិស្សនាគោជាគ្រូសូត្រស្តាំ និងព្រះតេជគុណ **អ៊ុន ខឹម** តិក្ខប្បញ្ញោ ជាគ្រូសូត្រឆ្វេង សូត្របំពេញកិច្ចឧបសម្បទា នៅថ្ងៃ១៥កើត ខែជេស្ឋ ឆ្នាំរោងឆស័ក ព.ស. ២៤៤៨ គ.ស. ១៩០៤។

សម្តេចទ្រង់ទទួលព្រះនាមបប្បញ្ញត្តិថា: ជោតញ្ញាណោ លុះទ្រង់បំពេញ ឧបសម្បទាជាភិក្ខុភាពរួចហើយ ទ្រង់ក៏និមន្តត្រឡប់មកគង់នៅ វត្តឧណ្ណា-លោម ទទួលការសិក្សាគន្ថធុរៈវិញទៀត។

## ៥.បរិយត្តិបរិច្ឆេទកំណត់អំពីការសិក្សា

សម្តេចព្រះសង្ឃរាជមានសេចក្តីព្យាយាម ប្រកបដោយថាមពលដ៏ក្លៀវ ក្លាក្នុងការសិក្សាទាំងផ្នែកភាសាបាលីទាំងផ្នែកភាសាឯទៀតមានភាសាបា-រាំងជាដើម។ការសិក្សារបស់ព្រះសង្ឃរាជ មានការជោគជ័យប្រសើរណាស់ បណ្តាលោកអ្នកសិក្សាក្នុងសម័យនោះ ក្នុងជំនាន់ជាមួយគ្នានឹងសម្តេចព្រះ សង្ឃរាជឃើញមានតែសម្តេចព្រះសង្ឃរាជ ដែលរៀនចម្រើនលូតលាស់

មានល្បឿនឈ្នះលោកឯទៀត។ ដំបូងសម្តេចរៀនមេសូត្រ ប្រែមូល-កច្ចាយនះនិងគម្ពីរធម្មបទ អំពីព្រះពុទ្ធឃោសាចារ្យព្រះនាម **ម៉ា កេត** ដែលជាព្រះឧបជ្ឈាយ៍នៃសម្តេចព្រះសង្ឃរាជ។ សម្តេចព្រះសង្ឃរាជពេលដែលទ្រង់ចាប់ផ្តើមរៀនវិជ្ជាណាមួយមានបាលីជាដើម គឺរៀនដោយយកព្រះទ័យទុកដាក់ខំប្រឹងប្រែង ឥតមានការបន្ធូរបន្ថយក្នុងការសិក្សានោះឡើយ ។សម្តេចទ្រង់ទទួលការសិក្សានោះ គឺសិក្សាដោយឆន្ទៈដ៏មានកម្លាំង មែនទែនពុំសិក្សាវិជ្ជា ណាមួយដោយលេងៗទេ។

វិជ្ជាខាងភាសាបាលី ភាសាសំស្ក្រឹត និងភាសាបារាំង សុទ្ធតែវិជ្ជាដែលប្រដាប់ដោយវេយ្យាករណ៍ហ្មត់ចត់ជ្រាលជ្រៅ លំបាករៀនលំបាកយល់ជាទីបំផុត ប៉ុន្តែសម្តេចអាចរៀន អាចយល់ច្បាស់លាស់ ដោយឆាប់រហ័ស គួរឱ្យកោតសរសើរពន់ពេកណាស់។ សម្តេចលោកទ្រង់ចេះដឹងយល់ធ្លុះធ្លាយចំពោះវេយ្យាករណ៍គ្រប់ភាសាដែលសម្តេចបានរៀនមានវេយ្យាករណ៍បាលីសំស្ក្រឹតជាដើមទាំងអក្សរសាស្ត្ររបស់ជាតិនិងពាក្យពេចន៍ក្នុងផ្នែកវប្បធម៌បុរាណក៏សម្តេចចេះចាំយល់ហេតុផលជាច្រើនណាស់។ ភាសាសៀម ភាសាឡាវ និង ភាសាបារាំង ដែលសម្តេចបានរៀន អាចនិយាយប្រស្រ័យទាក់ទងនឹងជនជាតិសៀម ជាតិឡាវ និងជាតិបារាំងបាន។ សម្តេចឈ្លាសវៃប្រសប់យកតម្រាប់សំឡេងភាសាជាតិដទៃៗ ឱ្យស្រដៀង ឬដូចភាសាជាតិដទៃទៀតបាន។ ភាសាអង់គ្លេស និងភាសាវៀតណាម ក៏សម្តេចបានរៀន អាចមើលសរសេរនិយាយប្រាស្រ័យបានច្រើនដែរ។

ក្នុងសម័យដែលសម្តេច កំពុងសិក្សាវិជ្ជាខាងបាលី ក្នុងរវាង គ.ស.១៩១០ ឃើញថាសម្តេចមានព្រះកិត្តិសព្ទល្បីថាជាព្រះថេរៈស្ទាត់ជំនាញពូកែភាសាបាលីអាចនិយាយភាសាបាលីបានច្រើនជាងភិក្ខុសាមណេរឯទៀតដែលបានរៀនជាមួយគ្នាក្នុង សម័យនោះ។

នៅ ព.ស.២៤៥៧ គ.ស.១៩១៣សម្តេចទ្រង់បានចូលប្រឡងដេញប្រ-យោគក្នុងឧបោសថរតនារាមវិហារ ព្រះកែវមរកត ចំពោះព្រះភក្ត្រព្រះករុណាព្រះបាទសម្តេចព្រះស៊ីសុវត្ថិបាន៤ប្រយោគ ដែលជាប្រយោគខ្ពស់បំផុតក្នុងសម័យនោះ។

នៅ ព.ស.២៤៥៩គ.ស.១៩១៥ សម្តេចទ្រង់បានប្រឡងជាប់ លេខ២ ដោយបានទទួលការតែងតាំងជាសាស្ត្រាចារ្យនៅសាលាបាលីជាន់ខ្ពស់ដែលសព្វថ្ងៃមានឈ្មោះថា ពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ក្រៅពីភាសាខ្មែរ ដែលសម្តេចទ្រង់បានស្រាវជ្រាវយល់ឬសគល់ពិតប្រាកដសម្តេចបានសិក្សាភាសាបាលីអាចអាន ឬសន្ទនាតាមសំនៀងជាតិបរទេសបានទាំងអស់គឺ
សំនៀង លង្កា ភូមា មន សៀម និង ឡាវ ឥតមានទើសទាក់ភ្លាំងភ្លាត់ឡើយ។

នៅក្នុង ព.ស.២៤៦៦ គ.ស.១៩២៣ និង ព.ស.២៤៦៧ សម្តេចកាលនៅជាព្រះ គ្រូសង្ឃសត្ថា ជាមួយនឹងសម្តេចព្រះពោធិវង្ស ហួត តាតវជិរប្បញ្ញោកាលនៅជាព្រះគ្រូវិជ្ជាបានធ្វើជាសមណនិស្សិតនិមន្តទៅបំពេញវិជ្ជាខាងភាសាសំស្ក្រឹតនិងអក្សរសិលាចារឹកជាដើមនៅសាលាបារាំង

សែសចុងបូពាំប្រទេសនៅក្រុងហាណូយ(វៀតណាមខាងជើង)ក្នុងសំណាក់លោកល្វីហ្វីណូត៍(ជាតិបារាំងសែស) ជាចាងហ្វាងសាលានេះ។

## ៦-បេសកកម្មបរិច្ឆេទកំណត់អំពីការទទួលបម្រើកិច្ចការ

នៅព.ស.២៤៦៣ គ.ស.១៩១៩ សម្ដេចទ្រង់បានធ្វើជាសមាជិកនៃក្រុមជំនុំតែងវចនានុក្រមខ្មែរដែលទ្រង់ជាលេខាធិការកាន់កិច្ចការផ្ទាល់លុះត្រាបានចប់ចុងចប់ដើម។

នៅព.ស.២៤៦៩ គ.ស.១៩២៥ សម្ដេចបានធ្វើជាសមាជិកនៃក្រុមជំនុំពិនិត្យអក្ខរាវិរុទ្ធនៃសៀវភៅនានាដែលសាលាបាលីជាន់ខ្ពស់បោះពុម្ពផ្សាយ

នៅព.ស.២៤៧០គ.ស.១៩២៦តមកជាច្រើនឆ្នាំសម្ដេចទ្រង់បានទទួលការតែងតាំងនាមប្រយោគ ក្នុងការប្រឡងយកវិញ្ញាបនបត្រ បឋមសិក្សាខ្មែរនិងប្រឡងយកសញ្ញាបត្រ បឋមសិក្សាជាន់ខ្ពស់បារាំងខ្មែរ នៅក្រុងភ្នំ-ពេញ។

នៅព.ស.២៤៧៤គ.ស. ១៩២៧ សម្ដេចទ្រង់ទទួលការតែងតាំងជាសមាជិកក្រុមជំនុំផ្ទៀងសម្រេចខាងវចនានុក្រមខ្មែរ ហើយសម្ដេចទ្រង់បានទទួលភារៈធ្វើវចនានុក្រមតែមួយព្រះអង្គឯង ដរាបដល់បានចង់សព្វគ្រប់បានបោះពុម្ពផ្សាយទាំងភាគ១ភាគ២បាន៥គ្រាហើយ។ ក្នុងឆ្នាំនោះសម្ដេចបានទទួលការតែងតាំងជាសមាជិកនៃក្រុមអភិបាល ជំនុំផ្ដាច់ឆ្នាំ សម្រាប់បណ្ណាល័យកម្ពុជាដែលសព្វថ្ងៃហៅថាវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ។

នៅព.ស.២៤៧៤គ.ស.១៩៣០សម្ដេចទ្រង់បានទទួលការតែងតាំងក្នុង

មុខតំណែងជាចាងហ្វាងរងនៃសាលាបាលីជាន់ខ្ពស់ក្រុងភ្នំពេញ។ ក្នុងឆ្នាំដដែលនោះ សម្តេចបានទទួលការតែងតាំងសមាជិកជំនួយនៃក្រុមជំនុំខាងការស្រាវជ្រាវជ្រើសរើសពាក្យពេចន៍ក្នុងផ្ទៃ នៃគម្ពីរនិពន្ធខ្មែរបុរាណដើម្បីប្រមូលបញ្ចូលពាក្យទាំងនេះទៅក្នុងវចនានុក្រមខ្មែរ។

នៅព.ស.២៤៧៧ គ.ស.១៩៣៣ សម្តេចទ្រង់បានទទួលការតែងតាំងជាសមាជិកនៃក្រុមជំនុំពិនិត្យសៀវភៅ ដែលក្រសួងសិក្សាធិការជាតិបោះពុម្ពផ្សាយ។

នៅព.ស.២៤៧៨ គ.ស.១៩៣៤ សម្តេចទ្រង់ទទួលការតែងតាំងសមាជិកនៃក្រុមជំនុំជ្រើសរើសពាក្យខ្មែរដើម្បីប្រៀបធៀបនឹងពាក្យបារាំងសម្រាប់ប្រើក្នុងការងាររាជការ។

នៅព.ស.២៤៧៩គ.ស.១៩៣៥ សម្តេចទ្រង់បានទទួលការតែងតាំងជាសាស្ត្រាចារ្យបង្រៀនភាសាបាលី សំស្ក្រឹតខ្មែរ និងឡាវ ប្រចាំថ្នាក់ទីបំផុតនៃធម្មសិក្សានៅវិទ្យាល័យព្រះស៊ីសុវត្ថិក្រុងភ្នំពេញ។

## ៧-ឋានន្តរបរិច្ឆេទកំណត់អំពីឋានន្តរ

នៅព.ស.២៥៨៦គ.ស.១៩៤២សម្តេចទ្រង់បានទទួលឋានន្តរជាចាង-ហ្វាងនៃសាលាបាលីជាន់ខ្ពស់ ក្រុងភ្នំពេញ ដែលសព្វថ្ងៃកែឈ្មោះជាពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត។

នៅព.ស. ២៤៨៨ គ.ស.១៩៤៤ សម្តេចទ្រង់បានទទួលនាទី ជាអធិបតីនៃថេរសភា គឺក្រុមជំនុំជាន់ខ្ពស់របស់សង្ឃ។

នៅព.ស. ២៤៩១ គ.ស. ១៩៤៧ សម្តេចទ្រង់បានទទួលនាទីជាអនុប្រធានគណៈកម្មការវប្បធម៌ផ្នែកអក្សរ"ក" នៃគណៈកម្មការជាតិខាងការសិក្សា។

នៅព.ស.២៤៩២ គ.ស.១៩៤៨ សម្តេចទ្រង់បានទទួលនាទីជាគណៈកម្មការធម្មវិន័យ ពិនិត្យការផ្សាយសៀវភៅ សម្រាប់សាលាធម្មវិន័យក្នុងព្រះ រាជាណាចក្រកម្ពុជា។

នៅគ.ស.១៩៦១រហូតមកសម្តេចទ្រង់ប្រោសមេត្តាទទួលនិមន្តរបស់សមាគមអ្នកនិពន្ធខ្មែរ ធ្វើជាព្រះប្រធាននៃការសម្ភាស អក្សរសាស្ត្រផ្សាយតាមវិទ្យុជាតិរៀងរាល់ថ្ងៃសុក្រ។

នៅគ.ស.១៩៦៨ទ្រង់ទទួលឋានៈជាព្រះប្រធាន គណៈកម្មការពិនិត្យអត្ថបទផ្សាយជារឿងខាងប្រវត្តិសាស្ត្រខ្មែរ។

នៅគ.ស.១៩៦៩ព្រះអង្គទទួលការតែងតាំងជាប្រធាន គណៈកម្មការពិនិត្យ និងកំណត់អំពីវិន័យរបស់ទង់ជាតិខ្មែរ។

## ព្រះកិច្ចការព្រះពុទ្ធសាសនាដែលសម្តេចទ្រង់បានបំពេញនៅបរទេស

នៅព.ស.២៤៧៥ គ.ស.១៩៣១ សម្តេចទ្រង់បានដឹកនាំគណៈប្រតិភូនៃមន្ត្រីសង្ឃទៅកាន់ក្រុងវៀងចន្ទន៍ និងក្រុងហ្លួងព្រះបាង ប្រទេសលាវ ដើម្បីចូលរួបរួមក្នុងពិធីសម្ពោធ ពុទ្ធសាសនបណ្ឌិត្យប្រទេសឡាវផង ដើម្បីជំនុំពិភាក្សាអំពីការសិក្សាសម្រាប់សាលាបាលីរងនៅប្រទេសលាវផង។

នៅព.ស.២៤៧៧ គ.ស.១៩៣៣ សម្តេចទ្រង់បានដឹកនាំ គណៈប្រតិភូព្រះសង្ឃខ្មែរទៅធ្វើទស្សនាចរណ៍ចំពោះវត្តខ្មែរទាំងឡាយក្នុងដែនកូសាំង-ស៊ីនកម្ពុជាក្រោម ។

នៅព.ស២៤៨៣គ.ស១៩៣៩សម្តេចបានដឹកនាំគណៈប្រតិភូមួយទៅកាន់ប្រទេសលាវម្តងទៀត ដើម្បីប្រជុំកិច្ចការ នៃព្រះពុទ្ធសាសនបណ្ឌិត្យប្រទេសលាវនិង ការសិក្សាសម្រាប់សាលា ភាសាបាលីនៅប្រទេសលាវផងដើម្បីជួយរំលឹកដាស់តឿនប្រជាជាតិលាវ ឱ្យមានការសិក្សាព្រះបរិយត្តិធម៌និងការប្រតិបត្តិព្រះពុទ្ធសាសនា ឱ្យស្របគ្នាតាមរបៀបការសិក្សា និងការប្រតិបត្តិព្រះពុទ្ធសាសនានៃប្រទេសកម្ពុជា ទាំងនៅក្នុងទីប្រជុំជន និងក្នុងខេត្តនានានៃព្រះរាជាណាចក្រលាវឱ្យខំប្រឹងយកចិត្តទុកដាក់ ក្នុងការសិក្សានិងការប្រតិបត្តិឱ្យបានត្រឹមត្រូវតាមគន្លងព្រះពុទ្ធសាសនាផង ។

នៅព.ស.២៤៨៤ គ.ស. ១៩៤៣ សម្តេចទ្រង់បានទទួលនាទីជាសមា-ជិកឆ្លើយឆ្លង នៃសាលាបារាំងសែសនៅចុងបូព៌ាប្រទេស ហើយនៅព.ស. ២៤៩២ គ.ស.១៩៤៨ សម្តេចទ្រង់បានទទួលនាទីជាសមាជិកកិត្តិយស នៃសាលានេះដរាបរៀងមក ។

នៅព.ស២៤៩៤ គ.ស ១៩៥០ សម្តេចទ្រង់បានដឹកនាំ គណៈប្រតិភូខ្មែរប្រជុំសន្និសីទ ដើម្បីបង្កើតពុទ្ធិកសមាគមពិភពលោកនៅក្រុងកូឡុំបូប្រទេសស្រីលង្កា ។

នៅព.ស.២៤៩៧គ.ស.១៩៥៣សម្តេចទ្រង់បានដឹកនាំគណៈប្រតិភូខ្មែរ ទៅបំពេញបេសកកម្ម សុច្ឆន្ទៈ ទីប្រឹក្សាសម្រេចរឿងឆដ្ឋសង្គាយនា នៅក្រុងរង្គូន សហភាពភូមា ។

ក្នុងឆ្នាំបន្ទាប់ នៅព.ស.២៤៩៨ គ.ស.១៩៥៥ សម្តេចទ្រង់បានដឹកនាំគណៈប្រតិភូខ្មែរទៅកាន់ឆដ្ឋសង្គាយនាក្រុងរង្គូន ប្រទេសភូមា ជាលើកទីបីដើម្បីប្រជុំហើយបិទសម័យប្រជុំប្រចាំឆ្នាំ ។

នៅព.ស. ២៥០៣ គ.ស.១៩៥៩ សម្តេចទ្រង់បានដឹកនាំ គណៈប្រតិភូខ្មែរទៅកាន់ក្រុងចាកាតា និងក្រុងសឺម៉ារាំង កោះជ្វា ប្រទេសឥណ្ឌូណេស៊ី ដើម្បីចូលរួមក្នុងពិធីបុណ្យវិសាខបូជាហើយនិងចូលរួមពិធីបញ្ចុះខណ្ឌសីមា និងពិធីសន្មតរោងឧបោសថ ព្រមទាំងធ្វើជាព្រះឧបជ្ឈាយ៍ បំបួសកុលបុត្រអ្នកប្រទេសនោះចំនួនបីរូប ។

## ៨-សមណសក្តិបរិច្ឆេទកំណត់អំពីសមណសក្តិ

ដោយព្រះមហាវីរិយភាព ដែលសម្តេចទ្រង់បានបំពេញ ទាំងផ្លូវព្រះពុទ្ធសាសនាទាំងផ្លូវលោក ដែលយើងបានឃើញជាភស្តុតាង ក្រៅពីនេះសម្តេចក៏បានទទួលជាសមណសក្តិជាលំដាប់លំដោយដូចតទៅនេះ គឺព.ស.២៤៥៤ គ.ស.១៩១០ សម្តេចបានទទួលការតែងតាំងសមណសក្តិជាព្រះបាឡាត់សាក្យបុត្តិយ៍( បាឡាត់របស់ព្រះសក្យវង្សនុតវត្តឧណ្ណាលោម) ។

ព.ស.២៤៥៦គ.ស.១៩១២សម្ដេចបានទទួលសមណសក្តិ ជាព្រះគ្រូសត្ថា (ទីឋានានុក្រមសម្រាប់ឯករបស់សម្ដេចព្រះសង្ឃរាជព្រះនាម ទៀង)។

ព.ស.២៤៧៥ គ.ស.១៩៣១ សម្ដេចបានឡើងសមណសក្តិជា ព្រះពុទ្ធឃោសាចារ្យ "រាជាគណៈថ្នាក់ទី២"។

ព.ស.២៤៨៨ គ.ស.១៩៤៤ សម្ដេចបានឡើងសមណសក្តិជាព្រះពោធិវង្ស (រាជាគណៈថ្នាក់ទី១)។

ព.ស.២៤៩២ គ.ស.១៩៤៨ សម្ដេចបានឡើងសមណសក្តិខ្ពស់បំផុតជាព្រះមហាសុមេធាធិបតីសង្ឃនាយក គណៈមហានិកាយ នៃកម្ពុជា។

ព.ស. ២៤៩៤គ.ស.១៩៥០ព្រះករុណាជាអម្ចាស់ជីវិត ទ្រង់បានប្រោសប្រគេនព្រះឋានៈសម្ដេចព្រះមហាសុមេធាធិបតីសង្ឃនាយកគណៈមហានិ-កាយផងដែរ។

លុះដល់មក ព.ស.២៤៩៨ គ.ស.១៩៥៤ រដ្ឋាភិបាលសហភាពភូមាបាន ប្រគេនព្រះឋានៈសម្ដេច ជាព្រះអគ្គមហាបណ្ឌិតសហភាពភូមា។

លុះមកដល់ ព.ស.២៥០១ គ.ស.១៩៥៧ រដ្ឋាភិបាលសហភាពភូមាបានសូមដំឡើងព្រះឋានៈ សម្ដេចជាព្រះអភិធជមហារដ្ឋគុរុនៃសហភាពភូមាទៀត ដែលជាសមណសក្តិដ៏ខ្ពស់បំផុតមានតែមួយអង្គក្នុងសហភាពភូមា។

ខែកុម្ភៈគ.ស. ១៩៦៤ អ្នកនិពន្ធខ្មែរទាំងអស់បានថ្វាយព្រះឋានៈ ព្រះ

អង្គជាព្រះអគ្គនិពន្ធអក្សរសាស្ត្រខ្មែរ និងជាសមាជិកកិត្តិយសនៃសមាគមអ្នកនិពន្ធខ្មែរផង។

ព.ស.២៥០៧ គ.ស.១៩៦៣សម្តេចព្រះនរោត្តមសីហនុ ព្រះប្រមុខរដ្ឋនៃប្រទេសកម្ពុជាទ្រង់បានប្រោសប្រទានព្រះឋានៈសម្តេចជា សម្តេចព្រះសង្ឃរាជថ្នាក់ទី១។

ថ្ងៃទី២៨ ឧសភា ១៩៦៧ ទ្រង់បានទទួលសញ្ញាបត្របណ្ឌិតអក្សរ-សាស្ត្រពេញលក្ខណៈអំពីសម្តេចព្រះប្រមុខរដ្ឋក្នុងនាមមហាវិទ្យាល័យអក្សរសាស្ត្រ និងមនុស្សសាស្ត្រនៃភូមិន្ទសាកលវិទ្យាល័យភូមិន្ទ។

## ៩.ឥស្សរិយយបរិច្ឆេទកំណត់អំពីឥស្សរិយយស

គ្រឿងឥស្សរិយយសដែលសម្តេចទទួលបានមានដូចតទៅនេះគឺ

-មេដាយអស្សប្ញទ្ធិមុនីសារាភរណ៍ នៅព.ស. ២៤៦១ គ.ស. ១៩១៧។

-មេដាយអស្សប្ញទ្ធិព្រះរាជាណាចក្រកម្ពុជានៅព.ស.២៤៧៦ គ.ស.១៩៣២។

-មេដាយអស្សប្ញទ្ធិដីរីមួយលាននិងស្វេតច្ឆត្រប្រទេសលាវនៅព.ស. ២៤៧៦ គ.ស.១៩៣២។

-មេដាយសេនា នៃបណ្ឌិតសភាសាធារណរដ្ឋបារាំងនៅ ព.ស.២៤៨១ គ.ស.១៩៣៧។

-មេដាយអស្សប្ញទ្ធិជីឡាឡេស្យុងដូណ្ណើរនៃសាធារណរដ្ឋបារាំងនៅ ព.ស.២៤៨៦ គ.ស.១៩៣៧។

-មេដាយសេនា នៃព្រះរាជាណាចក្រកម្ពុជានៅព.ស.២៤៨៨ គ.ស.១៩៤៤ ។

-មេដាយសេនាជីឡាឡេស្បុងដូណ្ណើរ នៃសាធារណរដ្ឋបារាំង នៅព.ស. ២៤៩២ គ.ស.១៩៤៨។

-មេដាយមហាសិរីវឌ្ឍន៍ ព្រះរាជាណាចក្រកម្ពុជា នៅព.ស. ២៥០៥គ.ស. ១៩៦២។

-មេដាយមហាសិរីវឌ្ឍន៍សុវត្ថារា នៅ ព.ស. ២៥០៦ គ.ស. ១៩៦៣។

-មេដាយជាតូបការដែលជាគ្រឿងឥស្សរិយយសធំបំផុតក្នុងព្រះរាជាណា-ចក្រកម្ពុជានៅ ព.ស.២៥១៣ គ.ស.១៩៦៩។

## ស្នាព្រះហស្ថខាងអក្សរសាស្ត្រ

សម្តេចបានកសាងគម្ពីរដីកាជាច្រើនណាស់ទាំងគម្ពីរស្លឹករឹតទាំងសៀវភៅជាពិសេសគឺសៀវភៅដែលសម្តេចប្រមូលរៀបរៀងនិងសៀវភៅដែលទ្រង់ប្រែបាលីមកជាភាសាខ្មែរសម្រាប់ពុទ្ធបរិស័ទរៀនសូត្រ។

សៀវភៅខ្លះជាសៀវភៅ ដែលកម្រនឹងធ្វើកើតទាំងមានប្រយោជន៍ ជាច្រើនណាស់គឺ

១-វចនានុក្រមខ្មែរមាន២ភាគក្នុងព.ស.២៤៦១ គ.ស.១៩១៧ សៀវភៅនេះបានបោះពុម្ពច្រើនគ្រាមកហើយ។

២-កច្ចាយនូបត្ថម្ភកៈ(វេយ្យាករណ៍បាលី)មាន២ភាគតាំងពីព.ស. ២៤៦២ គ.ស.១៩១៨ បានបោះពុម្ពច្រើនគ្រាមកហើយ។

៣-គហិបដិបត្តិក្នុង ព.ស.២៤៦៨ គ.ស.១៩២៦ ជាមួយនឹងព្រះឧត្តមុនី អ៊ុម ស៊ូ និងព្រះពោធិវង្ស ហួត តាត តាមបញ្ជានៃព្រះតេជគុណព្រះមហាវិមលធម្ម ថោង (ពុទ្ធសាសនបណ្ឌិត្យ)។

៤-សាមណេរវិន័យ ក្នុងព.ស.២៤៦០ គ.ស.១៩១៧ជាមួយនឹងព្រះថេរៈទាំងពីរព្រះអង្គខាងលើនេះដែរ។

៥-បាដិមោក្ខសំវរសង្ខេប(សម្រាយ)ព.ស.២៤៧០ គ.ស.១៩២៨ បានបោះពុម្ពច្រើនគ្រាមកហើយ។ មានសៀវភៅឯទៀតជាច្រើនទៀត ដែលជាបន្ទាប់បន្សំគឺ

៦-កាព្យលោកធម៌បោះពុម្ពដំបូងក្នុងព.ស.២៥០០ គ.ស.១៩៥៧ កាព្យនេះទ្រង់តែងកាលនៅជាព្រះគ្រូសង្ឃសត្ថា។

៧-នាគោបមាទិកថា ព.ស.២៤៧៥ គ.ស.១៩៣៣។

៨-ព.ស.២៤៨៤គ.ស.១៩៤១សម្តេចបានតែងសុភមង្គលគាថាបាលីបប្ប្យាវត្ត៧គាថា ព្រមទាំងប្រែសម្រាយផងសម្រាប់សូត្រថ្វាយ សុភមង្គលសួស្តីចំពោះព្រះករុណាជាអម្ចាស់ជីវិតព្រះបាទសម្តេចព្រះនរោត្តម សីហនុវរ្ម័ន។

៩-បព្វជ្ជាខន្ធកៈសង្ខេប។

១០-ចីវរក្ខន្ធកៈពិស្តារ។

១១-អត្ថបទផ្សេងៗជាច្រើនក្នុងទស្សនាវដ្តីកម្ពុជសុរិយារបស់ពុទ្ធសាសនបណ្ឌិត្យតាំងពីឆ្នាំ១៩២៦ និងឆ្នាំតៗមក ដែលពុំអាចស្រាវជ្រាវមកដាក់ក្នុង

ទីនេះបានដោយពេលមមាញឹកព្រមទាំងអត្ថបទធម៌ឯទៀតៗជាច្រើនដែលបោះពុម្ពចុះក្នុងទស្សនាវដ្ដីពន្លឺពុទ្ធចក្រ ។

១២-បានពិនិត្យកែសម្រួលពាក្យពេចន៍ របស់គណៈកម្មការខេមរយានកម្ម ដោយព្រះមេត្តាជួយឱ្យគណៈកម្មការនេះជារបស់ក្រសួងអប់រំជាតិបានរួប-រួមបោះពុម្ពសៀវភៅទស្សនាវដ្ដីសម្រាប់បង្រៀនសិស្សផ្នែកមធ្យមសិក្សាចេញរៀងរាល់ខែ ។

ព្រះកេរ្តិ៍មួយសំខាន់ណាស់ដែលរំលឹកឃើញរាល់ថ្ងៃ គឺព្រះរាជនិពន្ធទំនុកចម្រៀង បទនគររាជសម្រាប់ភ្លេងជាតិខ្មែរ ទ្រង់បាននិពន្ធពី ថ្ងៃទី ២០-៧-១៩៤១និងទំនុកព្រមទាំងបទសរភញ្ញដែលទ្រង់បាននិពន្ធកាលពីឱកាសបុណ្យពុទ្ធសករាជ២៥០០ ។

ព្រះគុណសម្បត្តិ នៃសម្ដេចព្រះសង្ឃរាជជាអម្ចាស់មានច្រើនយ៉ាងណាស់ ប៉ុន្តែយើងខ្ញុំបានពិចារណា ដោយហ្មត់ចត់ហើយសរសេរ រួបរួមប្រមូលយកចំពោះតែគោលធំៗ ដោយសង្ខេបមាន៥យ៉ាង ដោយមានសេចក្ដីរៀបរៀងដូចតទៅនេះ

១-វីរិយភាពក្នុងការសិក្សា

២-បដិភាណប្បញ្ញា ( ប្រាជ្ញាវាងវៃ)

៣-វេសារជ្ជប្បញ្ញា ( បញ្ញាក្លៀវក្លាអង់អាច)

៤-ធម្មទេសនាកោសល្យ ( ភាពឈ្លាសវៃក្នុងធម្មទេសនា)

៥-បណិតសកម្មភាព ( សកម្មភាពដ៏ប្រសើរ) ។

រយៈកាលមុនអំពីកាលដែលទ្រង់សោយទិវង្គត សម្ដេចព្រះសង្ឃរាជមានព្រះអាពាធជាដំបូងក្នុង ថ្ងៃអង្គារ១២កើត ខែភទ្របទ ឆ្នាំរកាឯកស័កត្រូវនឹង ថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ១៩៦៩។

ដំណឹងព្រះរោគាពាធ នៃសម្ដេចព្រះសង្ឃរាជនេះបានថ្វាយចំពោះសម្ដេចព្រះប្រមុខរដ្ឋរួចហើយឯកឧត្តមអ៊ឹង ហុងសាធតាមព្រះរាជបញ្ជានៃសម្ដេចព្រះប្រមុខរដ្ឋ បានចាត់ឱ្យអស់លោកវេជ្ជបណ្ឌិតខ្មែរ បារាំងដ៏ជំនាញៗទាំងឡាយមកជួយខ្វល់ខ្វាយ ព្យាបាលរោគ ព្រះអង្គយ៉ាងពេញសមត្ថភាពប៉ុន្តែធ្វើម្ដេចឡើយនឹងអាចយកជ័យជម្នះលើមច្ចុសង្គ្រាមបាន។ សម្ដេចព្រះសង្ឃរាជជាអម្ចាស់ទ្រង់បានជ្រាបមុន ចាប់តាំងពីថ្ងៃប្រឈួន ទ្រង់មានព្រះឱង្ការប្រាប់ព្រះសង្ឃនិងអស់លោកដែលមកថ្វាយបង្គំសាកសួរព្រះសុខភាពថា"អាត្មាមានជំងឺម្ដងនេះដូចជាគ្មានសង្ឃឹមទេ" ព្រះរាជឱង្ការនេះធ្វើឱ្យយើងរាល់គ្នាមានការព្រួយបារម្ភណាស់ប៉ុន្តែយើងរាល់គ្នាជឿថាព្រះអង្គមុខជានឹងគង់ព្រះជន្មាយុតទៅទៀតបាន ពីព្រោះសង្កេតទៅព្រះសិរីរាង្គកាយព្រះអង្គពុំឃើញមានប្រែប្រួលប្លែកប៉ុន្មានទេ ម្យ៉ាងទៀតទ្រង់នៅចាំព្រះស្មារតីល្អណាស់ អាចមានព្រះឱង្ការមាំមួនសំណេះសំណាលស្រួលនៅឡើយជាពិសេសកាលពីព្រឹកនៃថ្ងៃសោយព្រះទិវង្គតនេះ ឯកឧត្តមនាយករដ្ឋមន្ត្រីនិងអ្នកអង្គម្ចាស់ឧបនាយករដ្ឋមន្ត្រីទី១ បានចូលក្រាបបង្គំព្រះអង្គសាកសួរព្រះរោគព្រះអង្គផង ដើម្បីក្រាបបង្គំលាព្រះអង្គទៅកាន់បរទេសតាមការអញ្ជើញនៃសាធារណរដ្ឋប្រជាមានិតនិងសាធារណរដ្ឋប្រជាធិបតេយ្យអាល្លឺម៉ង់ផង ។គ្រានោះព្រះអង្គបានទទួលការរាក់ទាក់ហើយបានប្រសិទ្ធពរជូនចំពោះឯកឧត្តមនាយករដ្ឋមន្ត្រី និងថ្វាយចំពោះអ្នកអង្គម្ចាស់ឧបនាយករដ្ឋមន្ត្រីទី១សូមទៅបំពេញបេសកកម្មនៅប្រទេសគេបានជោគជ័យ ។ ក្រោយ មកទៀតសម្ដេចក៏បានព្រះរាជទានសន្ទនាជាមួយនឹងលោក ឌី ទូចរដ្ឋលេខាធិការក្រសួងធម្មការនិងលោកទ្រិញវ៉ាញប្រធានសមាគមអ្នកនិពន្ធ

ខ្មែរអំពីការធ្វើចេតិយ ។ព្រះអង្គមានព្រះបន្ទូលហួរហែហើយទ្រង់និទានអំពីចេតិយឈ្មោះសិង្គុត្តរៈនៅសហភាពភូមាថែមទៀតផង។ រួចព្រះអង្គត្រាស់រំលឹកអំពីការបោះពុម្ពវចនានុក្រមខ្មែរដែលទ្រង់បានខិតខំកែសម្រួលបន្ថែមពាក្យជាច្រើនទៀតទោះបីជរានិងព្យាធិចេះតែបៀតបៀនព្រះអង្គក៏ដោយសភាពទាំងនេះសឱ្យឃើញថា ព្រះអង្គនៅរឹងប៉ឹងណាស់មិនគួរឡើយនឹងប្រែប្រួលដោយឆាប់រហ័សបំផុតដូច្នេះសោះ នាំឱ្យយើងក្រៀមក្រំស្រងាកចិត្ត ហាក់ដូចជាធ្លាក់បេះដូងនេះ ហើយសមដូចព្រះថេរដីការបស់ព្រះអង្គដែល ទ្រង់ត្រាស់ជារឿយៗថា ជួនកាលពេលព្រឹក មនុស្សសត្វជួបគ្នា រញ្ជង់លុះពេលល្ងាចក៏ស្រាប់តែបែកគ្នាភ្លាមៗ សភាពទាំងនេះ ត្រូវដូចព្រះតម្រាស់នោះណាស់។ ព្រះអង្គបានយាងចោលពុទ្ធបរិស័ទ រាល់គ្នាឥតមានប្រទានដំណឹងជាមុនឱ្យច្បាស់ដល់យើងដើម្បីនឹងព្យាបាលព្រះអាការរោគឱ្យបានយូរថ្ងៃសោះគួរឱ្យយើងខ្ញុំស្តាយក្រៃពេកណាស់នឹងរកពាក្យណាមួយថ្លែងរៀបរាប់ពុំបានឡើយ។ ព្រះអង្គសោយទិវង្គតនេះ ធ្វើឱ្យរញ្ជួយសកលកម្ពុជាព្រោះព្រះអង្គមានព្រះគុណធម៌ច្រើនណាស់ លើពុទ្ធបរិស័ទទាំងបព្វ-ជិតទាំងគ្រហស្ថ។

សម្តេចទ្រង់សោយព្រះទិវង្គតបាត់ព្រះរូប ពិតមែនក៏ប៉ុន្តែព្រះកិត្តិនាមឋិតនៅដដែល អស់លោកអ្នកជាពុទ្ធបរិស័ទទាំងឡាយព្រះបរមសពនៃសម្តេចព្រះសង្ឃរាជនេះជាព្រះសពត្រូវតម្កល់ទុក តាមផ្លូវការរាជរដ្ឋាភិបាលដើម្បីធ្វើទក្ខិណានុប្បទានរៀងរាល់ថ្ងៃតទៅទម្រាំគណៈកម្មការបុណ្យជំនុំគ្នាដោះស្រាយ រៀបចំព្រះរាជពិធីបុណ្យព្រះបរមសពកំណត់យកថ្ងៃណាខែណាទៅជាក្រោយ។

ឥឡូវនេះគណៈកម្មការបុណ្យសពបណ្ដោះអាសន្ន បានព្រមព្រៀងគ្នាកំណត់ យកថ្ងៃ១រោច ខែភទ្របទ ត្រូវនឹងថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ១៩៦៩ ជាកិច្ចធ្វើទក្ខិណានុប្បទានមានទេសនា និងវេរភត្តរៀងរាល់ថ្ងៃដរាបតទៅចំនួន៦ខែ គិតពីខែភទ្របទនេះទៅក្រោមព្រះរាជអធិបតីភាពនៃសម្ដេចព្រះមហាក្សត្រីយានី និងសម្ដេចព្រះប្រមុខរដ្ឋ ។

| | |
|---|---|
| ព្រោះតែខ្លួនឯងគ្មានបរិញ្ញា | ចូលបម្រើការគេរួញរា |
| បានដោយខំបែកញើសហូរហៀរ | ទើបប្រាកដជាបានការធ្វើ ។ |
| ចូលបម្រើការសែនលំបាក | លំបិនឥតស្រាករាល់ទង្វើ |
| ការងារដែលគេដាក់ឱ្យធ្វើ | ដូចមនុស្សមើមើនៅក្មេងខ្ចី ។ |
| មូលហេតុខ្លួនឯងគ្មានវិជ្ជា | ដូច្នេះការងារវានៅថ្មី |
| លំបាកស្ទើរស្លាប់កុំត្អូញអី | ដែលខ្លួនអប្រិយគ្មានសញ្ញាបត្រ ។ |

(ត)៤

# សម្ដេចព្រះសុមេធាធិបតី

# ហួត តាត

# ព្រះសង្ឃរាជគណៈមហានិកាយ

# ព.ស.២៥១៣_គ.ស.១៩៦៩

# ព.ស.២៥១៩_គ.ស.១៩៧៥

ព្រះអង្គប្រសូតនៅថ្ងៃអាទិត្យ ១៥កើត ខែបុស្ស ឆ្នាំរោង ចត្វាស័ក ព.ស.២៤៣៥ គ.ស.១៨៩២ នៅភូមិផ្សារឧដុង្គ ខេត្តកំពង់ស្ពឺ។ បិតានាម ហុក សេង ហៅហួត មាតានាម ង៉ែត។

ព្រះជន្មាយុបាន៧ឆ្នាំ បានទៅរៀនអក្សរសាស្ត្រ លេខនពន្តក្នុងសំណាក់ ព្រះធម្មឃោសាចារ្យ មាស។

ព្រះជន្មាយុ១៣ឆ្នាំ បួសជាសាមណេរ នៅក្នុងសំណាក់ ព្រះធម្មឃោ-សាចារ្យ។ ព្រះអង្គបានសិក្សាព្រះបរិយត្តិធម៌ក្នុងសំណាក់ ព្រះធម្មលិខិត ស៊ូ។

ព្រះជន្មាយុបាន២១វស្សា នៅឆ្នាំជូត ព.ស.២៤៥៦ គ.ស.១៩១២ បានឧបសម្បទាក្នុងពទ្ធសីមាវត្តឧណ្ណាលោមក្នុងសំណាក់សម្តេច ព្រះសង្ឃរាជ ព្រះនាម និល ទៀង ជាព្រះឧបជ្ឈាយ៍ ។

ព្រះជន្មាយុបាន៥៧វស្សា នៅឆ្នាំជូត ព.ស.២៤៩២ គ.ស.១៩៤៨ ព្រះអង្គបានទទួលសមណសក្តិជាព្រះពោធិវង្ស។

ព្រះជន្មាយុបាន៧៣វស្សានៅឆ្នាំរោង ព.ស.២៥០៨ គ.ស.១៩៦៩ ព្រះអង្គបានទទួលសមណសក្តិជាសម្តេចព្រះពោធិវ័ង្ស តាមព្រះរាជក្រឹត្យលេខ ២៤ រ.វ ចុះថ្ងៃទី ២៤ កក្កដា ១៩៦៤។

ព្រះជន្មាយុបាន៧៨វស្សា នៅឆ្នាំរកា ព.ស.២៥១៣ គ.ស.១៩៦៩ ព្រះអង្គបានទទួលសមណសក្តិជាសម្តេចព្រះមហាសុមេធាធិបតី ព្រះសង្ឃនាយក គណៈមហានិកាយ។

ព្រះជន្មាយុ៧៩វស្សានៅឆ្នាំចព.ស.២៥១៤ គ.ស.១៩៧០ ព្រះអង្គបានទទួលសមណសក្តិជាសម្តេចព្រះមហាសុមេធាធិបតីព្រះសង្ឃរាជគណមហានិកាយ ពីឯកឧត្តម ចេង ហេង ប្រធានសភាជាតិ។

ក្នុងឆ្នាំថោះ ព.ស.២៥១៩ គ.ស.១៩៧៥ ព្រះអង្គបានចូលទិវង្គតក្នុងព្រះជន្មាយុ៨៤វស្សា។

ដូច្នេះហើយយើងជាបុត្រខេមរា រៀនចប់កាលណាបានដុះខាត់
ខំប្រឹងគ្រប់គ្នាយកសញ្ញាបត្រ ការងារប្រាកដរង់ចាំហើយ។

ពេជ្រ សំណាង

**ចប់**

# សម្តេចព្រះមហាសុមេធាធិបតី

# ទេព វង្ស

# ព្រះសង្ឃរាជ គណៈមហានិកាយ

ព.ស.២៤៣៤ គ.ស.១៩៩១

ព្រះអង្គប្រសូត នៅថ្ងៃព្រហស្បតិ៍ ១រោច ខែបុស្ស ឆ្នាំវក ចត្វាស័ក ព.ស.២៤៧៦ ត្រូវនឹងថ្ងៃទី១២ខែមករា គ.ស.១៩៣២ នៅភូមិត្រពាំងចក ឃុំជ្រាវ ស្រុកសៀមរាប ខេត្តសៀមរាប។ មាតានាម ប៊ិច អាត់ បិតានាម ទេព ឈិត។

ព្រះជន្មាយុបាន១០ឆ្នាំ នៅឆ្នាំម្សាញ់ ត្រីស័ក ព.ស.២៤៨៥ គ.ស.-១៩៤១ ព្រះមាតាបិតាបាននាំកុមារទេព វង្ស ឱ្យទៅនៅវត្តរាជបូពិ ដើម្បីរៀនអក្សរសាស្ត្រលេខនពន្ធក្រោមការគ្រប់គ្រងរបស់ព្រះគ្រូសមុហ៏-គណ ហ៊ីង ម៉ៅ ចៅអធិការវត្តរាជបូពិ។

ព្រះជន្មាយុបាន១៦ឆ្នាំ នៅឆ្នាំកុរ នព្វស័ក ព.ស.២៤៩១ គ.ស.១៩៤៧ បានបួសជាសាមណេរនៅក្នុងសំណាក់ព្រះគ្រូសមុហ៏គណព្រះគ្រូចៅអធិការវត្តរាជបូពិជាព្រះឧបជ្ឈាយ៏។ ការបួសជាសាមណេរបានត្រឹមតែ៩ខែទេ សូម លាចាកសិក្ខាបទមករកស៊ីចិញ្ចឹមព្រះមាតាវិញ។

ព្រះជន្មាយុបាន២១វស្សានៅឆ្នាំរោងចត្វាស័កព.ស.២៤៩៦គ.ស.១៩៥២ បានទៅបំពេញឧបសម្បទា នៅក្នុងសំណាក់ព្រះគ្រូសមុហ៏គណ ហ៊ីង ម៉ៅ ជាព្រះឧបជ្ឈាយ៏នៅក្នុងពទ្ធសីមាវត្តរាជបូពិ។

ព្រះជន្មាយុបាន២៥វស្សា នៅឆ្នាំវក ព.ស.២៥០០ គ.ស.១៩៥៦ ព្រះគ្រូសមុហ៏គណហ៊ីងម៉ៅ បានតែងតាំងភិក្ខុទេពវង្សឱ្យធ្វើជាគ្រូសូត្រជំនួយការ។

ព្រះជន្មាយុបាន៤៨វស្សា នៅពេលប្រជាជនខ្មែរបានរួចផុតពី របប ប៉ុល

៣ត ព្រះអង្គបាននិមន្តមកបួសឡើងវិញ នៅថ្ងៃ១៣រោច ខែភទ្របទ ឆ្នាំមមែឯកស័ក ព.ស.២៥២៣ ត្រូវនឹងថ្ងៃទី១៩ ខែកញ្ញា គ.ស.១៩៧៩។ ពេលបួសរួច ព្រះឧបជ្ឈាយ៍បានប្រកាសនៅក្នុងជំនុំសង្ឃថា ភិក្ខុ ទេព វង្ស ឱ្យឡើងឋានានុក្រមមានឋានន្តរសក្តិជាព្រះគ្រូវិន័យធរ។

ព្រះជន្មាយុបាន៦០វស្សា ព្រះអង្គបានទទួលសមណសក្តិ ជាសម្តេចព្រះមហាសុមេធាធិបតីព្រះសង្ឃនាយក គណៈមហានិកាយ នៅថ្ងៃសុក្រ ២កើត ខែកត្តិក ឆ្នាំមមែត្រីស័កព.ស.២៥៣៥ ត្រូវនឹងថ្ងៃទី ៨វិច្ឆិកា គ.ស.១៩៩១។

នៅក្នុងព្រះជន្មាយុ៦០វស្សានេះដែរ ព្រះអង្គបានទទួលសមណសក្តិជាសម្តេចព្រះមហាសុមេធាធិបតីព្រះសង្ឃរាជគណៈមហានិកាយនៅថ្ងៃសុក្រ ៩កើតខែកត្តិក ឆ្នាំមមែ ត្រីស័ក ព.ស.២៥៣៥ ត្រូវនឹងថ្ងៃ១៥ ខែវិច្ឆិកា គ.ស.១៩៩១។

**តើភាគបានក្រហមគឺជាអ្វី?**

| | |
|---|---|
| មានមនុស្សក្មេងចាស់ទាំងប្រុសស្រី | មានតាមានយាយច្រើនពណ្ណរាយ |
| រស់ក្នុងគ្រួសារគ្មានរីករាយ | មានទុក្ខផ្សំរំលាយព្រោះខ្លួនក្រ។ |
| មានជនទុគិតគ្មានទីពឹង | ជរាខំប្រឹងទាំងត្រដរ |
| រស់ទាំងខ្វះខាតគ្មានអង្ករ | ខំប្រឹងត្រាច់ចរទោះជិតឆ្ងាយ។ ត(១) |

# ប្រវត្តិរូបសង្ខេប

# នៃ

# សម្តេចព្រះសុគន្ធាធិបតី បញ្ញាសីលោ ប៉ាន

# គណៈធម្មយុត្តិកនិកាយ

# ព.ស.២៤០១-២៤៣៦

# គ.ស.១៨៥៧-១៨៩៣

សម្តេចព្រះសុគន្ធាធិបតី **ប៉ាន** សម្តេចសម្ភព នៅថ្ងៃព្រហស្បតិ៍ ១រោច ខែកត្តិកឆ្នាំច អដ្ឋស័ក ព.ស.២៣៧០ គ.ស.១៨២៦ ច.ស.១១៨៨ នៅភូមិព្រែកព្រះស្តេច ខេត្តបាត់ដំបង។ ឯស្រុកកំណើតមាតាបិតានៃសម្តេចនៅភូមិស្មោង ខេត្តកំពង់ធំ ។

សម្តេចព្រះសុមេធាធិបតី សង្ឃនាយក ប៉ាន ព្រះអង្គទ្រង់សោយទិវង្គត នៅថ្ងៃសៅរ៍ ៤រោច ខែមាឃ ឆ្នាំម្សាញ់បញ្ចស័ក ព.ស.២៤៣៧ ម.ស.-១៨១៥ ក្នុងព្រះជន្ម គម្រប់៦៧វស្សា។

| | |
|---|---|
| ខ្លួនកាន់តែចាស់ភ្នែកងងឹត | រោគារួបរឹតពេញរាងកាយ |
| រស់នៅជាតិនេះមិនសប្បាយ | គ្មានលុយចំណាយថ្នាំពេទ្យផង ។ |
| គន់មើលទៅផ្ទះក៏បាក់បែក | ដំបូលរហែកសែនសៅហ្មង |
| ពេលណាភ្លៀងធ្លាក់មកម្តង១ | រងាកន្លងពេញគេហា ។ |
| តើកាកបាទក្រហមគឺជាអ្វី? | ហើយមានអត្ថន័យថ្លៃយ៉ាងណា |
| ដូច្នេះយើងជាបុត្រខេមរា | ស្វះស្វែងសិក្សាឱ្យបានយល់ ។ត(២) |

# ប្រវត្តិសង្ខេប

# នៃ

# សម្ដេចមង្គលទេពាចារ្យ ព្រះនាម អៀម

# ព.ស.២៤៣៨-២៤៦៥

# គ.ស.១៨៩៤-១៩២២

សម្ដេចសម្ភព នៅថ្ងៃអាទិត្យ ខែផល្គុន ឆ្នាំរកាឯកស័ក ព.ស.២៣៩៣ គ.ស.១៨៤៩ ម.ស.១៧៧១ ច.ស.១២១១ នៅភូមិព្រៃពួច ស្រុកសំរោង-ទង ខេត្តកំពង់ស្ពឺ។ មាតានាម អ៊ុក បិតានាម មុឹង។

សម្ដេចព្រះមង្គលទេពាចារ្យព្រះនាម អៀមបានទិវង្គតនៅថ្ងៃព្រហស្បតិ៍ ១ រោច ខែមិគសិរ ឆ្នាំចចត្វាស័ក ព.ស. ២៤៦៦ គ.ស.១៩២២ ម.ស. ១៨៤៤ ច.ស.១២៨៤ វេលាម៉ោង៩ព្រឹក ក្នុងព្រះជន្ម៧៤វស្សា។

| | |
|---|---|
| កាកបាទក្រហមគឺអង្គការ | មានក្នុងរដ្ឋានៃយើងផ្ទាល់ |
| ទីណាដែលមានក្ដីកង្វល់ | អំណោយទៅដល់នៅទីនោះ។ |
| សំណាងបានកាកបាទក្រហម | កម្ពុជាអមបានទម្លុះ |
| ក្ដីទុក្ខទាំងឡាយរសាយជ្រុះ | ពីគ្រួសារនោះគ្រប់នាទី។ |
| លោកជំទាវលោកតែងខំខ្វល់ខ្វាយ | មិនថាជិតឆ្ងាយទីជលធី |
| គឺលោកជំទាវប៊ុនរ៉ានី | មានគ្រប់ទិសទីជួយអ្នកក្រ។ ត(៣) |

# ប្រវត្តិរូបសង្ខេប

# នៃ

# សម្តេចមង្គលទេពាចារ្យ ព្រះនាម ស៊ុក

# គណៈធម្មយុត្តិកនិកាយ

# ព.ស.២៤៦៦-២៤៨៥

# គ.ស.១៩២៣-១៩៤២

សម្តេចសម្ភពនៅថ្ងៃព្រហស្បតិ៍ ខែមាឃ ឆ្នាំរកា ត្រីស័ក ព.ស.២៤០៥ គ.ស.១៨៦១ ម.ស.១៧៨៣ ច.ស.១២២៣ ក្នុងស្រុកនគររាជ ប្រទេសថៃ បិតានាម អៀម មាតានាម ម៉ៅ មាតាបិតាចុះមករស់នៅភូមិរុន ស្រុកក្រឡាញ់ ខេត្តបាត់ដំបងវិញ កាលខេត្តនេះនៅក្រោមអំណាចប្រទេសថៃ។

សម្តេចព្រះមង្គលទេពាចារ្យព្រះនាម ស៊ុក ព្រះអង្គបានចូលទិវង្គតនៅថ្ងៃព្រហស្បតិ៍ ១រោច ខែពិសាខ ឆ្នាំមមី ចត្វាស័ក ព.ស.២៤៨៦ គ.ស.-១៩៤២ ម.ស.១៨៦៤ ច.ស.១៣០៤ វេលាម៉ោង១១និង១៥នាទីអធ្រាត្រ ដោយជរាពាធ ក្នុងព្រះជន្ម៨២វស្សា។

| | |
|---|---|
| ទីណាមានទុក្ខមានកាកបាទ | ខ្ទះខ្ទែងសង្ខាតកែលម្អ |
| គ្រប់ទីដែលមានជនក្រីក្រ | មានទាំងអង្គុរលុយត្រីប្រៃ។ |
| ទីណាមានអ្នកផ្ទុករោគអេដស៍ | ឃើញច្បាស់ក្រឡែតយើងសព្វថ្ងៃ |
| មានសប្បុរសធម៌មិដ៏ថ្លាថ្លៃ | លោកជំទាវកែច្នៃគ្រប់វេលា។ត(៤) |

# ប្រវត្តិរូបសង្ខេប
# នៃ
# សម្តេចសុធម្មាធិបតី ព្រះនាម អ៊ុង ស្រី
# គណៈធម្មយុត្តិកនិកាយ

ព.ស.២៤៨៥-២៤៩៨

គ.ស.១៩៤២-១៩៥៦

សម្តេចសម្ភពនៅថ្ងៃព្រហស្បតិ៍ ១៣កើត ខែមិគសិរ ឆ្នាំមមី ទោស័ក ព.ស.២៤១៤ គ.ស.១៨៧០ ម.ស.១៧៩២ ច.ស.១២៣២ បិតានាម អ៊ុង មាតានាម ណើ ស្រុកកំណើតនៅឃុំគោកត្រប់ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។

សម្តេចព្រះសុមេធាធិបតីព្រះសង្ឃនាយកបានចូលទិវង្គត នៅថ្ងៃចន្ទ ៣ រោច ខែមាឃ ឆ្នាំវក អដ្ឋស័ក ព.ស.២៥០០ ត្រូវនឹងថ្ងៃទី៣០ ខែមករា ឆ្នាំ១៩៥៦ ។

ពេលលោកដឹងហើយតែងចុះជួយ គ្រួសារណាមួយដែលវេទនា
លំបាកតោកយ៉ាកសែនគ្រាំគ្រា មានជនកំព្រាអនាថា ។
ជួយនេះគឺដោយក្តីអាណិត អាណោចដួងចិត្តសែនខ្លោចផ្សា
ពេលឃើញកូនចៅបុត្រខេមរា រងទុក្ខអន្ធការសែនដុកដាន់ ។
លោកជួយដោយក្តីស្រឡាញ់ស្មោះ គ្រប់គ្នាទាំងអស់មិនប្រកាន់
ប្រៀបបានរូបលោកជាដួងចន្ទ ជះរស្មីកាន់ភពផែនដី ។

ត( ៥)

# សម្តេចព្រះសុធម្មាធិបតី ព្រះសង្ឃរាជថ្នាក់ទី២

# គណៈធម្មយុត្តិកនិកាយ

# ព្រះនាម ឥន្ទញ្ញាណោ ភុល ទេស

ព.ស.២៤៩៨-២៥០៩

គ.ស.១៩៥៦-១៩៦៦

សម្តេចទ្រង់សម្ភពនៅថ្ងៃអាទិត្យទី១៥កើតខែស្រាពណ៍ ឆ្នាំថោះ ត្រីស័ក ព.ស.២៤៣៤ គ.ស.១៨៩១ ក្នុងភូមិ កោះរះ សង្កាត់កោះរះ ស្រុកល្វាឯម ខេត្តកណ្តាល ។ បិតានាម ភុល មាតានាម ទៃ។

សម្តេចទ្រង់សោយទិវង្គត ក្នុងព្រះជន្មគម្រប់៧៥វស្សា។

យល់ដឹងសុខទុក្ខអ្នកគ្រប់គ្នា ខំប្រឹងពុះពារយ៉ាងឃ្មាតខ្មី
លំបាកយ៉ាងណាមិនហ៊ានស្តី អាសូរប្រណីរីតទ្រៃឡើង។
ដូច្នេះខ្ញុំបាទជួសកូនខ្មែរ សោមនស្សម្ល៉េះទេនឹងតបគុណ
នៃអំពើល្អច្រើនពេកពន់ ដ៏វិសេសលន់គុណបារមី។
ខ្ញុំសូមបួងសួងដល់ទេវតា មានទិព្វនេត្រាទាំងប្រុសស្រី
សូមជួយប្រសិទ្ធិពរសុខសួស្តី ចម្រើនជោគជ័យក្នុងគ្រួសារ។
នៃលោកជំទាវប៉ុនវ៉ានី មានភគិនីកូនប្រសា
កូនចៅតូចធំគ្រប់អាត្មា សូមសុខថ្លៃថ្លាតរៀងទៅអ្ហើយ។

ពេជ្រ សំណាង

**ចប់**

# សម្តេចព្រះសុធម្មាធិបតី ព្រះសង្ឃរាជ

# នេព ល្បឿង

# គណៈធម្មយុត្តិកនិកាយ

ព.ស.២៥០៩-២៥១៩

គ.ស.១៩៦៦-១៩៧៥

ព្រះអង្គសម្ភពពីថ្ងៃទី២-២-១៨៨៣ ឆ្នាំមមែ ព.ស.២៤២៧ នៅភូមិរនាមត្នោត ឃុំអង្គប្រាសាទ ស្រុកគីរីវង្ស ខេត្តតាកែវ បិតានាម ង៉ែត មាតានាម ទូត អុង។

ព្រះអង្គបានសោយទិវង្គតនៅថ្ងៃទី១៥ ខែមេសា គ.ស.១៩៧៥ ក្នុងឆ្នាំថោះ ព.ស.២៥១៤ ក្នុងព្រះជន្ម៩៣ឆ្នាំនៅវត្តបទុមវតី។

# ព្រះសង្ឃនាយក ស្តីទី

# ហ៊ី ជា

# គណៈធម្មយុត្តិកនិកាយ

សម្តេចសង្ឃនាយកស្តីទី ហ៊ី ជា បានសម្ភពនៅថ្ងៃព្រហស្បតិ៍ ១៥កើត ខែអស្សុជឆ្នាំម្សាញ់សប្តស័កព.ស.២៤៤៧ គ.ស.១៩០៥ក្នុងសង្កាត់ស្វាយធំ ស្រុកស្វាយរៀង ខេត្តស្វាយរៀង ។

ព្រះអង្គចូលទិវង្គតនៅ គ.ស.១៩៨៦ ព្រះជន្ម៨២ឆ្នាំ នៅភូមិកំពង់ភ្នំ ក្នុងស្រុកលើកដែក ខេត្តកណ្តាល។

# សម្តេចព្រះសុគន្ធាធិបតី
# ប៊ូរ គ្រី
# ព្រះសង្ឃរាជ គណៈធម្មយុត្តិកនិកាយ

ព្រះអង្គប្រសូតនៅថ្ងៃព្រហស្បតិ៍ ១៣រោច ខែបុស្ស ឆ្នាំវក ព.ស. ២៤៨៨ ត្រូវនឹងថ្ងៃទី១១ ខែមករា ឆ្នាំ១៩៤៤ នៅក្នុងឃុំស្វាយប៉ោ ស្រុកសង្កែ ខេត្តបាត់ដំបង។ ព្រះមាតានាម ជា ជួន ព្រះបិតានាម ប៊ូរ វ៉ាន។

នៅថ្ងៃសៅរ៍ ១កើត ខែមិគសិរ ឆ្នាំមមែ ព.ស.២៥៣៥ ត្រូវនឹងថ្ងៃទី៧ ខែធ្នូ គ.ស.១៩៩១ សម្តេចព្រះនរោត្តមសីហនុ ទ្រង់បានប្រទានព្រះបរមងារជាសម្តេចព្រះសង្ឃរាជ គណៈធម្មយុត្តិកនិកាយ។[១៩]

-មនុស្សដែលចាស់ចិត្តចាស់គំនិត

ចាស់ពិតគិតគួរត្រឹមត្រូវ!

-បន្តដល់កូនចៅ

កេរ្តិ៍ឈ្មោះនៅស្លាប់ដូចរស់!

-បើចំណេះទាបត្រូវខំប្រឹង

ក្រោកឡើយសន្ទឹងតាំងប្រយុទ្ធ!

ពេជ្រ សំណាង

១៩-ភិក្ខុបញ្ញាវិមលោ លឹម-វាសនា ព្រះរាជជីវប្រវត្តិសម្តេចព្រះសង្ឃរាជ គណៈមហានិកាយ និងគណៈធម្មយុត្តិកនិកាយ ឆ្នាំ២០០៤។

# ធម៌សូត្រមន្តរំដោះគ្រោះនិងលើករាសី

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ៗ ៣ចប់

ពុទ្ធំ សរណំ គច្ឆាមិៗ

ធម្មំ សរណំ គច្ឆាមិៗ

សង្ឃំ សរណំ គច្ឆាមិៗ

ទុតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិៗ

ទុតិយម្បិ ធម្មំ សរណំ គច្ឆាមិៗ

ទុតិយម្បិ សង្ឃំ សរណំ គច្ឆាមិៗ

តតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិៗ

តតិយម្បិ ធម្មំ សរណំ គច្ឆាមិៗ

តតិយម្បិ សង្ឃំ សរណំ គច្ឆាមិៗ

តស្ស តេសី សន្តោ យថា គន្ធា មារសេនា ជលា យន្តិ មអឧៗ

-ព្រះអាទិត្យ ឧម គ្រោះជោគ គ្រោះជាំ គ្រោះខែ គ្រោះឆ្នាំ គ្រោះចាប់ គ្រោះចង គ្រោះកាច ចេញទៅ សុខជាចូលមក រក្សា រាសី សព្វទុក្ខ សព្វសោក សព្វរោគ សព្វភ័យ សព្វជំងឺ គ្រោះកាចចង្រៃ វិនាសាយ ជយ ជយោ សព្វលាភំ ភវន្តុតេ តេ ត្វំ រក្ខិតោ សន្តោ វិមុត្តោ ចតុរំ ភវំ ។

-ព្រះច័ន្ទ ព្រះអង្គារ ព្រះពុធ ព្រះហស្បតិ៍ ព្រះសុក្រ ព្រះសៅរ៍ ឧមគ្រោះជោគគ្រោះជាំ....។

-ព្រះរាហូ ព្រះកេតុ ព្រះកាល ព្រះភូមិ ឧម គ្រោះជោគ គ្រោះជាំ.......។ ព្រះឋាន ព្រះនព្វគ្រោះ ព្រះបាទទសមុខ ឧម គ្រោះជោគ គ្រោះជាំ......។

ចេត្រ ពិសាខ ជេស្ឋ អាសាធ ឧមគ្រោះជោគ គ្រោះជាំ ............។

ស្រាពណ៍ ភទ្របទ អស្សុជ កត្តិក ឧម គ្រោះជោគ គ្រោះជាំ............។

មិគសិរ បុស្ស មាឃ ផល្គុន ឧម គ្រោះជោគ គ្រោះជាំ.............។

ជូត ឆ្លូវ ខាល ថោះ ឧម គ្រោះ ឧម គ្រោះជោគ គ្រោះជាំ គ្រោះខែ គ្រោះឆ្នាំ គ្រោះចាប់ គ្រោះចង គ្រោះកាច ចេញទៅ សុខជាចូលមក រក្សារាសី សព្វទុក្ខសព្វសោក សព្វរោគ សព្វភ័យ សព្វជំងឺ គ្រោះកាច ចង្រៃ វិនាសាយ ជយ ជយោ សព្វលាភំ ភវន្តុតេ តេ ត្វំ រក្ខិតោ សន្តោ វិមុត្តោ ចតុរិ ភវន្តុ តេ ភគវន្តំ សរណំ គច្ឆាមិ ។

រោង ម្សាញ់ មមី មមែ ឧម គ្រោះ ជោគ គ្រោះជាំ គ្រោះខែ គ្រោះឆ្នាំ គ្រោះចាប់ គ្រោះចង គ្រោះកាច ចេញទៅ សុក្រជាចូលមក រក្សារាសី សព្វទុក្ខ សព្វសោក សព្វរោគ សព្វភ័យ សព្វជំងឺ គ្រោះកាចចង្រៃ វិនាសាយ ជយ ជយោ សព្វលាភំ ភវន្តុ តេ តេត្វំ រក្ខិតោ សន្តោ វិមុត្តោ ចតុរិ ភវន្តុ តេ ភគវន្តំ សរណំ គច្ឆាមិ ។

វក រកា ច កុរ ឧម្ម គ្រោះជោគ គ្រោះជាំ គ្រោះ ខែ គ្រោះឆ្នាំ.....។

(អាចដកសូធ្យម្តងមួយថ្ងៃ១ ម្តងមួយខែ១ ម្តងមួយឆ្នាំ១ក៏បាន ឬបី១ក៏បាន)(ត្រង់ចន្លោះចុច១ឱ្យថាបន្តដូចខាងលើ១គ្នា។

# ធម៌ចម្លងគ្រោះ

អាទិត្យ តស្មឹ ច ពុទ្ធគុណំ ច ធម្មគុណំ ច សង្ឃគុណំ សព្វទុក្ខ សព្វសោក សព្វរោគ សព្វភ័យ សព្វជំងឺ គ្រោះកាចចង្រៃ វិនាសាយ ជយ ជយោ សព្វលាភំ ភវន្តុ តេ តេត្វំ រក្ខិតោ សន្តោ វិមុត្តោ ចតុរិ ភវិ ។

ចន្ទ អង្គារ ពុធ តស្មឹ ច ពុទ្ធគុណំ............................... ។

ព្រហស្បតិ៍ សុក្រ សៅរ៍ តស្មឹ ច ពុទ្ធគុណំ .................... ។

ព្រះរាហូ ព្រះកេតុ ព្រះកាល ព្រះភូមិ តស្មឹ ច ពុទ្ធគុណំ ច ធម្មគុណំ ច សង្ឃគុណំ សព្វទុក្ខ សព្វសោក សព្វរោគ សព្វភ័យ សព្វជំងឺ គ្រោះកាចចង្រៃ វិនាសាយ ជយ ជយោ សព្វលាភំ ភវន្តុតេ តេ ត្វំ រក្ខិតោ សន្តោ វិមុត្តោ ចតុរិ ភវន្តុ តេ ភគវន្តំ សរណំ គច្ឆាមិ ។

ព្រះឋាន ព្រះនព្វគ្រោះ ព្រះបាទទសមុខ តស្មឹ ច ពុទ្ធគុណំ ....... ។

ចេត្រ ពិសាខ ជេស្ឋ អាសាធ តស្មឹ ច ពុទ្ធគុណំ ...................... ។

ស្រាពណ៍ ភទ្របទ អស្សុជ កត្តិក តស្មឹ ច ពុទ្ធគុណំ ................. ។

មិគសិរ បុស្ស មាឃ ផល្គុន តស្មឹ ច ពុទ្ធគុណំ ....................... ។

ជូត ឆ្លូវ ខាល ថោះ តស្មឹ ច ពុទ្ធគុណំ.................................. ។

រោង ម្សាញ់ មមី មមែ តស្មឹ ច ពុទ្ធគុណំ............................ ។

វក រកា ច កុរ តស្មឹ ច ពុទ្ធគុណំ...................................... ។[២០]

> នារីបីដូចជាឆ្នាំងខ្លាញ់បុរសបីដូចភ្លើងហេតុនោះបានជាអ្នកប្រាជ្ញលោកមិនតម្កល់ទុកឆ្នាំងខ្លាញ់និងភ្លើងក្នុងទីជិតគ្នាទេ។
>
> ទស្សនៈ ភិក្ខុ ប៉ាង ខាត់ វីរិយបណ្ឌិតោ

២០-គហិប្បតិបត្តិ ឃរាវាសធម៌ ទំព័រ៨៨-៩០ ផ្សាយចេញពីអាស្រមឧត្តម ព.ស.២៥៤៧។

# ធម៌មហាមេឃ

ឯវមេ សុត្តំ ឯកំ សមយំ ភគវា រាជគហេ វិហរតិ គិជ្ឈកូ ដេ បព្វ ជិតេ តេនខោ បន សមយេ ន មហាមេឃោ អហោសិ៕ តត្រ ខោ ភគវា ភិក្ខូ ភគវតោ បច្ចស្សោ សុំ ភគវា ឯត ទវោ ច!

១~បុរត្ថិមស្មឹ ភិក្ខវេ ទិសា ភាគេ ចត្តារោ យក្ខា មហាយក្ខា អធិបតិនោ សេយ្យថីទំ ទីឃោ ច សុរត្តោ ច បន្ថតោ ច ករណីតោ ច ឯតេ ចត្តារោ យក្ខា មហាយក្ខា ពុទ្ធេ បសន្នា ធម្មេ បសន្នា សង្ឃេ បសន្នា ពុទ្ធាសគារវា ធម្មាសគារវា សង្ឃាសគរវា តុម្ហំ វន្ទាមិ ទីឃញ្ច សរត្តញ្ច បន្ថតញ្ច ករណីតញ្ច យក្ខញ្ច យក្ខសេដ្ឋញ្ច យក្ខសម្ភារគមញ្ច យក្ខសន្និបាតញ្ច ឥមំ រក្ខំ សំវ ហន្តុ មាតេកោជីវហោថេតុ មនុស្សោវា មនុស្សីវា អមនុស្សោវ អមនុស្សីវា យក្ខោវា យក្ខីវា ភូតោវា ភូតីវា បេតោវា បេតីវា កម្ភណ្ឌោវា កម្ភណ្ឌីវា បីសាចោវា បីសាចីវា គន្ធព្វោ~វា គន្ធព្វីវា អសុរោវា អសុរីវា នាគោវា នាគីវា គ្រុឌ្ឍោវា គ្រុឌ្ឍីវា កិណ្ណរោវា កិណ្ណរីវា គច្ឆន្តំវា ចិត្តំវា

និសន្តំវា និមន្តំវា ឋាតិរត្តំវា បមត្តំវា អបមត្តំវា រត្តំវា ទិវំវា សទាៗ តុម្ហេ អនុរក្ខន្តុ មហាយក្ខាតិ។

២_ទក្ខិណស្មឹ ភិក្ខវេ ទិសា ភាគេ ចត្តារោ យក្ខា មហាយក្ខា អធិបតិនោ សេយ្យថីទំ កាលោ ច ឧបកាលោ ច សុសិមោ ច ភិម្ហសេនោ ច ឯតេ ចត្តារោ យក្ខា មហាយក្ខា ពុទ្ធេ បសន្នា ធម្មេ បសន្នា សង្ឃេ បសន្នា ពុទ្ធា សគារវា ធម្មា សគារវា សង្ឃា សគារវា តុម្ហំវន្ទាមិ កាលញ្ច ឧបកាលញ្ច សុសិមញ្ច ភុម្ហសេដ្ឋញ្ច យក្ខញ្ច យក្ខសេដ្ឋញ្ច យក្ខសម្ហាគមញ្ច យក្ខសន្និបាតញ្ច ឥមំ រក្ខំ សំវិទហន្តុ មាតេកោ ជី វហោថតុ មនុស្សោវ មនុស្សីវា ..........។ល។

៣_បច្ឆិមស្មឹ ភិក្ខវេ ទិសា ភាគេ ចត្តារោ យក្ខា មហាយក្ខា អធិបតិនោ សេយ្យថីទំ ហារោ ច ហារិយោ ច មន្ថលោ ច មន្ថលសេដ្ឋោ ច ឯតេ ចត្តា រោយក្ខា មហាយក្ខា ពុទ្ធេ បសន្នា ធម្មេ បសន្នា សង្ឃេ បសន្នា ពុទ្ធា សគារវា ធម្មា សគារវា សង្ឃា សគារវា តុម្ហំវន្ទាមិ ហរញ្ច ហារិយញ្ច មន្ថលញ្ច មន្ថលសេដ្ឋញ្ច យក្ខញ្ច យក្ខសម្ហាគមញ្ច យក្ខសន្និបាតញ្ច ឥមំ រក្ខំ សំវទហន្តុ

មាតេកោ ជីវហោថេតុ មនុស្សោវ មនុស្សីវា អមនុស្សោវ អមនុស្សី យក្ខោវា យក្ខីវា ភូត្តោវា ភូត្តីវា....................។ល។

៤-ឧត្តរិមស្មឹ ភិក្ខវេ ទិសា ភាគេ ចត្តារោ យក្ខា មហាយក្ខា អធិបតិនោ សេយ្យថីទំ កុវេរោ ច ធត្តរដ្ឋោ ច វិរុឡ្ហកោ ច វិរូបក្ខោ ច ឯតេ ចត្តារោ យក្ខា មហាយក្ខា ពុទ្ធេ បសន្នា ធម្មេ បសន្នា សង្ឃេ បសន្នា ពុទ្ធា សគារវា ធម្មា សគារវា សង្ឃា សគារវា តុម្ហំ វន្ទាមិ កុវេរញ្ច ធតរដ្ឋញ្ច វិរុឡ្ហកញ្ច វិរូបក្ខញ្ច យក្ខញ្ច យក្ខសេដ្ឋញ្ច យក្ខសម្មាគមញ្ច យក្ខសន្និបាតញ្ច ឥមំ រក្ខំ សំវទហន្តុ មាតេ កោជីវហោថេតុ មនុស្សោវា មនុស្សី-វា ....................។ល។

៥-ហេដ្ឋិមស្មឹ ភិក្ខវេ ទិសា ភាគេ ចត្តារោ នាគា មហានាគា អធិបតិនោ សេយ្យថីទំ វរុណ្ណោ ច វរុណសេដ្ឋោ ច គម្ភសេដ្ឋោ ច ឯតេ ចត្តារោ នាគា មហានាគា ពុទ្ធេ បសន្នា ធម្មេ បសន្នា សង្ឃេ បសន្នា ពុទ្ធា សគារវា ធម្មា សគារវា សង្ឃា សគារវា តុម្ហំ វន្ទាមិ វរុណញ្ច វរណសេដ្ឋញ្ច គម្ភសេដ្ឋញ្ច នាគញ្ច

នាគ្គសម្ហាគមញ្ច នាគ្គសន្និបាតញ្ច ឥមំ រក្ខំ សំវទហន្តុ មាតេកោជី វហោតុ មនុស្សោវា មនុស្សីវា........ខលខ

៦~ឧប្បរិមស្មឹ ភិក្ខវេ ទិសា ភាគេ ចត្តារោ ទេវា មហាទេវា អធិបតិនោ សេយ្យថីទំ ចន្ទោ ច សុរិយោ ច ឥន្ទោ ច ព្រហ្មោ ច ឯតេ ចត្តារោ ទេវា មហាទេវា ពុទ្ធេ បសន្នា ធម្មេ បសន្នា សង្ឃេ បសន្នា ពុទ្ធា សគារវា ធម្មា សគារវា សង្ឃា សគារវា តុម្ហំ វន្ទាមិ ចន្ទញ្ច សុរិយញ្ច ឥន្ទញ្ច ព្រហ្មញ្ច ទេវញ្ច ទេវសេដ្ឋញ្ច ទេវកសម្ហាគមញ្ច ទេវកសន្និបាតញ្ច ឥមំ រក្ខំ សំវទហន្តុ មាតេ កោជី វហេថេតុ មនុស្សោវា មនុស្សីវា អមនុស្សោវា អមនុស្សីវា យក្ខោវា យក្ខីវា ភូត្តោវា ភូត្តីវា បេត្តោវា បេត្តីវា គម្ភណ្ឌោវា គម្ភណ្ឌីវា បីសាចោវា បីសាចីវា គន្ធព្វោវា គន្ធព្វីវា អសុរោវា អសុរីវា នាគ្គោវា នាគ្គីវា គ្រុឡ្ហោវា គ្រុឡ្ហីវា កិណ្ណរោវា កិណ្ណរីវា គច្ឆន្តំវា ចិត្តំវា និសន្តំវា និមន្តំវា សុត្តំវា ជាតរន្តំវា បមត្តំវា អបមត្តំវា រតឹវា ទីវំវា សទាៗ តុម្ហេ អនុរក្ខន្តុ មហាទេវាតិខ ឥទម្ហវោច ភគវា អត្តមនាតេ ភិក្ខូ ភគវតោ ភាសិតំ អភិនន្ទុន្តិ បិសច្ចរិត្តំ មហាមេឃោ និដ្ឋិតោខ[21]

ឥតិបិសោ ភគវាថាំងធិន ថាំងឱិន ថាំងព្រះឥន្ទ្រ ថាំងព្រះព្រហ្ម ថាំងព្រះកាល ថាំងព្រះចតុលោកបាល ថាំងព្រះយមរាជ ថាំងព្រះយមកាល ថាំងស៊ី ថាំងព្រះពុទ្ធគុន្ទី ថាំងព្រះពុទ្ធគុណ្ណុំ ថាំងព្រះធរណី សាន យុ ដៃ ហៃ មឿត តង ណេះ តង លះ តង ចាន់ តងព្រះកណេះតងព្រះកណៃ តង ថំ ព្រះក្រក់ ទូដៃ៧ ខា ព្រះចៅខ ហៃមឿ ថៃ ចប៉ុងខុន ពុទ្ធោ ក្រាបក្រាយ ធម្មោ ក្រាបក្រាយ សង្ឃោ ក្រាបក្រាយ ពុទ្ធោ កម្ចាត់ ធម្មោ កម្ចាត់ សង្ឃោ កម្ចាត់ ពុទ្ធោ កម្ចាយ ធម្មោ កម្ចាយ សង្ឃោ កម្ចាយ ។

ពុទ្ធោ រលាយ ធម្មោ រលាយ សង្ឃោ រលាយ

ពុទ្ធោ ចាំងងាំង ធម្មោ ចាំងងាំង សង្ឃោ ចាំងងាំង

ពុទ្ធោ រម្ងាប់ ធម្មោ រម្ងាប់ សង្ឃោ រម្ងាប់

ពុទ្ធោ ថាត់ ថាយ ធម្មោ ថាត់ ថាយ សង្ឃោ ថាត់ ថាយ

ម ឡ ខណ្ឌ នមោ ពុទ្ធាយ ន ម អ ឧ បរមំ សញ្ញំ។

សាវំ គុណំ វិជ្ជាពលំ ដេជ្ជំ វិរយំ សទ្ធិ កម្មំ សច្ចំ និព្វានំ មុខំ គុយ្យហកំ ទានំ សិលំ នេខំ បុញ្ញំ ភាព្យំ តប្បំ យស្សំ សារិរូប្បំ ចតុវិសន្តិ ទេសនាឯវំ សហមន្តោ ចេត្តព្វំ មេ ស នមោ ពុទ្ធីស ស នមោ ធម្មីស ស នមោ សង្ឃីស សសេយ្យ ទី ទំ ហុលោ ៗ ស្វាហាយ ។

---

២១-ប្រជុំធមិរំដោះគ្រោះទាំង១២ឆ្នាំ ទំព័រ៨០-៨៤ បោះពុម្ពផ្សាយចេញពីតូបលេខ៦៦ ផ្សារអូរឬស្សី ព.ស.២៥៥២ គ.ស.១៩៩៨។

ឥន្ទ សាវិ ទេវា សាវិ ចក្កវត្តិ មហា ចក្កវត្តិ ព្រហ្ម សាវិ មហាព្រហ្ម សាវិ ឥសី សាវិ មហា ឥសី សាវិ មុនី សាវិ មហាមុនី សាវិ សប្បុរិស សាវិ មហា សប្បុរិស សាវិ បច្ចេកពុទ្ធ សាវិ អរហន្ត សាវិ សព្វរិទ្ធី តេជះ តារានំ សព្វលោកា កិរិយានំ សព្វលោកា បតិយានំ ឯតេ ន សច្ចវជ្ជេន នមាមិហំ ន សាវត្តិហន្តុ ស្វាហាយ ស នមោ ពុទ្ធីស ស នមោ ធម្មីស ស នមោ សង្ឃីស សសេយ្យ ទីទំ ហុលោ ៧ ស្វាហាយ ។

ឥន្ទគុណ្ណំ ឥន្ទវិជ្ជា ឥន្ទពលំ ឥន្ទតេជំ ឥន្ទវីរយំ ឥន្ទសិទ្ធី ឥន្ទ កម្មំ ឥន្ទធម្មំ ឥន្ទ សច្ចំ ឥន្ទនិព្វានំ ឥន្ទមុខំ ឥន្ទគុយហកំ ឥន្ទទានំ ឥន្ទសីលំ ឥន្ទ បញ្ញា ឥន្ទនេខំ ឥន្ទបុញ្ញំ ឥន្ទភាព្យំ ឥន្ទតប្បំ ឥន្ទយសំ ឥន្ទសារិ ឥន្ទរូបំ ឥន្ទសុខំ ទេ្វសុខំ ចក្កវត្តិសុខំ ព្រហ្ម សុខំ មហាព្រហ្មសុខំ ឥសីសុខំ មហាឥសីសុខំ មុនីសុខំ មហាមុនីសុខំ សប្បុរិសសុខំ មហាសប្បុរិសសុខំ បច្ចេកពុទ្ធសុខំ អរហន្តសុខំ សព្វរិទ្ធី តេជះ តារានំ សព្វលោកា បត្តិយានំ ឯតេ ន សច្ចវជ្ជេន នមាមិហំ នសាវត្តិ ហោន្តុ ស្វាហាយ ស នមោ ពុទ្ធីស ស នមោ ធម្មីស ស នមោ សង្ឃីស សសេយ្យ ទីទំ ហុលោ៧ ស្វាហាយ ។

ឥតិបិសោ ភគវា ព្រះអាទិត្យ សោយ អាយុដៃ ហុកសិបពីរ រក្សានុប្បទ្រី ព្រះគុណ កុសលសម្បន្នោ សព្វទុក្ខំ វិនាសន្តិ។

ឥតិបិសោ ភគវា ព្រះចន្ទ សោយអាយុដៃ សិបហាពីរ រក្សានុប្បទ្រី ព្រះគុណ កុសលសម្បន្នោ សព្វទុក្ខំ វិនាសន្តិ ។

ឥតិបិសោ ភគវា ព្រះអង្គារ សោយ អាយុ ដៃ ប៉ែតពីរ រក្សា នុប្បទ្រី ព្រះគុណ កុសលសម្បន្នោ សព្វទុក្ខំ វិនាសន្តិ ។

ឥតិបិសោ ភគវា ព្រះពុធ សោយ អាយុ ដៃ សុិបចិតពីរ រក្សា នុប្បទ្រី ព្រះគុណ កុសល្លសម្បន្នោ សព្វទុក្ខំ វិនាសន្តិ ។

ឥតិបិសោ ភគវា ព្រះហស្បតិ៍ សោយ អាយុ ដៃ សុិបកៅពីរ រក្សា នុប្បទ្រី ព្រះគុណ កុសលសម្បន្នោ សព្វទុក្ខំ វិនាសន្តិ ។

ឥតិបិសោ ភគវា ព្រះសុក្រ សោយ អាយុដៃ ឃីសុិបនឹងពីរ រក្សានុប្បទ្រី ព្រះគុណ កុសលសម្បន្នោ សព្វទុក្ខំ វិនាសន្តិ ។

ឥតិបិសោ ភគវា ព្រះសៅរ៍ សោយ អាយុ ដៃ សុិបពីរ រក្សា នុប្បទ្រី ព្រះគុណ កុសលសម្បន្នោ សព្វទុក្ខំ វិនាសន្តិ ។

ឥតិបិសោ ភគវា ព្រះរាហ៊ុ សោយ អាយុ ដៃ សុិប សងពីរ រក្សា នុប្បទ្រី ព្រះគុណ កុសលសម្បន្នោ សព្វទុក្ខំ វិនាសន្តិ ។

ឥតិបិសោ ភគវា ព្រះកេតុ សោយ អាយុដៃ កៅពីរ ព្រះគុណកុសលសម្បន្នោ សព្វទុក្ខ សព្វសោក សព្វរោគ សព្វភ័យ សព្វ ជំងឺ គ្រោះកាចចង្រៃ វិនាសន្តិ អសេសតោ ។

ឥតិបិសោ ភគវា អរហំ អរហំ ទេវា នៅ ព្រះអាទិត្យ ព្រះចន្ទ កម្លាំងដៃ ខ ច ហៃ ខ ប៉ានយ៉ៃ ខ រក្សា ខ រាសី ហឹង្កា បញ្ចវរា ហឹង្កា សម្មាធរនី ឡាក់ឡៃ ព្រះក្រក់ទូហៃ អសូរនិព្វានំ ព្រះក្រក់ សូន្យំ រោគា

ព្យាធិ បាបំ វិនាសន្តិ នត្ថិកម៉ៃហំ សព្វំ សត្រូវ ចោរំ វិនាសន្តិ អសេសតោ អក្ខរ សព្វ ក្រោធឹង មរណំ ភវោតិ។

ឥតិបិសោ ភគវា អរហំ អរហំ ទេវា នៅ ព្រះអង្គារ ព្រះពុធព្រះហស្បតិ៍ ព្រះ សុក្រ ខ ច ហៃ ខ ប៉ានយៃ ខ រក្សា ខ រាសី ហឹង្កា បញ្ចូវរា ហឹង្កា សម្មាធរនី ឡាក់ឡៃ ព្រះក្រក់ទូហៃ អសូរនិព្វានំ ព្រះក្រក់ សូន្យំ រោគា ព្យាធិ បាបំ វិនាសន្តិ នត្ថិមយ្ហំ សព្វំ សត្រូវ ចោរំ វិនាសន្តិ អសេសតោ អក្ខរ សព្វ ក្រោធឹង មរណំ ភវោតិ។

ឥតិបិសោ ភគវា អរហំ អរហំ ព្រះ អរស្ស ទេវា នូវ ព្រះកេតុ សូន្យ កម្លាំងដៃ ខ ច ហៃ ខ ប៉ានយៃ ខ រក្សា ខ រាសី ហឹង្កា បញ្ចូវរ៉ា ហឹង្កា សម្មាធរនី ឡាក់ឡៃ ព្រះក្រក់ទូហៃ អសូរនិព្វានំ ព្រះក្រក់ សូន្យំ រោគា ព្យាធិ បាបំ វិនាសន្តិ នត្ថិកម៉ៃហំ សព្វំ សត្រូវ ចោរំ វិនាសន្តិ អសេសតោ អក្ខរ សព្វ គ្រោធ្ឹង មរណំ ភវោតិ។

នមោ នមស្ការោ ពុទ្ធគុន្នោ សប្ប បរមត្ថ សព្វនិព្វានំ មអឧ ឧអម ទើប អញ្ជើញ ស្តេច ក្រុង សិរីទ្ធិ តូច មក សណ្ឋិត លើខ្លួនអាត្មា អញហោង ឥតិបិសោ លោកនាថោ អយៈ សម្បន្នោ ទិនៈ ប៉ិកៈពុទ្ធោ ជយ ជយោ ជយា ស្តេច មាន ព្រះបារមី បី ពន្លឹក ទូទាំង ជម្ពូទ្វីបា ធ្លាក់ ទាំងព្រាយ កាលកណ្ណី ព្រាយអាប ព្រាយធ្មប់ ព្រាយកុមារោ ព្រាយកុមារា ទាំងព្រាយគោបា ទាំងស្មារទេះ ទាំងស្តេច ព្រាយ ធំ ស្តេច ក្រុង មារាធិរាជ សឹងដ៏ខ្លាច អំណាច អញហោង សឹងដ៏រត់ខ្ចាត់ខ្ចាយ រលាយសូន្យរូប

ទើបអញស្រូប ទាំង ពិសក្តៅ ពិសត្រជាក់ ទាំងពិស រន្ទះបាញ់ ពិស កន្ទាល ត្រអាក ទាំងពិស ព្រួយកម្ទាយ ដែលសៀតសូក ចាក់សព្វកាយ ទាំងរន្ទះទឹក ទាំងរន្ទះភ្លើង ទាំងពិស ពីងសឹង សន្ធឹក ទើបអញយក ព្រះនប្បគុណ អញ មករំលត់ ពិសពីង ឱ្យខ្ចាត់ខ្ចាយ ចេញទៅ លំនៅពីងហោង ទើបអ្នកជូនដំណើរពីង អញរំលាយ ទាំងកាលកណ្ណី ជន្លេន រុកដី ស្រីជំទាវជេរប្តី មាន់រងាវ ឆ្មាររងាវ យប់សឹងដ៏ចង្រៃ សព្វ ពុទ្ធោ រលាយ សព្វ ធម្មោ រលាយ សព្វ សង្ឃោ រលាយ សព្វទុក្ខ រលាយ សព្វសោក រលាយ សព្វរោគ រលាយ សព្វ ជំងឺ គ្រោះកាច ចង្រៃ វិនាសន្តិ អសេសតោ។

ឥតិបិសោ ភគវា វិជ្ជាចរណសម្បន្នោ ទើបគ្នាអញបរន្ទូវខ្មោច ព្រាយ មេឃាហោង នូវសព្វ ជ្រោះ ជ្រង ជ្រលង ដងអួរ ព្រៃភ្នំ មានដើរ គេសន្ទុំ មនុស្ស ផងប្រុសស្រី ទើបអញកាន់ ទសបារមី អញ បីដូចព្រះខាន់ពេជ្រ មុតថ្លា អញសូធ្យកាលណា សឹងដ៏កក្រើក ស្ទប់ស្ទែង ទាំង កំពែង ចក្កវាឡ សត្តបរិភណ្ឌ ស្លន់ទាំងខ្មោច យក្ស អារក្ស បាក់ទាំង ហ៊ឹងធ្មប់ ជ្រប់ទាំងក្បាលអាប រាបទាំងក្បាលមេមត់ រន្ធត់អស់ទាំង ព្រះ ធរណី កក្រើក ដល់ស្តេចក្រុងពាលី សឹងចុះមកជួយរិទ្ធិអង្គអញ ឱម របើក មហារបើក របើកទាំងអាយ របើកទាំងនាយ របើកទាំងបន្ទាយ ៧ជាន់ រម្ងាប់ទាំងខ្មោចយក្ស រម្ងាប់ទាំងខ្មោច អារក្ស របើកទាំងព្រាយហោះ ព្រាយហើរ របើកទាំងព្រាយបណ្តើរ កូនខ្ចី របើកទាំងកិត្តិយ៉ាធ្មប់

ដែលធ្វើគេ ទប់ទល់ ហើម ហល់ ហើម ចុក ឧម នមោ ពុទ្ធឹស ឧម នមោ ធម្មឹស ឧម នមោ សង្ឃឹស សសៃ យ្យ ទីទាំង ហុលោ ៧ ស្វាហាយ ។

រម្ងាប់ ទាំងក្មេង ដេកយប់យល់សប្តិ ឆ្លុតលេលា រម្ងាប់ ទាំងឧបទ្រព ចង្រៃ រម្ងាប់ ទាំងខ្មោចព្រាយយាមា រម្ងាប់ ទាំងខ្មោចព្រាយ ណាណា ពីងមកយាយី ពីងមកទាំងថ្ងៃ ពីងមកទាំងយប់ ពីងឈរ ពីងឈប់ដោយសព្វណាណា ពីងមកម្នាក់ឯង ពីងមកមានគ្នាអញ្ច សំដែងព្រះទិព្វមន្ត នៃមាត់អញ្ចអើយ សឹងកក្រើកទាំង ក្រឡាមហា ប្រឹថពី ឧមជយោ ជយាមហារម្ងាប់ស្តាប់បង្គាប់អញ្ចជាគ្រូបា ធ្យាយហោងឱមសិទ្ធី ហុលោ ៧ ស្វាហាយ ។

ពុទ្ធំឆេះ ធម្មំឆេះ សង្ឃំឆេះ ឆេះទាំងក្បាលអាប កម្រាបអាមង មេមត់របស់ចុះក្តួត សង្គួតធ្មេញ ពេញអណ្តាត ស្រោតសំពត់ រត់ចេញទៅស្ទុះពីក្បាលទៅរន្ធគូទឱមសិទ្ធីហុលោ៧ស្វាហាយ ។

( ត្រូវទេះពីក្បាលរហូតដល់គូទហោង) ។

(សូធ្យយន្ទុនបណ្តាច់អំបោះពេលចប់សម្រាកសិន) លោកអាចារ្យ ជូនពៃចប់សព្វគ្រប់ អ្នកកាត់គ្រោះ បែរមកលើករាសីបន្តទៀត ។

> ធម្មជាតិជាស្រ្តី នឹងថាអៀនខ្មាសក៏មិនមែន នឹងថាមានខ្លួនទូន្មានហើយក៏មិនមែន នឹងថាមានចិត្តស្មោះត្រង់ចំពោះប្តីក៏មិនមែន ។
>
> ទស្សនៈ ភិក្ខុ ប៉ាង ខាត់ វីរិយបណ្ឌិតោ

# ធម៌សូត្រលើករាសី

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ៣ចប់

ពុទ្ធំ អាយុ ទុឡ្ហនំ ជីវិតំ យាវ និព្វានំ សរណំ គច្ឆាមិ

ធម្មំ អាយុ ទុឡ្ហនំ ជីវិតំ យាវ និព្វានំ សរណំ គច្ឆាមិ

សង្ឃំ អាយុ ទុឡ្ហនំ ជីវិតំ យាវ និព្វានំ សរណំ គច្ឆាមិ

ទុតិយម្បិ ពុទ្ធំ អាយុ ទុឡ្ហនំ ជីវិតំ យាវ និព្វានំ សរណំ គច្ឆាមិ

ទុតិយម្បិ ធម្មំ អាយុ ទុឡ្ហនំ ជីវិតំ យាវ និព្វានំ សរណំ គច្ឆាមិ

ទុតិយម្បិ សង្ឃំ អាយុ ទុឡ្ហនំ ជីវិតំ យាវ និព្វានំ សរណំ គច្ឆាមិ

តតិយម្បិ ពុទ្ធំ អាយុ ទុឡ្ហនំ ជីវិតំ យាវ និព្វានំ សរណំ គច្ឆាមិ

តតិយម្បិ ធម្មំ អាយុ ទុឡ្ហនំ ជីវិតំ យាវ និព្វានំ សរណំ គច្ឆាមិ

តតិយម្បិ សង្ឃំ អាយុ ទុឡ្ហនំ ជីវិតំ យាវ និព្វានំ សរណំ គច្ឆាមិ។

(ត្រូវសូត្រ ផ្គុំធាតុ អជ្ជមយា ចីវរ បិណ្ឌបាត សេនាសនៈ គិលាន ចប់សព្វគ្រប់)

ឥតិបិសោភគវាព្រះអាទិត្យទេវាជាតិជាអធិបតីចុះមកឃ្មាតខ្ចីលត់លើករាសីអ្នកនាងឈ្មោះ(.......)នេះឱ្យបានឧត្តុង្គឧត្តម សមសិក្តិសមសួនជាងជួយថែថួនខំខ្វល់ខ្វាយចម្រុងចម្រើនរីទ្ធីសាយឱ្យសុខសប្បាយថ្កើងស័ក្តិកេរ្តិ៍ឈ្មោះទម្លាយទម្លុះព្យាធិបាប គ្រោះរំលស់ ចេញមកអំពីឥន្ទ្រីមកជួយបិទជួយស្កិតរារាំងគ្រប់ទិសទីសត្រូវប៉ុនប៉ងចង់យាយីខ្លួបខ្លាចរីទ្ធីចាញ់ចេស្តាប្រកាក់ប្រកបមានធនំលាភោលាភំលាភភស្តុធីចម្រុងចម្រើន យសស័ក្តាសង់ហ៊ុំ សង្ហារាជ រីទ្ធីសម្បត្តិ សម្បូណិ ហូរចូលមក គគ្រឹក ចូលមកសន្ធឹកគ្រប់រាត្រី ចូលមកលើកបុណ្យ ស័ក្តិលើកជោគលើកថ្នាក់ លើករាសី

ចម្រើន ទាំងសុខ សួស្តីបីប្រការ ហ៊ុមដួងចិន្តា ឥតិបិសោ ភគវា សិទ្ធី ហុលោ ៧ ស្វាហាយ ។[២២]

ឥតិបិសោ ភគវា ព្រះចន្ទ ព្រះអង្គារ ព្រះពុធ............ ។ល ។

ឥតិបិសោ ភគវា ព្រះហស្បតិ៍ ព្រះសុក្រ ព្រះសៅរ៍......... ។ល ។

ឥតិបិសោ ភគវា ចេត្រ ពិសាខ ជេស្ឋ.......... ......... ។ល ។

ឥតិបិសោភគវា អាសាធ ស្រាពណ៍ ភទ្របទ................ ។ល ។

ឥតិបិសោ ភគវា អស្សុជ កត្តិក មិគសិ.................... ។ល ។

ឥតិបិសោ ភគវា បុស្ស មាឃ ផល្គុន...................... ។ល ។

ឥតិបិសោ ភគវា ជូត ឆ្លូវ ខាល .............................. ។ល ។

ឥតិបិសោ ភគវា ថោះ រោង ម្សាញ់..................... ។ល ។

ឥតិបិសោ ភគវា មមី មមែ វក............................... ។ល ។

ឥតិបិសោ ភគវា រកា ច កុរ....................................... ។ល ។

ឥតិបិសោ ភគវា ព្រះថាន ព្រះនព្វគ្រោះ ព្រះបាទ ទសមុខ ។ល ។

ឥតិបិសោ ភគវា ព្រះកេតុ ព្រះកាល ព្រះភូមិ........... ។ល ។

ឥតិបិសោ ភគវា រាពណ៍ សេដា សេដាយុស ហនុមាន ពិភេក ព្រះរាម ខរ៍ ព្រះល័ក្ខណ៏..................................... ។ល ។

២២-ប្រជុំធម៌រំដោះគ្រោះទាំង១២ឆ្នាំ ទំព័រ៩២ បោះពុម្ពផ្សាយចេញពីតូបលេខ៦៦ ផ្សារអូឬស្សី ព.ស.២៥៤២ គ.ស១៩៩៨ ។

ឥតិបិសោភគវា បូពិអាគ្នេយ៍ ទក្សិណ និរតី បស្ចិម ពាយព្យ ឧត្តរ ឦសាន ជាតិជាធិបតីចុះមកឃ្មាតខ្ចីលត់លើករាសីអ្នកនាងឈ្មោះ(...) នេះឱ្យបានឧត្តុង្គឧត្តម សមស័ក្តិសួនជាងជួយថៃថ្ងូនខំខ្វល់ខ្វាយ ចម្រុងចម្រើនរឹទ្ធីសាយឱ្យសុខសប្បាយថ្កើងស័ក្តិកើរ្តីឈ្មោះ ទម្លាយទម្លុះ ព្យាធិបាបគ្រោះរំលស់ចេញមកអំពីឥន្ទ្រីមកជួយបិទជួយ ស្ថិតរារាំងគ្រប់ទិសទីសត្រូវ ប៉ុនប៉ងចង់ យាយីខ្លួបខ្លាចរឹទ្ធីចាញ់ចេស្តា។ប្រកាក់ប្រកបមានធនំ លាភោលាភំលាភភស្តុធី ចម្រុងចម្រើនយសសក្កា សង់ហ៊ុំសង្ហារាជរឹទ្ធីសម្បត្តិសម្បូណិហូរចូលមកគគ្រឹកចូលមកសន្ធឹកគ្រប់រាត្រី លើកបុណ្យស័ក្តិ លើកជោគលើកថ្នាក់ លើករាសីចម្រើនទាំងសុខ សួស្តីបីប្រការហ៊ុមដួងចិន្តា ឥតិបិសោភគវាសិទ្ធីហុលោ២ស្វាហាយ្យ។ ចន្លោះចុច២នោះគឺដូចគ្នាទាំងអស់ចាប់ពីជាតិជាអធិបតីហុលោ២ ស្វាហាយ ។ចប់

ឥតិបិសោ ភគវា ព្រះអាទិត្យទេវា នូវកម្លាំងថ្ងៃ ព្រះអាទិត្យចូលមករក្សារាសី ហិង្សមបណ្ណី ខន្តី យស្សា បរិវារ ហិង្សា ឥតិបិសោ ភគវា។

ឥតិបិសោ ភគវា ព្រះចន្ទ ព្រះអង្គារ ព្រះពុធ នូវកម្លាំងថ្ងៃ ព្រះចន្ទព្រះអង្គារ ព្រះពុធ ចូលមករក្សារាសី ហិង្សមបណ្ណី ខន្តី យស្សា បរិវារហិង្សា ឥតិបិសោ ភគវា។

ឥតិបិសោ ភគវា ចេត្រ ពិសាខ ជេស្ឋ នូវកម្លាំងខែ ចេត្រ ពិសាខ ជេស្ឋចូលមករក្សារាសី ហិង្សមបណ្ណី ខន្តី យស្សា បរិវារ ហិង្សា ឥតិបិសោភគវា។

ឥតិបិសោ ភគវា អាសាធ ស្រាពណ៍ ភទ្របទ នូវកម្លាំងខែ អាសាធ ស្រាពណ៍ ភទ្របទ ចូលមករក្សារាសី ហិង្សមបណ្ណី ខន្តី យស្សា បរិវារ ហឹង្សា ឥតិបិសោ ភគវា។

ឥតិបិសោ ភគវា អស្សុជ កត្តិក មិគសិរ នូវកម្លាំងខែ អស្សុជ កត្តិក មិគសិ ចូលមករក្សារាសី ហិង្សមបណ្ណី ខន្តី យស្សា បរិវារ ហឹង្សា ឥតិបិសោ ភគវា។

ឥតិបិសោ ភគវា ជូត ឆ្លូវ ខាល នូវកម្លាំងឆ្នាំ ជូតឆ្លូវខាល ចូលមករក្សារាសី ហិង្សមបណ្ណី ខន្តី យស្សា បរិវារ ហឹង្សា ឥតិបិសោ ភគវា។

ឥតិបិសោ ភគវា ថោះ រោង ម្សាញ់ នូវកម្លាំងឆ្នាំ ថោះ រោង ម្សាញ់ ចូលមករក្សារាសី ហិង្សមបណ្ណី ខន្តី យស្សា បរិវារ ហិង្សា ឥតិបិសោ ភគវា។

ឥតិបិសោ ភគវា មមី មមែ វក នូវកម្លាំងឆ្នាំ មមី មមែ វក ចូលមករក្សារាសី ខន្តី យស្សា បរិវារ ហិង្សា ឥតិបិសោ ភគវា។

ឥតិបិសោ ភគវា វកា ច កុរ នូវកម្លាំងឆ្នាំ វកា ច កុរ ចូលមករក្សារាសី ហិង្សមបណ្ណី ខន្តី យស្សា បរិវារ ហឹង្សា ឥតិបិសោ ភគវា។

ឥតិបិសោ ភគវា ន មោ ពុទ្ធា យ សិទ្ធី **អ អា ឥ ឦ ឫ ឬ ឭ ឮ ឯ ឰ ឱ ឳឪ**
**ក ខ គ ឃ ង ច ឆ ជ ឈ ញ ដ ឋ ឌ ឍ ន ប ផ ព ភ ម យ រ ល វ ស**
**ហ ឡ អ .ន ម អ ឧ .ម អ ឧ ន. អ ឧ ន ម . ឧ ន ម អ.ឪ**
ន បារមី ន រាសី ន សុន ហៃ ន ហោនត្វា នៈ នៈ តៈ មករក្សា រាសី មេត្រី មេត្តា ករុណា មុទិតា ឧបេក្ខាព្រះពុទ្ធ កុសលសម្បន្នោ ឥតិបិសោ ភគវា ។

( អាចដកយកម្តង៥តួមកសូធ្យ ឬ ដកម្តងទាំងអស់ក៏បាន ) ។

( អាចសូធ្យធមិជ័យផ្សេងៗ បន្តទៀត តាមអ្នកចេះរួចសូធ្យ) ។

សព្វេ ពុទ្ធា ជនាចិត្តំ សព្វេ ធម្មា ជនា ចិត្តំ សព្វេសង្ឃាជនា ចិត្តំ សិម្ពលី ច មហាថេរោ នាម សព្វលាភំ ភវន្តុតេ តេតុំ វក្ខិតោ សន្តោ មុត្តោ សព្វភយេន ច សព្វរោគ វិនិមុត្តោ សព្វសន្តា បរិវជ្ជិតោ សព្វវេរ មតិកន្តោ និព្វុតោ ចតុវិ ភវិ ។( សូត្រ៣ចប់) ។

កុកដិជាតំ អហំគាថា កុកដរាជា សេនា មអឱ ។ កកិ កុក សទ្ធា វេ សទ្ធា អហិមម ។

សិទ្ធី កិច្ចំ សិទ្ធី កម្មំ សិទ្ធីការិយ តថាគតោ សិទ្ធីតេជោ ជយោ និច្ចំ សិទ្ធីលាភោ និរន្តរំ សព្វកម្មំ បសិទ្ធីមេ ឧម នមោ ឥតិបិសោ ន ទោសោ សព្វទោសោ នមោ មេ សព្វពុទ្ធានំ ចន្ទំ សុញ្ញំ សសិភូម្មោ ពុទ្ធោលាភសិរី ជិសុគ្រោធ សព្វទុក្ខោ រាហូ កេតុ កេតុមហាលាភំ សព្វសុខំ ភវន្តុតេ តេ តុំ វក្ខិតោ សន្តោ មុត្តោ សព្វភយេន ច សព្វលាភំ ភវន្តុតេ ។[២៣]

| |
|---|
| អ្នកមានទ្រព្យឈ្មោះថាមានមិត្តអ្នកមានទ្រព្យឈ្មោះថាមានផៅពង្សអ្នកមានទ្រព្យឈ្មោះថាជាបុរសអ្នកមានទ្រព្យឈ្មោះថាជាបណ្ឌិត ។ ទស្សនៈ ភិក្ខុ ប៉ាង ខាត់ វីរិយបណ្ឌិតោ |

២៣-ក្បួនសាមជាន់ ក្បួនអង្គរ ប៊ុន-ណាត ។

តេសំ សច្ចេន សីលេន ខន្តិពលេន ច តេបិតុម្ហេ អនុរក្ខន្តុអារោគ្យេន សុខេន ច!

បុរត្ថិមស្មឹ ទិសាភាគេ សន្តិ ភូតា មហិទ្ធិកាតេបិ តុម្ហេ អនុរក្ខន្តុអារោគ្យេន សុខេន ច!

ទក្ខិណស្មឹ ទិសាភាគេ សន្តិ ទេវា មហិទ្ធិកា តេ បិ តុម្ហេ អនុរក្ខន្តុ អារោគ្យេន សុខេន ច!

បច្ឆិមស្មឹ ទិសាភាគេ សន្តិ នាគា មហិទ្ធិកា តេ បិ តុម្ហេ អនុរក្ខន្តុ អារោគ្យេន សុខេន ច!

ឧត្តរស្មឹ ទិសាភាគេ សន្តិ យក្ខា មហិទ្ធិកា តេ បិ តុម្ហេ អនុរក្ខន្តុ អារោគ្យេន សុខេន ច!

បុរិមទិសំ ធតរដ្ឋោ ទក្ខិណេន វិរុឡ្ហកោ បច្ឆិមេន វិរូបក្ខោ កុវេរោ ឧត្តរំ

ទិសំ ចត្តារោ តេ មហារាជា លោកបាលា យសស្សិនោ តេបិ តុម្ហេ អនុរក្ខន្តុ អារោគ្យេន សុខេន ច!

អាកាសដ្ឋា ច ភុមដ្ឋា ទេវា នាគា មហិទ្ធិកា តេ បិ តុម្ហេ អនុរក្ខន្តុ អារោគ្យេន សុខេន ច!

នត្ថិ មេ សរណំ ពុទ្ធោ មេ ធម្មោ មេ សង្ឃោមេ សរណំ វរំ ឯតេន សច្ចវជ្ជេន ហោតុ តេ ជយមង្គលំ ។

យំ កិញ្ចិ រតនំ លោកេ វិជ្ជតិ វិវិធំ បុថុ រតនំ ពុទ្ធសមំ ធម្មសមំ
សង្ឃសមំ នត្ថិ តស្មា សោត្ថី ភវន្តុ តេ ។
សក្កត្វា ធម្ម រតនំ ឱសថំ ឧត្តមំ វរំ បរិឡាហូសមនំ ធម្មតេជេន
សោត្ថិនា នស្សន្តុបទ្ទវា សព្វេ ភយា វូបសមេន្តុ តេ ។
សក្កត្វា សង្ឃ រតនំ ឱសថំ ឧត្តមំ វរំ អាហុនេយ្យំ បាហុនេយ្យំ
សង្ឃតេជេន សង្ឃតេជេន សោត្ថិនា នស្សន្តុបទ្ទវា សព្វេ រោគា
វូបសមេន្តុ តេ។
សព្វីតិយោ វិវជ្ជន្តុ សព្វរោគា វិនស្សតុ មាតេ ភវត្វន្តរាយោ សុខី
ទីឃាយុកោ ភវ អភិវាទនសីលិស្ស និច្ចំ វុឌ្ឍាបចាយិនោ ចត្តារោ
ធម្មា វឌ្ឍន្តិ អាយុំ វណ្ណោ សុខំ ពលំ ។
ជយន្តោ ពោធិយា មូលេ សក្យានំ នន្ទិវឌ្ឍនោ ឯវំ ត្វំ វិជយោ
ហោហិ ជយស្សុ ជយមង្គលេ អបរាជិតបល្លង្កេ សីសេ បឋវិបោក្ខរេ
អភិសេកេ សព្វពុទ្ធានំ អគ្គប្បត្តោ បមោទតិ សុនក្ខត្តំ សុមង្គលំ
សុបភាតំ សុហុដ្ឋិតំ សុខណោ សុមុហុត្តោ ច សុយិដ្ឋំ ព្រហ្មចារីសុ
បទក្ខិណំ កាយកម្មំ វាចាកម្មំ បទក្ខិណំ បទក្ខិណំ មនោកម្មំ បណិធីតេ
បទក្ខិណា បទក្ខិណានិ កត្វា ន លភត្ថត្ថេ បទក្ខិណេ។ ភវតុសព្វមង្គលំ
មង្គលទាំងពួង ចូលមានដល់អ្នក រក្ខន្តុ សូមសព្វទេវតា
ទាំងអស់រក្សានូវអ្នក សព្វពុទ្ធានុភាវេន ដោយអានុភាពនៃព្រះពុទ្ធជាម្ចាស់
រាល់ព្រះអង្គ
សព្វ ធម្មានុភាវេន ដោយអានុភាពនៃព្រះធម៌ទាំងពួង!
សព្វ សង្ឃានុភាវេន ដោយ អានុភាពនៃព្រះសង្ឃទាំងពួង!
សទា សោត្ថី ភវន្តុ តេ សួស្តីទាំងឡាយចូរមានដល់អ្នកឱ្យបាន
សព្វកាលសព្វវេលា។(**នក្ខត្តយក្ស**) ។[២៤] ចប់

២៤-សែម-សូរ ប្រជុំភាណវារៈ ទំព័រ២០៥-២០៧ ផ្សាយដោយបណ្ណាគារត្រៃរតន៍ ព.ស.២៥៤៣ គ.ស. ១៩៩៩។

# គុណធម៌

ធម៌ពួក២

## ធម៌មានឧបការច្រើន២យ៉ាង

១-**សតិ** សេចក្តីរលឹកបាន

២-**សម្បជញ្ញៈ** សេចក្តីដឹងខ្លួន។

## ធម៌ជាលោកបាលគ្រប់គ្រងរក្សាលោកមាន២យ៉ាង

១-**ហិរិ** សេចក្តីខ្មាសបាប

២-**ឱត្តប្បៈ** សេចក្តីក្រែងខ្លាចបាប។

## ធម៌ធ្វើឲ្យល្អ២យ៉ាង

១-**ខន្តិ** សេចក្តីអត់ធន់

២-**សោរច្ចៈ** សេចក្តីស្ងប់ស្ងៀម។

## បុគ្គលរកបានដោយកម្រ២ពួក

១-**បុព្វការី** អ្នកធ្វើឧបការៈមុន

២-**កតញ្ញូកតវេទី** អ្នកដឹងឧបការៈដែលលោកធ្វើហើយធ្វើតបវិញ។[២៥]

## ទេសនា២យ៉ាង

១-**បុគ្គលាធិដ្ឋានទេសនា** ការសម្តែងមានបុគ្គលជាទីតាំង

២-**ធម្មាធិដ្ឋានទេសនា** ការសម្តែងមានធម៌ជាទីតាំង។

---

២៥-បណ្ឌិត ឈឹម-ទូច ប្រស្នាធម្មវិភាគ បុច្ឆា-វិសជ្ជនា ទំព័រ៥-១៤ ផ្សាយដោយបណ្ណាគារត្រៃរតន៍។

**និព្វាន២យ៉ាង**

១-**សឧបាទិសេសនិព្វាន** ការរលត់ កិលេសមានបញ្ចក្ខន្ធសល់ នៅ។

២-**អនុបាទិសេសនិព្វាន** ការរលត់កិលេសមិនមានបញ្ចក្ខន្ធ សល់នៅ។

**បូជា២យ៉ាង**

១-**អាមិសបូជា** បូជាដោយអាមិសៈ គឺគ្រឿងបរិក្ខារ

២-**បដិបត្តិបូជា** បូជាដោយសេចក្តីប្រតិបត្តិ។

**បដិសណ្ឋារៈ២យ៉ាង**

១-**អាមិសប្បដិសណ្ឋារៈ** ការទទួលដោយអាមិសៈ

២-**ធម្មប្បដិសណ្ឋារៈ** ការទទួលដោយធមិ។[២៦]

**មរណៈមាន២យ៉ាងគឺ**

១-**កាលមរណៈ** សត្វដែលអស់បុណ្យអស់បាបអស់អាយុហើយស្លាប់ទៅ នោះគឺស្លាប់ដ៏គួរ

២-**អកាលមរណៈ** គឺស្លាប់ក្នុងកាលដ៏មិនសមគួរនឹងស្លាប់។[២៧]

(ក្នុងគម្ពីរវិសុទ្ធមគ្គភាគ២ទំព័រ១)។

**សទ្ធាមាន២យ៉ាង**

១-**កម្មស្សកតាសទ្ធា** ជឿថាសត្វមានកម្មជារបស់ខ្លួន

២-**តថាគតពោធិសទ្ធា** ជឿសេចក្តីត្រាស់ដឹងជារបស់ព្រះសម្ពុទ្ធ។

> អ្នកមានប្រាជ្ញាតែខ្សត់ទ្រព្យ បើព្រេងវាសនាមិនជួយព្យាយាម
> របស់បុរសក៏ឥតប្រយោជន៍ តើនឹងស្វែងរកសេចក្តីសុខដទៃឯណា
> ក្រៅពីការចូលទៅក្នុងព្រៃ ?
>
> ទស្សនៈ ភិក្ខុ ប៉ាង ខាត់ វីរិយបណ្ឌិតោ

២៦-ប្រជុំកងធមិភាគ២ ទំព័រ៣-៤ ផ្សាយដោយពុទ្ធសាសនបណ្ឌិត្យ ព.ស.២៥៤២។

២៧-គម្ពីរវិសុទ្ធិមគ្គភាគ២ ទំព័រ១។

## កម្មស្សកតាសទ្ធាមានពីរយ៉ាង

១-**កម្ម** ជឿកម្ម

២-**វិបាក** ជឿផលរបស់កម្ម ។

## សទ្ធា២យ៉ាង

១-**លោកិយសទ្ធា** សេចក្តីជឿជាលោកិយ( គឺជឿនូវការប្រែប្រួល)

២-**លោកុត្តរសទ្ធា** សេចក្តីជឿលោកកុត្តរ:( គឺជឿការមិនប្រែប្រួល)

## សង្ខារ២យ៉ាង

១-**ឧបាទិន្នកសង្ខារ** សង្ខារគឺវិញ្ញាណចូលទៅកាន់យក

( សត្វមានវិញ្ញាណ)

២-**អនុបាទិន្នកសង្ខារ** សង្ខារគឺវិញ្ញាណមិនចូលទៅកាន់យក

( បានដល់សង្ខារដែលគ្មានចិត្តគ្រប់គ្រង) ។

## សេចក្តីសុខ២យ៉ាង

១-**គិហិសុខ** សេចក្តីសុខរបស់គ្រហស្ថ

២-**បព្វជ្ជាសុខ** សេចក្តីសុខក្នុងផ្នួស ។

## សុខពីរយ៉ាងទៀត

១-**កាមសុខ** សេចក្តីសុខក្នុងកាម

២-**នេក្ខម្មសុខ** សេចក្តីសុខក្នុងនេក្ខម្មគឺការចេញបួស ។

## ធម៌ដែលធ្វើឱ្យកើតសីលមាន២យ៉ាង

១-**ហិរិ** ធម្មជាតិដែលអៀនខ្មាសនឹងអំពើទុច្ចរិត

២-**ឱត្តប្បៈ** ធម្មជាតិដែលតក់ស្លុតនឹងផលរបស់អំពើទុច្ចរិត។

## សម្បត្តិឧបាសក២យ៉ាង

១-**សីលសម្បទា** ដល់ព្រមដោយសីល។

២-**អាជីវសម្បទា** ដល់ព្រមដោយការចិញ្ចឹមជីវិតប្រាសចាកទោស។

## ពលៈកម្លាំងមាន២យ៉ាង

១-**បដិសង្ខារពល** កម្លាំងពិចារណា

២-**ភាវនាពល** កម្លាំងភាវនា។

## ពហុស្សូតមាន២យ៉ាង

១-**បរិយត្តិ ពហុស្សូត** អ្នកចេះដឹងព្រះត្រៃបិដក

២-**បដិវេធ ពហុស្សូត** កិរិយាត្រាស់ដឹង។

## សាសនាមាន២យ៉ាង

១-**ពាហិរសាសនា** សាសនាខាងក្រៅ

២-**ពុទ្ធសាសនា** សាសនាព្រះពុទ្ធ។

## បង្គោលឬចន្ទល់របស់សីលមាន២យ៉ាង

១-**ខន្តិ** សេចក្ដីអត់ធន់។

២-**សោរច្ចៈ** សេចក្ដីស្ងប់ស្ងៀម។

**ចក្ខុមាន២ប្រភេទ**

១-**មំសចក្ខុ** បានដល់ភ្នែកសាច់មាន២យ៉ាង

២-**បញ្ញាចក្ខុ** បានដល់ភ្នែកគឺបញ្ញាមាន៥យ៉ាង។

## ធម៌ពួក៣

### រតនៈ៣យ៉ាង

ព្រះពុទ្ធ១ ព្រះធម៌១ ព្រះសង្ឃ១

១-លោកអ្នកប្រដៅពួកជនឱ្យប្រតិបត្តិល្អដោយកាយវាចាចិត្តតាមធម៌វិន័យ ហៅថាព្រះពុទ្ធ។

២-ធម៌វិន័យពាក្យប្រដៅរបស់ព្រះពុទ្ធ ហៅថាព្រះធម៌។

៣-ពួកជនដែលបានស្តាប់ពាក្យប្រដៅរបស់ព្រះពុទ្ធ ហើយបួសប្រតិបត្តិតាម ធម៌វិន័យ ហៅថាព្រះសង្ឃ។

### គុណរបស់ព្រះរតនៈ៣យ៉ាង

១-ព្រះពុទ្ធទ្រង់ត្រាស់ដឹងប្រពៃដោយព្រះអង្គជាមុន ហើយប្រដៅអ្នកដទៃឱ្យប្រតិបត្តិតាមផង។

២-ព្រះធម៌រក្សាអ្នកប្រតិបត្តិមិនឱ្យធ្លាក់ទៅក្នុងទីអាក្រក់ឡើយ។

៣-ព្រះសង្ឃលោកប្រតិបត្តិល្អតាមពាក្យប្រដៅរបស់ព្រះពុទ្ធ ហើយប្រដៅអ្នកដទៃឱ្យធ្វើតាមផង។

---

២៨-ធម្មវិន័យ ត្រី-ទោ-ឯក។

## អាការដែលព្រះពុទ្ធទ្រង់ប្រដៅមាន៣យ៉ាង

១-**អភិញ្ញាយៈ** ទ្រង់ប្រដៅដើម្បីឱ្យអ្នកស្តាប់ដឹងពិតឃើញពិតក្នុងធម៌ដែល គួរដឹងគួរឃើញ។

២-**សនិទានៈ**

ទ្រង់ប្រដៅមានហេតុកាលអ្នកស្តាប់ត្រិះរិះតាមរមែងឃើញ ពិតបាន។

៣-**សប្បាដិហារិយៈ** ទ្រង់ប្រដៅជាអស្ចារ្យ គឺកាលអ្នកស្តាប់ប្រតិបត្តិតាមរមែងសម្រេចប្រយោជន៍តាមគួរដល់សេចក្តីប្រតិបត្តិ។

## ឱវាទរបស់ព្រះពុទ្ធ៣យ៉ាង

១-**សព្វបាបស្ស អករណំ** មិនឱ្យធ្វើបាបទាំងពួង គឺឱ្យវៀរចាកទុច្ចរិត (ប្រព្រឹត្តអាក្រក់) ដោយកាយ វាចា ចិត្ត។

២-**កុសលស្សូបសម្បទា** ឱ្យញុំាងកុសលឱ្យដល់ព្រម គឺឱ្យប្រកបសុចរិត (ប្រព្រឹត្តល្អ) ដោយកាយ វាចា ចិត្ត។

៣-**សចិត្តបរិយោទបនំ** ឱ្យជម្រះចិត្តរបស់ខ្លួនឱ្យផូរផង់ ប្រាសចាកគ្រឿងសៅហ្មងចិត្តមាន លោភៈ ទោសៈ មោហៈជាដើម។

## ទុច្ចរិត៣យ៉ាង

១-**កាយទុច្ចរិត** ប្រព្រឹត្តអាក្រក់ដោយកាយ

២-**វចីទុច្ចរិត** ប្រព្រឹត្តអាក្រក់ដោយវាចា

៣-**មនោទុច្ចរិត** ប្រព្រឹត្តអាក្រក់ដោយចិត្ត។

## កាយទុច្ចរិត៣យ៉ាង

១-**បាណាតិបាតៈ** សម្លាប់សត្វ

២-**អទិន្នាទានៈ** លួចទ្រព្យគេ

៣-**កាមេសុ មិច្ឆាចារៈ** ប្រព្រឹត្តខុសក្នុងកាម ។

## វចីទុច្ចរិត៤យ៉ាង

១-**មុសាវាទៈ** និយាយកុហកគេ

២-**បិសុណវាចា** និយាយញុះញង់គេ

៣-**ផរុសវាចា** និយាយចាក់ដោតគេ

៤-**សម្ផប្បលាបៈ** និយាយពាក្យឥតប្រយោជន៍ ។

## មនោទុច្ចរិត៣យ៉ាង

១-**អភិជ្ឈា** សម្លឹងរំពៃចង់បានរបស់គេ

២-**ព្យាបាទៈ** ចងចិត្តប្រទូស្តគេ

៣-**មិច្ឆាទិដ្ឋិ** ឃើញខុសចាកគន្លងធម៌ ។

ទុច្ចរិត ៣ យ៉ាងនេះ ជាធម៌មិនគួរប្រព្រឹត្ត គួរលះចេញ ។

## សុចរិត៣យ៉ាង

១-**កាយសុចរិត** ប្រព្រឹត្តល្អដោយកាយ

២-**វចីសុចរិត** ប្រព្រឹត្តល្អដោយវាចា

៣-**មនោសុចរិត** ប្រព្រឹត្តល្អដោយចិត្ត ។

## កាយសុចរិត៣យ៉ាង

១-វៀរចាកការសម្លាប់សត្វ

២-វៀរចាកការលួចទ្រព្យគេ

៣-វៀរចាកការប្រព្រឹត្តខុសក្នុងកាម ។

## វចីសុចរិត៤យ៉ាង

១-វៀរចាកការនិយាយកុហក ។

២-វៀរចាកការនិយាយញុះញង់គេ ។

៣-វៀរចាកការនិយាយចាក់ដោតគេ ។

៤-វៀរចាកនិយាយឥតប្រយោជន៍ ។

## មនោសុចរិត៣យ៉ាង

១-មិនសម្លឹងរំពៃចង់បានរបស់គេ ។

២-មិនចងចិត្តប្រទូស្តគេ ។

៣-ឃើញត្រូវតាមគន្លងធម៌ ។

## អកុសលមូល៣យ៉ាង

ឫសគល់របស់អកុសល ហៅថា អកុសលមូលមាន៣យ៉ាងគឺ

១-**លោភៈ** ចង់បានមិនចេះស្កប់ ។

២-**ទោសៈ** គិតប្រទូស្តគេ ។

៣-**មោហៈ** វង្វេងមិនដឹងការពិត ។

កាលបើអកុសលមូល៣នេះណាមួយមានហើយអកុសលមូលដទៃដែលមិនទាន់កើតមាន រមែងកើតឡើងដែលកើតឡើងហើយក៏ចម្រើនច្រើនឡើង ហេតុនេះគួរលះបង់ឱ្យអស់ចេញ។

## កុសលមូល៣យ៉ាង

ឬសគល់របស់កុសលហៅថាកុសលមូលមាន៣យ៉ាងគឺ

១-**អលោភៈ** មិនចង់បាន

២-**អទោសៈ** មិនគិតប្រទូស្តគេ

៣-**អមោហៈ** មិនវង្វេង។

កាលបើកុសលមូល៣នេះណាមួយមានហើយកុសលដទៃដែលមិនទាន់កើត រមែងកើតឡើង ដែលកើតឡើងហើយក៏ចម្រើនច្រើនឡើងហេតុនេះគួរធ្វើឱ្យកើតមានក្នុងសន្តាន។

## បញ្ញត្តិរបស់សប្បុរស៣យ៉ាង

១-**ទានៈ** ឱ្យវត្ថុរបស់ខ្លួនដើម្បីជាប្រយោជន៍ដល់អ្នកដទៃ

២-**បព្វជ្ជា** កាន់ភេទបួសដើម្បីជាឧបាយវៀរចាកធមិសម្រាប់គ្រហស្ថ

៣-**មាតាបិតុឧបដ្ឋានៈ** ប្រតិបត្តិមាតាបិតាតាមគន្លងធមិ។

## បុញ្ញកិរិយាវត្ថុ៣យ៉ាង

វត្ថុជាទីតាំងនៃការបំពេញបុណ្យហៅថាបុញ្ញកិរិយាវត្ថុមានខ្លឹម៣យ៉ាងគឺ

១-**ទានមយ:** បុណ្យសម្រេចដោយការបរិច្ចាគទាន

២-**សីលមយ:** បុណ្យសម្រេចដោយការរក្សាសីល

៣-**ភាវនាមយ:** បុណ្យសម្រេចដោយការចម្រើនភាវនា។

## សាមញ្ញលក្ខណៈ៣យ៉ាង

លក្ខណៈ ដែលមានស្មើទូទៅដល់សង្ខារទាំងពួង ហៅថាសមញ្ញលក្ខណៈ ឬត្រៃលក្ខណ៍ចែកជា៣យ៉ាងគឺ

១-**អនិច្ចតា** សភាពជារបស់មិនទៀង

២-**ទុក្ខតា** សភាពជារបស់ទុក្ខ

៣-**អនត្តតា** សភាពជារបស់មិនមែនខ្លួន។

## ភ្លើង៣យ៉ាង

១-**រាគគ្គិ** ភ្លើងគឺរាគៈ

២-**ទោសគ្គិ** ភ្លើងគឺទោសៈ

៣-**មោហគ្គិ** ភ្លើងគឺមោហៈ។

## កម្ម៣យ៉ាង

១-**កាយកម្ម** អំពើប្រកបដោយកាយ

២-**វចីកម្ម** អំពើប្រកបដោយវាចា

៣-**មនោកម្ម** អំពើប្រកបដោយចិត្ត។

---

២៩-ប្រស្នាធម្មវិភាគ បុច្ឆា-វិសជ្ជនា ទំព័រ១៦-៣៣ រៀបរៀងដោយ បណ្ឌិត ឈឹម-ទូច ផ្សាយដោយបណ្ណាគារត្រៃរតន៍។

## ទ្វារ៣យ៉ាង

១-**កាយទ្វារ** ទ្វារគឺកាយ

២-**វចីទ្វារ** ទ្វារគឺវាចា

៣-**មនោទ្វារ** ទ្វារគឺចិត្ត ។

## អាសវៈ៣យ៉ាង

១-**កាមាសវៈ** អាសវៈគឺកាម ។

២-**ភវាសវៈ** អាសវៈគឺភព ។

៣-**អវិជ្ជាសវៈ** អាសវៈគឺអវិជ្ជា ។

## អត្ថប្រយោជន៍៣យ៉ាង

១-**ទិដ្ឋធម្មិកត្ថ** ប្រយោជន៍ក្នុងលោកនេះ

២-**សម្បរាយិកត្ថ** ប្រយោជន៍គឺភពខាងមុខ

៣-**បរមត្ថកត្ថ** ប្រយោជន៍ដ៏ខ្ពង់ខ្ពស់ គឺព្រះនិព្វាន ។

## ធម្មនិយាម៣យ៉ាង

១-សង្ខារទាំងឡាយមិនទៀង

២-សង្ខារទាំងឡាយជាទុក្ខ

៣-សង្ខារទាំងឡាយជាអនត្តា ។

## បិដក៣យ៉ាង

១-**វិនយបិដក** គម្ពីររួបរួមទុកនូវវិន័យ មាន២១០០០ធម្មក្ខន្ធ

២-**សុត្តន្តបិដក** គម្ពីររួបរួមទុកនូវសូត្រ មាន២១០០០ធម្មក្ខន្ធ

៣-**អភិធម្មបិដក** គម្ពីររួបរួមទុកនូវអភិធម្ម មាន៤២០០០ធម្មក្ខន្ធ ។

## លោក៣យ៉ាង

១-**មនុស្សលោក** បានដល់លោកជាទីអាស្រ័យនៅនៃមនុស្ស

២-**ទេវលោក** បានដល់លោកជាទីអាស្រ័យនៃទេវតា

៣-**ព្រហ្មលោក** បានដល់លោកជាទីអាស្រ័យនៃព្រហ្ម ។

## ញាណ៣យ៉ាង

១-**បុព្វេនិវាសានុស្សតិញ្ញាណ** ញាណគឺការរលឹកឃើញជាតិមុន ។

២-**ចុតូបបាតញ្ញាណ** ញាណក្នុងការកំណត់ដឹងឃើញចុតិ និងបដិសន្ធិ ។

៣-**អាសវក្ខយញ្ញាណ** ញាណក្នុងការធ្វើឱ្យអស់នូវអាសវៈ ។

## ព្រះសទ្ធម្ម៣យ៉ាង

១-**បរិយត្តិសទ្ធម្ម** បានដល់ការសិក្សា

២-**បដិបត្តិសទ្ធម្ម** បានដល់សេចក្តីប្រតិបត្តិ

៣-**បដិវេធសទ្ធម្ម** បានដល់មគ្គផលនិព្វាន ។

## សម្បត្តិ៣យ៉ាង

១-**មនុស្សសម្បត្តិ** សម្បត្តិក្នុងអត្តភាពជាមនុស្ស

២-**សគ្គសម្បត្តិ** សម្បត្តិក្នុងអត្តភាពជាទេវតាក្នុងឋានសួគ៌

៣-**និព្វានសម្បត្តិ** សម្បត្តិ គឺព្រះនិព្វាន ។[៣០]

## អភិនិហារកិរិយាកសាងរបស់ព្រះពុទ្ធ៣យ៉ាងគឺ

១-**បញ្ញាធិក** ច្រើនដោយបញ្ញាកំណត់៤អសង្ខេយ្យ និង១សែនកប្ប ។

២-**សទ្ធាធិក** ច្រើនដោយសទ្ធាកំណត់៨អសង្ខេយ្យ និង១សែនកប្ប ។

៣-**វីរិយាធិក**ច្រើនដោយព្យាយាមកំណត់១៦អសង្ខេយ្យនិង១សែនកប្បទើបបានត្រាស់ ។

( ព្រះសម្មាសម្ពុទ្ធបរមគ្រូនៃយើងជ្រើសរើសយកបញ្ញាធិកនេះឯង)

## បុត្រមាន៣ពួក

១-**អតិជាតោ** កូនកើតហើយដោយអំណាចនៃគុណធម៌ដ៏ក្រៃលែង

២-**អនុជាតោ** កូនដែលកើតតាមលំអាន

៣-**អវជាតោ** កូនកើតហើយដោយអំណាចនៃគុណធម៌ដ៏ទាប ។

## សុខ៣យ៉ាង

១-**មនុស្សសុខ** សេចក្តីសុខក្នុងមនុស្ស

២-**ទិព្វសុខ** សេចក្តីសុខក្នុងទិព្វ

៣-**បរមត្ថភូតំ និព្វានសុខ** សេចក្តីសុខក្នុងព្រះនិព្វាន ។

---

៣០-ប្រជុំកងធម៌ភាគ២ ទំព័រ១២-១៣-១៤ និង១៥ ផ្សាយដោយពុទ្ធសាសនបណ្ឌិត្យ ព.ស.២៥៤២ ។

## មូលហេតុដែលនាំឱ្យកើតសរណគមន៍៣យ៉ាង

១-**ពុទ្ធាទិសុវត្ថូសុ សទ្ធា បដិលោភោ** ការបានចំពោះនូវសេចក្ដីជឿក្នុងវត្ថុទាំងឡាយមានព្រះពុទ្ធជាដើម។

២-**សទ្ធាមូលិកា ច សម្មាទិដ្ឋិ**ការយល់ឃើញត្រូវមានសទ្ធាជាឫសគល់

៣-**ទសសុបុញ្ញកិរិយាវត្ថូសុ ទិដ្ឋុជុកម្មំ** ការធ្វើទិដ្ឋិឱ្យត្រង់បណ្ដាក្នុងបុញ្ញកិរិយាវត្ថុទាំង១០។

## សីលរបស់គ្រហស្ថមាន៣យ៉ាង

១-**និច្ចសីល** សីលដែលរក្សាជានិច្ច

២-**ឧបោសថសីល** សីលឧបោសថ(រង់ចាំកាល)

៣-**អតិរេកសីល** សីលដែលរក្សាក្រៃលែងជាងប្រក្រតី។

## កិច្ចដែលត្រូវចម្រើនក្នុងថ្ងៃឧបោសថមាន៣យ៉ាង

១-**កាលេន ធម្មសាកច្ឆា** ការប្រឹក្សាគ្នាអំពីធមិ និងវិន័យតាម កាលដ៏គួរ

២-**កាលេន ធម្មស្សវនំ** ការស្ដាប់ធមិតាមកាលគួរ

៣-**កាលេន សមថោ** ត្រូវខំចម្រើនកម្មដ្ឋានទាំង៤០កម្មដ្ឋាន ណាមួយតាមកាលដ៏គួរ។

## បង្អែកសាសនាមាន៣យ៉ាង

១-ព្រះពុទ្ធ ២-ព្រះធមិ ៣-ព្រះសង្ឃ។

## ត្រួយសាសនា មានតែមួយគឺ ព្រះនិព្វានតែម្យ៉ាងៗ

## ម្លប់សាសនាមាន៣យ៉ាងគឺ

**១ -សច្ចំ ២ -ខន្តិ ៣ -កតញ្ញូ ។**

## ចន្ទល់សាសនាមានតែមួយគឺវិន័យបិដកៗ

## ចែកសាសនាបីយ៉ាង

១-**សីល** ២-**សមាធិ** ៣-**បញ្ញា** ។

ឬ **បរិយត្តិធម៌** ១ **បដិបត្តិធម៌**១ **បដិវេធធម៌**១ ។

ឬក៏ ១-**សុត្តន្តបិដក** ២-**វិន័យបិដក** ៣-**អភិធម្មបិដក** ។

## ចំណង៣ប្រការ

១-**បុត្តគីវេ** កូនចំណងក

២-**ភរិយាហត្ថេ** ភរិយាចំណងដៃ

៣-**ធនំបាទេ** ទ្រព្យចំណងជើង ។

## ឫសគល់ព្រះសូត្រមាន៣យ៉ាង

១-**ទាន** ២-**សីល** ៣-**ភាវនា** ។

## ឫសគល់ព្រះវិន័យមាន៣យ៉ាង

១-**សីល** ២-**សមាធិ** ៣-**បញ្ញា** ។

## ឫសគល់ព្រះអភិធម្មមាន៣យ៉ាង

**១-លោភៈ ២-ទោសៈ ៣-មោហៈ ។**

## វត្ថុបរិភោគមិនឆ្អែត៣យ៉ាង

១-**និទ្ទាយតិ** ការដេកក៏មិនចេះឆ្អែត

២-**សុរាមេរយៈ** ការសេពសុរា និងមេរ័យ ក៏មិនចេះឆ្អែត

៣-**មេថុនធម្ម** ការសេពនូវមេថុនធម្មក៏មិនចេះឆ្អែត ។

## ស្រវឹង៣យ៉ាង

១-**យោព្វនមានោ** ស្រវឹងវ័យ

២-**អរោគមនោ** ស្រវឹងខ្លួនថាជាអ្នកមិនមានរោគ

៣-**ជាតិមនោ**ស្រវឹងក្នុងជាតិមានយសស័ក្តិខ្ពង់ខ្ពស់ ។

## ទិដ្ឋិមានទោសច្រើនមាន៣យ៉ាង

១-**អកិរិយទិដ្ឋិ** យល់ថាការធ្វើមិនជាអំពើ( គឺមិនជាអំពើល្អ-អាក្រក់) ។

២-**អហេតុកទិដ្ឋិ** យល់ថាអ្វីៗគ្រប់យ៉ាងមិនមានហេតុ( បុព្វកម្ម) ។

៣-**នត្ថិកទិដ្ឋិ** យល់ថាបុណ្យ និងបាបមិនមាន ។

## មហាកុសល៨ប្រកបដោយចេតនា៣

១-**បុព្វចេតនា** ចេតនាមុនធ្វើ

២-**មុញ្ចនចេតនា** ចេតនាកំពុងធ្វើ

៣-**អបរចេតនា** ចេតនាកាលធ្វើរួចហើយ ។

## សមាធិមាន៣យ៉ាង

១-**ខណិកសមាធិ** បានដល់ចិត្តតាំងមាំក្នុងអារម្មណ៏បានមួយខណៈៗ

២-**ឧបចារសមាធិ** បានដល់ចិត្តតាំងមាំនៅក្នុងអារម្មណ៏ជិតឈានចិត្ត

៣-**អប្បនាសមាធិ**បានដល់ចិត្តតាំងមាំស៊ប់នៅក្នុងអារម្មណ៏ដែលកំណត់ទុកកិលេសមិនអាចរុកកួនបានឈានចិត្តនោះបាន រមែងកើតឡើងដោយអប្បនាសមាធិនេះ។

## អសុរ៣ពួក

១-**ទេវអសុរ** បានដល់អសុរដែលជាទេវតា

២-**បេតអសុរ** បានដល់អសុរដែលជាប្រេត

៣-**និរយអសុរ** បានដល់អសុរដែលជាសត្វនរក។

## ព្រះនិព្វានមាន៣យ៉ាង

១-**សុញ្ញតនិព្វាន** ព្រោះសូន្យចាកសង្ខារទាំងពួង

២-**អនិមិត្តនិព្វាន** ព្រោះមិនមាននិមិត្តគឺសង្ខារទាំងពួង

៣-**អប្បណិហិតនិព្វាន** ព្រោះមិនមានទីតាំងគឺសង្ខារទាំងពួង។

## ហេតុដែលឲ្យកើតបុណ្យមាន៣យ៉ាង

១-**បសាទោ** មានចិត្តជ្រះថ្លា

២-**សទ្ធេគោ** មានចិត្តតក់ស្លុត

៣-**តេសុចរិតា** មានសេចក្ដីស្អាតដោយ **កាយ វាចា ចិត្ត**។

**បុណ្យចម្រើនព្រះជន្មមានន័យ៣យ៉ាង**

១-**ជីវិតមហាកម្ម** ប្រែថា អំពើដែលគេធ្វើដើម្បីអប់រំចង់បញ្ជាក់ថា សត្វលោកទាំងអស់សុទ្ធតែជាប់ក្នុង អនិច្ចលក្ខណៈទាំង៣គឺ អនិច្ចំ ទុក្ខំ អនត្តា គ្រប់ៗគ្នា ។

២-**អាយុវឌ្ឍនកម្ម** ប្រែថាអំពើដែលគេធ្វើដើម្បីចម្រើននូវសង្ខារ ឱ្យយឺនយូរដោយអានុភាពនៃធម្មរតនៈ មានការចម្រើននូវព្រះបរិត្តជាដើម ។

៣-**អនុប្បទានកម្ម** ប្រែថាអំពើដែលគេធ្វើឡើងដើម្បីអនុគ្រោះ រំដោះទុក្ខដល់សត្វទាំងអស់ ។

ធម៌ពួក៤

**ធម៌ចម្រើនមាន៤យ៉ាង**

១-**សប្បុរិសូបសំសេវៈ** សេពគប់សប្បុរសគឺលោកអ្នកប្រព្រឹត្តល្អដោយកាយ វាចា ចិត្ត ។

២-**សទ្ធម្មស្សវនៈ** ស្តាប់ពាក្យប្រដៅរបស់លោកដោយគោរព ។

៣-**យោនិសោមនសិការៈ** ត្រិះរិះឱ្យស្គាល់របស់ល្អឬអាក្រក់ដោយឧបាយដែលត្រូវ ។

៤-**ធម្មានុធម្មប្បដិបត្តិ** ប្រតិបត្តិធម៌សមគួរដល់ធម៌ ដែលបានត្រិះរិះឃើញហើយ ។[៣១]

---

៣១-ព្រះពោធិវង្ស ហួត-តាត ធម្មសង្គហៈ ទំព័រ៤១ ផ្សាយដោយរោងពុម្ពខេមររដ្ឋ ព.ស.២៥០១ គ.ស.១៩៥៨។

## ចក្កៈ៤យ៉ាង

១-**បដិរូបទេសវាសៈ** នៅក្នុងប្រទេសដ៏សមគួរ។

២-**សប្បុរិសូបសំសេវៈ** សេពគប់សប្បុរស។

៣-**អត្តសម្មាបណិធិ** តាំងខ្លួនទុកដោយប្រពៃ។

៤-**បុព្វេកតបុញ្ញតា** ភាពជាអ្នកបានធ្វើបុណ្យទុកមកពីក្នុងកាលមុន។

ធម៌ ៤ យ៉ាងនេះ បីដូចកង់រថនាំទៅកាន់សេចក្ដីចម្រើន។[៣២]

## អារក្ខកម្មដ្ឋាន កម្មដ្ឋានដែលគួរចម្រើនជានិច្ច៤យ៉ាង

១-**ពុទ្ធានុស្សតិ** រលឹកគុណព្រះពុទ្ធដែលមានក្នុងព្រះអង្គ និងគុណដែលទ្រង់សង្គ្រោះដល់អ្នកដទៃ។

២-**មេត្តា** ផ្សាយមេត្តាចិត្តគិតឱ្យមនុស្សសត្វទាំងពួងបានសុខគ្រប់គ្នា។

៣-**អសុភៈ**ពិចារណារាងកាយខ្លួននិងអ្នកដទៃឱ្យឃើញថាជារបស់បដិកូលគួរខ្ពើម។

៤-**មរណានុស្សតិ** នឹកដល់សេចក្ដីស្លាប់តែងនឹងមានដល់ខ្លួន។

## ព្រហ្មវិហារ៤យ៉ាង

១-**មេត្តា** សេចក្ដីប្រាថ្នា ចង់ឱ្យគេបានសុខ។

២-**ករុណា** សេចក្ដីអាណិតគិតជួយឱ្យគេរួចចាកទុក្ខ។

៣-**មុទិតា** សេចក្ដីត្រេកអរតាម ក្នុងវេលាគេបានល្អ។

៤-**ឧបេក្ខា** សេចក្ដីតាំងចិត្តជាកណ្ដាល មិនឱ្យមានសោមនស្សទោមនស្សក្នុងវេលាដែលបានជួបវិបត្តិ។

ធម៌ ៤ យ៉ាង នេះ ជាគ្រឿងប្រព្រឹត្តរបស់អ្នកធំ។

---

៣២-បណ្ឌិត ឈឹម-ទូច ប្រស្នាធម្មវិភាគ បុច្ឆា-វិសជ្ជនា ទំព័រ៣៥ ផ្សាយដោយបណ្ណាគារត្រៃរតន៍។

## សតិប្បដ្ឋាន៤យ៉ាង

១-**កាយានុបស្សនា** សតិរលឹកពិចារណាកាយជាអារម្មណ៍ថា កាយនេះគ្រាន់តែជាកាយប៉ុណ្ណោះ មិនមែនជាសត្វជាបុគ្គលជាខ្លួនប្រាណជាយើងជាគេឡើយ ។

២-**វេទនានុបស្សនា** សតិរលឹកពិចារណាវេទនា គឺសេចក្ដីដឹងសុខទុក្ខឧបេក្ខាជាអារម្មណ៍ថាវេទនានេះគ្រាន់តែជាវេទនាប៉ុណ្ណោះ មិនមែនជាសត្វជាបុគ្គលជាខ្លួនប្រាណជាយើងជាគេឡើយ ។

៣-**ចិត្តានុបស្សនា** សតិរលឹកពិចារណាចិត្តដែលសៅហ្មង និងផូរផង់ជាអារម្មណ៍ថាចិត្តនេះគ្រាន់តែជាចិត្តប៉ុណ្ណោះ មិនមែនជាសត្វជាបុគ្គលជាខ្លួនប្រាណជាយើងជាគេឡើយ ។

៤-**ធម្មានុបស្សនា**សតិរលឹកពិចារណាធមិជាកុសលឬអកុសលដែលកើតឡើងជាមួយនឹងចិត្តជាអារម្មណ៍ថាធមិនេះគ្រាន់តែជាធមិប៉ុណ្ណោះ មិនមែនជាសត្វ ជាបុគ្គល ជាខ្លួនប្រាណយើងគេឡើយ ។[៣៣]

## អបាយមុខ ហេតុជាគ្រឿងវិនាស៤យ៉ាង

១-**ឥត្ថីធុត្តៈ** ជាអ្នកលេងស្រី

២-**សុរាធុត្តៈ** ជាអ្នកលេងស្រា

៣-**អក្ខធុត្តៈ** ជាអ្នកលេងល្បែងភ្នាល់ឬល្បែងស៊ីសង

៤-**បាបមិត្តៈ** យកមនុស្សអាក្រក់ធ្វើជាមិត្ត ។

ទោស ៤ យ៉ាងនេះ មិនគួរប្រកបឡើយ ។

---

៣៣-ព្រះពោធិវង្ស ហួត-តាត ធម្មសង្គហៈ ទំព័រ៩២-៩៣ ផ្សាយដោយរោងពុម្ពខេមរវដ្ឋ ព.ស.២៥០១ គ.ស.១៩៥៨ ។

## ទិដ្ឋធម្មិកត្ថៈ ប្រយោជន៍បច្ចុប្បន្ន៤យ៉ាង

១-**ឧដ្ឋានសម្បទា** ដល់ព្រមដោយសេចក្ដីព្យាយាម គឺព្យាយាមក្នុងការប្រកបកិច្ចការងារ ចិញ្ចឹមជីវិតក្ដី ក្នុងការសិក្សារៀនសូត្រក្ដី ក្នុងភារកិច្ចជាមុខការនាទីរបស់ខ្លួនក្ដី។

២-**អារក្ខសម្បទា**ដល់ព្រមដោយការរក្សា គឺរក្សាទ្រព្យដែលរកបានមកដោយសេចក្ដីព្យាយាមមិនឱ្យអន្តរាយទៅក្ដី រក្សាការងាររបស់ខ្លួនមិនឱ្យសាបសូន្យទៅក្ដី។

៣-**កល្យាណមិត្តតា** ភាពជាអ្នកមានមិត្តល្អមិនសេពគប់មិត្តអាក្រក់។

៤-**សមជីវិតា** ការចិញ្ចឹមជីវិតតាមសមគួរដល់កម្លាំងទ្រព្យដែលរកបានមក គឺមិនត្បិតត្បៀតពេក មិនខ្ជះខ្ជាយពេក។

## សម្បរាយិកត្ថៈ ប្រយោជន៍ខាងមុខ៤យ៉ាង

១-**សទ្ធាសម្បទា** ដល់ព្រមដោយសទ្ធា គឺជឿរបស់ដែលគួរជឿដូចជឿថាធ្វើល្អបានផលល្អធ្វើអាក្រក់បានផលអាក្រក់ជាដើម។

២-**សីលសម្បទា**ដល់ព្រមដោយសីលគឺរក្សាកាយវាចាឱ្យរៀបរយឱ្យផុតចាកទោស។

៣-**ចាគសម្បទា**ដល់ព្រមដោយការបរិច្ចាគទាន ជាការចែកសុខដល់អ្នកដទៃ។

៤-**បញ្ញាសម្បទា** ដល់ព្រមដោយបញ្ញា គឺស្គាល់បុណ្យបាប គុណទោសប្រយោជន៍និងឥតប្រយោជន៍ជាដើម។[៣៥]

៣៤-ព្រះពោធិវង្ស ហួត-តាត ធម្មសង្គហៈ ទំព័រ៤១-៤២ ផ្សាយដោយរោងពុម្ពខេមររដ្ឋ ព.ស.២៥០១ គ.ស.១៩៥៨។

## ការបែងទ្រព្យជាចំណែក៤

គ្រហស្ថអ្នករកទ្រព្យបានមក គប្បីបែងជាចំណែក ៤គឺ
១-ដោះបំណុលចាស់ ចិញ្ចឹមមាតាបិតា
២-បុលបំណុលថ្មី ចិញ្ចឹមបុត្រ
៣-បោះចូលក្នុងជ្រោះជ្រៅ ចិញ្ចឹមខ្លួនឯង
៤-កប់ចោលក្នុងធរណី គឺធ្វើបុណ្យទានក្នុងព្រះពុទ្ធសាសនា។
កាលបើគ្រហស្ថ បែងចែកទ្រព្យបានយ៉ាងនេះហើយ រមែងបានសេចក្តីចម្រើន។

## សុខរបស់គ្រហស្ថមាន៤យ៉ាង

១-សុខកើតអំពីការមានទ្រព្យ
២-សុខកើតអំពីចាយទ្រព្យបរិភោគ
៣-សុខកើតអំពីការមិនជំពាក់បំណុលគេ
៤-សុខកើតអំពីការប្រកបការងារប្រាសចាកទោស។

## ត្រកូលស្តុកស្តម្ភដែលនឹងតាំងនៅយូរមិនបានព្រោះស្ថាន៤យ៉ាង

១-មិនស្វែងរករបស់ដែលបាត់ទៅហើយ
២-មិនជួសជុលរបស់ដែលគ្រាំគ្រា
៣-មិនដឹងប្រមាណក្នុងការចាយប្រើទ្រព្យធន
៤-តាំងស្ត្រីឬបុរសទ្រុស្តសីលឱ្យជាមេផ្ទះ។
អ្នកដែលចង់ឱ្យត្រកូលគង់វង្សនៅត្រូវលះវៀរស្ថាន៤យ៉ាងនេះចេញ។

## ធម៌របស់ឃរាវាស៤យ៉ាង

១-**សច្ចៈ** ស្មោះត្រង់ដល់គ្នានឹងគ្នា

២-**ទមៈ** ទូន្មានចិត្ត

៣-**ខន្តិ** អត់ធន់

៤-**ចាគៈ** លះចែកវត្ថុរបស់ខ្លួនដល់បុគ្គលដែលគួរឱ្យ។

## អបាយភូមិ៤យ៉ាង

១-**និរយៈ** កំណើតនៃសត្វនរក

២-**តិរច្ឆានយោនិ** កំណើតនៃសត្វតិរច្ឆាន

៣-**បិត្តិវិសយៈ** ភូមិនៃប្រេត

៤-**អសុរកាយ** ពួកអសុរកាយ។

## ឱឃៈ៤យ៉ាង

១-**កាមោឃៈ** អន្លង់គឺកាម

២-**ភវោឃៈ** អន្លង់គឺភព

៣-**ទិដ្ឋោឃៈ** អន្លង់គឺទិដ្ឋិ

៤-**អវិជ្ជោឃៈ** អន្លង់គឺអវិជ្ជា។

## បរិស័ទ៤ពួក

១-ភិក្ខុ ៣-ឧបាសក ២-ភិក្ខុនី ៤-ឧបាសិកា។

"បញ្ជាក់ៈ សព្វថ្ងៃនេះអស់**ភិក្ខុនី**ហើយនៅសល់តែ**សាមណេរ**"

## បរិស័ទ៤ពួកទៀត

១-ខត្តិយបរិស័ទ ៣-គហបតិបរិស័ទ

២-ព្រាហ្មណ៍បរិស័ទ ៤-សមណបរិស័ទ។

## យោនិកំណើត៤យ៉ាង

១-**ជលាពុជៈ** កំណើតក្នុងគភ៌

២-**អណ្ឌជៈ** កំណើតនៅក្នុងស៊ុត

៣-**សំសេទជៈ** កំណើតក្នុងញើស

៤-**ឧបបាតិកៈ** កំណើតដែលអណ្តែតទៅកើត។

## សទ្ធា៤យ៉ាងគឺ

១-**កម្មសទ្ធា** ជឿកម្ម

២-**វិបាកសទ្ធា** ជឿផលរបស់កម្ម

៣-**កម្មស្សកតាសទ្ធា** ជឿថាសត្វមានកម្មជារបស់ខ្លួន

៤-**តថាគតពោធិសទ្ធា** ជឿសេចក្តីត្រាស់ដឹងរបស់ព្រះតថាគត។

## កូន៤ពួក

១-**អត្តជៈ** កូនដែលកើតអំពីខ្លួន។

២-**ខេត្តជៈ** កូនដែលកើតក្នុងទីជាខេត្ត។

៣-**ទិន្នក** កូនដែលគេឱ្យឬកូនសុំ។

៤-**អន្តេវាសិក** កូនសិស្ស។

## ហេតុដែលនាំឱ្យកើតសុខ៤យ៉ាង

១-**សុខំយាវជរាសីលំ** មានសីលជាទីតម្កល់ដល់ចាស់ជរាជាហេតុនាំឱ្យកើតសុខ។

២-**សុខា សទ្ធាបតិដ្ឋិតា** តម្កល់សទ្ធាជាហេតុនាំឱ្យកើតសុខ។

៣-**សុខោ បញ្ញោបដិលាភោ** បាននូវបញ្ញាជាហេតុនាំឱ្យកើតសុខ។

៤-**បាបានំ អករណំ សុខំ** មិនធ្វើនូវអំពើបាបជាហេតុនាំឱ្យកើតសុខ។

## លោកិយសរណគមន៍មាន៤យ៉ាង

១-**អត្តសន្និយ្យាតនេន** ដល់ព្រះរតនត្រ័យដោយប្រគល់កាយថ្វាយជីវិត

២-**តប្បរាយនតាយ**ដល់ព្រះរតនត្រ័យដោយភាពជាអ្នកមានព្រះរតនៈត្រ័យ ជាទីប្រព្រឹត្តទៅក្នុងខាងមុខ។

៣-**សិស្សភាវូគមនេន** ដល់ព្រះរតនត្រ័យ ដោយភាពថ្វាយខ្លួន ជាកូនសិស្ស

៤-**បណិបាតេន** ដល់ព្រះរតនត្រ័យដោយទម្លាក់ដៃចុះក្រាបបង្គំ។

## អត្ថរបស់សីល៤យ៉ាងគឺ

១-**សិរដ្ឋោ** សីលនេះជាទីរីករាយក្នុងកុសលធម៌ទាំងពួង។

២-**សីសដ្ឋោ** សីលនេះជារបស់ត្រជាក់ឱ្យកុសលលូតលាស់បាន។

៣-**សីតលដ្ឋោ** សីលនេះគឺទឹកសម្រាប់រលត់នូវភ្លើងគឺទោសៈ។

៤-**សីវដ្ឋោ** សីលនេះអ្នកទាំងពួងតែងសេពគប់។

## ប្រាជ្ញមាន៤យ៉ាងគឺ

**១-ចិន្តកវិ** អ្នកប្រាជ្ញព្រោះគិត

**២-សុត្តកវិ** អ្នកប្រាជ្ញព្រោះស្តាប់

**៣-អត្ថកវិ** អ្នកប្រាជ្ញព្រោះអាស្រ័យសេចក្តី

**៤-បដិភាណកវិ** អ្នកប្រាជ្ញព្រោះប្រាជ្ញាវាងវៃ ។

## បុគ្គល៤ពួក

**១-ខិណោគោណគោ** បុគ្គលទាបកាន់តែទាបទៅ

**២-ខិណោតុណ្ណគោ** បុគ្គលទាបត្រឡប់ទៅជាខ្ពស់វិញ

**៣-ឧណ្ណគោណគោ** បុគ្គលខ្ពស់ត្រឡប់ទៅជាទាបវិញ

**៤-ឧណ្ណតុណ្ណគោ** បុគ្គលខ្ពស់កាន់តែខ្ពស់ឡើង ។

## អានិសង្សកតញ្ញូ៤យ៉ាងគឺ

**១-កុសលមូលតា** ជាឫសគល់នៃកុសលធមិទាំងពួង ។

**២-បធានតា** ជាប្រធាននៃបារមីទាំង៣០ ។

**៣-បុញ្ញាភិវឌ្ឍនោ** ជាទីចម្រើនបុណ្យកុសល ។

**៤-សម្បត្តិសម្បជិច្ឆន្នោ** ជាទីសម្រេចនូវផ្លូវសម្បត្តិ៣ស្ថាន ។

## ប្រេត៤ពួក

**១-ឧត្តុបជីវិត** **៣-និជ្ឈាមតណ្ហក**

**២-ឧប្បាសិក** **៤-បរទត្តូបជីវិត ។**

---

បញ្ជាក់ ត្រង់ប្រេតមួយពួកឈ្មោះ ឧតុបជីវិតប្រេត គឺប្រេតជាញាតិក្នុងវដ្តសង្សារ ប្រេតនេះមិនបាច់ចាំមានញាតិណាម្នាក់ឧទ្ទិសឱ្យនោះទេក៏អាចទទួលបានដែរប៉ុន្តែលុះណាតែរបស់នោះក្លាយជាស្អុយទើបអាចបាន ។តែបីពួកក្រៅពីនោះលុះណាតែអ្នកឧទ្ទិសជាញាតិហើយថាចំឈ្មោះទៀត ទើបអាចទទួលបាន ។

## ច្រូចទឹកមាន៤យ៉ាង

១-**ទក្ខិណោទក** ច្រូចទឹកជំនួសទក្ខិណាដូចព្រះបាទនន្ទិយឧបាសកច្រូចទឹកដាក់លើព្រះហស្តព្រះសាស្តា។

២-**សក្ខិណោទក** ច្រូចទឹកដើម្បីជាកសិណសាក្សី។

៣-**ឧទ្ទិសោទក** ច្រូចទឹកដើម្បីឧទ្ទិសផលដល់បេតជន។

៤-**បដ្ឋនោទក** ច្រូចទឹកដើម្បីជាភស្តុតាង គឺប្រាថ្នាយកនូវផលានិសង្ស (ឱ្យបានសម្រេចដោយសម្បត្តិទាំងបីប្រការ)។

## អន្លង់ទាំង៤

១-**កាមោឃៈ** អន្លង់គឺកាម ៣-**ទិដ្ឋោឃៈ** អន្លង់គឺទិដ្ឋិ

២-**ភវោឃៈ** អន្លង់គឺភព ៤-**អវិជ្ជោឃៈ** អន្លង់គឺអវិជ្ជា។

## អាចឆ្លងអន្លង់ទាំង៤នោះបានដោយធម៌៤យ៉ាង

១-**សទ្ធាយ តរតិ ឱឃំ** សត្វឆ្លងអន្លង់បានដោយសារសទ្ធា។

២-**អប្បមាទេនអណ្ណវំ** សត្វឆ្លងសមុទ្រទៅបានដោយសារសេចក្តី មិនធ្វេសប្រហែស។

៣-**វីរិយេន ទុក្ខមច្ចេន្តិ** សត្វឆ្លងសេចក្តីទុក្ខបានដោយសេចក្តីព្យាយាម។

៤-**បញ្ញាយបរិសុជ្ឈតិ** សត្វឆ្លងសេចក្តីមិនបរិសុទ្ធឱ្យបរិសុទ្ធបានដោយសារបញ្ញា។

## ធម៌ធ្វើបុគ្គលឱ្យជួបជុំគ្នាមាន៤យ៉ាង

១-**សមសទ្ធា** មានសទ្ធាស្មើគ្នា។

២-**សមសីលា** មានសីលស្មើគ្នា។

៣-**សមចាគា** បរិច្ចាគទ្រព្យស្មើគ្នា។

៤-**សមបញ្ញា** មានបញ្ញាស្មើគ្នា។

## សករាជមាន៤យ៉ាង

១-ពុទ្ធសករាជ

២-គ្រិស្តសករាជ

៣-មហាសករាជ

៤-ចុល្លសករាជ។

## ប្រវត្តិសករាជទាំង៤មានដូចតទៅ

# ប្រវត្តិពុទ្ធសករាជ

ពុទ្ធសករាជ ជាសករាជ ដែលរាប់ចំនួន ថ្ងៃ ខែ ឆ្នាំ តាំងពីថ្ងៃពុធ ១រោច ខែពិសាខ ឆ្នាំម្សាញ់ ក្រោយថ្ងៃដែលព្រះសក្យមុនីបរិនិព្វានទៅបាន១ថ្ងៃ រៀងមក ពោលគឺព្រះបរមគ្រូបរិនិព្វាននៅ ថ្ងៃអង្គារ ១៥កើត ខែពិសាខ ឆ្នាំម្សាញ់ពុទ្ធសករាជសរសេរកាត់អក្សរ ព.ស.។

## ប្រវត្តិគ្រិស្តសករាជ

កើតឡើងក្រោយពុទ្ធសករាជចំនួន៥៤៣ឆ្នាំ ដែលមានគណាចារ្យម្នាក់ឈ្មោះ យេស៊ូ ឬយេស៊ូគ្រិស្ត ជាអ្នកបង្កើតលទ្ធិសាសនាគ្រេដែន ឬគ្រិស្ត កើតនៅប្រទេសស៊ីរីក្នុងសតវត្សទី៦នៃពុទ្ធសករាជ៥៧៦ក្នុងគម្រប់អាយុ៣៣ឆ្នាំ គ្រិស្តសករាជសរសេរកាត់ជា គ.ស.។

## ប្រវត្តិមហាសករាជ

មហាសករាជ កើតឡើងក្នុងរាជព្រះបាទសកៈ ឬសាលីវាហលៈ នៅក្នុងប្រទេសឥណ្ឌាក្នុងរវាងព.ស.៦២១ដោយប្រារព្ធយកជ័យជំនះយ៉ាងសម្បើមរបស់ក្សត្រអង្គនោះប៉ុន្តែក្នុងជំនាន់មុនហៅត្រឹមតែសករាជប៉ុណ្ណោះលុះខាងក្រោយមកមានសករាជថ្មីកើតឡើងហៅថាសករាជព្រះចៅសាលីវាហនៈ។ មហាសករាជសរសេរអក្សរកាត់ ម.ស.។ ក្នុងព្រះរាជពង្សាវតារខ្មែរថា ព្រះបាទសម្តេចព្រះអរិត្តិពលពាហនោ ព្រះកេតុមាលាសូរ្យវង្ស បានតាំងមហាសករាជ១ក្នុងព.ស.៦២១ ព្រះបាទសម្តេចព្រះសិទ្ធពរអមរិនបរមកិពញាក្រែក បានតាំងសករាជ១ ក្នុង ព.ស. ១១៨១។

## ប្រវត្តិចុល្លសករាជ

ក្សត្រភូមា ទ្រង់ព្រះនាមសង្ឃរាជ ឬហៅថាពូពូសោហៅរី ជាក្សត្រទី១៩ ក្នុងវង្សសមុទ្ទិរិទ្ធ ទ្រង់តាំងឡើងក្នុងឆ្នាំកុរ ហើយរាប់ឆ្នាំជាឯកស័ក ក្នុង ព.ស.១១៩២ ដោយយកសុរិយគតិគឺពេលប្រជួបខួបថ្ងៃអាទិត្យដែលគោចរចេញអំពីមេសរាសីហើយ ត្រឡប់ចូលមេសរាសីវិញ ការដែលជ្រើសជា

ឯកស័ក ទោស័ក ត្រីស័ក ចត្វាស័ក បញ្ចស័កជាដើម ប្រកបនឹងឈ្មោះឆ្នាំក៏កើតឡើងក្នុងវេលាដែលកើតចុល្លសករាជដែរ ទំនៀមទម្លាប់ចូលឆ្នាំក្នុងខែមេសា( អាព្រីល) គឺត្រូវនឹងខែចេត្រតាមចន្ទគតិក៏កើតមានឡើងក្នុងសម័យដែលកើតចុល្លសករាជនេះដែរ ហើយសរសេរអក្សរកាត់ថា ច.ស.។

## ព្រះពុទ្ធមាន៤យ៉ាង

១-ព្រះសព្វញ្ញូពុទ្ធ

២-ព្រះអនុពុទ្ធ

៣-ព្រះសាវ័កពុទ្ធ

៤-ព្រះបច្ចេកពុទ្ធ។

## ហេតុឱ្យកើតលោភសោមនស្សមាន៤យ៉ាង

១-**សោមនស្សបដិសន្ធិកតា**ភាពជាអ្នកបដិសន្ធិដោយសោមនស្ស

២-**អគម្ភីរបកតិតា** ភាពជាអ្នកមានប្រក្រតីមិនហ្មត់ចត់

៣-**ឥដ្ឋារម្មណសមាយោគោ** ប្រកបជាមួយនឹងឥដ្ឋារម្មណ៍

៤-**ព្យសនវិមុត្តិ** ផុតចាកការវិនាស៥យ៉ាង។

## ហេតុឱ្យកើតឧបេក្ខាមាន៤យ៉ាង

១-**ឧបេក្ខាបដិសន្ធិកតា** ភាពជាអ្នកបដិសន្ធិមកដោយឧបេក្ខា។

២-**គម្ភីរបកតិតា** ភាពជាអ្នកមានប្រក្រតីសុខុម។

៣-**មជ្ឈត្តារម្មណសមាយោគោ** ប្រកបជាមួយនឹងអារម្មណ៍ប្រភេទជាកណ្ដាល ។

៤-**ព្យសនវិមុត្តិ** ផុតចាកការវិនាស ។

## ហេតុឱ្យកើតទោសមូលចិត្តមាន៤យ៉ាង

១-**ទោសជ្ឈាសយតា** មានអធ្យាស្រ័យជាអ្នកក្រោធច្រើន

២-**អគម្ភីរបកតិតា** មានសេចក្ដីមិនសុខុមជាប្រក្រតី

៣-**អប្បស្សុតតា** មានការស្ដាប់ព្រះសទ្ធម្មតិច

៤-**អនិដ្ឋារម្មណសមាយោគោ** ប្រកបជាមួយនឹងអារម្មណ៍ដែលមិនល្អ ។[៣៥]

## អបាយភូមិ៤យ៉ាង

១-**និរយ**(នរក) ព្រោះអត្ថថាទៅប្រាសចាកសេចក្ដីចម្រើនគឺសេចក្ដីសុខ ។

២-**តិរច្ឆាន** ព្រោះអត្ថថាទៅទទឹងគឺសណ្ដូកខ្លួនទៅខាងក្រោម ។

៣-**បេតៈ** ព្រោះអត្ថថាទៅគឺកន្លងហួសទៅ ចាកសេចក្ដីសុខដ៏ ប្រសើរ ។

៤-**អសុរ** មានវចនត្ថៈថា សត្វពួកណារមែងមិនលេងគឺមិនលេងរីករាយដោយការលេងទាំងឡាយមានឥស្សរិយកីឡាជាដើម ។ ព្រោះហេតុនោះ សត្វទាំងឡាយទើបឈ្មោះថាអសុរបានដល់ពួកប្រេតអសុរ ។

---

៣៥-ភិក្ខុ គង់ សុមិត្ត អភិធម្មត្ថសង្គហៈ៩បរិច្ឆេទ ទំព័រ៤៨-៥០ និង១៧៩ ផ្សាយដោយពុទ្ធិកបណ្ឌិតសភា នៃសាកលវិទ្យាល័យបញ្ញា សាស្ត្រ ព.ស.២៥៥២ ។

## សត្វតិរច្ឆានទាំងអស់ចែកបាន៤ប្រភេទ

១-**អបាទតិរច្ឆានោ** សត្វមិនមានជើង មានត្រីនិងពស់ជាដើម

២-**ទ្វិបាទតិរច្ឆានោ** សត្វមានជើង២ មានបក្សីជាដើម

៣-**ចតុប្បាទតិរច្ឆានោ** សត្វមានជើង៤ មានគោជាដើម

៤-**ពហុប្បាទតិរច្ឆានោ** សត្វមានជើងច្រើន មានក្អែបជាដើម។

## មនុស្សក្នុងទ្វីបទាំង៤យ៉ាង

១-មនុស្សក្នុងបុព្វវិទេហទ្វីប

២-មនុស្សក្នុងអបរគោយានទ្វីប

៣-មនុស្សក្នុងជម្ពូទ្វីប

៤-មនុស្សក្នុងឧត្តរកុរុទ្វីប។

មនុស្សដែលនៅក្នុងបុព្វវិទេហទ្វីបកាលបើមានការប្រព្រឹត្តល្អ មានអាយុ ៧០០ឆ្នាំ។

មនុស្សដែលនៅក្នុងអបរគោយានទ្វីបតាំងនៅទិសខាងលិចរបស់ភ្នំសិនេរុ ពួកមនុស្សទាំងនេះមានរូបរាងសណ្ឋានផ្ទៃមុខដូចព្រះចន្ទពេញវង់ មានអាយុ ៥០០ឆ្នាំ។

មនុស្សក្នុងជម្ពូទ្វីបតាំងនៅទិសខាងត្បូងរបស់ភ្នំសិនេរុមានរូបរាងសណ្ឋានផ្ទៃមុខដូចពងមាន់ ឬពាជ្រុងមានអាយុមិនឋិតថេរក្នុងសម័យណាដែលមានគុណធម៌ចម្រើនឡើង ក្នុងសម័យនោះក៏មានអាយុច្រើន ឡើងរហូតដល់

មានអាយុ១អសង្ខេយ្យឆ្នាំតែសម័យណាមានគុណធម៌ថយចុះ សម័យនោះក៏មានអាយុថយចុះរហូតនៅត្រឹមអាយុ១០ឆ្នាំ។

មនុស្សក្នុងឧត្តរកុរុទ្វីប តាំងនៅទិសខាងជើងរបស់ភ្នំសិនេរុ ពួកមនុស្សក្នុងទ្វីបនោះ មានរូបរាងសណ្ឋានផ្ទៃមុខ៤ជ្រុងមានអាយុ១០០០ឆ្នាំ ស្មើគ្នាទាំងអស់។

## អសង្ខេយ្យកប្បមាន៤យ៉ាង

១-**សំវដ្ដ អសង្ខេយ្យ** អសង្ខេយ្យកប្បដែលកំពុងវិនាស។
២-**សំវដ្ដដ្ឋាយី អសង្ខេយ្យ** អសង្ខេយ្យកប្បតាំងក្នុងសេចក្ដីវិនាស។
៣-**វិវដ្ដ អសង្ខេយ្យ** អសង្ខេយ្យកប្បដែលកំពុងចម្រើន។
៤-**វិវដ្ដដ្ឋាយី អសង្ខេយ្យ** អសង្ខេយ្យកប្បតាំងក្នុងសេចក្ដីចម្រើន។

ដែលឈ្មោះថាអសង្ខេយ្យកប្ប បានដល់ចំណែកទី៤នៃមហាកប្បដែលមានកាលដ៏យូរអង្វែង។

## ការប្រៀបធៀបអាយុកប្ប

ក្នុងគំនរគ្រាប់ស្ពៃធំ ដែលមានបណ្ដោយនិងទទឹង១យោជន៍៧កាលកន្លងទៅ១០០ឆ្នាំទើបមានមនុស្សនាំគ្រាប់ស្ពៃនោះចេញ១គ្រាប់។

គ្រប់៧១០០ឆ្នាំយ៉ាងនេះ សូម្បីគ្រាប់ស្ពៃនោះអស់ទៅក៏មិនទាន់អស់អាយុនៃអសង្ខេយ្យកប្បក៏អសង្ខេយ្យកប្ប១នោះ មានប្រមាណ៦៤អន្តរកប្បដោយអំណាចអន្តរកប្ប ដែលលោកកំណត់ទុកយ៉ាងនេះថាក្នុងកាលសត្វជាច្រើនដល់សេចក្ដីវិនាសដោយការប្រព្រឹត្តទៅនៃសស្ត្រាឬរោគឬទុព្ភិក្ខភ័យ

យ៉ាងណាមួយ ហើយដោយអានុភាពនៃកុសលកម្មដែលប្រព្រឹត្តទៅក្នុងសន្តានសត្វដែលសល់ ក៏មាន អាយុចម្រើនឡើងដោយលំដាប់តាំងពី១០ឆ្នាំរហូតដល់១អសង្ខេយ្យហើយត្រឡប់វិនាសចុះ ដោយលំដាប់លំដោយអំណាចសមាទានអធម៌រហូតដល់អាយុ១០ឆ្នាំទៀតសត្វក៏ដល់សេចក្ដីវិនាសដោយការប្រព្រឹត្តទៅនៃរោគជាដើមណាមួយអស់រយៈកាលប៉ុណ្ណេះជាអន្តរកប្បអាចារ្យទាំងឡាយពោលថាវិវដ្តដ្ឋាយីអសង្ខេយ្យនោះប្រមាណ២០អន្តរកប្ប ។ តាំងទីទុតិយជ្ឈានឡើងទៅកំណត់ដោយអំណាចមហាកប្បដែលគ្រប់បរិបូណ៌មិនមែនដោយអំណាចអសង្ខេយ្យកប្ប ។

## អាយុរបស់អរូបព្រហ្ម៤

**១-អាកាសានញ្ចាយតនភូមិ** អាយុ២ម៉ឺនមហាកប្ប

**២-វិញ្ញាណញ្ចាយតនភូមិ** អាយុ៤ម៉ឺនមហាកប្ប

**៣-អាកិញ្ចញ្ញាយតនភូមិ** អាយុ៦ម៉ឺនមហាកប្ប

**៤-នេវសញ្ញានា សញ្ញាយតនភូមិ** អាយុ៨ម៉ឺន៤ពាន់មហាកប្ប ។

## រសមាន៤យ៉ាង

១-**ធម្មរស** បានដល់មគ្គចិត្តុប្បាទ ៤

២-**អត្ថរស** បានដល់ផលចិត្តុប្បាទ ៤

៣-**វិមុត្តិរស** បានដល់ព្រះនិព្វាន

៤-**អាយតនរស** បានដល់រសារម្មណ៍ដូចរសប្រៃរសផ្អែមជាដើម ។

## ឥទ្ធិបាទធម៌មាន៤ប្រការ

១-**ឆន្ទៈ** បំណង សេចក្តីពេញចិត្តក្នុងកិច្ចការដែលខ្លួនធ្វើ

២-**វិរិយៈ** ព្យាយាម ធ្វើក្នុងកិច្ចការនោះៗ

៣-**ចិត្តៈ** គំនិត ការយកចិត្តទុកដាក់ដោយប្រុងប្រយត្ន័

៤-**វិមំសា** ការគិតពិចារណារកហេតុផល ក្នុងកិច្ចការដែលធ្វើ

ឥទ្ធិបាទធម៌ទាំង៤ប្រការនេះជាធម៌សំខាន់បំផុតរបស់សត្វលោក"ទាំងផ្លូវលោក ទាំងផ្លូវធម៌"។

## មាតាបិតាមានឈ្មោះ៤យ៉ាង

១-**ព្រះព្រហ្ម** ព្រហ្មរបស់កូន

២-**បុព្វទេវា** ទេវតាដំបូងរបស់កូន

៣-**បុព្វាចារ្យ** អាចារ្យរបស់កូន

៤-**អាហុនេយ្យ បុគ្គល** ព្រះអរហន្តរបស់កូន។

ធម៌ពួក៥

## អនន្តរិយកម្ម៥យ៉ាង

១-**មាតុឃាត** សម្លាប់មាតា។

២-**បិតុឃាត** សម្លាប់បិតា។

៣-**អរហន្តឃាត** សម្លាប់ព្រះអរហន្ត។

៤-**លោហិតុប្បាទៈ** ប្រទូស្តព្រះពុទ្ធអង្គ រហូតដល់ញុំាងព្រះលោហិតឱ្យពុរពង់ឬឱ្យជោកជាំ។

៥-**សង្ឃភេទ** ញុំាងសង្ឃឱ្យបែកគ្នា។

កម្ម៥យ៉ាងនេះជាបាបធ្ងន់ឃាត់សួគ៌ឃាត់និព្វានតាំងនៅក្នុងឋានបារាជិក របស់អ្នកកាន់ព្រះពុទ្ធសាសនា ហាមមិនឱ្យធ្វើយ៉ាងនេះជាដាច់ខាត ។

## អាយុកាលនៃមហានរកនីមួយៗ

| ឈ្មោះ | អាយុ | ធៀបមកមនុស្ស | សរុបឆ្នាំមនុស្ស |
|---|---|---|---|
| ១-សញ្ជីវនរក | ៤០០ឆ្នាំ | ១ថ្ងៃនរក=៩លានឆ្នាំ | ៤,៥០០ លានឆ្នាំ |
| ២-កាឡសុត្តនរក | ១០០០ឆ្នាំ | ១ថ្ងៃនរក=៣៦លានឆ្នាំ | ៣៦,០០០លានឆ្នាំ |
| ៣-សង្ឃាតនរក | ២០០០ឆ្នាំ | ១ថ្ងៃនរក=១៤៥លានឆ្នាំ | ២៩០,០០០លានឆ្នាំ |
| ៤-ចូឡរោរុវនរក | ៤០០០ឆ្នាំ | ១ថ្ងៃនរក=២៣៤លានឆ្នាំ | ៩៣៦,០០០លានឆ្នាំ |
| ៥-មហារោរុវនរក | ៨០០០ឆ្នាំ | ១ថ្ងៃនរក=៩២១៦លានឆ្នាំ | ៧៣,៧២៨,០០០លានឆ្នាំ |
| ៦-តាបននរក | ១៦០០០ឆ្នាំ | ១ថ្ងៃនរក=១៨៤២១២លានឆ្នាំ | ២,៩៤៧,៣៩២,០០០ លានឆ្នាំ |
| ៧-មហាតាបននរក | ១ភាគ២កប្ប | មិនមានសរសេរទុក | រាប់មិនអស់ |
| ៨-អវិចីនរក | ១កប្ប | មិនមានសរសេរទុក | រាប់មិនអស់ ។ |

## អភិណ្ហប្បច្ចវេក្ខណៈ៥យ៉ាង

គ្រហស្ថបព្វជិតគួរពិចារណាធម៌៥ប្រការនេះរាល់ថ្ងៃថា

១-**ជរាធម្មោម្ហិ** អាត្មាអញមានសេចក្តីចាស់ជរាជាធម្មតា មិនកន្លងសេចក្តីចាស់ជរាបានឡើយ ។

២-**ព្យាធិធម្មោម្ហិ** អាត្មាអញមានសេចក្តីឈឺចាប់ជាធម្មតា មិនអាចកន្លងសេចក្តីឈឺចាប់បានឡើយ ។

៣-**មរណធម្មោម្ហិ** អាត្មាអញមានសេចក្តីស្លាប់ជាធម្មតា មិនកន្លងសេចក្តីស្លាប់បានឡើយ ។

៤-**សព្វេហិ មេ បិយេហិ**អាត្មាអញមានសេចក្តីព្រាត់ប្រាសចាក របស់ជាទីស្រឡាញ់ជាទីគាប់ចិត្តទាំងអស់ ។

៥-**កម្មស្សកោម្ហិ** អាត្មាអញមានកម្មជារបស់ខ្លួនអាត្មាអញ ធ្វើកម្មល្អនឹងបានផលល្អធ្វើកម្មអាក្រក់នឹងបានផលអាក្រក់ ។

## វេសារជ្ជករណធម៌ ធម៌ធ្វើឱ្យក្លាហាន៥យ៉ាង

១-**សទ្ធា** ជឿរបស់ដែលគួរជឿ

២-**សីល** រក្សាកាយវាចាឱ្យរៀបរយ

៣-**ពាហុស្សច្ចៈ** ជាអ្នកសិក្សារៀនសូត្រច្រើន

៤-**វីរិយារម្ភៈ** ប្រារព្ធសេចក្ដីព្យាយាម

៥-**បញ្ញា** ដឹងរបស់ដែលគួរដឹង ។

## អង្គនៃធម្មកថិក អ្នកសម្ដែងធម៌៥យ៉ាង

១-សម្ដែងតាមលំដាប់មិនច្រួតកាត់ពេក ឱ្យខូចសេចក្ដី ។

២-លើកយកហេតុផលមកអាងណែនាំឱ្យអ្នកស្ដាប់ងាយចូលចិត្ត ។

៣-តាំងចិត្តមេត្តាប្រាថ្នាឱ្យជាប្រយោជន៏ដល់អ្នកស្ដាប់ ។

៤-មិនសម្ដែងធម៌ព្រោះឃើញអាមិសៈ ។

៥-មិនសម្ដែងធម៌លើកខ្លួនឯងបន្តុះបង្អាប់អ្នកដទៃ ។

ភិក្ខុជាធម្មកថិកគប្បីតាំងអង្គ៥យ៉ាងនេះទុកក្នុងខ្លួន ។

## ធម្មស្សវនានិសង្ស អានិសង្សនៃការស្តាប់ធម៌៥យ៉ាង

១-**អស្សុតំ សុណាតិ** រមែងបានស្តាប់ធម៌ដែលមិនធ្លាប់បានស្តាប់

២-**សុតំ បរិយោទបេតិ** ធម៌ណាដែលធ្លាប់ស្តាប់ហើយ តែមិនទាន់ចូលចិត្ត នឹងចូលចិត្តច្បាស់ឡើង

៣-**កង្ខំ វិហនតិ** រមែងកម្ចាត់បង់សេចក្តីសង្ស័យចេញបាន

៤- **ទិដ្ឋឹ ឧជុំ ករោតិ** រមែងធ្វើសេចក្តីឃើញឱ្យត្រង់តាមការពិត

៥-**ចិត្តមស្ស បសីទតិ** ចិត្តអ្នកស្តាប់នោះរមែងជ្រះថ្លា។

> សេចក្តីក្រីក្រ នាំឱ្យកើតក្តីអៀនខ្មាស ក្តីអៀនខ្មាសនាំឱ្យបាត់ក្តីក្លាហាន ការបាត់ក្លាហាន នាំឱ្យបុគ្គលដទៃមើលងាយ ការមើលងាយ នាំឱ្យកើតសេចក្តីទុក្ខ និងវិនាស។
>
> ទស្សនៈ ភិក្ខុ ប៉ាង ខាត់ វីរិយបណ្ឌិតោ

## ពលៈធម៌ជាកម្លាំង៥យ៉ាង

១-**សទ្ធា** សេចក្តីជឿ

២-**វីរិយៈ** សេចក្តីព្យាយាម

៣ **សតិ** សេចក្តីរលឹកបាន

៤-**សមាធិ** សេចក្តីតាំងចិត្តខ្ជាប់

៥-**បញ្ញា** សេចក្តីដឹងស្គាល់ការខុសត្រូវ។

**ស្វាមីគប្បីទំនុកបម្រុងដោយស្ថាន៥យ៉ាង**

១-រាប់អានលើកមុខថាជាភរិយា

២-មិនមើលងាយ

៣-មិនប្រព្រឹត្តកន្លងចិត្ត គឺមិនក្បត់ចិត្តភរិយា

៤-ប្រគល់ភារៈជាធំក្នុងផ្ទះឱ្យ

៥-ឱ្យគ្រឿងតែងខ្លួន។

**ភរិយាគប្បីប្រតិបត្តិស្វាមីដោយស្ថាន៥យ៉ាង**

១-ចាត់ចែងការងារដោយល្អ

២-សង្គ្រោះញាតិខាងស្វាមីដោយល្អ

៣-មិនប្រព្រឹត្តកន្លងចិត្តស្វាមីគឺមិនក្បត់ចិត្តប្តី

៤-រក្សាទ្រព្យដែលស្វាមីរកបានមក

៥-ឧស្សាហ៍ មិនខ្ជិលក្នុងកិច្ចការទាំងពួង។

**មច្ឆរិយៈ៥យ៉ាង**

១-**អាវាសមច្ឆរិយៈ** សេចក្តីកំណាញ់ក្នុងអាវាស

២-**កុលមច្ឆរិយៈ** កំណាញ់ក្នុងត្រកូល

៣-**លាភមច្ឆរិយៈ** កំណាញ់ក្នុងលាភ

៤-**វណ្ណមច្ឆរិយៈ** កំណាញ់ក្នុងវណ្ណៈ

៥-**ធម្មមច្ឆរិយៈ** កំណាញ់ក្នុងធមិ។

## មារ៥យ៉ាង

១-**ខន្ធមារ** មារគឺខន្ធ៥

២-**កិលេសមារ** មារគឺកិលេស

៣-**អភិសង្ខារមារ** មារគឺអកុសលកម្ម

៤-**មច្ចុមារ** មារគឺសេចក្តីស្លាប់

៥-**ទេវបុត្តមារ** មារគឺទេវបុត្រ ។

## សម្បទា ការបរិបូណ៌៥យ៉ាង

១-**ញាតិសម្បទា** បរិបូណ៌ដោយញាតិ

២-**ភោគសម្បទា** បរិបូណ៌ដោយភោគៈ

៣-**អារោគ្យសម្បទា** បរិបូណ៌ដោយភាពមិនមានរោគ

៤-**សីលសម្បទា** បរិបូណ៌ដោយសីល

៥-**ទិដ្ឋិសម្បទា** បរិបូណ៌ដោយទិដ្ឋិ គឺសម្មាទិដ្ឋិ ។

## ស្ត្រីប្រកបដោយកល្យាណធម៌៥យ៉ាង

១-**បុព្វុដ្ឋាយិនី** ជាស្ត្រីក្រោកឡើងមុនប្តី ។

២-**បច្ឆានិបាតិនី** ជាស្ត្រីបរិភោគ និងផ្ទំក្រោយប្តី ។

៣-**និវាសន្តបតិសេវនី** ជាស្ត្រីរួមសំវាសជាមួយ នឹងប្តីឥតមានគំនិតអាក្រក់ ។

៤-**បិយវាទី** ជាស្ត្រីមានសវនីយ៍ពីរោះគួរឱ្យប្តី គួរឱ្យព្រះរាជាផ្សៀងព្រះកាណ៌ចាំស្តាប់ ។

៥-**មនាបចារិនី** គឺជាស្ត្រីចេះផ្គាប់ផ្គុនប្តីមិនឱ្យឆ្គងចិត្តសោះ ។

"កល្យាណធម៌នេះគឺភរិយាត្រូវគោរពប្តីដើម្បីនៅជាសុខ"

## វត្ថុតាងសម្រាប់ព្រះពុទ្ធសាសនាមាន៥យ៉ាង

១-ព្រះស្តូប

២-ព្រះសារីរិកធាតុ

៣-ព្រះពោធិព្រឹក្ស

៤-ព្រះពុទ្ធបដិមា

៥-ព្រះត្រៃបិដក៨៤000ព្រះធម្មក្ខន្ធ។

## ថ្ងៃ ខែ ឆ្នាំ ជាដំណើរនៃព្រះសម្មាសម្ពុទ្ធ

**ចាប់** រ. អា. ព្រ.

**ចេញ** ច. ពិ. សុក្រ

**រាជ្យ** ឆ្លូវ ក. អា.

**បួស** ថោះ អា. ព្រ.

**ត្រាស់** រ. ពិ. ពុធ.

**កំ.** រោង មាឃ សុក្រ

**និ.** ម្សាញ់ ពិ អង្គ។

| | |
|---|---|
| ចាប់ គឺចាប់បដិសន្ធិ | រ.គឺឆ្នាំរកា |
| ចេញ គឺប្រសូត | អា.គឺខែអាសាធ |
| រាជ្យ គឺសោយរាជ្យ | ព្រ.គឺថ្ងៃព្រហស្បតិ៍ |
| បួស គឺថ្ងៃបួស | ក.គឺខែកត្តិក |
| ត្រាស់ គឺត្រាស់ដឹង | ពិ.គឺខែពិសាខ |
| កំ គឺកំណត់អាយុសង្ខារ | |
| និ គឺនិព្វាន | |

# ក្នុងភទ្ទកប្បនេះមានព្រះពុទ្ធ៥ព្រះអង្គត្រាស់ដឹង

| នាមព្រះពុទ្ធ | កន្លែងត្រាស់ដឹង | ព្រះជន្ម | បល្ល័ង្ក កម្ពស់ |
|---|---|---|---|
| -កកុសន្ធោ | សិរីលព្រឹក្ស(ច្រេស) | ៤០០០០ឆ្នាំ | ២៦ហត្ថ |
| -កោនាគមនោ | ឧទុម្ពរព្រឹក្ស (ល្វា) | ៣០០០០ឆ្នាំ | ២០ហត្ថ |
| -កស្សបោ | និគ្រោធព្រឹក្ស (ជ្រៃ) | ២០០០០ឆ្នាំ | ១៥ហត្ថ |
| -គោតម | អស្សត្ថព្រឹក្ស (ពោធិ៍បាយ) | ៨០ឆ្នាំ | ១៤ហត្ថ |
| -មេត្តេយ្យ | | ៨០០០០ឆ្នាំ | |

កិរិយាបានទ្រព្យ១ ភាពជាបុគ្គលមិនមានរោគជានិច្ច១ ភរិយាជាទីស្រឡាញ់១ ភរិយាពោលពាក្យពីរោះ១ កូនប្រដៅងាយ១ និងមានវិជ្ជាធ្វើប្រយោជន៍ដល់សាធារណជន១ បពិត្រព្រះរាជា ធម៌ទាំង៦ប្រការនេះជាបរមសុខក្នុងជីវិតលោកនេះ ។

បិតាធ្វើបំណុលទុកឱ្យកូនជាសត្រូវ មាតាប្រព្រឹត្តទុច្ចរិតខុសគន្លងប្រពៃណីជាសត្រូវ ភរិយាមានរូបល្អជាសត្រូវ កូនល្ងង់ក៏ជាសត្រូវ ។

ទស្សនៈ ភិក្ខុ ប៉ាង ខាត់ វីរិយបណ្ឌិតោ

# ប្រតិទិនឆ្នាំព្រះពុទ្ធសមណគោតម[៣៦]

| ជូត | ឆ្លូវ | ខាល | ថោះ | រោង | ម្សាញ់ | មមី | មមែ | វក | រកា | ច | កុរ |
|---|---|---|---|---|---|---|---|---|---|---|---|

| ច | កុរ | ជូត | ឆ្លូវ | ឃាល | ថោះ | រោង | ម្សាញ់ | មមី | មមែ | វក | រកា |
|---|---|---|---|---|---|---|---|---|---|---|---|
| ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ |
| ១៣ | ១៤ | ១៥ | ១៦ អភិសេក | ១៧ | ១៨ | ១៩ | ២០ | ២១ | ២២ | ២៣ | ២៤ |
| ២៥ | ២៦ | ២៧ | ២៨ | ២៩ ចេញបួស | ៣០ | ៣១ | ៣២ | ៣៣ | ៣៤ | ៣៥ ត្រាស់ដឹង | ៣៦ |
| ៣៧ | ៣៨ | ៣៩ | ៤០ | ៤១ | ៤២ | ៤៣ | ៤៤ | ៤៥ | ៤៦ | ៤៧ | ៤៨ |
| ៤៩ | ៥០ | ៥១ | ៥២ | ៥៣ | ៥៤ | ៥៥ | ៥៦ | ៥៧ | ៥៨ | ៥៩ | ៦០ |
| ៦១ | ៦២ | ៦៣ | ៦៤ | ៦៥ | ៦៦ | ៦៧ | ៦៨ | ៦៩ | ៧០ | ៧១ | ៧២ |
| ៧៣ | ៧៤ | ៧៥ | ៧៦ | ៧៧ | ៧៨ | ៧៩ | ៨០ បរិនិព្វាន | | | | |

## ចេតិយ៥គឺ

**១-បរិភោគ ចេតិយ** អដ្ឋបរិក្ខារ( តម្កល់បរិក្ខារ) ។

**២-ធាតុ ចេតិយ** គឺបញ្ចុះព្រះសារីរិកធាតុ ឬតម្កល់ព្រះសារីរិកធាតុ

**៣-អធិដ្ឋាន ចេតិយ** ព្រះបាទទាំង៥ស្ថាន( តម្កល់ស្ថានព្រះបាទ)

**៤-ធម្ម ចេតិយ** បរិយត្តិធម៌ (តម្កល់គម្ពីរ) ។

**៥-ឧទ្ទេសិក ចេតិយ** តម្កល់ព្រះពុទ្ធបដិមា ។

## ចំណងធំ១០ប្រការ

**១-មាតា លោកេ ពន្ធនំ** មាតាចំណងក្នុងលោក

**២-បិតា លោកេ ពន្ធនំ** បិតាចំណងក្នុងលោក

**៣-ភរិយា លោកេ ពន្ធនំ** ភរិយាចំណងក្នុងលោក

**៤-ញាតិ លោកេ ពន្ធនំ** ញាតិចំណងក្នុងលោក

**៥-មិត្ត លោកេ ពន្ធនំ** មិត្តចំណងក្នុងលោក

---

៣៦-មាគ៌ាជីវិតនៃព្រះពោធិសត្វ ទំព័រ១៧០ រៀបរៀងដោយ បណ្ឌិត កុល-ផេង ព.ស.២៥៥២ ។

៦-**ធនំ លោកេ ពន្ធនំ** ទ្រព្យចំណងក្នុងលោក
៧-**លាភសក្ការ លោកេ ពន្ធនំ** លាភ សក្ការៈចំណងក្នុងលោក
៨-**ឥស្សរិយយស លោកេ ពន្ធនំ** ឥស្សរិយយសចំណងក្នុងលោក
៩-**បញ្ចកាមគុណា លោកេ ពន្ធនំ** កាមគុណ៥ចំណងក្នុងលោក
១០-**បុត្តំ លោកេ ពន្ធនំ** បុត្រចំណងក្នុងលោក ។

## វត្ថុតាងនៃព្រះពុទ្ធសាសនាលក្ខិតមាន៥យ៉ាង

១-**ព្រះបដិមា** រូបស្នងរបស់ព្រះពុទ្ធ
២-**ដើមពោធិព្រឹក្ស** ដើមឈើដែលព្រះអង្គត្រាស់ដឹង
៣-**ព្រះស្តូបឬចេតិយ**សម្រាប់បញ្ចុះព្រះធម្មក្ខន្ធនិងអដ្ឋិព្រះសម្មាសម្ពុទ្ធ
៤-**ព្រះជិនធាតុ** ធាតុរបស់ព្រះជិនស្រី
៥-**ព្រះធម្មក្ខន្ធ៨៤000** ដែលតាំងនៅក្នុងភាជន៍គឺបិដកទាំងបី ។

## ពុទ្ធកិច្ចមាន៥យ៉ាង

ពុទ្ធកិច្ចប្រែថាកិច្ចដែលព្រះអង្គត្រូវធ្វើឬត្រូវប្រព្រឹត្តមាន៥យ៉ាង÷
១-**បុព្វណ្ហេ បិណ្ឌបាតញ្ច** ទ្រង់បិណ្ឌបាតក្នុងវេលាព្រឹក ។
២-**សាយណ្ហេ ធម្មទេសនំ** ទ្រង់សម្តែងព្រះធម៌ក្នុងវេលាល្ងាច ។
៣-**បទោសេ ភិក្ខុឱវាទំ** ទ្រង់ប្រទានឱវាទដល់ភិក្ខុក្នុងវេលាព្រលប់ ។
៤-**អឌ្ឍរត្តេ ទេវបញ្ហានំ** ទ្រង់ដោះប្រស្នាទេវតាវេលាអធ្រាត្រ ។
៥-**បច្ចូសេវគតេកាលេ ភព្វាភព្វេ វិលោកនំ** ទ្រង់ពិចារណាមើល ឧបនិស្ស័យសត្វ ដែលត្រូវគួរត្រាស់ដឹង និងមិនគួរត្រាស់ដឹងក្នុងវេលាបែកបច្ចូសសម័យជិតភ្លឺ ។

## បុគ្គលដែលធរណីស្រូបក្នុងជំនាន់ពុទ្ធកាលមាន៥នាក់

១-**សុប្បពុទ្ធ សក្យរាជ** ព្រោះទោសបិទផ្លូវជាទីគោចរនៃព្រះពុទ្ធ។

២-**ទេវទត្ត** ព្រោះទោសសង្ឃភេទជាដើម។

៣-**នាងចិញ្ចាមាណវិកា** ព្រោះទោសធ្វើឧបាយ បង្ខូចព្រះពុទ្ធដោយអសទ្ធម្មជារឿងមិនពិត។

៤-**នន្ទិយ** ព្រោះទោសប្រហារព្រះសារីបុត្រ។

៥-**អជាតសត្តុរាជ** ព្រោះទោសសម្លាប់បិតាខ្លួនឯង។

## ពាក្យដែលត្រូវសួរមាន៥ប្រការ

១-**អទិដ្ឋជោតនា បុច្ឆា** សួរដើម្បីដឹងក្នុងវត្ថុ ដែលខ្លួនមិនទាន់ដឹងមិនទាន់យល់។

២-**ទិដ្ឋសំ សន្ទនា បុច្ឆា** សួរដើម្បីប្រៀបធៀបនឹងវត្ថុដែលខ្លួនដឹង។

៣-**វិមតិច្ឆេទនា បុច្ឆា** សួរដើម្បីកាត់នូវសេចក្តីសង្ស័យ។

៤-**អនុមតិ បុច្ឆា** សួរដើម្បីការយល់ឃើញប្រពៃ (អនុមតិយល់ស្រប)។

៥-**កថេតុកម្យតា បុច្ឆា** សួរដើម្បីឆ្លើយខ្លួនឯង។

> វិជ្ជាបើមិនយកទៅប្រើប្រាស់ ជាពិសពុល ភោជនដែលបរិភោគទៅហើយមិនរលួយជាពិសពុលសភាពជាពិសពុលសម្រាប់អ្នកក្រីក្រ ស្ត្រីក្រមុំជាពិសពុលសម្រាប់មនុស្សចាស់ជរា។
>
> ទស្សនៈ ភិក្ខុ ប៉ាង ខាត់ វីរិយបណ្ឌិតោ

## ព្យសនៈ ការវិនាស៥យ៉ាង

១-**ញាតិព្យសន** ការវិនាសចាកញាតិ

២-**ភោគព្យសន** ការវិនាសចាកភោគៈ

៣-**រោគព្យសន** ការវិនាសព្រោះរោគ

៤-**សីលព្យសន** ការវិនាសចាកសីល

៥-**ទិដ្ឋិព្យសន** ការវិនាសចាកសម្មាទិដ្ឋិ។

## ហេតុឱ្យកើតទិដ្ឋិគតសម្បយុត្តចិត្តមាន៥យ៉ាង

១-**ទិដ្ឋិជ្ឈាសយតា** មានការយល់ខុសជាអធ្យាស្រ័យ

២-**ទិដ្ឋិវិប្បន្នបុគ្គលសេវនតា** សេពគប់បុគ្គលដែលវិបត្តិព្រោះទិដ្ឋិ

៣-**សទ្ធម្មវិមុខតា** បែរមុខចេញពីព្រះសទ្ធម្ម

៤-**មិច្ឆាវិតក្កពហុលតា** ជាអ្នកច្រើនទៅដោយមិច្ឆាវិតក្កៈ

៥-**អយោនិសោ ឧម្មុជ្ជនំ** មិនពិចារណាដោយឧបាយប្រាជ្ញា។

## សង្ស័យក្នុងអនាគត៥

១-**ភវិស្សាមិនុខោ អហំ អនាគតមទ្ធានំ** ក្នុងអនាគតកាលអាត្មាអញនឹងកើតទៀតដែរឬទេ?

២-**ននុខោ ភវិស្សាមិ អនាគតមទ្ធានំ** ឬក្នុងអនាគតកាលអាត្មាអញនឹងមិនកើតទៀតឬទេ?

៣-**កឹនុខោ ភវិស្សាមិ អនាគតមទ្ធានំ** ក្នុងអនាគតកាលអាត្មាអញនឹងកើតជាជាតិអ្វី?

៤-**ភវិស្សាមិ ឧទាហុ អនាគតមទ្ធានំ** ក្នុងអនាគតកាលអាត្មាអញមានសណ្ឋានទ្រង់ទ្រាយដូចម្ដេច?

៥-**កឹ ហុត្វា កឹ ភវិស្សាមិ នុខោអហំ អនាគតមទ្ធានំ** ក្នុងអនាគតកាលអាត្មាអញនឹងមានជាតិជាអ្វី ឬមានសណ្ឋានទ្រង់ទ្រាយដូចម្ដេច? ។

## លោកិយអភិញ្ញា៥យ៉ាង

១-**ឥទ្ធិវិធ អភិញ្ញា** អភិញ្ញាដែលសម្ដែងឫទ្ធិបានផ្សេងៗ។

២-**ទិព្វសោត អភិញ្ញា** អភិញ្ញាដែលធ្វើឱ្យកើតត្រចៀកទិព្វ។

៣-**ចេតោបរិយ អភិញ្ញា** អភិញ្ញាដែលកំណត់ដឹងចិត្តអ្នកដទៃ។

៤-**បុព្វេនិវា សានុស្សតិ អភិញ្ញា** អភិញ្ញាដែលឱ្យរលឹកដល់ជាតិមុនបាន។

៥-**ទិព្វចក្ខុ អភិញ្ញា** អភិញ្ញាដែលឱ្យកើតភ្នែកទិព្វ។

## បញ្ញាចក្ខុ៥យ៉ាង

១-**ពុទ្ធចក្ខុ** ព្រះនេត្ររបស់ព្រះពុទ្ធ ដែលជ្រាបនិស្ស័យបារមីរបស់សត្វ។

២-**សមន្តចក្ខុ** ព្រះនេត្រដែលដឹងធម៌ដោយជុំវិញ។

៣-**ញាណចក្ខុ** ព្រះនេត្រដែលជាប្រាជ្ញាត្រាស់ដឹងធម៌។

៤-**ទិព្វចក្ខុ** ព្រះនេត្រដែលអាចឃើញបានឆ្ងាយ។

៥-**ធម្មចក្ខុ** ព្រះនេត្រឃើញធម៌ដែលជាត្រៃលក្ខណ៍។[៣៧]

> អាយុ១ កម្ម១ ទ្រព្យ១ វិជ្ជា១ និងសេចក្ដីស្លាប់១
> ធម៌ទាំងប្រាំប្រការនេះកើតសម្រេចមកជាមួយរាង
> កាយមនុស្ស តាំងពីស្ថិតនៅក្នុងគភ៌ម្ដេះ ។
> ទស្សនៈ ភិក្ខុ ប៉ាង ខាត់ វីរិយបណ្ឌិតោ

៣៧-ភិក្ខុ គង់ សុមិត្ត អភិធម្មត្ថសង្គហៈ៩បរិច្ឆេទ ព.ស.២៥៥២។

## បុណ្យមានអានិសង្ស៥យ៉ាង

១-**ភិក្ខុបញ្ញា វិសារទា** មានប្រាជ្ញាក្លៀវក្លាមុះមុត

២-**សុវណ្ណតា** មានពណ៌សម្បុរល្អ

៣-**សុរូបតា** មានរូបល្អ

៤-**សុសណ្ឋានា** មានទ្រង់ទ្រាយល្អ

៥-**ចក្កវត្តិរាជា ហោតិ** នឹងបានទៅជាស្តេចចក្រពត្តិ ក្នុងជាតិណាមួយពុំខានឡើយ ។

## តួនាទីមាតាបិតាមាន៥យ៉ាង

១-**បាបានិ វារេន្តិ** មាតាបិតាគប្បីហាមកូនឱ្យវៀរចាកអំពើបាបទាំងពួង ។

២-**កល្យាណេ និវេសេន្តិ** ញុំាងកូនឱ្យតម្កល់នៅក្នុង កុសលធម៌ទាំងឡាយ ។

៣-**សិប្បំសិក្ខាបេន្តិ** គប្បីអប់រំកូនឱ្យពេញចិត្ត ក្នុងការសិក្សារៀនសូត្រ និយាយសម្តីត្រឹមត្រូវច្បាស់លាស់ ។

៤-**បដិរូបេនទារេន សំយោជេន្តិ** លុះកូនមានវ័យធំល្មមកន្លងផុតពីការសិក្សាហើយមាតាបិតាគប្បីរៀបចំឱ្យមានផ្ទះសំបែងគូស្វាមីភរិយាតាមការយល់ព្រមរវាងសាមីទាំងសងខាង ។

៥-**ទាយជ្ជំនិយ្យា ទេន្តិ** លុះរៀបចំកូនហើយមាតាបិតាត្រូវចែកទ្រព្យសម្បត្តិដល់កូន ។[៣៨]

៣៨-យិន-វ៉ន់ ប្រជុំបុញ្ញប្បវត្តិ គ.ស.១៩៧២ ។

## តួនាទីបុត្រធីតា៥យ៉ាង

១-**ភរណំ** បុត្រធិតាទាំងឡាយគប្បីដឹងថា ខ្លួនអាចរស់មកដោយសារមាតាបិតាដូច្នេះត្រូវចិញ្ចឹមគាត់វិញដោយបច្ច័យទាំងឡាយ ៤ជាដើម ។

២-**កិច្ច ករណំ** ការងាររបស់មាតាបិតាទាំងប៉ុន្មានដែលមានឡើង យើងជាបុត្រធិតា គួរបញ្ឈប់ការងាររបស់ខ្លួនសិន ហើយទៅជួយការងារពួកគាត់ ។

៣-**កុលវង្សថបនំ** យើងជាកូនត្រូវប្រព្រឹត្តចរិយាសណ្ដាប់ធ្នាប់ឱ្យ សមរម្យល្អដើម្បីលើកតម្កើងវង្សត្រកូលរបស់ខ្លួនឱ្យស្ថិតស្ថេរ ។

៤-**ទាយជ្ជារហបដិបជ្ជនំ** យើងជាកូនត្រូវយកចិត្តទុកដាក់បម្រើមាតាបិតាដោយសុចរិតតាំងចិត្តសុភាពរាបសា គោរពកោតខ្លាចព្រមទាំងស្ដាប់ការទូន្មានរបស់លោកហើយប្រតិបត្តិតាមដោយគោរព ។

៥-**ទក្ខិណានុប្បទានំ** បើមាតាបិតាទម្លុះកាយទម្លាយខន្ធ ទៅកាន់លោកខាងមុខ កូនត្រូវទទួលតបគុណគឺធ្វើបុណ្យឈាបនកិច្ចធ្វើបុណ្យឆ្លងឧស្សាហ៍សាងបុណ្យកុសល ឧទ្ទិសផលចំពោះមាតាបិតាកាលបើបុត្រធិតាទាំងឡាយណា បានធ្វើនូវតួនាទីទាំង៥នេះបុត្រធិតានោះឯងគឺរមែងបានសេចក្ដីសុខចម្រើនពុំខានឡើយ ។

## មហាបរិច្ចាគ៥យ៉ាង

១-**អង្គ បរិច្ចាគ** បរិច្ចាគអវយវៈតូចធំ ។

២-**ធន បរិច្ចាគ** បរិច្ចាគទ្រព្យសម្បត្តិឱ្យទៅជាទាន ។

៣-**បុត្ត បរិច្ចាគ** បរិច្ចាគបុត្រឱ្យទៅជាទាន ។

៤-**ភរិយ បរិច្ចាគ** បរិច្ចាគភរិយាឱ្យទៅដល់ស្មូមយាចក ។

៥-**ជីវិត បរិច្ចាគ** បរិច្ចាគជីវិត ។[៣៥]

៣៤-បណ្ឌិត កុល-ផេង មាគ៌ាជីវិតនៃព្រះពោធិសត្វ ព.ស.២៥៥២ ។

ធម៌ពួក៦

**អាលស្សានុយោគៈ** ខ្ជិលធ្វើការងារមានមូលហេតុ៦យ៉ាង

១-អាងថា រងាណាស់ មិនធ្វើការងារ ។

២-អាងថា ក្តៅណាស់ មិនធ្វើការងារ ។

៣-អាងថា ល្ងាចណាស់ មិនធ្វើការងារ ។

៤-អាងថា ព្រឹកណាស់ មិនធ្វើការងារ ។

៥-អាងថា ឃ្លានណាស់ មិនធ្វើការងារ ។

៦-អាងថា ស្រេកណាស់ មិនធ្វើការងារ ។

អ្នកស្រឡាញ់ចង់បានសេចក្តីចម្រើនដោយភោគទ្រព្យគប្បីវៀរចាកអបាយមុខ( ហេតុជាគ្រឿងឱ្យវិនាស) ៦យ៉ាងនេះចេញ ។

**ហេតុឱ្យកើតអសង្ខារិកចិត្តមាន៦យ៉ាង**

១-**អសង្ខារិកកម្មជនិត បដិសន្ធិកតា** ជាអ្នកបដិសន្ធិដោយកម្មដែលជាអសង្ខារិក ។

២-**កល្លកាយ ចិត្តតា** ជាអ្នកមានកាយនិងចិត្តរឹងប៉ឹងមាំមួន ។

៣-**ខន្តិ ពហុលតា** ជាអ្នកច្រើនដោយសេចក្តីអត់ធន់ ។

៤-**កត្តព្វកម្មេសុទិដ្ឋានិសំសតា** ជាអ្នកដែលឃើញនូវប្រយោជន៍ក្នុងការងារដែលគប្បីធ្វើ ។

៥-**កម្មេសុ ចិណ្ណវសិតា** ជាអ្នកជំនាញក្នុងការងារទាំងឡាយ ។

៦-**ឧតុភោជនាទិសប្បាយ លាភោ**បានសេចក្តីសប្បាយចិត្តក្នុងឧតុនិងភោជនជាដើម ។

## ហេតុឱ្យកើតសសង្ខារិកចិត្ត៦យ៉ាង

១-**សសង្ខារិក កម្មជនិត បដិសន្ធិកតា** ជាអ្នកបដិសន្ធិដោយកម្ម ដែលជាសសង្ខារិក ។

២-**អកល្លកាយចិត្តតា** ជាអ្នកមានកាយនិងចិត្តមិនរឹងប៉ឹងមិនមាំមួន ។

៣-**អខន្តិ ពហុលតា** ជាអ្នកច្រើនដោយសេចក្តីមិនអត់ធន់ ។

៤-**អកត្តព្វ កម្មេសុទិដ្ឋានិសំសតា** ជាអ្នកមិនឃើញប្រយោជន៍ក្នុង ការងារដែលគប្បីធ្វើ ។

៥-**កម្មេសុ អចិណ្ណវសិតា** មិនជំនាញក្នុងការងារទាំងឡាយ ។

៦-**ឧតុភោជនាទិអសប្បាយ លាភោ** មិនបានសេចក្តីសប្បាយចិត្ត ក្នុងឧតុ និងភោជនជាដើម ។

## ធម៌ដែលជាហេតុលះទោសៈមាន៦យ៉ាង

១-**មេត្តានិមិត្តស្ស ឧគ្គហោ** ការរៀនមេត្តានិមិត្ត ។

២-**មេត្តាភាវនា នុយោគោ** ការបំពេញព្យាយាមចម្រើនមេត្តា ។

៣-**កម្មស្សកតា បច្ចវេក្ខណា** ការពិចារណាថា សត្វមានកម្មជា របស់ខ្លួន ។

៤-**បដិសង្ខា នពហុលីកតា** ជាអ្នកច្រើនដោយការពិចារណា ។

៥-**កល្យាណ មិត្តតា** ជាអ្នកមានកល្យាណមិត្ត ។

៦-**សប្បាយកថា** សន្ទនារឿងជាទីពេញចិត្ត ។

## សង្ស័យក្នុងបច្ចុប្បន្ន៦យ៉ាង

១-**អហំ នុ ខោស្មិ** ឥឡូវនេះ?

២-**នោ នុ ខោស្មិ** ឬមិនមានទេ?

៣-**កឹ នុ ខោស្មិ** ឥឡូវនេះ អាត្មាអញមានជាតិជាអ្វី?

៤-**កថំ នុ ខោស្មិ** មានសណ្ឋានទ្រង់ទ្រាយដូចម្ដេច?

៥-**អយំ នុខោ សត្តោ កុតោ អាគតោ** តើសត្វនេះមកអំពីណា?

៦-**សោកុហឹគាមី ភវិស្សតិ** សត្វនោះ នឹងទៅកាន់ទីណាវិញ? ។

## ធម៌ដែលជាហេតុលះវិចិកិច្ឆា៦យ៉ាង

១-**ពហុស្សុ តតា** ភាពជាអ្នកស្ដាប់រៀនច្រើន

២-**បរិបុច្ឆ កតា** ភាពជាអ្នកចេះសាកសួរ

៣-**វិនយេ បកតញ្ញុតា** ការដឹងក្នុងព្រះវិន័យដោយជុំវិញ

៤-**អធិមោក្ខ ពហុលតា** ភាពជាអ្នកច្រើនដោយអធិមោក្ខ

៥-**កល្យាណ មិត្តតា** ភាពជាអ្នកមានកល្យាណមិត្ត

៦-**សប្បាយ កថា** មានការសន្ទនារឿងជាទីស្រឡាញ់ ។

## ហេតុឱ្យកើតកុសលឧបេក្ខា៦យ៉ាង

១-**ឧបេក្ខា បដិសន្ធិកតា** បដិសន្ធិដោយឧបេក្ខា

២-**អប្បសន្នតា** ជាអ្នកមានសទ្ធាតិច

៣-**អវិសុទ្ធ ទិដ្ឋិតា** មានការយល់ឃើញមិនបរិសុទ្ធ

៤-**អានិសំស អនស្សាទិតា** មិនឃើញអានិសង្សរបស់កុសល

៥-**មជ្ឈត្តារម្មណ សមាយោគោ** ប្រកបជាមួយនឹងអារម្មណ៍ប្រភេទកណ្តាល

៦-**កស្សចិបិឌ្ឍិតតា** មានឧបសគ្គរារាំង ។[៤០]

## រស្មី៦ពណ៌

១-**ពណ៌ខៀវ** កាលព្រះអង្គកើតជាស្តេចស្រីពិរាស្ត្រ ព្រះអង្គឆ្កៀលព្រះនេត្រទាំងពីរឱ្យជាទានដល់ឥន្ទព្រាហ្មណ៍ ។

២-**ពណ៌លឿង** កាលព្រះអង្គអារសាច់បិទព្រះពុទ្ធរូបព្រះចន្ទកាឡា ជាយក្សធ្វើជាជាងទងសាច់ក៏ក្លាយទៅជាមាស ។

៣-**ពណ៌ក្រហម**កាលកើតជាបទុមមាណព ម្តាយលោកពស់ខាំព្រះអង្គវះទ្រូងលូកកាត់យកសាច់បេះដូងផ្សំឱ្យម្តាយបានរួចជីវិត ។

៤-**ពណ៌ស**កាលកើតជាវេស្សន្តរឱ្យទានដំរីបច្ច័យនាគ្គេនទៅព្រាហ្មណ៍ស្រុកក្លិង្គរាស្ត្រ ឬកលិង្គរាស្ត្រ ។

៥-**ហង្សបាទ** កើតជាវិជ្ជាធរអារសាច់ឱ្យទានយក្ខបិសាច ។

៦-**ពណ៌ផ្លេក** កើតជាសោមបណ្ឌិត បង្កាត់ភ្លើងលោតចូលក្នុងភ្លើងចម្អិនសាច់ឱ្យទានប្រេត ។[៤១]

---

៤០-ភិក្ខុ គង់ សុមិត្ត អភិធម្មត្ថសង្គហៈ៩បរិច្ឆេទ ព.ស.២៥៥២ ។

៥១-ប្រជុំធមិបទ ។

ធម៌ពួក៧

**អរិយទ្រព្យ៧យ៉ាង**

ទ្រព្យគឺគុណសេចក្ដីល្អដែលមានក្នុងសន្ដានយ៉ាងប្រសើរហៅថាអរិយទ្រព្យ មាន៧យ៉ាងគឺ

១-**សទ្ធាធនំ** ទ្រព្យគឺសេចក្ដីជឿរបស់ដែលគួរជឿ

២-**សីលធនំ** ទ្រព្យគឺការរក្សាកាយឱ្យរៀបរយល្អ

៣-**ហិរិធនំ** ទ្រព្យគឺសេចក្ដីខ្មាសអំពើបាប

៤-**ឱត្តប្បធនំ** ទ្រព្យគឺសេចក្ដីខ្លាចអំពើបាប

៥-**សុតធនំ** ទ្រព្យគឺការធ្លាប់បានឮបានស្ដាប់មកច្រើន ការចេះចាំធម៌និងវិជ្ជាសិល្បៈច្រើន

៦-**ចាគធនំ** ទ្រព្យគឺការលះបែងចែករបស់ខ្លួនឱ្យដល់បុគ្គលដែលគួរឱ្យ

៧-**បញ្ញាធនំ** ទ្រព្យគឺសេចក្ដីដឹងស្គាល់របស់ ដែលជាប្រយោជន៍និងមិនជាប្រយោជន៍។ **កុសលកម្មឱ្យផលផ្សេងគ្នា៧យ៉ាងទៀត**

១-មានអាយុវែង ព្រោះមិនសម្លាប់សត្វ

២-មានរោគតិច ព្រោះមិនបៀតបៀនសត្វ

៣-មានសម្បុរល្អ ព្រោះមិនក្រោធ

៤-មានស័ក្តិធំ ព្រោះមិនច្រណែនក្នុងលាភជាដើមរបស់បុគ្គលដទៃ

៥-មានភោគច្រើន ព្រោះជាអ្នកឱ្យបាយទឹកជាដើមច្រើន

៦-កើតក្នុងត្រកូលខ្ពស់ ព្រោះជាអ្នកមិនរឹងត្អឹង ចេះគោរព

៧-មានបញ្ញាច្រើន ព្រោះសាកសួរ និង សិក្សាធម៌ ។

## ចាយចាណាពបានសមាទានវត្តបទ៧ប្រការ

១-ត្រូវចិញ្ចឹមមាតាបិតាអស់មួយជីវិត ។

២-ត្រូវកោតក្រែងបុគ្គលជារៀមច្បងក្នុងត្រកូលអស់មួយជីវិត ។

៣-ត្រូវមានវាចាល្អិតទន់( ផ្អែមល្ហែម) អស់មួយជីវិត ។

៤-មិនត្រូវមានវាចាញុះញង់អស់មួយជីវិត ។

៥-ត្រូវមានចិត្តប្រាសចាកសេចក្តីកំណាញ់ជាមន្ទិលជាអ្នកមានការបរិច្ចាគរួសរាន់ មានដៃលាងហើយដើម្បីឱ្យទានត្រេកអរនឹងការលះបង់អស់មួយជីវិត ។

៦-ត្រូវមានវាចាទៀងទាត់អស់មួយជីវិត ។

៧-មិនត្រូវមានសេចក្តីក្រោធ បើទុកជាសេចក្តីក្រោធឡើងដល់អាត្មាអញ អាត្មាអញត្រូវបន្ទោបង់នូវសេចក្តីក្រោធនោះមួយរំពេចអស់មួយជីវិត ។

## ដើមឈើប្រចាំកប្ប៧ដើម

១-ដើមជម្ពូព្រឹក្ស ដើមព្រីងប្រចាំនៅក្នុងជម្ពូទ្វីប

២-ដើមសិម្ពលី ដើមរការបស់ពួកគ្រុឌ

៣-ដើមកទម្ព ដើមក្ទម្ពប្រចាំនៅក្នុងអមរគោយានទ្វីប

៤-កប្បរុក្ខ ដើមកប្បព្រឹក្សក្នុងឧត្តរកុរុទ្វីប

៥-សិរីសៈ ដើមច្រេសក្នុងបុព្វវិទេហទ្វីប

៦-បារិឆត្តកៈ ដើមបារិឆត្តកៈនៅក្នុងឋានតាវត្តិង្ស

៧-ចិត្តបាដលិ ដើមច្រនៀងក្នុងភពអសុរ ។

ធម៌ពួក៨

## លោកធម៌៨យ៉ាង

ធម៌ដែលគ្របសង្កត់សត្វលោកសត្វលោកប្រព្រឹត្តទៅតាមធម៌នោះហៅថា លោកធម៌ៗនោះមាន៨យ៉ាងគឺ មានលាភ១ គ្មានលាភ១ មានយស១ គ្មានយស១ និន្ទា១ សរសើរ១ សុខ១ ទុក្ខ១ ។

លោកធម៌ទាំង៨នេះណាមួយកើតឡើងគួរពិចារណាថារបស់នេះកើតឡើង ហើយដល់អាត្មាអញសុទ្ធតែជារបស់មិនទៀងជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតាគួរឱ្យដឹងពិត តាមធម្មតាកុំឱ្យមកគ្របសង្កត់ចិត្តបានគឺកុំឱ្យមានសោមនស្សចំពោះអារម្មណ៍ ដែលជាទីប្រាថ្នាកុំទោមនស្សចំពោះអារម្មណ៍មិនជាទីប្រាថ្នា ។

## កម្លាំងរបស់មនុស្ស៧ប្រការ

១-**រោទនពលាទារកា** ទារកមានការយំជាកម្លាំង ។

២-**កោធពលាមាតុគាមា** មាតុគ្រាមមានសេចក្តីក្រោធជាកម្លាំង ។

៣-**អាវុធពលាចោរា** ចោរទាំងឡាយមានអាវុធជាកម្លាំង ។

៤-**ឥស្សរិយពលារាជានោ** ព្រះរាជាមានអំណាចជាកម្លាំង ។

៥-**ឧជ្ឈត្តិកពលាពាលា** បុគ្គលពាលមានការរករឿងជាកម្លាំង ។

៦-**និជ្ឈត្តិកពលាបណ្ឌិតា** បណ្ឌិតទាំងឡាយមានកិរិយារវាំងសតិជាកម្លាំង ។

៧-**បដិសង្ខារពលាពហុស្សុតា**ពហុស្សូតមានសេចក្តីពិចារណាជាកម្លាំង ។

៨-**ខន្តិ ពលាសមណព្រាហ្មណា** សមណព្រាហ្មណ៍ទាំងឡាយមានខន្តីជាកម្លាំង ។

## ស្ត្រីមើលងាយប្តីដោយហេតុ៨យ៉ាង

១-**ទលិទ្ទតា** ព្រោះប្តីជាមនុស្សកំសត់ទុគិត ។

២-**អាតុរតា** ព្រោះប្តីជាមនុស្សមានជំងឺជានិច្ច ។

៣-**ជិណ្ណកតា** ព្រោះប្តីជាមនុស្សចាស់គ្រាំគ្រា ។

៤-**សុរាសោណ្ឌតា** ព្រោះប្តីជាមនុស្សផឹកសុរា ។

៥-**មន្ទតា** ព្រោះប្តីជាមនុស្សល្ងង់ខ្លៅ ។

៦-**បមត្តតា** ព្រោះប្តីជាមនុស្សធ្វេសប្រហែស ។

៧-**សព្វកិច្ចេសុអវត្តនិកតា** ព្រោះប្តីមិនប្រព្រឹត្តធ្វើកិច្ចការទាំងពួង ។

៨-**សព្វធន មនុប្បាទនា** ព្រោះប្តីស្វែងរកទ្រព្យមិនបាន ។

> បុគ្គលសូម្បីគិតឃើញព្រេងវាសនា ក៏មិនគួរលះបង់សេចក្តីព្យាយាមខ្លួនចោលឡើយ បើបុគ្គលមិនព្យាយាមចម្រាញ់ល្ង មិនបានប្រេងល្ងទេ ។
>
> ទស្សនៈ ភិក្ខុ ប៉ាង ខាត់ វីរិយបណ្ឌិតោ

## ព្រះអានន្ទសូមពរ៨ប្រការពីព្រះសម្ពុទ្ធ

១-សូមព្រះអង្គកុំប្រទានចីវរប្រណីតដល់ខ្ញុំព្រះអង្គ។

២-សូមព្រះអង្គកុំប្រទានបិណ្ឌបាតប្រណីតដល់ខ្ញុំព្រះអង្គ។

៣-សូមកុំឱ្យខ្ញុំព្រះអង្គនៅក្នុងទីប្រថាប់ជាមួយនឹងព្រះអង្គ។

៤-សូមទ្រង់កុំនាំខ្ញុំព្រះអង្គទៅកាន់ទីនិមន្តនី។

៥-សូមព្រះអង្គយាងទៅកាន់ទីនិមន្តនីដែលខ្ញុំព្រះអង្គទទួលគេទុកហើយ។

៦-ខ្ញុំសូមព្រះអង្គនាំបរិស័ទមកពីចម្ងាយចូលគាល់បានក្នុងខណៈដែលគេបានមកដល់ហើយ។

៧-បើស្តេចសង្ស័យកើតឡើងក្នុងវេលាណា ខ្ញុំព្រះអង្គគាល់ទូលសួរបានក្នុង វេលានោះ។

៨-បើព្រះអង្គទ្រង់ទេសនាអ្វីក្នុងទីណាដែលខ្ញុំព្រះអង្គមិនទាន់បានស្តាប់សូមព្រះអង្គត្រាស់សម្តែងនូវរឿងនោះដល់ខ្ញុំព្រះអង្គ។

## សេចក្តីសង្ស័យ៨យ៉ាង

១-**ពុទ្ធេ កង្ខតិ** សង្ស័យក្នុងព្រះពុទ្ធ

២-**ធម្មេ កង្ខតិ** សង្ស័យក្នុងព្រះធម៌

៣-**សង្ឃេ កង្ខតិ** សង្ស័យក្នុងព្រះសង្ឃ

៤-**សិក្ខាយ កង្ខតិ** សង្ស័យក្នុងសិក្ខា

៥-**បុព្វន្តេ កង្ខតិ** សង្ស័យក្នុងខន្ធាយតនធាតុដែលជាអតីត

៦-**អបរន្តេ កង្ខតិ** សង្ស័យក្នុងខន្ធាយតនធាតុដែលជាអនាគត

៧-**បុព្វន្តាបរន្តេ កង្ខតិ** សង្ស័យក្នុងខន្ធាយតនៈធាតុដែលជាអតីត និង អនាគត

៨-**បដិច្ចសមុប្បាទេ កង្ខតិ** សង្ស័យក្នុងបដិច្ចសមុប្បាទធម៌ ។

## សំឡេងរបស់ព្រហ្មប្រកបដោយអង្គ៨

១-**វិសដ្ឋោ** ក្បោះក្បាយ

២-**វិញ្ញេយ្យោ** ងាយយល់

៣-**មញ្ជុ** ទន់ពីរោះ

៤-**សវនេយ្យោ** គួរស្តាប់

៥-**បិន្ទុ មូលំ** មូលល្អ

៦-**អវិសារី** មិនគ្រាវ

៧-**គម្ភីរោ** ក្រអួន

៨-**និន្នាទី** លាន់រំពង ។

## មហានរក៨រណ្តៅ

១-**សញ្ជីវ នរក** នរកឈ្មោះថាសញ្ជីវៈ

២-**កាឡសុត្ត នរក** នរកឈ្មោះថាកាឡសុត្តៈ

៣-**សង្ឃាត នរក** នរកឈ្មោះថាសង្ឃាតៈ

៤-**ចូឡរោរុវ នរក** នរកឈ្មោះថាចូឡរោរុវៈ

៥-**មហារោរុវ នរក** នរកឈ្មោះថាមហារោរុវៈ

៦-**តាបន នរក** នរកឈ្មោះថាតាបនៈ

៧-**មហាតាបន នរក** នរកឈ្មោះថាមហាតាបនៈ

៨-**អវិចី នរក** នរកឈ្មោះថាអវិចិ ។

បកិណ្ណកធម៌

**ប្រេត១២ពួក**

១-**វន្តាស ប្រេត** ប្រេតស៊ីរបស់ដែលខ្ជាក់ចេញហើយ

២-**កុណបាស ប្រេត** ប្រេតដែលស៊ីសាកសព

៣-**គូថខាទក ប្រេត** ប្រេតដែលស៊ីឧច្ចារៈ

៤-**អគ្គិជាលមុខ ប្រេត** ប្រេតដែលមានភ្លើងនៅក្នុងមាត់

៥-**សូចិមុខ ប្រេត** ប្រេតដែលមានមាត់ប៉ុនម្ជុល

៦-**តណ្ហដ្ដិត ប្រេត** ប្រេតដែលត្រូវសេចក្ដីលំបាកបៀតបៀន

៧-**សុនិជ្ឈាមក ប្រេត** ប្រេតដែលត្រូវឆេះខ្មៅដូចគល់ឈើ

៨-**សត្ថង្គ ប្រេត** ប្រេតមានកាយដូចភ្នំ

៩-**អជគរង្គ ប្រេត** ប្រេតមានរាងកាយដូចពស់ថ្លាន់

១០-**កុម្ភណ្ឌភារី ប្រេត** ប្រេតមានអណ្ឌៈជាភារៈធំប៉ុនឆ្នាំង

១១-**វិមានិក ប្រេត** ប្រេតមានវិមាន

១២-**មហិទ្ធិក ប្រេត** ប្រេតមានឫទ្ធិច្រើន។

> កូនក្មេងដែលមាតាបិតាបានហ្វឹកហ្វឺនហើយ ទៅជាកូនមាន
> គុណគាប់ប្រសើរបាន មិនដែលមានកូនក្មេង ណាបានទៅ
> ជាបណ្ឌិតដោយគ្រាន់តែច្បុតចេញពីគភ៌មាតាទេ។
>
> ទស្សនៈ ភិក្ខុ ប៉ាង ខាត់ វីរិយបណ្ឌិតោ

## ប្រេត២១ពួក

១-**អដ្ឋិសង្ខលិកបេត** ប្រេតឥតមានសាច់ឈាមឡើយមានតែរាងឆ្អឹង។

២-**មំសបេសី បេត** ប្រេតមានរាងកាយដូចជាចម្រៀកសាច់។

៣-**មំសបិណ្ឌ បេត** ប្រេតមានរាងកាយដូចជាដុំសាច់។

៤-**និច្ឆវិបុរិស បេត** ប្រេតប្រុសមានរាងកាយរងាលឥតស្បែក។

៥-**អសិលោម បេត** ប្រេតមានដាវដោតជាប់និងរាងកាយដូចជារោម។

៦-**សត្តិកលោម បេត** ប្រេតមានលំពែងដោតជាប់និងរាងកាយដូចជារោម។

៧-**ឧសុលោម បេត** ប្រេតមានព្រួញដោតជាប់នឹងរាងកាយដូចជារោម។

៨-**សូចិលោម បេត** ប្រេតទី១មានម្ជុលដោតជាប់ និងរាងកាយដូចជារោម។

៩-**សូចិលោម បេត** ប្រេតទី២មានដែកស្រួចចាក់ច្រូងច្រាងនា រាងកាយដូចជារោម។

១០-**កុម្ភណ្ឌភារី បេត** ប្រេតមានអណ្ឌៈជាភារៈធំប៉ុនឆ្នាំង។

១១-**គូថនិមុគ្គ បេត** ប្រេតលិចនៅក្នុងរណ្ដៅឧច្ចារៈ។

១២-**គូថខាទក បេត** ប្រេតស៊ីលាមក។

១៣-**និច្ឆវិត្ថី បេត** ប្រេតស្រីមានរាងកាយរងាលឥតស្បែក។

១៤-**មង្គុលិត្ថី បេត**ប្រេតស្រីមានរាងកាយអាក្រក់គួរខ្ពើមឆ្អើមមានក្លិនស្អុយ។

១៥-**ឱភិលិនី បេត** ប្រេតស្រីមានរាងកាយឆេះរោលនិងស្រោចដោយរងើកភ្លើង។

១៦-**អសីសកពន្ធ បេត** ប្រេតឥតក្បាលមានរាងកាយដូចសាកសពដាច់ ក្បាល( មុខមាត់នៅទ្រូង) ។

១៧-**ភិក្ខុ បេត** ប្រេតភិក្ខុមានភ្លើងឆេះសន្ធោសន្ធៅ ។

១៨-**ភិក្ខុនី បេត** ប្រេតភិក្ខុនីមានភ្លើងឆេះសន្ធោសន្ធៅ ។

១៩-**សិក្ខមានា បេត** ប្រេតសិក្ខាកាមមានភ្លើងឆេះសន្ធោសន្ធៅ

២០-**សាមណេរ បេត** ប្រេតសាមណេរមានភ្លើងឆេះសន្ធោសន្ធៅ

២១-**សាមណេរី បេត** ប្រេតសាមណេរីមានភ្លើងឆេះសន្ធោសន្ធៅ ។

# អាយុនៅទេវលោកនិងព្រហ្មលោក

## អាយុទេវតាជាន់ចាតុម្មហារាជិកា

ទេវតាចាតុម្មហារាជិកានេះមានអាយុ៥០០ឆ្នាំទិព្វជាប្រមាណ ។

គិតជាឆ្នាំមនុស្សគឺ

-១ថ្ងៃទេវតានេះ = ៥០ ឆ្នាំមនុស្ស

-១ខែទេវតានេះ = ១៥០០ ឆ្នាំមនុស្ស

-១ឆ្នាំទេវតានេះ=១៨០០០ឆ្នាំមនុស្ស ៥០០ឆ្នាំទេវតានេះស្មើនឹង៩លានឆ្នាំមនុស្ស ។

## អាយុទេវតាជាន់តាវត្តិង្ស

ទេវតាជាន់តាវត្តិង្សនេះមានអាយុ១០០០ឆ្នាំទិព្វជាប្រមាណ ។

គិតជាឆ្នាំមនុស្សគឺ

-១ថ្ងៃទេវតានេះ = ១០០ឆ្នាំមនុស្ស

-១ខែទេវតានេះ = ៣០០០ឆ្នាំមនុស្ស

-១ឆ្នាំទេវតានេះ=៣៦០០០ឆ្នាំមនុស្ស ១០០០ឆ្នាំទិព្វនេះស្មើនឹង ៣៦លាន ឆ្នាំមនុស្ស( ស្មើ៤ដងនៃចាតុម្មហារាជិកា)

## អាយុទេវតាជាន់យាមា

ទេវតាជាន់យាមានេះមានអាយុ២០០០ឆ្នាំទិព្វជាប្រមាណ។

គិតជាឆ្នាំមនុស្ស គឺ

-១ ថ្ងៃទេវតានេះ = ២០០ ឆ្នាំមនុស្ស

-១ ខែ ទេវតានេះ= ៦០០០ ឆ្នាំមនុស្ស

-១ ឆ្នាំទេវតានេះ = ៧២០០០ ឆ្នាំមនុស្ស ២០០០ ឆ្នាំទេវតានេះ =១៤៤ លានឆ្នាំមនុស្ស( ស្មើ១៦ដងនៃចាតុម្មហារាជិកាឬ៤ដងនៃតាវត្តិង្ស)

## អាយុទេវតាជាន់តុសិត

ទេវតាជាន់តុសិតានេះមានអាយុ៤០០០ឆ្នាំទិព្វជាប្រមាណ។

គិតជាឆ្នាំមនុស្ស គឺ

១ថ្ងៃទេវតានេះ = ៤០០ឆ្នាំមនុស្ស

១ខែទេវតានេះ = ១២០០០ឆ្នាំមនុស្ស

១ឆ្នាំទេវតានេះ = ១៤៤០០០ ឆ្នាំមនុស្ស ៤០០០ឆ្នាំទេវតានេះ=៥៧៦ លានឆ្នាំមនុស្ស( ស្មើ ៦៤ ដង នៃ ចាតុម្មហារាជិកា ឬ១៦ដងនៃតាវត្តិង្ស ឬ ៤ដងនៃយាមា)

## អាយុទេវតាជាន់និម្មានរតី

ទេវតាជាន់និម្មានរតីនេះមានអាយុ៨០០០ឆ្នាំទិព្វជាប្រមាណ។

គិតជាឆ្នាំមនុស្ស គឺ

១ថ្ងៃទេវតានេះ = ៨០០ឆ្នាំមនុស្ស

១ខែទេវតានេះ = ២៤០០០ឆ្នាំមនុស្ស

១ឆ្នាំទេវតានេះ=២៨៨០០០ឆ្នាំមនុស្ស ៨០០០ឆ្នាំទេវតានេះ=២៣០៤ លានឆ្នាំមនុស្ស( ស្មើ២៥៦ដងនៃចាតុម្មហារាជិកាឬ៤ដង នៃតុសិត)

## អាយុទេវតាជាន់បរនិម្មិតវសវត្តី

ទេវតាជាន់បរនិម្មិតវសវត្តីនេះមានអាយុ១៦០០០ឆ្នាំទិព្វជាប្រមាណ។

គិតជាឆ្នាំមនុស្សគឺ

១ថ្ងៃទេវតានេះ = ១៦០០ឆ្នាំមនុស្ស

១ខែទេវតានេះ = ៤៨០០០ឆ្នាំមនុស្ស

១ឆ្នាំទេវតានេះ = ៥៧៦០០០ឆ្នាំមនុស្ស ១៦០០០ឆ្នាំទេវតានេះ = ៩២១៦លានឆ្នាំមនុស្ស (ស្មើ១០២៤ដងនៃចាតុមមហារាជិកា ឬ៤ដង នៃនិម្មានរតី)។

## អាយុរបស់ព្រហ្ម១៦ជាន់

បឋមជ្ឈានភូមិ៣គឺ

១-**ព្រហ្មបរិសជ្ជា** មានអាយុមួយភាគបីនៃវិវដ្តដ្ឋាយីអសង្ខេយ្យកប្ប។

២-**ព្រហ្មបរោហិតា** មានអាយុពាក់កណ្តាលនៃវិវដ្ដដ្ឋាយីអសង្ខេយ្យកប្ប ។

៣-**មហាព្រហ្មា** មានអាយុ១វិវដ្ដដ្ឋាយីអសង្ខេយ្យកប្ប ។

ទុតិយជ្ឈានភូមិ៣គឺ

១-**បរិត្តាភាព្រហ្ម** មានអាយុ២មហាកប្ប

២-**អប្បមាណាភាព្រហ្ម** មានអាយុ៤មហាកប្ប

៣-**អាភស្សរាព្រហ្ម** មានអាយុ៨មហាកប្ប ។

តតិយជ្ឈានភូមិ ៣ គឺ

១-**បរិត្តសុភាព្រហ្ម** មានអាយុ១៦មហាកប្ប

២-**អប្បមាណសុភាព្រហ្ម** មានអាយុ៣២កប្ប

៣-**សុភកិណ្ហព្រហ្ម** មានអាយុ៦៤មហាកប្ប ។

**ចតុត្ថជ្ឈានភូមិ៧គឺ**

១-**វេហប្ផលាព្រហ្ម** មានអាយុ៥00មហាកប្ប

២-**អសញ្ញីសត្តាព្រហ្ម** មានអាយុ៥00មហាកប្ប

៣-**អវិហាព្រហ្ម** មានអាយុ ១000មហាកប្ប

៤-**អតប្បាព្រហ្ម** មានអាយុ២000មហាកប្ប

៥-**សុទស្សាព្រហ្ម** មានអាយុ៤000មហាកប្ប

៦-**សុទស្សីព្រហ្ម** មានអាយុ៨000មហាកប្ប

៧-**អកនិដ្ឋព្រហ្ម** មានអាយុ១៦000មហាកប្ប

## ស្ត្រីនឹងក្បត់ចិត្តប្តីដោយហេតុ៩យ៉ាង

១-**អារាមគមនសីលា** ឧស្សាហ៍ដើរទៅលេងសួនច្បារ ។

២-**ឧយ្យានគមនសីលា** ឧស្សាហ៍ដើរទៅលេងឧទ្យាន ។

៣-**នទីតិត្ថគមនសីលា** ឧស្សាហ៍ដើរទៅលេងកំពង់ទឹក ។

៤-**ញាតិកុលគមនសីលា** ឧស្សាហ៍ដើរទៅកាន់ត្រកូលញាតិ ។

៥-**បរកុលគមនសីលា** ឧស្សាហ៍ដើរលេងឯត្រកូលអ្នកដទៃ ។

៦-**អាភរណាយ គមនសីលា** ឧស្សាហ៍ទៅរកគ្រឿងតែងខ្លួន ។

៧-**មជ្ជបាយិនី** ចូលចិត្តផឹកទឹកស្រវឹង ។

៨-**តិត្ថិច្ឆិទ្ទេសុ ឱលោកនី** ចូលចិត្តសម្លឹងមើលតាមចន្លោះជញ្ជាំង និងតាមបង្អួច ។

៩-**គាមទ្វារេឋិត សីលា** ឧស្សាហ៍ទៅឈរលេងក្បែរទ្វារភូមិស្រុក

## បារមី១០យ៉ាង

១-**ទានបារមី** បារមី គឺការឱ្យទាន

២-**សីលបារមី** បារមី គឺការរក្សាសីល

៣-**នេក្ខម្មបារមី** បារមី គឺការចេញចាកកាម

៤-**បញ្ញាបារមី** បារមី គឺប្រាជ្ញាស្គាល់ហេតុផល

៥-**វីរិយបារមី** បារមី គឺសេចក្តីព្យាយាម

៦-**ខន្តិបារមី** បារមី គឺសេចក្តីអត់ធន់

៧-**សច្ចបារមី** បារមី គឺការប្រព្រឹត្តដោយស្មោះត្រង់

៨-**អធិដ្ឋានបារមី** បារមី គឺការតាំងមាំខ្ជាប់ខ្ជួន

៩-**មេត្តាបារមី** បារមី គឺមេត្តា

១០-**ឧបេក្ខាបារមី** បារមី គឺឧបេក្ខា។

## ឱវាទធនញ្ជ័យសេដ្ឋី១០យ៉ាង

១-ភ្លើងក្នុង កុំនាំចេញក្រៅ

២-ភ្លើងក្រៅ កុំនាំចូលក្នុង

៣-ត្រូវឱ្យបុគ្គលដែលគួរឱ្យ

៤-មិនត្រូវឱ្យដល់បុគ្គលដែលមិនគួរឱ្យ

៥-ត្រូវឱ្យដល់បុគ្គល ដែលឱ្យក្តី មិនឱ្យក្តី

៦-ត្រូវអង្គុយដោយស្រួលបួល

៧-ត្រូវបរិភោគដោយស្រួលបួល

៨-ត្រូវមានការគោរពជាចំបង (សៀវភៅខ្លះក៏ខុសគ្នាខ្លះត្រង់ចំណុចទី៨)

៩-ត្រូវបូជាភ្លើង ឬបម្រើភ្លើង

១០-ត្រូវថ្វាយបង្គំទេវតានៅផ្ទះ។

(ឱវាទនេះសេដ្ឋីឱ្យដល់នាង វិសាខាជាបុត្រី)

## នាថករណធម៌ធម៌ធ្វើជាទីពឹង១០យ៉ាង

១-**សីលៈ** រក្សាកាយវាចាឱ្យរៀបរយ។

២-**ពហុស្សច្ចៈ** ជាអ្នកបានរៀនបានស្តាប់ច្រើន។

៣-**កល្យាណមិត្តតា** ជាអ្នកមានមិត្តសម្លាញ់ល្អ។

៤-**សោតបស្សុតា** ជាអ្នកដែលគេប្រដៅងាយ ។

៥-**កឹករណីយេសុទក្ខតា**ជាអ្នកប៉ិនប្រសប់ព្រមទាំងឧស្សាហ៍យកចិត្តទុកដាក់ជួយក្នុងធុរៈរបស់ភិក្ខុ-សាមណេរផងគ្នា ។

៦-**ធម្មកាមតា** ជាអ្នកស្រឡាញ់ធមិ ។

៧-**វិរិយៈ** ព្យាយាមលះសេចក្ដីអាក្រក់ ប្រព្រឹត្តសេចក្ដីល្អ ។

៨-**សន្តុដ្ឋិ** សន្តោសចំពោះបច្ច័យ៤ តាមមានតាមបាន ។

៩-**សតិ**ចាំការដែលបានធ្វើនឹងពាក្យដែលបានពោលហើយសូម្បីយូរអង្វែង ។

១០-**បញ្ញា** ដឹងសេចក្ដីប្រព្រឹត្តទៅនៃកងសង្ខារ ។

## កថាវត្ថុ ពាក្យដែលគួរពោល១០យ៉ាង

១-**អប្បិច្ឆកថា** ពាក្យដែលនាំឱ្យមានប្រាថ្នាតិច ។

២-**សន្តុដ្ឋិកថា**ពាក្យដែលនាំឱ្យមានសន្តោសត្រេកអរចំពោះបច្ច័យ៤តាមមានតាមបាន ។

៣-**បវិវេកថា** ពាក្យដែលនាំឱ្យស្ងាត់កាយស្ងាត់ចិត្ត ។

៤-**អសំសគ្គកថា** ពាក្យដែលនាំមិនឱ្យច្រឡូកច្រឡំដោយពួកគណៈ ។

៥-**វិរិយារម្ភកថា** ពាក្យដែលនាំឱ្យប្រារព្ធព្យាយាម ។

៦-**សីលកថា** ពាក្យដែលនាំឱ្យតាំងនៅក្នុងសីល ។

៧-**សមាធិកថា** ពាក្យដែលនាំឱ្យធ្វើចិត្តឱ្យស្ងប់ ។

៨-**បញ្ញាកថា** ពាក្យដែលនាំឱ្យកើតបញ្ញា។

៩-**វិមុត្តិកថា** ពាក្យដែលនាំឱ្យធ្វើចិត្តឱ្យផុតចាកកិលេស។

១០-**វិមុត្តិញ្ញាណទស្សនកថា**ពាក្យដែលនាំឱ្យកើតសេចក្ដីដឹងឃើញក្នុងការណ៍ដែលចិត្តផុតចាកកិលេស។

## អាឃាតវត្ថុ១០យ៉ាងគឺ

១-គំនុំកើតឡើងថា ជនឯណោះបានប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍ដល់អាត្មាអញ។

២-គំនុំកើតឡើងថា ជនឯណោះកំពុងប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍ដល់អាត្មាអញ។

៣-គំនុំកើតឡើងថា ជនឯណោះនឹងប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍ដល់អាត្មាអញ។

៤-គំនុំកើតឡើងថា ជនឯណោះបានប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍ដល់បុគ្គលជាទីស្រឡាញ់ជាទីពេញចិត្តរបស់អាត្មាអញ។

៥-គំនុំកើតឡើងថា ជនឯណោះកំពុងប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍ដល់បុគ្គលជាទីស្រឡាញ់ជាទីពេញចិត្តរបស់អាត្មាអញ។

៦-គំនុំកើតឡើងថា ជនឯណោះនឹងប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍ដល់បុគ្គលជាទីស្រឡាញ់ជាទីពេញចិត្តរបស់អាត្មាអញ។

៧-គំនុំកើតឡើងថាជនឯណោះបានប្រព្រឹត្តនូវអំពើជាប្រយោជន៍ដល់បុគ្គល មិនជាទីស្រឡាញ់មិនជាទីពេញចិត្តរបស់អាត្មាអញ។

៨-គំនុំកើតឡើងថា ជនឯណោះកំពុងប្រព្រឹត្តនូវអំពើជាប្រយោជន៍ដល់បុគ្គលមិនជាទីស្រឡាញ់មិនជាទីពេញចិត្តរបស់អាត្មាអញ ។

៩-គំនុំកើតឡើងថា ជនឯណោះនឹងប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍ដល់បុគ្គលមិនជាទីស្រឡាញ់មិនជាទីពេញចិត្តរបស់អាត្មាអញ ។

១០-សេចក្តីក្រោធកើតឡើងក្នុងទីមិនគួរដូចពេលដែលដើរជំពប់ឬជាន់បន្លាជាដើម ។

## បុញ្ញកិរិយាវត្ថុ១០យ៉ាង

១-**ទានមយៈ**បុណ្យសម្រេចពីការធ្វើទានគឺការលះបង់ទ្រព្យឱ្យជា ប្រយោជន៍ដល់អ្នកដទៃ ។

២-**សីលមយៈ** បុណ្យសម្រេចពីការរក្សាសីលគឺវៀរទុច្ចរិតកម្ម ។

៣-**ភាវនាមយៈ**បុណ្យសម្រេចពីការចម្រើនសមថនិងវិបស្សនា ។

៤-**អបចាយនមយៈ**បុណ្យសម្រេចពីការគោរពឱនលំទោនដល់អ្នក ដែលគួរគោរពឱនលំទោន ។

៥-**វេយ្យាវច្ចមយៈ**បុណ្យសម្រេចពីការជួយធ្វើកិច្ចការនៃបុណ្យ ។

៦-**បត្តិទានមយៈ** បុណ្យសម្រេចពីការឧទ្ទិសចំណែកបុណ្យឱ្យអ្នកដទៃ ។

៧-**បត្តានុមោទនាមយៈ** បុណ្យសម្រេចពីការអនុមោទនា ។

៨-**ទេសនាមយៈ** បុណ្យសម្រេចពីការសម្តែងធម៌ ។

៩-**ធម្មស្សវនមយៈ** បុណ្យសម្រេចពីការស្តាប់ធម៌។

១០-**ទិដ្ឋុជុកម្ម** ដោយការធ្វើទិដ្ឋិឱ្យត្រឹមត្រូវល្អ។

**សម្មាទិដ្ឋិទសវត្ថុ១០យ៉ាង**

១-**អត្ថិ ទិន្នំ** យល់ថាទានដែលគេឱ្យហើយមានផល។

២-**អត្ថិ យិដ្ឋំ** យល់ថាការបូជាធំមានផល។

៣-**អត្ថិ ហុតំ** យល់ថាការបូជាតូចមានផល។

៤-**អត្ថិសុកតទុក្កតានំកម្មានំ វិបាកោ** យល់ថា ផលវិបាករបស់កម្ម ដែលគេធ្វើល្អ និងធ្វើអាក្រក់មានផល។

៥-**អត្ថិ អយំលោកោ** យល់ថា (សត្វដែលមកកើតក្នុង)លោកនេះ មាន។

៦-**អត្ថិ បរោ លោកោ** យល់ថា (សត្វដែលកើតក្នុង)លោកខាង មុខមាន។

៧-**អត្ថិ មាតា** យល់ថា គុណមាតាមាន។

៨-**អត្ថិ បិតា** យល់ថា គុណបិតាមាន។

៩-**អត្ថិ សត្តា ឱបបាតិកា** យល់ថាពួកសត្វជាឱបបាតិកកំណើតមាន។

១០-**អត្ថិ លោកេ សមណព្រាហ្មណា សម្មគ្គតា សម្មាបដិបន្នា** យល់ថា ពួកសមណព្រាហ្មណ៍ក្នុងលោកជាអ្នកប្រព្រឹត្តល្អ ប្រតិបត្តិត្រឹមត្រូវ ដែលធ្វើឱ្យជាក់ច្បាស់នូវលោកនេះ និងលោកខាងមុខដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯងហើយសម្តែងបានមាន។

## សាកសព១០យ៉ាងគឺ

១-**ឧទ្ធុមាតកៈ** សាកសពហើមប៉ោង

២-**នីលកៈ** សាកសពមានពណ៌ខៀវ

៣-**វិបុព្វកៈ** សាកសពមានខ្ទុះហូរចេញ

៤-**វិច្ឆិទ្ទកៈ** សាកសពដែលកាត់ដាច់ពាក់កណ្តាល

៥-**វិក្ខាយិតកៈ** សាកសពដែលមានសត្វខាំកកេរស៊ី

៦-**វិក្ខិត្តកៈ** សាកសពដែលមានដៃ និងជើងដាច់ខ្ចាត់ខ្ចាយ

៧-**ហតវិក្ខិត្តកៈ**សាកសពដែលកាប់សាច់ចិញ្ច្រាំចោលរាត់រាយ

៨-**លោហិតកៈ** សាកសពដែលមានឈាមហូរប្រឡាក់

៩-**បុឡុវកៈ** សាកសពដែលមានដង្កូវចោះច្រើន

១០-**អដ្ឋិកៈ**សាកសពដែលជារាងឆ្អឹង ។[៤២]

ទាំង១០យ៉ាងនេះហៅថា អសុភក៏បាន ។

## ធម៌មួយមានឧបការៈច្រើន

**អប្បមាទោ កុសលេសុ ធម្មេសុ** សេចក្តីមិនធ្វេសប្រហែសក្នុងធម៌ទាំងឡាយជាកុសល ។

## ធម៌មួយគួរកំណត់ដឹង

**ផស្សោ អាសវោ ឧបាទានិយោ** ផស្សៈប្រកបដោយអាសវៈ ជាទីតាំងនៃឧបាទាន។

កញ្ចក់នៅរួមជាមួយនឹងមាស អាចចោលស្រមោលក្លាយទៅជាកែវមរកតយ៉ាងណា មនុស្សល្ងង់ នៅរួមជាមួយនឹងលោកសប្បុរស ក៏អាចត្រឡប់ទៅជាសប្បុរសឆ្លៀវឆ្លាតបានយ៉ាងនោះដែរ ។

ទស្សនៈ ភិក្ខុ ប៉ាង ខាត់ វីរិយបណ្ឌិតោ

---

៤២-ភិក្ខុគង់ សុមិត្ត អភិធម្មត្ថសង្គហៈ៩បរិច្ឆេទ ផ្សាយដោយពុទ្ធិកបណ្ឌិតសភានៃសាកលវិទ្យាល័យបញ្ញាសាស្ត្រ ព.ស.២៥៥២។

## ធម៌មួយជាចំណែកនៃសេចក្ដីវិនាស

**អយោនិសោ មនសិការោ** ការមិនធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញា។

## ធម៌មួយដែលគួរដឹងច្បាស់គឺ

**សព្វេ សត្តា អាហារដ្ឋិតិកា** ពួកសត្វទាំងពួងតាំងនៅបានចិញ្ចឹមជីវិតបានព្រោះអាហារ។[៤៣]

## កម្ម១២យ៉ាង

កម្មពួកទី១ឱ្យផលតាមគ្រា

១-**ទិដ្ឋធម្មវេទនីយកម្ម** កម្មឱ្យផលក្នុងបច្ចុប្បន្ន

២-**ឧបបជ្ជវេទនីយកម្ម** កម្មឱ្យផលក្នុងជាតិបន្ទាប់

៣-**អបរាបរវេទនីយកម្ម** កម្មឱ្យផលក្នុងជាតិត១ទៅ

៤-**អហោសិកម្ម** កម្មឱ្យផលសម្រេចហើយ

កម្មពួកទី២ ឱ្យផលតាមកិច្ច

៥-**ជនកកម្ម** កម្មញុំាងសត្វឱ្យកើត

៦-**ឧបត្ថម្ភកកម្ម** កម្មដែលជួយជ្រោមជ្រែង

៧-**ឧបបីឡកកម្ម** កម្មដែលបៀតបៀន។

៨-**ឧបឃាតកម្ម** កម្មដែលផ្ដាច់ផ្ដិលកម្មពួកទី៣ឱ្យផលតាម លំដាប់

៩-**គរុកម្ម** កម្មធ្ងន់

១០-**ពហុលកម្ម** កម្មដែលសន្សំច្រើន

១១-**អាសន្នកម្ម** កម្មដែលធ្វើក្នុងវេលាជិតស្លាប់

១២-**កដត្តាកម្ម** កម្មដែលគ្រាន់តែធ្វើឥតចេតនា។[៤៤]

---

៤៣-ប្រជុំកងធម៌ភាគ២ ទំព័រ១ ផ្សាយដោយពុទ្ធសាសនបណ្ឌិត្យ ព.ស.២៥៤២។

៤៤-អភិធម្មត្ថសង្គហៈ៩បរិច្ឆេទ ផ្សាយដោយពុទ្ធិកបណ្ឌិតសភា ព.ស.២៥៥២

## ឈាបនកិច្ច

សពមនុស្សក្នុងលោកមានវិធីធ្វើ៤យ៉ាង

១-បូជាដោយព្រះអគ្គី

២-កប់ទុកក្នុងព្រះធរណី

៣-បណ្តែតចោលក្នុងស្ទឹងស័ក្តិសិទ្ធិ

៤-ចោលក្នុងទីស្មសាន

**វិធីធ្វើបន្ត**

១-សណ្តោងស្បូវភ្លាំង

២-ប្រាយលាជ

៣-កៀសចិញ្ចៀនត្បូង

៤-បួសមុខភ្លើង

៥-ប្រែរូប ។

## ទសជាតក

ទី១-**តេមិយ** បំពេញនេក្ខម្មបារមី

ទី២-**មហាជនក** បំពេញវីរិយបារមី

ទី៣-**សុវណ្ណសាម** បំពេញមេត្តាបារមី

ទី៤-**នេមិរាជ** បំពេញអធិដ្ឋានបារមី

ទី៥-**មហោសថ** បំពេញបញ្ញាបារមី

ទី៦-**ភូរិទត្ត** បំពេញសីលបារមី

ទី៧-**ចន្ទកុមារ** បំពេញខន្តីបារមី

ទី៨-**នារទ** បំពេញឧបេក្ខាបារមី

ទី៩-**វិធុរ** បំពេញសច្ចបារមី

ទី១០-**វេស្សន្តរ** បំពេញទានបារមី ។

**មហាវេស្សន្តរជាតក១៣កណ្ឌ**

១-**ទសពរ**

២-**ហេមពាន្ត**

៣-**ទានកណ្ឌ**

៤-**វនប្បវេស**

៥-**ជូជក**

៦-**ចូឡពន ឬចុល្លពន**

៧-**មហាពន**

៨-**កុមារបព្វ**

៩-**មទ្រីបព៌**

១០-**សក្កបព្វ**

១១-**មហារាជបព្វ**

១២-**ឆក្សត្រ**

១៣-**នគរកណ្ឌ** ។

**(តេ. ជ. សុ. នេ. ម. ភូ. ច. នា. វិ. វេ.)**

# មហាវេស្សន្តរជាតក១៣កណ្ឌ

១ -ទសពរ

២ -ហេមពាន្ត

៣ -ទានកណ្ឌ

៤ -វនប្បវេស

៥ -ជូជក

៦ -ចូឡពន

៧ -មហាពន

៨ -កុមារបព្វ

៩ -មទ្រីបព្វ

១០ -សក្កបព្វ

១១ -ឆក្សត្រ

១៣ -នគរកណ្ឌ។[៤៥]

> ទីឋានឆ្ងាយចំនួនមួយរយយោជន៏ មិនមែនឆ្ងាយណាស់ណាទេ សម្រាប់បុគ្គលជាខ្ញុំតណ្ហា ឯបុគ្គលមានចិត្តសន្តោស សូម្បីទ្រព្យមកដល់ដៃហើយ ក៏មិនរវល់អើពើប៉ុន្មានដែរ ។
>
> ទស្សនះ ភិក្ខុ ប៉ាង ខាត់ វីរិយបណ្ឌិតោ

៤៥-ប្រជុំបុញ្ញប្រវត្តិ ឃិន-វន់។

## នាមនៃអ្នកពោលនមោ

១-**នមោ សាតា គិរិយក្ខោ** សាតាគិរិយក្សពោលថា**នមោ** ។

២-**តស្ស អសុរិន្ទោ** អសុរិន្ទរាហូពោលថា**តស្ស** ។

៣-**ភគវតោចាតុម្មហារាជិកា**ស្តេចចាតុមហារាជិកាពោលថា**ភគវតោ** ។

៤-**អរហតោ សក្កោតថា** ស្តេចសក្កទេវរាជពោលថា **អរហតោ** ។

៥-**សម្មា សម្ពុទ្ធស្ស** មហាព្រហ្ម ពោលថា**សម្មាសម្ពុទ្ធស្ស** ។

## ប្រយោជន៍នៃការពោលនមោ

១-ដើម្បីនឹងឱ្យអ្នកប្រាជ្ញទាំងឡាយលោកជ្រាបថា ការប្រព្រឹត្តយ៉ាងនេះ ជិតចំពោះព្រះអរិយជាម្ចាស់ ។

២-ដើម្បីការពារសព្វន្តរាយ ។

៣-ដើម្បីនឹងជម្រះសន្តានចិត្តឱ្យបរិសុទ្ធ ។

៤-ដើម្បីនឹងឱ្យជីវិតមានខ្លឹមសារ ។

> បុគ្គលជាពហុស្សូត ចេះដឹងនូវសាស្ត្រវិជ្ជាទាំងឡាយច្រើន មហិមា អាចកាត់នូវសេចក្តីសង្ស័យគ្រប់ប្រការបាន កាល បើសេចក្តីលោភចង់បានមកបំបាំងគំនិតឱ្យងងឹតសូន្យសុង ហើយក៏តែងទទួលសេចក្តីទុក្ខលំបាកតោកយ៉ាក ។
>
> ទស្សនៈ ភិក្ខុ ប៉ាង ខាត់ វីរិយបណ្ឌិតោ

## អានិសង្សសិក្ខាបទ

សិក្ខាបទទី១ មានអានិសង្ស២៣ ។ បាណាតិបាតៈ

សិក្ខាបទទី២ មានអានិសង្ស១១ ។ អទិន្នាទានៈ

សិក្ខាបទទី៣ មានអានិសង្ស២០ ។ កាមេសុមិច្ឆាចារៈ

សិក្ខាបទទី៤ មានអានិសង្ស១៤ ។ មុសាវាទៈ

សិក្ខាបទទី៥ មានអានិសង្ស៣០ ។ សុរាមេរយមជ្ជមាទដ្ឋានា

## អានិសង្សរបស់សីល១២យ៉ាង

១-**សីលំសមាធានន្តិ** សីលរមែងបិទបាំងនូវសេចក្តីមិនប្រមាទ ។

២-**សីលំឧបធារេន្តិ** សីលតែងចូលទៅជិតទ្រទ្រង់នូវកុសលធម៌ទាំងពួងឱ្យនៅបាន ។

៣-**សីលំ សីតន្តិ** សីលជារបស់ត្រជាក់ស្ងប់រំងាប់នូវទោស ។

៤-**សីលំ វឌ្ឍន្តិ** សីលជាទីញ៉ាំងកុសលទាំងពួងឱ្យចម្រើន ។

៥-**សីលំ គន្ធោ អនុត្តរោ** សីលមានក្លិនក្រអូបច្រាសខ្យល់ ។

៦-**សីលំ អាភរណំ សេដ្ឋំ** សីលជាគ្រឿងអម្ពរដ៏ល្អ ។

៧-**សីលំ អបាយ សព្វន្នំ** សីលជាគ្រឿងបិទបាំងនូវអបាយភូមិបាន ។

៨-**សីលំ បាថេយ្យំ មុត្តមំ** សីលជាគ្រឿងអាហារដ៏ឧត្តម ។

៩-**សីលំសមាធិភាមិនំ** សីលជាបច្ច័យញ៉ាំងសមាធិធម៌ឱ្យចម្រើនឡើង

១០-**សីលំ សុគតឹ យន្តិ** សត្វទៅកាន់ឋានសួគ៌ក៏ព្រោះសីល ។

១១-**សីលេន ភោគសម្បទា** សត្វទាំងឡាយបរិបូណ៌ដោយភោគ

សម្បត្តិក៏ព្រោះសីល ។
១២-**សីលេន និព្វុតឹយន្តិ** សត្វទាំងឡាយបានទៅកាន់ទីរំលត់ទុក្ខក៏ព្រោះសីល ។

**និច្ចសីលមានសិក្ខាបទ៥**

**១.បាណាតិបាតា វេរមណី សិក្ខាបទំ សមាទិយាមិ**
**២.អទិន្នាទានា វេរមណី សិក្ខាបទំ សមាទិយាមិ**
**៣.កាមេសុមិច្ឆាចារា វេរមណី សិក្ខាបទំ សមាទិយាមិ**
**៤.មុសាវាទា វេរមណី សិក្ខាបទំ សមាទិយាមិ**
**៥.សុរាមេរយមជ្ជប្បមាទដ្ឋានាវេរមណីសិក្ខាបទំសមាទិយាមិ។**

**ឧបោសថមានសិក្ខាបទ៨**

**១.បាណាតិបាតា វេរមណី សិក្ខាបទំ សមាទិយាមិ**
**២.អទិន្នាទានា វេរមណី សិក្ខាបទំ សមាទិយាមិ**
**៣.អព្រហ្មចរិយា វេរមណី សិក្ខាបទំ សមាទិយាមិ**
**៤.មុសាវាទា វេរមណី សិក្ខាបទំ សមាទិយាមិ**
**៥.សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី សិក្ខាបទំ សមាទិយាមិ**
**៦.វិកាលភោជនា វេរមណី សិក្ខាបទំ សមាទិយាមិ**
**៧.នច្ចគីតវាទិតវិសូកទស្សនមាលាគន្ធវិលេបនធារណមណ្ឌនវិភូសនដ្ឋានា វេរមណី សិក្ខាបទំ សមាទិយាមិ**
**៨.ឧច្ចាសយនមហាសយនា វេរមណី សិក្ខាបទំសមាទិយាមិ។**[៤៦]

៤៦-គ្រូធម្មាចារ្យ ចក់-កន ប្រជុំនានាធម្មសង្គហៈ ។

## អង្គនៃសិក្ខាបទ

### បាណាតិបាតមានអង្គ៥

១-**បាណោ** សត្វមានជីវិត

២-**បាណសញ្ញិតា** សេចក្តីដឹងថាសត្វមានជីវិត

៣-**វធកចិត្តំ** គិតនឹងសម្លាប់

៤-**ឧបក្កមោ** ព្យាយាមនឹងសម្លាប់

៥-**តេន មរណំ** សត្វស្លាប់ដោយព្យាយាមនោះ។

### អទិន្នាទានមានអង្គ៥

១-**បរបរិគ្គហិតំ** ទ្រព្យដែលមានម្ចាស់របស់គេហួងហែងរក្សា

២-**បរបរិគ្គហិតសញ្ញិតា**

សេចក្តីដឹងថាទ្រព្យមានម្ចាស់របស់គេហួងហែង រក្សា

៣-**ថេយ្យចិត្តំ** គិតនឹងលួច

៤-**ឧបក្កមោ** ព្យាយាមនឹងលួច

៥-**តេន ហរណំ** លួចបានដោយការព្យាយាមនោះ

### កាមេសុមិច្ឆាចារមានអង្គ៤

១-**អគមនីយដ្ឋានំ** ស្ត្រីដែលមិនគួរនឹងគប់រកគឺស្ត្រីដែលមានគេហួងហែង រក្សា

២-**តស្មឹ សេវនចិត្តំ** គិតនឹងសេពនូវមេថុនធម្មនឹងស្ត្រីនោះ

៣-**ឧបក្កមោ** ព្យាយាមសេពនូវមេថុនធម្មនោះ

៤-**មគ្គេន មគ្គប្បដិបាទនំ** ញ៉ាំងមគ្គនិងមគ្គឱ្យដល់គ្នា។

## មុសាវាទមានអង្គ៤

១-**អតថំវត្ថុ** វត្ថុមិនពិត

២-**វិសំវាទនចិត្តំ** គិតនឹងពោលឱ្យខុស

៣-**តជ្ជោ វាយាមោ** ព្យាយាមធ្វើឱ្យខុស

៤-**បរស្សតទត្ថវិជាននំ** ញុំាងអ្នកដទៃឱ្យដឹងច្បាស់សេចក្ដីនោះ។

## សុរាមេរយមានអង្គ៤

១-**មជ្ជនីយវត្ថុ** វត្ថុជាទីតាំងនៃសេចក្ដីស្រវឹងគឺសុរានិងមេរ័យ

២-**បាតុកម្យតាចិត្តំ** ចិត្តបម្រុងនឹងផឹក

៣-**តជ្ជោ វាយាមោ** ព្យាយាមនឹងផឹកនូវទឹកស្រវឹងនោះ

៤-**តស្ស បានំ** បានផឹកនូវទឹកស្រវឹងនោះឱ្យកន្លងបំពង់កចូលទៅ។

## អព្រហ្មចរិយមានអង្គ៤

១-**សេវនវត្ថុ** វត្ថុជាទីទម្លាយនូវសីលគឺទ្វារទាំង៣០ចំពោះ ត្រង់ទ្វារណាមួយ។

២-**សេវនចិត្តំ**គិតនឹងសេព

៣-**តជ្ជោ វាយាមោ** ព្យាយាមនឹងសេពនូវមេថុនធម្មនោះ

៤-**មគ្គេន មគ្គប្បដិបាទនំ** ញុំាងមគ្គនិងមគ្គឱ្យដល់គ្នា។

សេចក្ដីក្រោធមានដើមកំណើតមកពីលោភៈ កាមរាគកើតមកពីលោភៈមោហៈនិងសេចក្ដីវិនាស ក៏កើតមកពីលោភៈដែរព្រោះហេតុនោះលោភៈ ជាប្រភពនៃសេចក្ដីអាក្រក់គ្រប់ប្រការ។

ទស្សនៈ ភិក្ខុ ប៉ាង ខាត់ វីរិយបណ្ឌិតោ

១-**វិកាលោ** កាលខុស គឺព្រះអាទិតជ្រេទៅហើយដរាបទល់នឹងអរុណរះ

២-**យាវកាលិកំ** របស់ដែលគួរបរិភោគបានក្នុងកាល គឺតាំងពីអរុណរះឡើងដរាបដល់ថ្ងៃត្រង់

៣-**អជ្ឈោហរណំ** បានលេបចូលទៅក្នុងបំពង់ក ។

**នច្ចគីតមានអង្គ៣**

១-**និច្ចគីតាទិ** ការកំសាន្តមានរាំនិងច្រៀងជាដើម

២-**អត្តុកម្យតា ចិត្តំ** គិតបម្រុងនឹងធ្វើ

៣-**សុតទស្សនត្ថាយគមនំ** ទៅដើម្បីនឹងស្តាប់ឬមើលហើយបានស្តាប់ឬមើល ។

**មាលាមានអង្គ៣**

១-**មាលាទិ** វត្ថុសម្រាប់ប្រដាប់កាយ មានផ្កាកម្រងជាដើម

២-**ធារណច្ឆន្ទតា** សេចក្តីប្រាថ្នានឹងប្រដាប់តាក់តែងនោះ

៣-**តស្សធារណំ** បានប្រដាប់តាក់តែងនូវវត្ថុសម្រាប់ប្រដាប់កាយមានផ្កាកម្រងជាដើមនោះ ។

> អ្នកណាមិនរីករាយហួសហេតុក្នុងគ្រាបានសេចក្តីសុខចម្រើនមិនខូចកម្លាំងទឹកចិត្តក្នុងគ្រាក្រទុក្ខព្រួយមានសេចក្តីក្លាហានក្នុងរណង្គ មាតាបង្កើតកូនដែលមានតិលកៈ ដូច្នេះក្នុងលោកទាំងបីនេះកម្រមានណាស់ ។
>
> ទស្សនៈ ភិក្ខុ ប៉ាង ខាត់ វីរិយបណ្ឌិតោ

១-**ឧច្ចាសយនមហាសយនំ** ទីដេកទីអង្គុយដ៏ខ្ពស់ដ៏ប្រសើរហួសប្រមាណ

២-**បរិភោគ ចិត្តំ** គិតនឹងដេកឬអង្គុយ

៣-**បរិភោគ ករណំ** បានដេកឬអង្គុយ ។

កាលបើឧបាសកឧបាសិកា ប្រព្រឹត្តកន្លងនូវសិក្ខាបទណា១ លុះត្រាតែព្រមដោយអង្គក្នុងសិក្ខាបទនោះ១ ទើបបានឈ្មោះថាកន្លងបើមិនទាន់ព្រមដោយអង្គនោះក៏មិនបានឈ្មោះថាកន្លងនូវសិក្ខាបទនោះឡើយ ។[៤៧]

**ធម៌ដែលស្ត្រីប្រាថ្នាកើតជាប្រុស**

**ឥទំ នោ បុញ្ញំ បុរិសស្ស ភាវំ សំវត្តតុ៊ខ**

**ពោធិបក្ខិយធម៌៣៧ប្រការ**

សតិប្បដ្ឋាន៤ សម្មប្បធាន៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥

ពលៈ៥ ពោជ្ឈង្គៈ៧ មគ្គមានអង្គ៨ សរុប៣៧ប្រការ ។

| |
|---|
| ការចងបាច់វង្សត្រកូលរបស់ខ្លួនសូម្បីពីរបីនាក់ ឱ្យរួបរួមមូលត្រកូលគ្នា ក៏ជាការគាប់ប្រសើរណាស់ ដូចគ្រាប់ស្រូវដែលបកសំបកចេញហើយ យកទៅសាបព្រោះមិនដុះលូតលាស់ឡើងបានទេ ។<br>ទស្សនៈ ភិក្ខុ ប៉ាង ខាត់ វីរិយបណ្ឌិតោ |

៤៧-ឧត្តមប្រឹជា ចាប-ពិន អានិសង្សសាមសិប ផ្សាយដោយ ពុទ្ធសាសនបណ្ឌិត្យ ព.ស.២៥៤៣ ។

# សេចក្ដីសង្ស័យក្នុងព្រះសូត្រ១៦យ៉ាង

សង្ស័យក្នុងអតីត៥ អនាគត៥ និង បច្ចុប្បន្ន៦ ។

សង្ស័យក្នុងអតីត៥គឺ

១-**អហោសិ នុខោអហំ អតីតមទ្ធានំ** អំពីអតីតកាលអាត្មាអញបានកើតដែរឬ។

២-**ននុខោអហោសិ អតីតមទ្ធានំ** ឬអំពីអតីតកាលអាត្មាអញមិនបានកើតទេ។

៣-**កឹនុខោអហោសិ អតីតមទ្ធានំ** អំពីអតីតកាលអាត្មាអញមានជាតិជាអ្វី? ។

៤-**កថំនុខោអហោសិ អតីតមទ្ធានំ** អំពីអតីតកាលអាត្មាអញមានជាតិជាអ្វី? ។

៥-**កឹ ហុត្វា កឹ អហោសិ នុខោអហំ អតីតមទ្ធានំ** អំពីអតីតកាលអាត្មាអញ កើតជាជាតិអ្វីឬមួយអាត្មាអញមានសណ្ឋានទ្រង់ទ្រាយដូចម្ដេច? ។

> រោគាព្យាធិ សោកសង្រេងសង្រៃ សេចក្ដីក្ដៅក្រហាយ ការជាប់អន្ទាក់ចំណង និងសេចក្ដីវិនាសអន្តរាយទាំង-ឡាយនេះ ជាផលដែលមកពីព្រឹក្សាជាតិ គឺទោសកំហុសរបស់ខ្លួននៃមនុស្សទាំងឡាយ ។
>
> ទស្សនៈ ភិក្ខុ ប៉ាង ខាត់ វីរិយបណ្ឌិតោ

១-រឿងស្តេច ១៧-រឿងក្រុង
២-រឿងចោរ ១៨-រឿងជនបទ
៣-រឿងមហាមាត្យ ១៩-រឿងស្រី
៤-រឿងសេនា ២០-រឿងប្រុស
៥-រឿងភ័យ ២១-រឿងកុមារី
៦-រឿងចម្បាំង ២២-រឿងកុមារា
៧-រឿងបាយ ២៣-រឿងសុរា
៨-រឿងទឹកផឹក ២៤-រឿងច្រក
៩-រឿងសំពត់ ២៥-រឿងកំពង់ទឹក
១០-រឿងទីដេក ២៦-រឿងញាតិដែលស្លាប់ទៅ
១១-រឿងផ្កាកម្រង ២៧-រឿងផ្សេងៗ
១២-រឿងគ្រឿងក្រអូប ២៨-រឿងលោក
១៣-រឿងញាតិ ២៩-រឿងសមុទ្រ
១៤-រឿងយាន ៣០-រឿងសេចក្តីសាបសូន្យនិងចម្រើន
១៥-រឿងស្រុក ៣១-រឿងព្រៃ
១៦-រឿងនិគម ៣២-រឿងភ្នំ

បយោគក្នុងរឿងនេះមានតែវចីបយោគប៉ុណ្ណោះ ។[៤៨]

---

៤៨-ភិក្ខុ គង់ សុមិត្ត អភិធម្មត្ថសង្គហៈ៩បរិច្ឆេទ ព.ស.២៥៥២។

# គាថាផ្សេងៗ

## គាថាទី១

សម័យថ្ងៃមួយព្រះមានព្រះភាគទ្រង់គង់នៅក្នុងក្រុងសាវត្ថីទ្រង់ ប្រារព្ធព្រះរាជាព្រះនាម**វិឌូឌភៈ**ព្រមទាំងបរិវារដែលត្រូវស្លាប់ដោយទឹកជំនន់ទើបត្រាស់នូវព្រះគាថានេះថាៈ **បុប្ផានិ ហេវ បចិនន្តំ ព្យាសត្តមនសំ នរំ សុត្តំ គាមំ មហោឃោវ មច្ចុអាទាយ គច្ឆតិ**។

មច្ចុគឺសេចក្តីស្លាប់តែងកៀរយកទៅនូវនរជនអ្នកមានចិត្តជាប់ជំពាក់ក្នុងអារម្មណផ្សេងៗ កំពុងជ្រើសរើសនូវផ្កាគឺកាមគុណ៥នុ៎ះឯងដូចទឹកជំនន់ធំដែលកួចយកអ្នកស្រុកកំពុងដេកលក់ទៅដូច្នោះឯង ។

## គាថាទី២

សម័យថ្ងៃមួយព្រះមានព្រះភាគទ្រង់គង់នៅក្នុងក្រុងសាវត្ថី ទ្រង់ប្រារព្ធនូវនាង**បតិបូជិកា**ទើបត្រាស់នូវព្រះគាថានេះថា

**បុប្ផានិ ហេវ បចិនន្តំ ព្យាសត្តមនសំ នរំ ឣតិត្តំយេវ កាមេសុ អន្តកោ កុរុតេ វសំ ។**

អ្នកធ្វើទីបំផុតគឺមរណៈតែងក្រុងសត្វដែលមានចិត្តជាប់ជំពាក់ក្នុងអារម្មណ៍ផ្សេងៗកំពុងជ្រើសរើសនូវផ្កាគឺកាមគុណ៥មិនឆ្អែតឆ្អន់ក្នុងកាមទាំងឡាយនុ៎ះឯង ឱ្យនៅក្នុងអំណាចរបស់ខ្លួន។

## គាថាទី៣

សម័យមួយព្រះមានព្រះភាគទ្រង់គង់នៅក្នុងក្រុងសាវត្ថី ទ្រង់ប្រារព្ធនូវ**មច្ឆរិយកោសិយសេដ្ឋី**ដែលកំណាញ់ស្វិតស្វាញទើបត្រាស់នូវព្រះគាថានេះ

**យថាបិ ភមរោ បុប្ផំ វណ្ណគន្ធំ អហេឋយំ បលេតិ រសមាទាយ ឯវំ គាមេ មុនី ចរេ។**

ភមរជាតិ មិនធ្វើផ្កាឈើ ដែលមានពណ៌និងក្លិនឱ្យវិនាសវាក្រេបយកតែរសជាតិរួចហើរទៅយ៉ាងណាមិញអ្នកប្រាជ្ញគប្បីត្រាច់ទៅក្នុងស្រុកក៏យ៉ាងនោះឯង។ បណ្ឌិតអាស្រ័យ នឹងបិណ្ឌបាតដូចភមរជាតិក្រេបលម្អងផ្កាមិនឱ្យខូចខាតដល់ដើមសទ្ធាម្ចាស់ទានគ្រប់គ្នាដែលបានជ្រះថ្លា។ដូចឃ្មុំតែងក្រេបយកត្រឹមលម្អងមិនឱ្យសៅហ្មងដល់ជាតិបុប្ផា បណ្ឌិតអាស្រ័យបិណ្ឌ-បាតណាក៏ខំឧស្សាហ៍ញុំាងគុណឱ្យកើត។

## គាថាទី៤

សម័យថ្ងៃមួយព្រះមានព្រះភាគទ្រង់គង់នៅក្នុងក្រុងសាវត្ថី ទ្រង់ប្រារព្ធនូវអាជីវកឈ្មោះ**បាដិកៈ**ទើបត្រាស់នូវព្រះគាថានេះថា

**ន បរេសំ វិលោមានិ ន បរេសំ កតាកតំ អត្តនោវ អវេក្ខេយ្យ កតានិ អកតានិ ច។**

ពាក្យចាក់ដោតទាំងឡាយ របស់ជនដទៃបុគ្គលមិនគួរធ្វើទុកក្នុងចិត្តទេកិច្ចដែលធ្វើហើយនិងមិនទាន់ធ្វើហើយរបស់ជនដទៃ(ដែលមិនមែនជាមុខការរបស់ខ្លួន) បុគ្គលមិនគួរពិនិត្យមើលទេបុគ្គលគួរពិនិត្យពិចារណា

តែកិច្ចការទាំងឡាយដែលធ្វើហើយនិងមិនទាន់ធ្វើហើយរបស់ខ្លួនតែម្យ៉ាង បុគ្គលដែលឆ្លុះមុខក្នុងកញ្ចក់ បែរទៅសម្លក់មើលអ្នកដទៃ ធ្វើម្ដេចនឹងដឹងបានដោយប្រពៃព្រោះអ្នកដទៃមិនមែនអាត្មាមើលតែខ្លួនឯងមិនទាំងសព្វ ផងមិនគួររំលងមើលទោសអ្នកណា ដ្បិតខ្លួននៅមានបាបក្នុងចិន្ដាអ្នកមានប្រាជ្ញាគួរគិតផងចុះ ។

## គាថាទី៥

សម័យថ្ងៃមួយព្រះមានព្រះភាគទ្រង់គង់នៅក្នុងក្រុងសាវត្ថី ទ្រង់ប្រារព្ធនូវ**ឆត្តបាណិឧបាសក** ទើបត្រាស់នូវព្រះគាថានេះថា

**យថាបិ រុចិរំ បុប្ផំ វណ្ណវន្តំ អគន្ធកំ ឯវំ សុភាសិតា វាចា អផលា ហោតិ អកុព្វតោ ។យថាបិ រុចិរំ បុប្ផំ វណ្ណវន្តំ សុគន្ធកំ ឯវំ សុភាសិតា វាចា សផលា ហោតិ សុកុព្វតោ ។**

ផ្កាឈើមានទ្រង់ទ្រាយល្អមានពណ៌(ល្អ)តែគ្មានក្លិន(ក្រអូប) (រមែងមិនក្រអូបដល់អ្នកដែលទ្រទ្រង់)ដូចម្ដេចមិញវាចាជាសុភាសិតរមែងគ្មានផលដល់អ្នកដែលមិនធ្វើតាមដូច្នោះ ។

## គាថាទី៦

សម័យថ្ងៃមួយព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តបុព្វារាម នាក្រុងសាវត្ថី ទ្រង់ប្រារព្ធនូវ**នាងវិសាខា** ទើបត្រាស់នូវព្រះគាថានេះថា

**យថាបិ បុប្ផរាសិម្ហា កយិរា មលាគុណេ ពហូ ឯវំ ជាតេន មច្ចេន កត្តព្វំ កុសលំ ពហុំ ។**

មាលាការ ចេះធ្វើសំណុំនៃកម្រងផ្កាអំពីគំនរនៃផ្កា (ផ្សេងៗគ្នា) ឱ្យច្រើនបានយ៉ាងណាមិញកុសលដែលសត្វកើតមកហើយគួរធ្វើច្រើនយ៉ាងនោះ។ កំណើតជាមនុស្សកើតបានដោយក្រ ព្រោះកម្មល្អសាងពីអតីតបង្កើតឱ្យមានរូបរាងជីវិតបានជាមនុស្សពិតនៅក្នុងលោកា ជីវិតជាតិនេះចាយបុណ្យបុព្វេហុចផលហូរហែស្កប់ចិន្តា មិនគួរបណ្តោយខ្លួនតាមតណ្ហាឱ្យធ្វើអាចារ្យដឹកនាំគំនិត។

## គាថាទី៧

សម័យថ្ងៃមួយព្រះមានព្រះភាគទ្រង់គង់នៅក្នុងក្រុងសាវត្ថី ទ្រង់ប្រារព្ធនូវប្រស្នារបស់**ព្រះអានន្ទ**ទើបត្រាស់នូវព្រះគាថានេះថា

**ន បុប្ផគន្ធោ បដិវាតមេតិ ន ចន្ទនំ តគរមល្លិកា វា សតញ្ច គន្ធោ បដិវាតមេតិ សព្វា ទិសា សប្បុរិសោ បវាយតិ ។ ចន្ទនំ តគរំ វាបិ ឧប្បលំ អថ វស្សិកី ឯតេសំ គន្ធជាតានំ សីលគន្ធោ អនុត្តរោ ។**

ក្លិនផ្កាឈើ ផ្សាយទៅច្រាសខ្យល់មិនបាន ក្លិនខ្លឹមចន្ទន៍ក្តី ក្លិនខ្លឹមក្រស្នាក្តី ក្លិនផ្កាម្លិះរួតក្តី ក៏ផ្សាយទៅច្រាសខ្យល់មិនបាន ចំណែកក្លិនរបស់សប្បុរសទាំងឡាយ រមែងផ្សាយទៅច្រាសខ្យល់បានព្រោះសប្បុរសរមែងផ្សាយទៅបានគ្រប់ទិស។

ក្លិននៃសីលជាគុណជាតិប្រសើរបំផុតជាងគន្ធជាតិទាំងនេះ គឺខ្លឹមចន្ទន៍ ខ្លឹមក្រស្នា ផ្កាឧប្បល ផ្កាម្លិះលា។

## គាថាទី៤

សម័យថ្ងៃមួយព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធនូវការថ្វាយចង្ហាន់បិណ្ឌបាតដល់**ព្រះមហាកស្សប**ទើបត្រាស់នូវព្រះគាថា

**អប្បមត្តោ អយំ គន្ធោ យាយំ តគរចន្ទនំ យោ ច សីលវតំ គន្ធោ វាតិ ទេវេសុ ឧត្តមោ ។**

ក្លិនក្រស្នា និង ក្លិនចន្ទន៍ ក្លិននេះក្រអូបមានប្រមាណតិចទេ ចំណែកក្លិននៃបុគ្គលមានសីលទាំងឡាយ ទើបក្រអូបលើសលប់ផ្សាយទៅក្នុងទេវលោកនិងមនុស្សលោកបាន។ គ្រឿងអលង្ការមិនប្រាកដថា ស័ក្តិសមគ្រប់វ័យ ព្រោះគេធ្វើឡើងតាមបែបសម័យ មានតែក្មេងវ័យទើបពាក់សង្ហា។ ឯគ្រឿងតាក់តែង ដែលទ្រង់សម្ដែងគឺសីលសិក្ខា មិនមែនសម្រាប់តែវ័យមួយណាក្មេងឬចាស់ពាក់សមទាំងអស់។

## គាថាទី៥

សម័យថ្ងៃមួយព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តវេឡុវ័ន នាក្រុងរាជគ្រឹះទ្រង់ប្រារព្ធនូវការបរិនិព្វានរបស់ **ព្រះគោធិកត្ថេរ** ទើបត្រាស់ព្រះគាថានេះថា

**តេសំ សម្បន្ន សីលានំ អប្បមាទវិហារិនំ សម្មទញ្ញា វិមុត្តានំ មារោ មគ្គំ ន វិន្ទតិ ។**

មារាធិរាជ (ទុកជាខំស្វែងរក) ក៏មិនជួបផ្លូវរបស់លោកអ្នកមានសីលបរិបូណ៌អ្នកនៅដោយសេចក្តីមិនប្រមាទអ្នករួចស្រឡះ (ចាកធម៌ជាគ្រឿង

សៅហ្មង) ព្រោះដឹងច្បាស់តាមហេតុ។ ព្រះអរិយៈ អ្នកបានប្រចក្សថ្នាក់ធមិ ឧត្តមមានព្រះនិព្វានមកជាអារម្មណ៍ជាធម៌សុខុមឥតអ្វីប្រៀបបាន។ លោកឡើងកាន់ផ្លូវមានមុខឆ្ពោះទៅនិព្វាន ថ្កើងថ្កានជាទីផុតទុក្ខរុកកួន រំខានមារាលែងបានឱកាសមើលឃើញ។

## គាថាទី១០

សម័យមួយព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវសាវ័ករបស់និគ្រន្ថឈ្មោះ**គរហទិន្នៈ**ទើបត្រាស់នូវព្រះគាថានេះថា

**យថា សង្ការធានស្មឹ ឧជ្ឈិ តស្មឹ មហាបថេ បទុមំ តត្ថ ជាយេថ សុចិគន្ធំ មនោរមំ ឯវំ សង្ការភូតេសុ អន្ធភូតេ បុថុជ្ជនេ អតិរោចតិ បញ្ញាយ សម្មាសម្ពុទ្ធ សាវកោ ។**

ផ្កាឈូកទុកជាកើតក្នុងគំនរសំរាមដែលគេចាក់ចោលក្បែរផ្លូវធំនោះក៏គង់មានក្លិនក្រអូបជាទីរីករាយនៃចិត្តបាន ដូចម្តេចមិញបណ្តាជនដែលដូចជាគំនរសំរាម សាវ័ករបស់ព្រះសម្មាសម្ពុទ្ធ រមែងរុងរឿងកន្លងផុតបុថុជ្ជនទាំងឡាយដែលងងឹតល្ងង់ដោយប្រាជ្ញា(របស់ខ្លួនដូច្នោះឯង)។ ផ្កាឈូកដែលដុះនៅក្នុងបឹងភក់ឬក្នុងទឹកល្អក់ កខ្វក់សម្បូរក្លិនលម្អងកេសរជាទីប្រាថ្នានៃជនប្រុសស្រីយ៉ាងណាសាវ័កអ្នកធ្លាប់កម្សត់ត្រកូលទុគិតអត់យសសិរីតែបានចូលបួសក្នុងធម៌វិន័យដូចកើតជាថ្មីផុតក្តីសៅហ្មង។ ថ្លៃថ្លាដោយគុណ គឺសីលសិក្ខានិងមគ្គផលាប្រសើរកន្លង ព្រោះបានលះបង់អស់ក្តីសៅហ្មងដែលមានទំនងដូចជាបឹងភក់។

## គាថាទី១១

សម័យថ្ងៃមួយព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវព្រះបាទ**បសេនទិកោសល**ផងនិង**បុរសម្នាក់**ផងទើបត្រាស់នូវព្រះគាថា

**ទីឃា ជាគរតោ រត្តិ ទីឃំ សន្តស្ស យោជនំ ទីឃោ ពាលានំ សំសារោ សទ្ធម្មំ អវិជានតំ ។**

រាត្រីវែង ចំពោះអ្នកដេកមិនលក់ យោជន៍វែងចំពោះអ្នកនឿយហត់ សង្សារវដ្តវែង ចំពោះបុគ្គលពាលមិនដឹងច្បាស់នូវព្រះសទ្ធម្ម។ យប់យូរសម្រាប់អ្នកដេកមិនលក់ ព្រោះចិត្តខ្វល់ខ្វាយរសាប់រសល់ ឯដំណើរឆ្ងាយនៅក្នុងវដ្តៈគ្មានទិសដៅជាក់ សម្រាប់អ្នកជ្រប់ងប់វង្វេងដោយក្តីមោហា ទ្រង់ត្រាស់ហៅថាជាបុគ្គលពាល។

## គាថាទី១២

សម័យថ្ងៃមួយព្រះមានព្រះភាគទ្រង់គង់នៅក្នុងក្រុងសាវត្ថី ទ្រង់ប្រារព្ធនូវភិក្ខុដែលជាសទ្ធិវិហារិក របស់ព្រះមហាកស្សបទើបត្រាស់នូវព្រះគាថានេះថា

**ចរញ្ចេ នាធិគច្ឆេយ្យ សេយ្យំ សទិសមត្តនោ ឯកចរិយំ ទឡ្ហំ កយិរា នត្ថិ ពាលេ សហាយតា ។**

បុគ្គលកាលស្វះស្វែងរកកល្យាណមិត្ត បើមិនបានមិត្តដ៏ប្រសើរជាងខ្លួនឬមិត្តដែលស្មើនឹងខ្លួនទេគប្បីប្រព្រឹត្តទៅតែម្នាក់ឯង ឱ្យខ្ជាប់ខ្ជួនវិញព្រោះសហាយតាគុណមិនមានក្នុងបុគ្គលពាលឡើយ។ការសេពគប់មិត្តត្រូវគិតឱ្យច្បាស់ត្រូវគិតថាបើសេពគប់ពាលរស់ឥតសិរី ចិត្តក្តីកាយក្តីត្រូវបាបខ្ចីប្រើ

ដ្បិតបុថុជ្ជនដូចដៃដំបៅ បើលូកចូលទៅថ្នាំពិសសាកមើលខ្លួនឯង នឹងបាត់អស់ភាពគ្រាន់បើត្រូវថ្នាំរុករើឱ្យចុកពើតផ្សា។ ដូច្នេះគួរសេពគប់រាប់រកបណ្ឌិតអ្នកមានគំនិតប្រសើរថ្លៃថ្លា និងមានគុណធមិខ្ពស់ជាងអាត្មាយ៉ាងហោចស្មើគ្នាក៏ល្អប្រពៃ។ បើសិនក្នុងលោកមិនមានមិត្តល្អគួរតែត្រាច់ចរដូចរមាសព្រៃ បំពេញការងារកសាងស្នាដៃឱ្យមានតម្លៃដោយខ្លួនឯងចុះ។

## គាថាទី១៣

សម័យថ្ងៃមួយព្រះមានព្រះភាគទ្រង់គង់នៅក្នុងក្រុងសាវត្ថី ទ្រង់ប្រារព្ធនូវ**អានន្ទសេដ្ឋី** ទើបត្រាស់នូវព្រះគាថានេះថា

**បុត្តា មត្ថិ ធនមត្ថិ ឥតិ ពាលោ វិហញ្ញតិ អត្តាហិ អត្តនោ នត្ថិ កុតោ បុត្តា កុតោ ធនំ ៥**

ជនពាលតែងព្រួយលំបាកដោយសេចក្តីសម្គាល់ថាកូនទាំងឡាយ របស់អញមានទ្រព្យតាម ដែលពិតសូម្បីខ្លួនក៏មិនមានចំណង់បើកូនទាំងឡាយនឹងរាប់ថាមានអំពីណាបានទ្រព្យនឹងរាប់ថាមានអំពីណាបាន។

អណ្តាតចង្កៀងឆេះឡើង ព្រោះប្រេងសម្គាល់ថាផ្សែងរបស់អាត្មាអណ្តាតចង្កៀងបានត្រឹមសោកាត្បិតផ្សែងសោតណា អណ្តែតចោលប្រាណប្រៀបដូចសត្វលោកវិយោគចិន្តាព្រោះតែគិតថាកូនចៅអញមានឬមួយហួងហែងទ្រព្យដែលខ្លួនបាន ថាពិតជាមានសារៈខ្លឹមសារដល់ពេលកូនចៅឬទ្រព្យរបស់វិនាសបាត់អស់ចាកចោលអាត្មាបានត្រឹមវិយោគតក់ស្លុតចិន្តា ត្បិតអីសង្ខារ គ្មានអ្នកឃាត់បានកុំពោលដល់ទៅទ្រព្យឬកូនស្ងួន សូម្បីតែខ្លួនសត្វលោកគ្រប់ប្រាណហាមការឈឺចាស់ស្លាប់ក៏មិនបានសត្វលោកគ្រប់ឋានបានអ្វីខ្លះហើយ ?

## គាថាទី១៤

សម័យមួយព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវ**ចោរអ្នកឧទ្ទាក់នូវកញ្ចប់ខាំងឡាយ**ទើបត្រាស់នូវព្រះគាថានេះថា:

**យោ ពាលោ មញ្ញតី ពាលយំ បណ្ឌិតោ វាបិ តេន សោ ពាលោ ច បណ្ឌិតមានី ស វេ ពាលោតិ វុច្ចតិ។**

អ្នកណាជាមនុស្សពាលហើយដឹងខ្លួនថា ជាពាលអ្នកនោះនឹងទៅជាបណ្ឌិតបានខ្លះដោយដឹងខ្លួនថាជាពាលនោះម្យ៉ាងទៀតអ្នកណាជាមនុស្សពាលមានសេចក្តីប្រកាន់ថាខ្លួនជាបណ្ឌិតអ្នកនោះឈ្មោះថាជាមនុស្សពាលដោយពិត ។ អ្នកមានជំងឺដឹងខ្លួនថាឈឺ ពេទ្យងាយព្យាបាលពេទ្យសួរចេះឆ្លើយតាមឈឺធ្ងន់ស្រាល វិលមុខឈឺក្បាលព្យាបាលបានងាយ ។

## គាថាទី១៥

សម័យថ្ងៃមួយព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវព្រះថេរៈមួយអង្គព្រះនាម**ឧទាយី** ទើបត្រាស់នូវព្រះគាថានេះថា

**យាវជីវម្បិ ចេ ពាលោ បណ្ឌិតំ បយិរុបាសតិ ន សោ ធម្មំ វិជានាតិ ទព្វី សូបរសំ យថា ។**

មនុស្សពាលបើចូលទៅអង្គុយជិតអ្នកប្រាជ្ញសូម្បីអស់មួយជីវិតក៏ឥតបានដឹងរសធមិអ្វីឱ្យច្បាស់លាស់ឡើយដូចវែកដែលមិនដឹងរសសម្ល ។ បានរស់ជិតបណ្ឌិតគ្មានគំនិតគិតសង្វាតគំនិតដូចសត្វឆ្មាតគិតសង្វាតតែសាកសព ។ ពាក្យពេចន៍ជាធមិអាថិ មិនស្រវាយកជាទ្រព្យរស់នៅដូចជាងាប់

ព្រោះគ្មានទ្រព្យគឺវិជ្ជា។ ដូចវែកក្នុងសម្លទ្រង់ទ្រាយល្អតែកំព្រាខ្លួននៅក្នុងអាហារតែឱជារសពុំដឹង។ បើចង់បានប្រយោជន៍កុំដូចខ្មោច ត្រូវតែប្រឹងបណ្ឌិតឱ្យយើងពឹងកុំមិនដឹងដូចជាវែក។

## គាថាទី១៦

សម័យថ្ងៃមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវ**ភិក្ខុ៣០រូប**នៅក្នុងដែនបាថេយ្យៈទើបត្រាស់នូវព្រះគាថានេះថា

**មហុត្តម្បិ ចេ វិញ្ញូ បណ្ឌិតំ បយិរុបាសតិ ខិប្បំ ធម្មំ វិជានាតិ ជិវ្ហា សូបរសំ យថា ។**

វិញ្ញូជន បើចូលទៅអង្គុយជិតអ្នកប្រាជ្ញសូម្បីតែមួយរំពេច រមែងយល់រស ធម៌ដោយឆាប់រហ័សដូចអណ្តាតដឹងនូវរសសម្ល។

ជាតិជាឃ្មុំ ហើររងំស្វែងបុប្ផា ជួបកាលណាក៏ស្រវាក្រេបលម្អង យករសជាតិដែលពិសិដ្ឋក្រៃកន្លងធ្វើបង្គងពងនិងញាស់រស់កូនស្ងួនវិញ្ញូជនសុន្ទរីគំនិតគិតប្រយោជន៍ខ្លួនជួបប្រាជ្ញហើយមិនព្រងើយ តែងចាប់ជួនមិនធ្វេសខ្លួនក្រេបរសធម៌ ល្អបានភ្លាម។

## គាថាទី១៧

សម័យថ្ងៃមួយព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធនូវ បុរសឃ្លង់ឈ្មោះ**សុប្បពុទ្ធ**ទើបត្រាស់នូវព្រះគាថានេះថា

**ចរន្តិ ពាលា ទុម្មេធា អមិត្តេនេវ អត្តនា ករោន្តា បាបកំ កម្មំ យំ ហោតិ កដុកប្ផលំ។**

ពួកជនពាលមិនមានប្រាជ្ញាមានខ្លួនដូចជាសត្រូវតែងធ្វើកម្មលាមកដែលជាអំពើមានផលក្តៅក្រហាយ ។រីគប់ភ្លើងឆេះរុងរឿងឡើងច្រាសខ្យល់អ្នកកាន់ដល់ផលវិបាករលាកកាយ បើមិនរលត់ឬក៏បោះចោលឱ្យឆ្ងាយពិតឆេះសាយ រាយរលាក ចាកជីវិត ។ដូចជនពាលរាលគំនិត គិតមិនត្រូវដើរខុសផ្លូវនៃពពួកជនបណ្ឌិតកាលធ្វើកម្មប្រចាំកាយសុចរិតគួរអាណិតដ្បិតធ្វើទុក្ខរុកខ្លួនឯង ។

## គាថាទី១៨

សម័យមួយព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវបុរសអ្នកភ្ជួរស្រែម្នាក់ទើបត្រាស់នូវព្រះគាថានេះថា

**ន តំ កម្មំ កតំ សាធុ យំ កត្វា អនុតប្បតិ យស្ស អស្សុមុខោ រោទំ វិបាកំ បដិសេវតិ។**

បុគ្គលធ្វើកម្មណាហើយ រមែងក្តៅក្រហាយឬមានមុខប្រឡាក់ដោយទឹកភ្នែកស្រែកយំទទួលផលនៃកម្មណា កម្មដែលគេធ្វើហើយនោះឈ្មោះថាជាកម្មមិនល្អឡើយ ។ បុគ្គលអ្នកមិនដឹងកាលខំប្រឹងចាប់ដែកក្តៅរែងបានការសោកសៅហេតុខ្លួនខ្លៅមិនដឹងការណ៍ ។ យ៉ាងណាអ្នកធ្វើបាបព្រោះមិនជ្រាបធម៌ទេសនាធ្វើបាបពេញចិន្តាព្រោះមោហាមិនជឿកម្ម ។ លុះកម្មនោះមកផ្តល់ទុក្ខឱ្យ ដល់រយសែនឆ្នាំទើបបានរលឹកចាំថាកម្មនោះមិនល្អមែន ។

## គាថាទី១៩

សម័យថ្ងៃមួយព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធនូវនាយមាលាការឈ្មោះ**សុមនៈ**ទើបត្រាស់នូវព្រះគាថានេះថា

**តញ្ច កម្មំ កតំ សាធុ យំ កត្វា នានុតប្បតិ យស្ស បតីតោ សុមនោ វិបាកំ បដិសេវតិ ។**

បុគ្គលធ្វើកម្មណាហើយ រមែងមិនក្តៅក្រហាយឬដល់នូវសេចក្តីពេញចិត្ត មានចិត្តល្អទទួលផលនៃកម្មណា កម្មដែលគេធ្វើហើយនោះឯងឈ្មោះថាជាកម្មល្អ ។អ្នកបណ្តុះដំណាំផ្សាំពូជធារបំពេញការងារ យ៉ាប់កម្លាំងធ្វើស្រូវវស្សាឬមួយប្រាំងទោះនឿយហត់ខ្លាំងមិនរួញរា។ យកចិត្តទុកដាក់ភ្ញាក់ថែទាំ គ្មានអ្នកបង្ខំក៏ឧស្សាហ៍ព្រោះជឿជាក់ច្បាស់ក្នុងចិន្តាថា បានផ្លែផ្កាព្រោះប្រឹងប្រែង ។រីឯក្តីសុខក្នុងជីវិតជារបស់ពិតមិនមែនក្លែងកើតព្រោះធ្វើបុណ្យដោយខ្លួនឯងឱ្យផលជាក់ស្តែងមិនបន្លំ ។

## គាថាទី២០

សម័យមួយព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវ**ឧប្បលវណ្ណាថេរី** ទើបត្រាស់នូវព្រះគាថានេះថា:

**មធុវា មញ្ញតី ពាលោ យាវ បាបំ ន បច្ចតិ យទា ច បច្ចតី បាបំ អថ (ពាលោ) ទុក្ខំ និគច្ឆតិ។**

បាបមិនទាន់ឱ្យផលត្រឹមណា ជនពាលតែងសម្គាល់នូវបាបនោះថាដូចទឹកឃ្មុំលុះតែកាលណាបាបឱ្យផល ជនពាលទើបប្រទះនូវសេចក្តីទុក្ខក្នុងកាល

ណោះ ។ទឹកឃ្មុំផ្អែមប្រាកដតែអ្នកក្បត់ដាក់បំពុលអ្នកផឹកមិនដឹងយល់ទទួលផលវិនាសប្រាណ ។ រីឯបាបកម្មដែលដេកត្រាំក្នុងសន្តានដូចថ្នាំពិសសាមាន្យរមែងបានឱ្យទុក្ខា ។ ពេលធ្វើផ្អែមត្រជាក់មិនបានភ្ញាក់ដឹងអាត្មាលុះបាបឱ្យផ្លែផ្កាទើបដឹងថាលំបាកទ្រាំ ។

## គាថាទី៧១

សម័យមួយព្រះដ៏មានព្រះភាគទ្រង់គង់ក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធនូវ**អាជីវក**ឈ្មោះជម្ពុកៈទើបត្រាស់នូវព្រះគាថានេះថា

**មាសេ មាសេ កុសគ្គេន ពាលោ ភុញ្ជេថ ភោជនំ ន សោ សង្ខាត ធម្មានំ កលំ អគ្ឃតិ សោឡសឹ ។**

ជនពាលទុកជាបរិភោគភោជន ដោយចុងស្បូវរាល់៧ខែជនពាលនោះក៏មិនដល់មួយចំណិតនៃចំណែកទី១៦ របស់បុគ្គលទាំងឡាយដែលមានធមិបានដឹងឬបានពិចារណាហើយនោះឡើយ ។

## គាថាទី៧២

សម័យថ្ងៃមួយព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធនូវប្រេតមានអត្តភាពដូចជាពស់ទើបត្រាស់នូវព្រះគាថានេះថាៈ

**ន ហិ បាបំ កតំ កម្មំ សជ្ជុខីរំវ មុច្ចតិ ឌហន្តំ ពាលមន្វេតិ ភស្មាច្ឆន្នោវ បាវកោ ។**

កម្មលាមកដែលជនពាលធ្វើហើយ មិនទាន់ឱ្យផលដូចទឹកដោះស្រស់ដែលមិនទាន់ប្រែក្លាយ( ក្នុងមួយរំពេច)ដូច្នោះបាបកម្មនោះតាមដុតបុគ្គលពាលដូចរងើកភ្លើង ដែលបិទបាំងទុក ដោយផេះដូច្នោះ ។
ទឹកដោះគោរឹតថ្មីជាទឹកថ្មីនៅស្រស់ថ្លា រសជាតិនៅធម្មតាមិនទាន់ជាមានជាតិជូរ ។តែថាបើគេតាំងទុកក្នុងឆ្នាំងអស់ពេលយូររសជាតិពិតជាប្តូរក្លាយជាជូរជាក់មិនខាន ។យ៉ាងណាកម្មសត្វធ្វើជាអំពើបាបសាមាន្យជួនកាលមិនទាន់បានមានឱកាសចេញឱ្យផល ។

**គាថាទី២៣**

សម័យថ្ងៃមួយព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធនូវ**សេដ្ឋីក្ងក្រែត** ទើបត្រាស់នូវព្រះគាថានេះថា

**យាវ ទេវ អនត្ថាយ ញត្តំ ពាលស្ស ជាយតិ ហន្តិ ពាលស្ស សុក្កំ សំ មុទ្ធមស្សវិ បាតយំ។**

ការចេះដឹងកើតឡើងដល់បុគ្គលពាលគ្រាន់តែដើម្បីសេចក្តីវិនាសប៉ុណ្ណោះរមែងញ៉ាំងបញ្ញាឱ្យធ្លាក់ចុះបំផ្លិចបំផ្លាញចំណែកធមិសគឺកុសលរបស់បុគ្គលពាលនោះ ។

បុគ្គលគប្បីថែរក្សាទ្រព្យទុកដើម្បីការពារគ្រាក្រគប្បីរក្សាភរិយាដោយទ្រព្យ តែគប្បីរក្សាខ្លួនរឿយៗដោយភរិយាផងដោយទ្រព្យផង ។

ទស្សនៈ ភិក្ខុ ប៉ាង ខាត់ វីរិយបណ្ឌិតោ

## គាថាទី៧៤

សម័យថ្ងៃមួយព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវព្រះថេរៈឈ្មោះ **សុធម្មៈ** ទើបត្រាស់នូវព្រះគាថានេះថា

**អសន្តំ ភាវមិច្ឆេយ្យ បុរេក្ខារញ្ច ភិក្ខុសុ អាវាសេសុ ច ឥស្សរិយំ បូជា បរកុលេសុ ច។**

**មមេវ កត មញ្ញន្តុ គិហិប្បព្វជិតា ឧភោ មមេវ អតិវសា អតិវសា អស្សុ កិច្ចា កិច្ចេសុ កិស្មិចិ ឥតិ ពាលស្ស សង្កប្បោ ឥច្ឆា មានោ ច វឌ្ឍតិ។**

ភិក្ខុពាល រមែងប្រាថ្នានូវសេចក្តីសរសើរមិនមាន(ក្នុងខ្លួន)ផងនូវទង្វើខាងមុខ គឺជាប្រមុខក្នុងពួកភិក្ខុផងនូវភាពជាឥស្សរៈក្នុងអាវាសទាំងឡាយ ផងនូវការបូជាទាំងឡាយ ក្នុងត្រកូលជនទាំងឡាយដទៃផង ភិក្ខុពាលតែងមានសេចក្តីត្រិះរិះថា គ្រហស្ថនិងបព្វជិតទាំង២ពួក ចូរសម្គាល់នូវកិច្ចដែលមនុស្សដទៃធ្វើហើយថាជាកិច្ចរបស់អញវិញ អំណាចដ៏ក្រៃលែង របស់អញចូរមានក្នុងកិច្ចតូចធំយ៉ាងណា១មួយ (កាលបើយ៉ាងនេះ) ឫស្យានិងមានះរមែងចម្រើន។ការសរសើរនិងការរាប់អានពិតជារំខានសត្វបោកសត្វឱ្យល្វីល្វើភ្លើភ្លេចខ្លួនមិនដឹងប្រាណ។ការបំពេញគ្រប់កិច្ចការគឺប្រាថ្នាចង់ឱ្យគេឯងរាប់អានទោះប្រាណធ្លាក់ជ្រោះក៏មិនគិត។

> ថាបើបុគ្គលគប្បីបាននូវកិត្តិយស ដែលទៀងទាត់ មិនមានមន្ទិល ដោយការបរិច្ចាគកាយដែលផ្ទុកដោយគ្រឿងមន្ទិលសៅហ្មង ស្មោកគ្រោក មិនទៀងទាត់នេះបាន បើដូច្នោះ តើបុគ្គល នឹងមិនគប្បីកាន់យកនូវគុណធម៌គឺកិត្តិយស នោះឬអ្វី ? *ទស្សនៈ ភិក្ខុ ប៉ាង ខាត់*

## គាថាទី៧៥

សម័យថ្ងៃមួយព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវព្រះថេរៈមួយព្រះអង្គឈ្មោះ**វនវាសីតិស្សៈ**ទើបត្រាស់នូវព្រះគាថានេះថា

**អញ្ញា ហិ លាភូបនិសា អញ្ញា និព្វានគាមិនី ឯវមេតំ អភិញ្ញាយ ភិក្ខុ ពុទ្ធស្ស សាវកោ សក្ការំ នាភិនន្ទេយ្យ វិវេកមនុព្រូហយេ។**

បដិបទា អាស្រ័យនូវលាភផងបដិបទាជាដំណើរទៅកាន់ព្រះនិព្វានផង ភិក្ខុសាវ័ក ដឹងច្បាស់នូវហេតុនុ៎ះ យ៉ាងនេះហើយ មិនគួរត្រេកអរចំពោះសក្ការៈឡើយគប្បីញ៉ាំងវិវេកឱ្យចម្រើនដោយលំដាប់ ។

ពាលនិងបណ្ឌិតមានការប្រព្រឹត្តខុសគ្នាគឺ មួយប្រព្រឹត្តដើម្បីលាភមួយចរ-យាត្រាមិនជាប់ជំពាក់ដោយលាភ ។ ពួកវិញ្ញូជន រួចពីជំនន់គឺសក្ការៈដែលលោកមានចិត្តល្អគ្មានអ្វីប្រឡាក់ ព្រោះមានពំនាក់គឺព្រះនិព្វាន ។

## គាថាទី៧៦

សម័យថ្ងៃមួយព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវព្រះថេរៈមួយអង្គព្រះនាម**រាធៈ**ទើបត្រាស់គាថានេះថា

**និធីនំវ បវត្តារំ យំ បស្សេ វជ្ជទស្សិនំ និគ្គយ្ហវាទឹ មេធាវឹ តាទិសំ បណ្ឌិតំ ភជេ តាទិសំ ភជមានស្ស សេយ្យោ ហោតិ ន បាបិយោ ។**

បុគ្គលគួរឃើញអ្នកប្រាជ្ញណា ដែលជាអ្នកពោលសង្កត់សង្កិនចង្អុលប្រាប់ទោសថាដូចជាបុគ្គលអ្នកប្រាប់កំណប់ទ្រព្យ ឱ្យដូច្នោះគួរសេពគប់អ្នកប្រាជ្ញបែបនោះ ( ព្រោះថា) កាលបុគ្គលសេពគប់អ្នកប្រាជ្ញបែបនោះហើយរមែងមានសេចក្តីគាប់ប្រសើរ ឥតមាន ទោសដ៏លាមកឡើយ ។ គួរសប្បាយចិត្តនឹងពួកបណ្ឌិត អ្នកប្រាប់កំហុសព្រោះបុថុជ្ជនទាំងស្រីប្រុសតែងតែមានខុសជារឿងធម្មតា ។ គួរចូលឱ្យជិតបង្អោនគំនិតស្តាប់ធម៌ទេសនា លោកប្រៀនប្រដៅត្រូវចេះជ្រះថ្លាទើបមានបញ្ញាប្រហារបាបបាន ។

## គាថាទី២៧

សម័យថ្ងៃមួយព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពនទ្រង់ប្រារព្ធនូវភិក្ខុដែលរាប់ចូលក្នុងពួកនៃភិក្ខុឈ្មោះ**អស្សជិ** និងភិក្ខុឈ្មោះ **បុនព្វសុកៈ** ទើបត្រាស់នូវព្រះគាថានេះថា

**ឱវទេយ្យានុសាសេយ្យ អសព្ភា ច និវារយេ សតំ ហិ សោ បិយោ ហោតិ អសតំ ហោតិ អប្បិយោ។**

បណ្ឌិតគួរទូន្មានប្រៀនប្រដៅ គួរហាមឃាត់ជនទាំងឡាយឱ្យចាកអំពើអសប្បុរសបណ្ឌិតនោះរមែងជាទីស្រឡាញ់របស់សប្បុរសតែម្យ៉ាងមិនជាទីស្រឡាញ់នៃអស ... ាយ ពាក្យល្អពិសិដ្ឋ ។

សិរីរៈ និងកិត្តិគុណ មានចន្លោះតាំងនៅឆ្ងាយពីគ្នា សិរីរៈនេះរលត់រលាយទៅក្នុងមួយខណៈ ឯកិត្តិគុណស្ថិតនៅរហូតលុះគ្រាអវសាន ។ *ទស្សនៈ ភិក្ខុ ប៉ាង ខាត់*

## គាថាទី២៨

សម័យថ្ងៃមួយព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវ**ព្រះឆន្នត្ថេរ**ទើបត្រាស់នូវគាថានេះថា

**ន ភជេ បាបកេ មិត្តេ ន ភជេ បុរិសាធមេ ភជេថ មិត្តេ កល្យាណេ ភជេថ បុរិសុត្តមេ។**

បុគ្គលមិនគួរសេពគប់មិត្តអាក្រក់ មិនគួរសេពគប់បុរសថោកទាបគួរសេពគប់តែមិត្តល្អមិត្តឧត្តមបើមិនដូច្នោះជីវិតពិតជាមិនស្ងប់ឡើយ។

## គាថាទី២៩

សម័យថ្ងៃមួយព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវព្រះថេរៈឈ្មោះ **មហាកប្បិន** ទើបត្រាស់នូវព្រះគាថានេះថា

**ធម្មប្បីតិ សុខំ សេតិ វិប្បសន្នេន ចេតសា អរិយប្បវេទិតេ ធម្មេ សទា រមតិ បណ្ឌិតោ។**

បណ្ឌិត ដែលមានសេចក្ដីឆ្អែតក្នុងធម៌មានចិត្តជ្រះថ្លាហើយរមែងដេកជាសុខរមែងត្រេកអរក្នុងធម៌ដែលព្រះអរិយៈប្រកាសទុកហើយគ្រប់ពេល។ ការត្រេកអរក្នុងកាម សត្វញៀនញ៉ាមជាមជាប់ចិត្តកាមនោះក្រាស់ហើយស្ថិតសត្វលោកពិតមិនងាយលះ។ រសជាតិកាមផ្អែមត្រជាក់ដូចទឹកចំណែកពួកបណ្ឌិតប្រាជ្ញព្រេងព្រឹទ្ធពិតនឿយណាយ ឃើញកាមនាំអន្តរាយក្ដៅក្រហាយឥតមានល្ហែ។ លោកបែររេមករកពឹងពួនជ្រកជ្រៀតនៅក្បែរ ព្រះធម៌ជាហូរហែបានកាត់ខ្សែភពកាមគុណ។ លោកត្រេកអរក្នុងធម៌ ព្រះព្យាករណ៍ទុកដោយសុន្ទរ៏ចម្រើនតែផ្ទែកបុណ្យគុណល្អគាប់ជាប់រហូត។

## គាថាទី៣០

សម័យមួយព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវ**បណ្ឌិតសាមណេរ**ទើបត្រាស់សម្ដែងនូវព្រះគាថានេះថា

**ឧទកញ្ហិ នយន្តិ នេត្តិកា ឧសុការា នមយន្តិ តេជនំ ទារុំ នមយន្តិ តច្ឆកា អត្តានំ ទមយន្តិ បណ្ឌិតា។**

ធម្មតាអ្នកបង្ហូរទឹកតែងបង្ហូរទឹកទៅ អ្នកធ្វើព្រួញតែងពត់ព្រួញ (ឱ្យត្រង់) អ្នកចាំងឈើតែងចាំងឈើ ឯបណ្ឌិតទាំងឡាយតែងទូន្មានខ្លួន (ដូច្នោះដែរ) ។អ្នកបង្ហូរទឹកតែងតែគិតនឹកឱ្យទឹកហូរទៅកាន់ទីកន្លែងដែលខ្លួនសំដៅទោះទីរាក់ឬជ្រៅក្ដីដែលទឹកអាចហូរទៅបាន ។ ។អ្នកធ្វើជាងចាំងផ្ចិតផ្ចង់ជាខ្លាំងមិនប្រហែសប្រាណឬអ្នកធ្វើព្រួញ ក៏មិនមែនស្មានគឺសុទ្ធតែបានវាស់វែងដោយល្អ។ ឯអ្នកប្រតិបត្តិក៏ត្រូវប្រយ័ត្ន កុំកាត់តំណនៃការព្យាយាមខាត់ចិត្តឱ្យសទើបបានផលល្អរកធមិនិព្វាន ។[៤៩]

> បុគ្គលមានត្រកូលឧត្តមខ្ពង់ខ្ពស់បើមានភ្ញៀវត្រកូលថោកទាបមកដល់ផ្ទះហើយ ក៏គួរតែគោរពបូជា តាមគួរដែលអាចទទួលបាន ព្រោះភ្ញៀវទាំងអស់សុទ្ធតែទេវតា។
>
> ទស្សនៈ ភិក្ខុ ប៉ាង ខាត់ វិរិយបណ្ឌិតោ

៤៩-ភិក្ខុ វជិរប្បញ្ញោ សាន-សុជា ព្រះធម្មបទ៣០គាថា ទំព័រ១-៥៩ ព.ស.២៥៤៩។

# អានិសង្សផ្សេងៗ

## អានិសង្សឆត្រ

-មិនពាល់ត្រជាក់និងក្តៅ

-ផង់ធូលីមិនប្រឡាក់

-មិនមានឧបទ្រពមិនមានចង្រៃ

-ត្រូវគេគោរពកោតក្រែងសព្វៗកាល

-មានសម្បុរដ៏សុខុម

-មានចិត្តក្សេមក្សាន្ត

-បានឆត្រគឺវិមុត្តិមិនទៅកាន់ទុគតិអស់៩៤កប្ប

បានជាស្តេចចក្រពត្តិបានបដិសម្ភិទា៤ វិមោក្ខ៨និងអភិញ្ញា៦

## អានិសង្សសំពត់

-មានវណ្ណៈដូចមាស

-ប្រាសចាកធូលី

-ប្រកបដោយពន្លឺ

## អានិសង្សបាត្រ

-រមែងប្រើប្រាស់នូវថាសមាស ថាសប្រាក់

-ត្រូវគេគោរពកោតក្រែងគ្រប់កាល

-ជាអ្នកបាននូវបាយ ទឹក សំពត់ និង ទីដេក

## អានិសង្សកាំបិត

-បានកល្យាណមិត្ត

-កាំបិត គឺខន្តី និង មេត្តា

-អាចកាត់នូវសេចក្តីសង្ស័យ ។

## អានិសង្សថ្វាយម្ជុល

-កាលអន្ទោលទៅក្នុងភពតូចភពធំ

-ជាអ្នកមាន បញ្ញាមុត ។

## អានិសង្សថ្វាយកន្ត្រៃកាត់ក្រចក

-បាននូវខ្ញុំប្រុសខ្ញុំស្រី

-បានគោ និង សេះ

## អានិសង្សថ្វាយឆ្នុត ស្លឹកត្នោតជំល្អ

-មានត្រជាក់ និង កម្តៅសុខស្រួល

-បានជាស្តេចចក្រពត្តិ

-មិនមានភ្លើងគឺរាគៈទោសៈមោហៈ ។[៥០]

## អានិសង្សថ្វាយក្រអូប

-មានរាងកាយក្រអូប

-មានយស

-មានប្រាជ្ញារហ័ស

---

៥០-ភិក្ខុ ធម្មបាលោ សាន-សប្បាយ អានិសង្ស១២៥ ទំព័រ១-៧ វត្តនិគ្រោធវ័ន (គល់ទទឹង) ព.ស.២៥៤៨ គ.ស.២០០៤។

-មានកេរ្តិ៍ឈ្មោះ

-មានប្រាជ្ញាមុតមានប្រាជ្ញាដូចផែនដី

-មានប្រាជ្ញាស្រស់ស្រាយ

-មានប្រាជ្ញាជ្រៅ

-មានប្រាជ្ញាទូលាយមានប្រាជ្ញាស្ទុះទៅលឿន

(បិដកភាគ៧៤ ទំព័រ១៣០)

## អានិសង្សផ្កាឈូក

-បានទៅកើតក្នុងឋានតាវត្តិង្ស

-មានវិមាន ក្នុងឋានតាវត្តិង្ស មានកម្ពស់ ៦០ យោជន៍

-បានធ្វើឱ្យជាក់ច្បាស់នូវធម៌មិនទៅកាន់ទុគ្គតិអស់១សែនកប្ប

(បិដកលេខ ៧៤ ទំព័រ ៦៦)

## អានិសង្សបល្ល័ង្ក

-កើតក្នុងត្រកូលខ្ពង់ខ្ពស់

-ជាអ្នកមានភោគៈច្រើន

-ជាអ្នកមានសម្បត្តិគ្រប់មុខ

-មិនមានសេចក្តីកំណាញ់

-បល្ល័ង្ករមែងផុសឡើងក្នុងដំណើរដែលចិត្តប្រាថ្នា

(បិដកភាគ៧៤ ទំព័រ១៦៣)

## អានិសង្សថ្វាយទឹកឃ្មុំ

-រីករាយក្នុងទេវលោកអស់៣ម៉ឺនកប្ប

-ជាអ្នកបានបាយទឹកជាប្រក្រតី

-កើតក្នុងទេវលោកនិងមនុស្សលោកជាអ្នកបានសម្រេចនូវសេចក្តីប្រាថ្នាគ្រប់យ៉ាង ។

(បិដក ភាគ ៧៤ ទំព័រ ១៨៣)

## អានិសង្សឱសថព្យាបាលជំងឺ

-នឹងត្រេកអរក្នុងទេវលោក អស់១សែនកប្ប

-បានជាស្តេចសោយរាជ្យ

-ទោះកើតជាទេវតាក្តីជាមនុស្សក្តីមិនមានអាពាធ និង វៀរបង់នូវ ព្យាធិជាគ្រឿងក្តៅក្រហាយក្នុងលោក ។

(បិដកភាគ៧៤ ទំព័រ១៩២)

## អានិសង្សបូជាប្រទីបចំពោះព្រះពុទ្ធ

នឹងបាននូវទិព្វចក្ខុរស្មីចេញពីរាងកាយតែងផ្សាយទៅក្នុងទេវលោកឬមនុស្សលោក ។

(បិដក៧៤ ទំព័រ ២០៨)

## អានិសង្សសប្បិ

-កើតជាទេវតា ឬមនុស្សតែងបានសេចក្ដីសុខដ៏ធំ

-បានដល់នូវអចលបទគឺព្រះនិព្វាន

-បាននូវភោគៈប្រមាណមិនបានសប្បិកើតឡើងតាមសេចក្ដីប្រាថ្នា ។

(បិដក ៧៤ ទំព័រ ២២៥)

## អានិសង្សស្ពាន

បុគ្គលនេះបើទុកជាធ្លាក់ទៅក្នុងជ្រោះឬធ្លាក់ពីភ្នំរមែងបានទីឈរបានយាន ដ៏វិសេសដែលជាបុញ្ញកម្មរង់ចាំបានសេចក្ដីសុខ ។

(បិដក៧៤ ទំព័រ២២៩)

## អានិសង្សបាំងបារាំ ដែលប្រក់ដោយផ្កាឈើ ចំពោះព្រះពុទ្ធ

-បើបានកើតជាទេវតាឬមនុស្សនឹងមានសម្បុរដូចមាស

-ជាអ្នកមានភោគៈច្រើន ។

(បិដក៧៥ ទំព័រ២)

## អានិសង្សប្រគេនសាច់ឆ្អាញ់

-បានទទួលសម្បត្តិទាំងពីរ

-បានទៅកើតឋានតាវត្តឹង្ស

-ភាពជា អ្នកមានអាយុវែង

(បិដក៧៥ ទំព័រ ២៨)

## អានិសង្សត្រែ

នៅឋានតាវត្តិង្សទីសម្រាប់ដេកមានតម្លៃច្រើនក៏កើតឡើងតាមសេចក្តីប្រាថ្នាជាបុគ្គលមានសេចក្តីសុខមានយស ។

(បិដក៧៥ ទំព័រ៣៥)

## អានិសង្សបោសសម្អាត

-បានទៅរីករាយក្នុងទេវលោក

-ជាចិត្តត្រង់មិនភាន់ភាំង

(បិដក៧៥ទំព័រ៣៨)

## អានិសង្សកសាងខឿននៃដើមពោធិព្រឹក្ស

-បានទៅកើតឋានតុសិត ផ្ទះជាវិការៈ នៃមាសទាំងអស់ដែលវិស្សកម្មទេវបុត្រ សាងថ្វាយ ។

(បិដក៧៥ ទំព័រ១០៤)

## អានិសង្សថ្វាយសសរ

-វិមានមានកម្ពស់៧ជាន់ផុសឡើង

-បានជាស្តេចកើតជាទេវតានិងមនុស្សតែងទទួលសេចក្តីសុខគ្រប់ប្រការ ។

(បិដក៧២ទំព័រ១២៧)

## អានិសង្សទង់

សេនាមានអង្គ៤គឺដំរីសេះរថពលថ្មើរជើងពួកនារី៨៦ពាន់ មានខ្លួនពាក់តែងយ៉ាងល្អមានសំពត់ និងគ្រឿងអម្ពរដ៏វិចិត្រពាក់កែវមណីតែងចោមរោមជានិច្ចមិនទៅកាន់ទុគ្គតិអស់១សែនកប្ប ។

(បិដក៧២ទំព័រ១៦៦)

## អានិសង្សសរណគមន៍

-បានទៅកើតឋានតាវត្តិង្ស

-គេតែងបូជាទិសទាំងឡាយ

-ជាអ្នកមានប្រាជ្ញាមោះមុត

-ពួកទេវតាទាំងអស់រមែងប្រព្រឹត្តទៅតាមបុគ្គលនោះជាអ្នកមានអាយុវែងមានទ្រព្យច្រើន ។

(បិដក៧២ទំព័រ២០២)

## អានិសង្សស្រោចទឹកក្រអូបលើដើមពោធិ៍

បានត្រេកអរក្នុងទេវលោកភពជាទីនៅរបស់បុគ្គលនោះមានជាន់៧ខ្ពស់ត្រដែតត្រដឹមពួកនាងកញ្ញា១សែននាក់តែងចោមរោមសព្វៗកាលមិនមានអាពាធមិនមានសោកមិនជួបសេចក្តីខ្វល់ខ្វាយ ។

(បិដក៧២ទំព័រ២៣៩)

## អានិសង្សកម្រាល

-បានទៅកើតឯឋាននិម្មានរតី មិនទៅកាន់ទុគ្គតិ

-បានជាស្តេច ចក្រពត្តិ មានកម្លាំងច្រើន

(បិដក៧២ទំព័រ២៧៤)

## អានិសង្សធ្វើផ្លូវ

មិនទៅកាន់កំណើតតិរច្ឆានប្រេតអសុរកាយនរកបានជាស្តេចជាឥស្ស-រៈលើពួកនរជន

(បិដក៧៣ទំព័រ៧២)

## អានិសង្សអ្នកទំនុកបម្រុងអារាម(ញោមវត្ត)

-មិនទៅកាន់កំណើតអបាយភូមិទាំង៤

-បានស្តេចចក្រពត្តិ៧ជាតិ ណាមួយ!

-បរិបូណ៌ដោយកម្លាំងមានរូបល្អ

(បិដក៧៣ ទំព័រ១១០)

## អានិសង្សកន្ទេល

មិនទៅកាន់ទុគ្គតិអស់៩៤កប្ប បានជាស្តេចចក្រពត្តិបរិបូណ៌ដោយកែវ៧ប្រការ។

(បិដក៧៣ទំព័រ១៧៣)

## អានិសង្សថ្វាយត្រី

មិនទៅកាន់កំណើតអបាយភូមិ៤អស់៩៤កប្បរស់នៅតែងបានសេចក្ដីសុខចម្រើន។

(បិដក៧៣ ទំព័រ២០៣)

## អានិសង្សបួស៧ថ្ងៃ

-មិនទៅកាន់អបាយភូមិ៤អស់៩១កប្ប មានប្រាជ្ញាមោះមុត

-បានជាស្ដេចចក្រពត្តិ៧ជាតិ បានបដិសម្ភិទា៤ វិមោក្ខ៨ អភិញ្ញា៦

(បិដក៧៣ទំព័រ២២៦)

## អានិសង្សក្រាលកម្រាលទូទនាប់ជើង

-មិនទៅអបាយភូមិអស់៩៤កប្បបាននូវពាហនៈគឺសេះអាជានេយ្យ

-មានរូបល្អ ។

(បិដក៧៣ទំព័រ២៣៤)

## អានិសង្សចង្ហាន់មួយវែកថ្វាយចំពោះព្រះពុទ្ធ

-បានទៅកើតឋានតាវត្តិង្ស

-បើស្ត្រីនឹងបានជាអគ្គមហេសីនៃស្ដេចទេវតា៣៦ដង

-មិនមានសេចក្ដីកង្វល់

-បានដល់អចលបទគឺព្រះនិព្វានមិនទៅកាន់ទុគ្គតិអស់៩២កប្បដូចភិក្ខុទាយិកាថេរី។

(បិដក៧៦ទំព័រ១២)

## អានិសង្សប្រទីប៩ដួង

-បានទៅកើតឋានតាវត្តិង្ស

-ប្រទីបទាំងឡាយតែងភ្លឺជុំវិញខ្លួន

-ភ្នែកនៅក្នុងផ្ទៃមាតាមិនដែលធ្មេច

-អាយុ៧ឆ្នាំបានដល់ព្រះអរហត្តមិនទៅកាន់អបាយឡើយអស់១សែនកប្ប ។

(បិដក៧៦ទំព័រ១៩)

## អានិសង្សរក្សាឧបោសថ

-បានទៅកាន់ឋានសួគ៌

-មានវិមានកម្ពស់ទៅលើ១យោជន៍ប្រដាប់ដោយផ្ទះកំពូលដ៏ប្រសើរ មានអាសនៈស្អិតស្អាងល្អ

-មានសម្បុរដូចមាស

-តែងបាននូវវត្ថុទាំងពួងគឺ យានដំរីសេះ យានរថ សម្បូរទ្រព្យ សម្បត្តិ។ ឯកុបោសថិកាថេរី

(បិដក៧៦ទំព័រ២៩)

## អានិសង្សនំអន្សម

-បរិបូណ៌ដោយអាហារ

-បានទទួលនូវសម្បត្តិទាំងអស់

-បាននូវអចលបទគឺព្រះនិព្វាន

មោទកទាយិកាថេរី (បិដក៧៦ទំព័រ៣០)

# ដំណើរនៃការត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធ

## វយៈទី១ : **ឈានវិធី**

ព្រះសទ្ធត្ថបានឮថាមានតាបស២រូប គឺឈ្មោះ**អាឡារតាបសកាលាម-គោត្រ**និង**ឧទកតាបសរាមបុត្រ**។ ការរៀនសូត្រពីតាបសទាំងពីរនេះបានត្រឹមតែឈានលោកិយ មិនបានឃើញផ្លូវនៃការរលត់ទុក្ខ ទើបព្រះអង្គទ្រង់យាងចេញពីទីនោះដើម្បីស្វែងរកសច្ចធម៌ដោយព្រះអង្គឯង។ លុះទៅដល់តំបន់មួយឈ្មោះឧរុវេលាសេនានិគម ទ្រង់បានទតឃើញថាភូមិប្រទេសទីនោះមានព្រៃខៀវខ្ចីមានស្ទឹងនេរញ្ជរាទឹករងថ្លាដូចកញ្ចក់ ជាទីស្ងប់ស្ងាត់គួរដល់ការព្យាយាមដើម្បីស្វែងរកនូវមោក្ខធម៌ (ធម៌សម្រាប់ធ្វើខ្លួនឱ្យរួចផុតពីសេចក្ដីទុក្ខ) ហើយមិនឆ្ងាយប៉ុន្មានពីភូមិនោះក៏មានអ្នកស្រុកដែលអាចឱ្យព្រះអង្គនិមន្តបិណ្ឌបាតបាន ទើបទ្រង់ជ្រើសរើសយកទីនោះដើម្បីបំពេញភាវនាតទៅ ។

## វយៈទី២ :**អត្តកិលមថានុយោគវិធី**

ការស្វែងរកមោក្ខធម៌ដោយព្រះអង្គឯងព្រះអង្គទ្រង់បំពេញសេចក្ដីព្យា-យាមតាមបែបអ្នកបួសផ្សេងៗ ក្នុងសម័យនោះគឺទ្រង់បានព្យាយាមសាកល្បងធ្វើទារុណកម្មកាយឱ្យលំបាកដែលមានឈ្មោះថា វិធីអត្តកិលមថានុ-យោគ ជាវិធីដែលគេនិយមថា អាចធ្វើឱ្យរួចចាកផុតពីសេចក្ដីទុក្ខបាន។ ឯវិធីដែលព្រះអង្គបានធ្វើនោះគឺ

អាក្រាតកាយ ឈរជើងមួយចំហៀងរហូត ឈរដើរ ដេក លើបន្លាស្រួចមុត បរិភោគអាហារដែលជាសំបកឈើ សារាយ ចុងអង្ករ កន្ទក់ ផ្លែឈើ ឫសឈើ និងសូម្បីតែស្មៅ និងលាមកគោ ក៏ព្រះអង្គបានសាកល្បងសោយដែរ ។យកសំពត់រុំខ្មោច ដែលគេចោលមកហ៊ុមដណ្ដប់ខ្លួនយកស្បូវភ្លាំងស្លឹកឈើមកក្រងជាសំពត់ស្លៀកដណ្ដប់ យកស្បែកសត្វស្លាប់មកស្លៀកដណ្ដប់ បណ្ដោយឱ្យល្អងធូលីដីប្រឡាក់ខ្លួនរហូតបែកស្រកា ដោយមិនខ្វីស្រង់ទឹក ហើយទ្រង់គេចពីមនុស្សមិនឱ្យជួបទាល់តែសោះ ក្នុងរដូវក្ដៅពេលថ្ងៃព្រះអង្គនៅកណ្ដាលវាល លុះដល់ពេលយប់ក៏ចូលទៅនៅក្នុងព្រៃជ្រៅវិញ ព្រះអង្គផ្ទំជាមួយនឹងសាកសពទាំងឡាយជួនកាលពេលព្រះអង្គកំពុងភាវនាធមិមានពួកក្មេងឃ្វាលគោមករំខានស្រែកហ៊ោរកញ្ជ្រៀវ ដាក់ត្រចៀកខ្លះនោម ដាក់ខ្លះបាចធូលីលើអង្គខ្លះយកឈើស្រួចៗមកត្បារត្រចៀកលេងដោយសម្គាល់ថាព្រះអង្គឆ្កួតតែព្រះអង្គក៏មិនក្រោធខឹងជាមួយនឹងក្មេងទាំងនោះឡើយ ។

រយៈទី៣ :**ទុក្ករកិរិយាវិធី**

ពេលដែលពិសោធនូវវិធីផ្សេងៗ ដែលគេនិយមធ្វើក្នុងជំនាន់នោះហើយក៏នៅតែពុំទាន់បានរួចផុតទុក្ខទៀតព្រះអង្គក៏ចាប់ផ្ដើមវិធីធ្វើទារុណកម្មបែបថ្មីចំនួន៣យ៉ាងទៀត ដែលពុំទាន់ដែលមាន នរណាធ្វើសោះគឺ

១-យកធ្មេញលើខាំជាប់ធ្មេញក្រោម ដោយមិនព្រមកម្រើកហើយយកអណ្តាតទៅទល់នឹងពិតានមាត់។

២-អត់ដង្ហើមដោយមិនព្រមដកចេញដកចូលរហូតទាល់តែស្ទះស្ទើរប្រកាច់ទើបដកដង្ហើមវិញហើយក៏អត់ទៀត។

៣-ទ្រង់អត់អាហារ គឺបន្ថយអាហារតាំងពីមួយចានមកនៅកន្លះចានរហូតទាល់តែដាច់មិនព្រមសោយសោះ។

-រយៈទី៤ : **មជ្ឈិមាបដិបទាវិធី**

ការស្វែងរកសច្ចធម៌ដោយសាកល្បងនូវវិធីផ្សេងៗនៅតែមិនបានសម្រេច ។ល។ ពេលនោះសតិសម្បជញ្ញៈរបស់ព្រះអង្គក៏រលឹកនឹកឃើញដល់សិល្បៈនៃការប្រគុំតន្ត្រីមានឧបករណ៍ពិណដែលធ្លាប់បានជួប.....។ ខ្សែពិណដែលរឹតធូរពេកសំឡេងមិនពីរោះឬខ្សែពិណដែលរឹតតឹងពេកក៏មិនពីរោះហើយបើរឹតតឹងថែមទៀតប្រាកដជាដាច់។ ឯខ្សែពិណដែលរឹតល្មមមធ្យមនឹងមានសំឡេងពីរោះ។ព្រះអង្គទ្រង់ពិចារណាយ៉ាងនេះត្រឡប់មកឆាន់ចង្ហាន់វិញ (ព្រះអង្គយល់ថាមិនតឹងពេកមិនធូរពេក) លោកហៅថាមជ្ឈិមាបដិបទា លុះត្រាតែមានសុខភាពដូចដើម ព្រះអង្គទ្រង់ងាកមកតម្រង់ទិដ្ឋិព្រះអង្គឱ្យបានត្រឹមត្រូវតាម**សម្មាទិដ្ឋិ សម្មាសង្កប្បៈ សម្មាវាចា សម្មាកម្មន្តៈ សម្មាអាជីវៈ សម្មាវាយាមៈ សម្មាសតិ សម្មាសមាធិ** ម្តងបន្តិចៗរហូតទាល់តែត្រឹមត្រូវល្មមល្អឥតខ្ចោះ។ ផ្លូវទាំង៤នេះ គឺជាការ

ច្របាច់ត្រង់លើការពិសោធច្រើនលើកច្រើនគ្រា អស់រយៈកាល៦ឆ្នាំរហូតទីបំផុតព្រះអង្គក៏បានរកឃើញដោយច្បាស់ផ្ទាល់(សន្ទិដ្ឋិកោ)ថានេះគឺៈពិតជាមាគ៌ាឆ្ពោះទៅរកការត្រាស់ដឹងប្រាកដមែន។

ការត្រាស់ដឹងទីបំផុតនៃការស្វែងរកអស់រយៈកាល៦ឆ្នាំដោយវិធីទាំង៤ មានឈានវិធីអត្តកិលមថានុយោគវិធីទុក្ករកិរិយា និងមជ្ឈិមាបដិបទាមក ព្រះសិទ្ធត្ថក៏បានទៅដល់គោលដៅដែលទ្រង់កំណត់ទុកគឺមោក្ខៈ (ការរួចពីសេចក្ដីទុក្ខ)ឬនិព្វាននៅថ្ងៃពុធ១៥កើតខែពិសាខមុនគ្រិស្ដសករាជ៥៨៨ឆ្នាំ វេលាថ្ងៃជិតរះ ព្រះអង្គបានសម្រេចបុព្វេនិវាសានុស្សតិញ្ញាណ។ ពាក់កណ្ដាលអធ្រាត្រព្រះចន្ទចរចំពីលើទ្រង់បានចុតូបបាតញ្ញាណនៅថ្ងៃចុងនៃរាត្រីជំនក្ខត្តឫក្ស នោះព្រះទ័យព្រះអង្គកាន់តែបរិសុទ្ធឡើងនិងស្ងប់ជាទីបំផុតពិចារណាលើជាតិជរាព្យាធិមរណៈវេទនាឧបាទានផស្សៈអាយតនៈទាំង៦ជាហេតុគឺសេចក្ដីប្រាថ្នាផ្សេងៗ។ ការរកឃើញផ្លូវរលត់ទុក្ខទាំងពួងគឺព្រះនិព្វានពោលគឺបានអាសវក្ខញ្ញាណទីបំផុតទើបព្រះអង្គបានត្រាស់ដឹង។[៥១]

> នឹងថាអ្នកណាជាមិត្តអ្នកណា ក៏ពុំទាន់បាន នឹងថាអ្នកណាជាសត្រូវនឹងអ្នកណាក៏ពុំទាន់បានដោយអំពើដែលគេ ប្រព្រឹត្តទើបគេស្គាល់គ្នា អ្នកនេះជាមិត្ត អ្នកនោះជាសត្រូវ។
>
> ទស្សនៈ ភិក្ខុ ប៉ាង ខាត់ វីរិយបណ្ឌិតោ

៥១-ឥន្ទបញ្ញោ ភិក្ខុ ហ. មណីចិន្ដា មគ្គុទ្ទេសក៍ជីវិត ទំព័រ២១-២៤ ផ្សាយដោយ ពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍។

# ស្ងួនកំណាព្យកម្សាន្តអារម្មណ៍

## លោកធាតុ

លោកធម៌ទាំងឡាយមានចិត្តជាធំ រួមប្រមូលផ្តុំឧត្តមលើចិត្ត
ចង់សើចឬយំអន់ឬអាណិត សម្រេចដោយចិត្តជាអ្នកកំណត់ ។
ជនណាមានចិត្តទោសៈកើតហើយ ឥតធ្វើល្អឡើយអាក្រក់ប្រាកដ
ទោះនិយាយស្តីចម្រៀងជូរចត់ ទាំងកាយទាំងមាត់ឥតមានកុសល ។
ព្រោះតែអំពើអាក្រក់នោះឯង ក្តីទុក្ខរមែងដេញតាមបុគ្គល
ដូចកង់រទេះតែងតែវិលវល់ តាមគោមង្គលដែលអូសដូច្នេះ ។
ដានគោទៅណាដានកង់ទៅហ្នឹង គួរតែយល់ដឹងកុំធ្វេសប្រហែស
គួរតែសិក្សាធម៌អាថ៌ឱ្យចេះ កុំឱ្យចិត្តនេះនាំទៅអវិជ្ជា ។

**លោក គុយ សុធន**

## កើតតែងស្លាប់

ភាជនៈដីដែលស្មូនឆ្នាំងធ្វើ តូចធំជំទើរឆៅក្តីឆ្អិនក្តី
រមែងត្រូវបែកបំណែកជាដី ក្លាយជាឥតន័យនៅទីបំផុត ។
នោះយ៉ាងណាមិញជីវិតសត្វលោក ឈឺឬឥតរោគវិយោគតក់ស្លុត
រមែងត្រូវស្លាប់ចោលកាយកប់ដុត នៅទីបំផុតក៏ដូច្នោះដែរ ។
ភាពពិតយ៉ាងនេះរិះគិតយ៉ាងណា គួររកធម៌អាថ៌ឬគួរកុំក្បែរ
អ្នកក្រក៏ស្លាប់មានក៏ស្លាប់ដែរ កម្មករថៅកែស្លាប់តែទាំងអស់ ។
អ្នកកើតតែងស្លាប់មិនយ៉ាប់គិតទេ ទាំងយើងទាំងគេស្លាប់ឥតសល់សោះ
គ្រាន់តែមុនក្រោយយូរឆាប់ប៉ុណ្ណោះ គួរគិតមើលចុះគួរធ្វើយ៉ាងណា ។

## ស្វែងរកសេចក្ដីសុខក្នុងភពកម្ម

អាកាសពុំឆ្អែតទៅដោយព្រះពាយ សមុទ្រទាំងឡាយពុំឆ្អែតដោយទឹក
ចិត្តអ្នកជាម្ដាយពុំឆ្អែតក្ដីនឹក គិតកូនល្ងាចព្រឹកដោយក្ដីមេត្តា ។
ភ្លើងពុំដែលឆ្អែតទៅដោយឈើងាប់ លោភៈពុំស្កប់ដោយក្ដីប្រាថ្នា
កិលេសពុំឆ្អែតដោយកាមតណ្ហា មានរូបសង្ខារពុំផុតជរា ។
តើឧបាទានណាមិនប្រកាន់ តើបញ្ចក្ខន្ធណាគ្មានរោគា
តើអារម្មណ៍ណាដែលគ្មានវេទនា កាយចិត្តគ្រាំគ្រាលោកណាគ្មានទុក្ខ ។
ដោយសុខតិចជាងលួចលួងចិត្តកាយ ហាក់ដូចសប្បាយមោហៈបាំងមុខ
សប្បាយភ្លេចខ្លួននៅក្នុងកងទុក្ខ ខំស្វែងរកសុខនៅក្នុងភពកម្ម ។
រកម្លប់ត្រជាក់កណ្ដាលវាលក្ដៅ យកទឹកស្រោចស្មៅរកផលដំណាំ
គ្រាប់ល្អមិនសាបពូជល្អមិនដាំ ឥតជឿផលកម្មរកចាំព្រះជួយ ។

## បើចិត្តខឹងក្រោធកុំចោទអ្នកដទៃ

ល្អាងភ្នំជុំសព្វឥតស្ងប់ព្រះពាយ សមុទ្រទាំងឡាយឥតស្ងប់រលក
មេឃមិនស្រឡះឥតខ្វះពពក មាសសុទ្ធមិនយកទៅរកដុំថ្ម ។
សាបពូជមិនដុះបន្ទោសតែគ្រាប់ ជាងផ្សារមិនជាប់បន្ទោសសំណ
ស្រមោចរោមនំទៅបន្ទោសស្ករ ដេកផ្អៀងផ្ងោះកទៅបន្ទោសខ្នើយ ។
បើចិត្តក្រោធខឹងនឹងបុគ្គលណា មិនត្រូវប្រហារព្យាបាទគេឡើយ
គឺត្រូវសម្លាប់ក្ដីក្រោធនោះហើយ សន្ដានបានស្បើយល្ហើយដេកជាសុខ ។
អ្នកឈ្នះរមែងមានពៀរវេរា អ្នកចាញ់គ្រាំគ្រារមែងរងទុក្ខ
អ្នកឥតក្រោធខឹងរមែងបានសុខ ចិត្តស្រួលស្រណុកព្រោះឥតសត្រូវ ។
ពៀរពុំដែលស្ងប់ដោយការចងពៀរ អ្នកបៀតបៀនគ្មានរមែងអាស្រូវ
អ្នកមានមេត្តាចិត្តឥតឃោរឃៅ ពិតដើរចំផ្លូវព្រះអរិយៈ ។

# សម្តីជាអ្វី?

សម្តីជាទ្រព្យប្រើរាប់មិនអស់ តែបើប្រើទាស់នាំកើតហិង្សា
នាំឱ្យគុំកួនជាប់ក្នុងចិន្តា អាចហ៊ានប្រហារប្រាថ្នាធ្វើឃាត ។
បើប្រើត្រឹមត្រូវត្រង់តាមព្រះធម៌ នាំជួបផលល្អបវរឥតឃ្លាត
សម្តីកើតយសរស់មានមិត្តញាតិ សម្តីសជាតិមារយាទ សព្វជ ។
សម្តីល្អជាពូជធារល្អគាប់ សម្តីឥតភ័ព្វបង់ទ្រព្យខាតខូច
សម្តីមានន័យល្បីឆ្ងាយរាប់យោជន៍ សម្តីឥតខូចប្រយោជន៍គង់មាន ។
សម្តីគួរគាប់ជាប់ព្រហ្មវិហារ ព្រមដោយសទ្ធាបូជាសីលទាន
សម្តីជាធម៌ល្អប្រៀបផ្ទឹមគ្មាន ប្រាប់ផ្លូវនិព្វានធម្មយានបរិយាយ ។

# ល្អបូកល្អស្មើធម៌អ្នកប្រាជ្ញ

ឆ្លាតបូកព្យាយាមស្មើលាមបញ្ញា ល្ងង់បូកឥស្សាស្មើទ្វារអវិចី
ល្ងីតបូកនឹងយប់ស្មើអាប់រស្មី ភ្លឺបូកនឹងថ្ងៃចាញ់រស្មីធម៌ ។
ខឹងបូកគំនុំស្មើផ្តុំអកុសល ភ្លេចបូកមិនស្គាល់ស្មើផលវឹកវរ
ស្រឡាញ់បូកស្នេហ៍ស្មើខ្សែវណ្ឌក ស្រស់បូកស្អាតល្អកំដរអ្នកហ៊ាន ។
មាយាបូកស្និទ្ធស្មើចិត្តឥតខ្មាស រឹងបូកមុខក្រាស់ស្មើឥតវិញ្ញាណ
កំណាញ់បូកស្អប់ស្មើកប់ថ្នាក់ទាន សទ្ធាបូកមានចម្រើនបុណ្យល្អ ។
ល្ងង់ដកមានះប្រទះសួគ៌ជាក់ ឆ្លាតដកគារវៈស្មើអ្នកអធម៌
អ្នកអួតលើកខ្លួនស្មើក្បួនភូតភរ ឆ្លាតគប់មិត្តល្អស្មើធម៌កុសល ។
រកបូកប្រសប់ស្មើទ្រព្យអ្នកមាន សីលបូកនឹងទានស្មើស្ពានមគ្គផល
សុខបូកលាភយសស្មើរសបុណ្យផ្តល់ មគ្គបូកនឹងផលស្មើថ្នល់និព្វាន ។

## កុំរកទោសគេ

សេពគប់នឹងល្បែងវិនាសតែងចាំ ប្រព្រឹត្តចោរកម្មគុកចាំទទួល
ប្រព្រឹត្តមិនសមអារម្មណ៍មិនស្រួល សតិប្រែប្រួលដួលព្រោះស្រវឹង ។
គួរសាងកុសលតម្កល់ចិត្តកាយ រស់ដោយសប្បាយរំសាយកំហឹង
កុំឱ្យស្ដាយក្រោយព្រោះថាមិនដឹង បាបធ្ងន់យ៉ាងហ្នឹងគួរដឹងគួរវាង ។
ខ្លួនទីពឹងខ្លួនតាមក្បួនតម្រា ព្រះធម៌ចែងថាជីវិតមិនទៀង
កុំអាងនៅក្មេងវង្វេងតែវាង បញ្ឆិតបញ្ឆៀងផ្ទៀងរកទោសគេ ។
កំហុសខ្លួនឯងជាក់ស្ដែងឥតស្ដី ទោសអ្នកដទៃរំពៃធំទ្វេ
ដីរមួយស្លាប់បាំងនឹងចង្អេរ ជិតដៃរឬទេគួរពិចារណា ។
កំហុសតែងមានចំពោះអ្នកធ្វើ អ្នកអង្គុយមើលកុំចេះតែថា
គួរមានមេត្រីដោយក្ដីមេត្តា ទៅតាមធម៌អាថ៌ដែលព្រះទូន្មាន ។

## អន់ណាស់គង់ប្រើខ្លះបាន

ប្រហុកត្រីស្អុយគង់មានគេស្ល ធ្វើនំឥតស្ករគង់មានរសជាតិ
នៅស្រែឬក្រុងគង់តែមានញាតិ រស់ឥតមារយាទញាតិពោលបង្អាប់ ។
កូនស្លូតឬកាចគង់មានម្ដាយស្ដី ក្មេងតូចស្រដីគង់មានគេត្រាប់
ជនល្ងង់ពោលត្រង់គង់មានគេស្លាប់ ខ្ពស់ហួសលំដាប់គ្មានញាតិរាប់អាន ។
ទឹកថ្លុកមួយក្អឹកផឹកគង់បាត់ស្រេក សមុទ្រធំពេករកផឹកពុំបាន
កើតទាន់សាសនាមិនគួរលង់ប្រាណ គេទៅនិព្វានឯងញៀនតណ្ហា ។
ទម្រាំភ្ញាក់ខ្លួនជួនជាជរា មច្ចុទាមទារបើកទ្វារប៉ាឆា
បើយល់ធម៌ទាន់គ្រាន់យោងអាត្មា ព្រះធម៌រក្សាឥតរើសក្មេងចាស់ ។
របស់អន់ណាស់គង់ប្រើខ្លះបាន បើអន់សន្ដានរំខានខ្លាំងណាស់
មានអ្វីដែលល្អជាជាងធម៌ព្រះ គួរដាក់មានះរូតរះរកធម៌ ។

បើចង់បានទឹកកុំលុបប្រឡាយ បើចង់សប្បាយកុំធ្វេសប្រហែស
បើចង់ទុំល្អកុំបន្ទាន់បេះ បើចង់យកចេះកុំរហ័សខឹង ។
បើចង់រាប់អានកុំចេញចូលញាប់ បើចង់បញ្ចប់កុំធ្វើពាក្យប្តឹង
ចង់បានអំណោយកុំឱ្យមាត់រឹង ចង់បានដំណឹងកុំនិយាយកាត់ ។
បើចង់ជំនួញកុំជួញប្រដេញ បើចង់ចំណេញកុំកេងបំបាត់
ចង់ធ្វើប្រធានកុំហ៊ានតែមាត់ ចង់លាក់ឱ្យស្ងាត់កុំមាត់រអិល ។
បើចង់បានល្អកុំភ្លេចបុណ្យទាន បើចង់បានមានកុំភ្លេចទានសីល
បើចង់ផុតទុក្ខកុំពុតខូចខិល បើចង់ជាប់សីលកុំភ្លេចសង្រួម ។

## សាមគ្គីរឹងមាំសមនឹងឈ្មោះល្អ

សត្វគោមាឌតូចតែមានអំណត់ ក្របីធំធាត់តែចាញ់កម្តៅ
សត្វរុយវារោមព្រោះមានដំបៅ គេស្គាល់ក្រយៅព្រោះឃើញមារយាទ
ចំណងមេបារៀបការកូនចៅ អញ្ជើញញាតិផៅឱ្យពរឱ្យជ័យ
ស៊ីការសប្បាយចាយប្រាក់ចងដៃ ធ្វើការដប់ថ្ងៃចងដៃការមួយ ។
ពេលមង្គលការហ៊ឺហាសប្បាយ ស៊ីផឹកក្អាកក្អាយកាយចិត្តឥតព្រួយ
គិតថាបានគ្នាគ្រាន់ជាជំនួយ ភ្លេចគិតថែមមួយព្រួយស្មើខន្ធដប់ ។
កាយមួយខន្ធប្រាំរងកម្មអនេក កាយពីរទឹកភ្នែកសង្វេគគ្រប់សព្វ
កាយច្រើនរោគច្រើនចម្រើនទុក្ខជាប់ រស់ចាំថ្ងៃស្លាប់ក្រែងអស់អាស្រូវ ។
ព្រះធម៌នៅមានម្តេចមិនរៀនស្តាប់ ព្រះធម៌ជាច្បាប់ប្រាប់បង្ហាញផ្លូវ
មានរូបមានទុក្ខមានខុសមានត្រូវ គួរខំរៀនទៅកុំខុសច្រើនពេក ។

## សង្ខារមិនទៀង

លំហអាកាសស្រឡះបវរ ជាទីត្រាច់ចរនៃសត្វបក្សី
រុក្ខជាតិព្រៃភ្នំមនោរម្យប្រពៃ ជាទីត្រាច់នៃម្រឹគីម្រឹគា ។
ទន្លេជលសាមហាសាគរ ជាទីត្រាច់ចរមច្ឆានានា
សង្ខារតាក់តែងក្មេងចាស់ជរា ជាទីលីលានៃការមិនទៀង ។
កាយមួយខន្ធប្រាំចូរចាំប្រុងស្តាប់ ដកខន្ធមួយស្លាប់នៅតែរូបរាង
គល់ឈើធ្វើឧសនោះគ្រាន់បើជាង គួរខ្ពើមគួររាងគួរវាំងរកធម៌ ។
កុំអាងមានទ្រព្យជាប់ដោយយសស័ក្តិ សេចក្តីមរណៈឥតយល់ខ្មៅស
អ្នកសាងកុសលទើបជួបផលល្អ អ្នកសេពគប់ធម៌មិនសូវតក់ស្លុត ។

## ស្អប់តែឈ្មោះ

ដើមដូងពូជដូងដើមខ្នុរពូជខ្នុរ ពូជមនុស្សចិត្តចោរពូជខ្នុរឥតផ្លែ
ដាំដូងពូជធំក្លាយជាតឹកកែ ចង់រៀនធម៌ដែរតែនៅជាប់ជើង ។
ពាក្យថាការពិតគឺភាពជាក់ស្តែង ទីណាមានផ្សែងតែងតែមានភ្លើង
កាលណាដាច់គល់ទើបឈើរលើង បក្សពួកកើតឡើងទើបមានជម្លោះ ។
បព្វជិតទាំងឡាយខ្វល់ខ្វាយប្រតិបត្តិ តាមធម៌បញ្ញត្តិនៃព្រះសាស្តា
បរិស័ទទាំងឡាយសប្បាយបូជា ដោយចិត្តសទ្ធាបូជាឥតស្តាយ ។
ព្រះសង្ឃសាវ័កជាក់ជាស្រែបុណ្យ ជនសាបពូជមុនបានផលឯនាយ
ពុំព្រួយរីងរាំងពុំខ្លាចជន់សាយ រីករាយសប្បាយឥតស្តាយស្រណោះ
ប្រសិនបើវត្តអត់មានព្រះសង្ឃ លោកមានតែស្បង់សង្ឃបាត់បង់អស់
ទាំងធម៌វិន័យបាត់បង់សម្រស់ នោះហៅថាគ្រោះអន្តរាយសាសនា ។
ហៃអស់នរជនទាំងឡាយអើយ ចូរកុំកន្តើយខិតខំសិក្សា
ទាន់ធម៌នៅមានរៀនពិចារណា ចង់ឈ្នះចាញ់គ្នាបានប្រយោជន៍អ្វី ។

## ចេះពិតមិនអត់

ចេញដំណើរឃើតតែមានគោលដៅ ជាជាងលឿនស្លៅទាំងមិនដឹងទិស
សង់ផ្ទះតូចទាបគង់តែមានគ្រឹះ ឈើខ្ពស់ឥតឫសមានអ្វីប្រាកដ ។
ឈើខ្ពស់ដើមលៃតែងភ័យនឹងខ្យល់ ឈើទាបមែកទាល់ខ្វល់នឹងវល្លិពទ្ធ
ឈើខ្លឹមឫសធំថ្មភ្នំសង្កត់ ឈរមាំអំណត់អត់ខ្លាចព្រះពាយ ។
នោះយ៉ាងណាមិញចំណេះចេះស្ទាត់ ឥតភ័យក្រែងអត់ប្រាកដពណ្ណរាយ
ការងារសុចរិតឥតគិតរាយមាយ បុណ្យទានឥតស្ដាយចំណាយបូជា ។
នេះហៅថាចេះចំណេះខុសត្រូវ ឥតចេញចាកផ្លូវនៃព្រះធម្មា
ស្ថានសួគ៌ស្ថានសុខចាំគ្រប់វេលា និព្វានបើកទ្វារជានិច្ចរង់ចាំ ។

## ឥតសីល

ក្រហមជិតភ្លឺព្នមាត់សុំសីល តែមាត់រអិលចេញពីដំណេក
យប់មិញយល់សប្ដិភ្លេចចាក់កន្ទុយលេខ រវល់តែដេកភ្លេចចាក់ខ្ទង់សែ ។
ក្រហមជិតភ្លឺព្នមាត់សុំសីល ភ្លឺភ្លៀងរអិលអ្នកខិលកុំក្បែរ
ត្រីឡើងច្រើនណាស់នៅតាមភ្លឺស្រែ ខ្ញុំពុំហ៊ានក្បែរគ្រាន់តែប្រើគេ ។
ក្រហមជិតភ្លឺព្នមាត់សុំសីល កុំមាត់រអិលតាមតៀមកាហ្វេ
ពេលពេញមួយព្រឹករលីកដើមគេ គ្មានពេលទំនេរទេរៀនធម៌អាថ៌ ។
ថ្ងៃសីលម្សិលមិញឃើញចេញពីវត្ត ពោលថានឿយហត់មាត់ធុំសុរា
រឿងនេះគួរស្លុតស្រយុតចិន្ដា យកម្កុដទេវតាពាក់ទៅអវិចី ។

# មាយាតណ្ហា

ជនក្នុងលោកិយ តែងឱ្យតម្លៃ មាសពេជ្រទ្រព្យធន
ថាមានតម្លៃ ប្រសើរលើសលន់ អាចជួយសម្រន់
សម្រាលក្តីទុក្ខ ។

គេតែងប្រាថ្នា ព្រោះតែយល់ថា រស់នៅសោយសុខ
ព្រោះតែមាសប្រាក់ នេះជាប្រមុខ រស់លែងកើតទុក្ខ
សោយសុខមួយជាតិ ។

ព្រោះតែយ៉ាងហ្នឹង ទើបគេខំប្រឹង ប្រើគ្រប់ល្បិចស្ទៀត
បានប៉ុណ្ណេះហើយ ចង់ប៉ុណ្ណោះទៀត ចាញ់កលមារយាទ
មាយាតណ្ហា ។

ពុំឃើញសុខសោះ ទោះទ្រព្យរបស់ នោះច្រើនប៉ុណ្ណា
ព្រោះពុំអាចស្កប់ ចប់ក្តីប្រាថ្នា មានតែក្តៅផ្សា
ចិន្តាមួហ្មង ។

សុខក្នុងសាសនា តាមពុទ្ធដីកា ថាសុខចម្បង
គឺស្ងប់ក្នុងចិត្ត ឥតក្តីសៅហ្មង សុខក្រៃកន្លង
គ្មានអ្វីប្រៀបស្មើ ។

អ្នកស្រី ជូ ស៊ូហៀង

# ភ្លើងកាមតណ្ហា

ពាក្យថាស្រឡាញ់ ពីរោះផ្អែមឆ្ងាញ់ អន្ទាក់ដួងចិត្ត
ជនក្នុងលោកិយ កើតក្តីវិបរិត អំពល់ពេលពិត
ជ្បិតពាក្យស្រឡាញ់ ។

ឯក្តីស្នេហា បក្សពួកតណ្ហា ជនផងតែងចាញ់
ស្ថិតនៅក្រោមនឹម ប្រឹងឱ្យត្របាញ់ មានះគិតកាញ់
ជ្បិតត្រូវពិសពុល ។

ឱ!ក្តីស្រឡាញ់ ប្រៀបដូចសំណាញ់ ដែកមានឥទ្ធិពល
ជនដែលជាប់ហើយ ពិតជាវិលវល់ ពុំអាចបានយល់
រស្មីក្តីសុខ ។

ដូចជនត្រូវពិស តែងវង្វេងទិស តណ្ហាដឹកមុខ
រស់នៅវងកម្ម ក្នុងវិមានទុក្ខ រស់នៅក្នុងគុក
ភពកាមកិលេស ។

ចិត្តអន្ទះសា ភ្លើងកាមតណ្ហា ដុតរោលឆាបឆេះ
ឈឺចាប់ខ្លោចផ្សា ឱរាស្ទើរប្រេះ អន្លង់កាមស្រេះ
ឆេះលុះថ្ងៃស្លាប់ ។

# អានិសង្សបុណ្យទាន

រីការធ្វើទាន ធ្វើបានជាស្ពាន ឈានទៅសួគ៌សុខ
ធ្វើបានជាទុន ទុកទៅជាតិមុខ កើតក្នុងសំបុក
សម្បត្តិភោគទ្រព្យ ។

ទានមានអង្គបី ឱ្យផលក្រាស់ក្រៃ ប្រសើរគួរគាប់
ទីមួយទេយ្យធម៌ សមគួរដល់ទ្រព្យ ទីពីរនោះភ្ជាប់
នឹងចិត្តជ្រះថ្លា ។

រីឯទីបី អ្នកទទួលទេ- យ្យធម៌នេះណា
បរិបូណ៌ដោយគុណ ទើបញុំាងផលា អានិសង្សា
ថ្លៃថ្លាកន្លង ។

ទោះបីមានទ្រព្យ តែមិនបានភ្ជាប់ អង្គបីនេះផង
ធ្វើច្រើនយ៉ាងណា តែខុសគន្លង ច្រើនតែសៅហ្មង
ផលបានពុំគាប់ ។

អ្នកសោយបុណ្យចាស់ កើតមកប្រទះ លើគំនរទ្រព្យ
តែមិនចេះប្រើ ដោយផ្លូវគួរគាប់ មុខតែអភ័ព្វ
ក្នុងជាតិខាងមុខ ។

អ្នកសាងបុណ្យថ្មី មានពីរអត្ថន័យ ផ្សេងទាំងក្តីសុខ
អ្នកមួយសាងកម្ម ជាទ្រព្យកប់ទុក កប់តស៊ីចុក
ទុកចាយជាតិថ្មី ។

អ្នកសាងម្យ៉ាងទៀត ព្រោះលះបង់ជាតិ ចេញចាញភពបី
ប្រាថ្នានិព្វាន ស្ពានសុខសិរី ឥតមានសុខអ្វី
អាចប្រៀបផ្ទឹមបាន ។

# ខ្សែជីវិត

បានជាកើត មកជាមនុស្ស ផុតតិរច្ឆាន
គួរប្រិតប្រាណ គិតប្រយោជន៍ ដោយប្រយ័ត្ន
ប្រព្រឹត្តល្អ ទុកបន្ត កុំឱ្យបាត់
ក្រែងវាខ្ចាត់ ទៅអបាយ ស្ដាយពុំខាន ។
ថ្ងៃនិងយប់ វិលទៅមុខ ឥតបង្អង់
ទោះមិនចង់ គិតអែអង់ ក៏មិនបាន
លេបត្របាក់ នូវសង្ខារ ជនគ្រប់ប្រាណ
ឥតសល់ខាន គ្មានរួចបាន ម្នាក់ណាឡើយ ។
បើក្ដីស្លាប់ យូរឬឆាប់ គង់មកដល់
ម្ដេចអំពល់ ឈ្លោះដណ្ដើម គ្នាឥតស្បើយ ។

# តារារាប់រយចន្ទមួយភ្លឺជាង

ផ្កាយច្រើនអនេក រះនៅពេញមេឃ តើប្រយោជន៍អ្វី
ព្រោះមិនអាចញុំាង ស្បែខ្មៅរាត្រី ឱ្យភ្លឺស្វាងស្វៃ
ចាកក្ដីអន្ធការ ។
អ្នកមានបុត្រច្រើន តែមិនចម្រើន ដល់ពូជពង្សា
ច្រើនតែបុត្រពាល នាំរាលក្ដៅផ្សា តើនឹងប្រាថ្នា
បុត្រនោះឬទេ?

ទោះបុត្រតែមួយ តែអាចលើកស្ទួយ គិតគួរគ្មាន់គ្នេរ
ឱ្យម្ដាយឪពុក ខ្ពស់មុខនឹងគេ យសស័ក្តិខ្ពស់ទ្វេ
ព្រោះបុត្រពិសី ។
ដូចដួងចន្ទ្រា តែមួយអង្គា ហៅសែនប្រពៃ
ពេញវង់ត្រចង់ ចាំងចែងរស្មី អាចញ៉ាំងរាត្រី
ឱ្យស្រស់ត្រកាល ។

## ចៅកែដាច់ដាប

ចិត្តអើយចិត្តខឹង ចិត្តឯងខំប្រឹង ដុតខ្លួនឯងទៅ
ចិត្តអើយចិត្តពាល នាំរាលក្ដៅៗ ចិត្តឯងនោះខ្មៅ
ជាប់ផៅកិលេស ។
ចិត្តអើយចិត្តបាប ចិត្តឯងនេះដាប ដោយក្លិនឆ្អាបឆ្អេះ
ចិត្តអើយចិត្តចង់ បំណងយ៉ាងនេះ ចង់នោះមិនចេះ
ចប់អស់ក្ដីចង់ ។
ចិត្តអើយចិត្តលោភ ទោះបានបរិភោគ ក៏នៅត្រាច់ត្រង់
ត្រាច់ទៅត្រាច់មក រកបានដូចបង់ ដកករហង់
បាក់ពោះដដែល ។
ចិត្តអើយៗចិត្ត គួរណាស់តែគិត រកផ្លូវគេចកែ
ខ្ញុំអ្វីក៏គ្រាន់ ជាងខ្ញុំចៅកែ តណ្ហានេះដែរ
ចៅកែដាច់ដាប ។

## អានិសង្សសីល

សីលជាកម្មល្អ សីលជាគុណធមិ ខ្ពង់ខ្ពស់ឧត្តម
អ្នកដែលប្រព្រឹត្ត គំនិតស័ក្តិសម នោះសីលនឹងនាំ
ដាក់ដល់សួគិសុខ ។

សីលជាពំនឹង ពំនាក់ពាក់ពឹង ជាគ្រឿងនាំមុខ
ជាទីអាស្រ័យ ការពារក្តីសុខ រួចផុតចាកគុក
នៃថ្លុកអបាយ ។

សីលល្អនេះណា ទោះអលង្ការ ស្រស់ល្អឆើតឆាយ
ដែលព្រះរាជា ប្រដាប់អង្គកាយ គង់នៅចាញ់ឆ្ងាយ
មិនល្អដូចសីល ។

សីលកម្ចាត់ភ័យ រីករាយប្រពៃ ជម្រះមន្ទិល
ក្តីក្តៅក្រហាយ ក៏កាត់ផ្តាច់ផ្តិល អានិសង្សសីល
សុខស្ងប់ក្រៃលែង ។

## ឆឹកចិត្តម៉ែ

-ម៉ែខំពរកូននៅក្នុងផ្ទៃ ម៉ែសែនភិតភ័យឥតឧបមា
ម៉ែតមចំណីមិនពិសា ម៉ែឃ្លានយ៉ាងណាមិនហ៊ានឆី ។

-ម៉ែផឹកទឹកថ្នាំរក្សាគភ៌ ម៉ែផឹកស្មៅវល្លិ៍ថៃកូនខ្ចី
ម៉ែខំថៃខ្លួនព្រោះពិសី ម៉ែចិត្តប្រណីមិនខឹងតប ។

-ម៉ែឈឺពោះពើតចុកខ្លោចផ្សា ម៉ែឈោងស្រវ៉ាអោបដៃឆ្នប

ម៉ែខំបន់ស្រន់ឱ្យប្រកប ម៉ែធ្វើមាត់ហបញ័រជើងដៃ ។
-ម៉ែឈឺខ្លាំងណាស់ឆ្លងទន្លេ ម៉ែភ័យជាងគេខ្លាចកូនក្ស័យ
ម៉ែហូរទឹកភ្នែកច្រើនពេកក្រៃ ម៉ែចិត្តអាល័យតែកូនមួយ ។
-ម៉ែឆ្លងទន្លេបានរួចហើយ ម៉ែចិត្តធូរស្បើយបាត់ភ័យព្រួយ
ម៉ែអរខ្លាំងណាស់គេមកជួយ ម៉ែបាត់ចុករួយឈឺពើតផ្សា ។
-ម៉ែប្រឹងបើកភ្នែកមើលព្រឹមៗ ម៉ែចិត្តញញឹមក្នុងអាត្មា
ម៉ែអើតរកកូនដៃស្រវ៉ា ម៉ែពោលវាចាថាមាសម្ដាយ ។
-ម៉ែសសៃខ្ទីបីកូនបៅ ម៉ែផឹកទឹកក្ដៅរក្សាកាយ
ម៉ែអោបកូនជាប់មិនទៅឆ្ងាយ ម៉ែខ្លាចកូនម្ដាយឃ្លានបៅដោះ ។
-ម៉ែលឺមាត់កូនស្រែកយំង៉ា ម៉ែស្ទុះឆ្លេឆ្លាមុខក្រៀមក្រោះ
ម៉ែមិនចង់លឺកូនយំសោះ ម៉ែលួកលាត់ដោះមិនខ្មាស់គេ ។
-ម៉ែលើកកូនទូលដាក់លើក្បាល ម៉ែស្រែកថាស្រាលមិនធ្ងន់ទេ
ម៉ែខំស្រែកច្រៀងមាត់បំពេរ ម៉ែលឺកូនជេរថាពីរោះ ។
-ម៉ែបញ្ចុកបាយនំចំណី ម៉ែឱ្យកូនឆ្អិបានពេញពោះ
ម៉ែមិនគិតទេកិត្តិយស ម៉ែឱ្យកូនរស់ព្រោះស្នេហា ។

**និពន្ធដោយ មុត ឡោម**

# សង្គ្រាមកិលេស

សេចក្ដីព្យាយាម នេះជាទំនៀម គូនឹងឆន្ទៈ
ដូចជាសេនា ខ្លាំងក្លាពីរនាក់ បញ្ញានោះជាក់
អាវុធមុតថ្លា ។

សេនាទាំងពីរ រួបរួមសាមគ្គី ពិតជាអស្ចារ្យ
ចាប់លើកអាវុធ ប្រយុទ្ធប្រហារ ដេញខ្មាំងឫស្យា
គឺខ្មោចកិលេស ។

ធម៌បីនេះពិត ប្រជុំនឹងចិត្ត ពិតជាពិសេស
ពិសាលក្លាខ្លាំង ខ្មាំងចាល់តម្រិះ នគរកាយប្រេះ
ឆេះខ្មោចគុកកម្ម ។

ជីវិតតែមួយ រំពឹងគិតព្រួយ ច្រើនថ្ងៃខែឆ្នាំ
ខំធ្វើបុណ្យទាន ជាប់ជាប្រចាំ លះនូវបាបកម្ម
ចេះចាំមានក្បួន ។

បុណ្យបានដោយបុណ្យ អ្នកសន្សំគុណ បុណ្យកើតច្រើនផ្ទួន
អ្នកប្រព្រឹត្តបាប ផ្ទុំអ្នាបពេញខ្លួន គិតតែគុំកួន
ច្រណែននឹងគេ ។

ឃើញបុណ្យគេល្អ ខ្លួនឯងខ្វារ-ក តូចចិត្តម្ល៉េះទេ
មិនសន្សំបុណ្យ ជាទុនដូចគេ គិតតែរិះរេ
ធ្វើបាបបន្ថែម ។

បាបកម្មគួរយល់ ពុំទាន់ឱ្យផល បាបដូចជាផ្អែម
ពេលបានឱ្យផល ទុក្ខជួនបន្ថែម ឥតមានផ្អែមល្ហែម
ដូចពាលគិតស្មាន ។

ភ្លើងនោះពិតក្ដៅ មនុស្សអាចច្នៃទៅ ជាប្រយោជន៍បាន
កាយនេះពិតស្អុយ មានរោគរំខាន តែជនចំណាន
ស្រង់បានប្រយោជន៍ ។

យើងអាចសាងបុណ្យ សាងបានជាទុន មុនស្លាប់ជាខ្មោច
សាងបានជាស្ពាន ឆ្លងភពអសោច សម្រេចប្រយោជន៍
ឆ្លងផុតភពបី ។

## គុកកាម

គុកកម្មគុកកាម គុកញៀនគុកញ៉ោម ដាមជាប់ដួងចិត្ត
គុកចាប់ខ្ញុំចង ចំណងជីវិត គុកដាក់ខ្ញុំពិត
ដ្បិតអវិជ្ជា ។

ហេតុតែខ្ញុំល្ងង់ បានមកជាប់ជង់ បញ្ចក្ខន្ធា
ជាប់ក្នុងអន្ទាក់ កាមរាគា រស់រងវេទនា
រោលរាលក្ដៅផ្សា ។

ត្រូវភ្លើងរាគៈ ទោសៈលោភៈ ដុតរោលចិន្ដា
ឆេះក្ដៅរងទុក្ខ ក្នុងគុកកាមា ព្រោះតែប្រាថ្នា
តណ្ហាលោភលន់ ។

ត្រូវនីវរណៈ ជាគ្រឿងរាំងស្ទាក់ ងងឹតពេកពន់
បិទស្ថានសួគ៌សុខ ជួបទុក្ខមហាធ្ងន់ ខំប្រឹងរែកពុន
ទារុណលោកិយ ។

កម្មអ្នកចាត់ចែង សង្ខារតាក់តែង ផ្គុំអង្គប្រុសស្រី
បង្កើតខន្ធគុក ជាទុក្ខឥតបី គួរណាស់លកលៃ
គិតកែដើរចេញ ។

លះក្តីប្រាថ្នា នៅក្នុងកាមា ដែលនាំទោម្នេញ
កាត់ក្តីអាល័យ ឥតបីវិលវិញ ញ៉ាំងចិត្តឱ្យពេញ
ដោយបុណ្យកុសល ។

ដូច្នេះតទៅ កុំលង់លក់នៅ ក្នុងក្តីកង្វល់
សម្មាសតិ នោះត្រូវតម្កល់ នឹងបានមគ្គផល
ក្នុងគ្រាខាងមុខ ។

ឈប់លែងបណ្តោយ បណ្តែតទៀតហើយ ទើបរួចផុតទុក្ខ
រំលត់កិលេស ដែលឆេះលុយលុក កម្ទេចកម្មគុក
បានសុខតទៅ ។

## ពេញបូណ៌មីថ្ងៃឧបោសថ

រាត្រីស្រឡះ ចន្ទរះភ្លឺច្បាស់ ប្រាសចាកមន្ទិល
ថ្ងៃឧបោសថ សមាទានសីល ជម្រះផ្តាច់ផ្តិល
បាបអកុសល ។

រាត្រីប្រពៃ ចន្ទពេញបូណ៌មី ចិត្តឥតកង្វល់

ដួងចន្ទស្អាតល្អ ដូចចិត្តតម្កល់ តាំងក្នុងកុសល
បរិសុទ្ធម៉ត់ហ្មង ។

រាត្រីសោភា មើលដួងចន្ទ្រា កំពុងរះឆ្លង
បញ្ចេញរស្មី បំភ្លឺសត្វផង ដូចសីលចម្លង
ជនផងដល់ត្រើយ ។

រាត្រីភ្លឺថ្លា ចន្ទចរយាត្រា ហាក់បានល្ហែល្ហើយ
ដូចសីលកម្ចាត់ មន្ទិលចិត្តហើយ ចិត្តនោះបានស្បើយ
ឃើញត្រើយសុខា ។

ពន្លឺចន្ទថ្លៃ ញ៉ាំងពេលរាត្រី ឱ្យស្រស់អស្ចារ្យ
ដូចសីលជម្រះ ដុសខាត់បញ្ញា ឱ្យបានភ្លឺថ្លា
ប្រហារកិលេស ។

## ប្រទីបបញ្ញា

ជនអ្នកប្រាថ្នា ដុសខាត់បញ្ញា ឱ្យភ្លឺប្រពៃ
ដូចដួងប្រទីប ពេញដោយរស្មី គួរចូលអាស្រ័យ
នឹងសប្បុរស ។

នឹងបានសាកសួរ នូវហេតុដែលគួរ មិនគួរទាំងអស់
អ្វីជាកុសល ពុំមានទើសទាល់ បាបគួរបង់បោះ
ដឹងអស់សេចក្តី ។

នេះជាប្រយោជន៍ រស់ពុំអសោច នៅនាលោកិយ
បានគប់បណ្ឌិត ពិតមានសិរី រស់ក្នុងសេចក្តី
សុខអស់កាលយូរ ។[៥២]

# នាទីស្វាមីនិងភរិយា

នាទីស្វាមីនិងភរិយា ប្រាំ៧ដូចគ្នាធមិសង្គ្រោះ
សម្រាប់ឱ្យយើងកាន់រួមរស់ សន្តោសដល់គ្នាជាប្រក្រតី ។
បើមានខាតខុសខាងភរិយា តាំងចិត្តឱ្យជាកុំជេរស្តី
ពុំនោះមានខុសខាងប្រុសក្តី ភរិយាជាស្រីទូន្មានបាន ។
ព្រោះខ្លួនទាំងពីរជីវិតមួយ កុំឱ្យមានព្រួយកើតរំខាន
អត់ឃ្លានមានស៊ីត្រូវក្លាហាន សាងគ្រួសារឋានឱ្យសុខអើយ ។

បើមានអ្នកណានីមួយនិយាយថា ខ្ញុំមិនមានចិត្តអាក្រក់ព្យាបាទទេ ដូច្នេះក៏ដោយ បុគ្គលមិនគួរជឿពាក្យនេះយកជាហេតុមេត្រីស្និទ្ធស្នាលឡើយ សេចក្តីពិត អ្នកដែលមានគុណគឺការចេះដឹងច្រើន ក៏តែងមានភ័យកើតមកពីមនុស្សទុច្ចរិតទាំងឡាយដែរ ។

ទស្សនៈ ភិក្ខុ ប៉ាង ខាត់ វិរិយបណ្ឌិតោ

៥២-ប៊ុត សាវង្ស ជំនួយសតិភាគទី៥ ទំព័រ២៦៨-២៨៤ ព.ស.២៥៤៣-៤៤ ។

## នាទីសិស្សនិងគ្រូ

លោកគ្រូនិងសិស្សតែងមានធម៌ ប្រាំយ៉ាងនេះល្អសង្គ្រោះគ្នា
ពន្យល់ហេតុផលការសិក្សា ឱ្យសិស្សជ្រះថ្លាយល់ចូលចិត្ត ។
វិជ្ជាផ្លូវលោកនិងផ្លូវធម៌ ជួយលុយអង្គរមូររឹតត្បិត
ឱ្យគ្នាបានចេះស្គាល់ក្រមក្រឹត្យ ព្រោះដ្បិតលោកគ្រូសង្គ្រោះសិស្ស
ឯសិស្សវិញសោតត្រូវយល់ការ កុំអាងបញ្ញាថាបំផ្លើស
ស្គាល់នាទីយើងថាជាសិស្ស កុំឆ្កឹះដេញដោលតែគ្រូឯង ។
ត្រូវចេះគោរពប្រណិប័តន៍គ្រូ អង្គសព្វញ្ញូទ្រង់សម្តែង
ថាត្រូវតបគុណចេះកោតក្រែង លោកបង្រៀនឯងផុតអវិជ្ជា ។
ដោយ យិន វន់

## អដ្ឋមហាឋាន

ឋានធំទាំងឡាយ៨កន្លែង ជាទីស្ងប់ស្ងែងដល់ពពួកសត្វ
ទី១ ឧទ្យានជាឋានព្រៃស្ងាត់ គឺព្រៃវាំងរតន៍ដែលទ្រង់ប្រសូត ។
ទី២ ប្រសើរដែលព្រះទ្រង់ស្រូត ត្រាស់ក្រោមដើមពោធិព្រឹក្សឧត្តម
-ទី៣ កន្លែងដែលព្រះបរម សម្តែងព្រះធម៌ឈ្មោះធម្មចក្រ ។
ប្រោសភិក្ខុ ៥អង្គគឺពួកបញ្ចវ- គ្គីយ៍ដែលជាអ្នកបម្រើព្រះអង្គ
ដោយព្រះទ័យថ្លៃមិនអាចលះបង់ ហើយយាងតម្រង់ពីដើមជ្រៃទៅ ។
-ទី៤ ជាទីដែលទ្រង់គង់នៅ ក្នុងឋានព្រៃជ្រៅឈ្មោះបាលិលេយ្យ
ទីនោះគ្មានមនុស្សមានតែសត្វព្រៃ គឺដំរីថ្លៃបម្រើព្រះអង្គ ។

ទី៥ គឺទីដែលព្រះពុទ្ធអង្គ ផ្ចាញ់សត្វទ្រនង់នាឡាគិរី
ទីនោះមានមនុស្សបែកពួកជា២ ទៅមើលពិធីនៃព្រះសម្ពុទ្ធ ។
ទី៦ កាលអង្គព្រះសព្វញ្ញុត្ត- ញ្ញាណជាម្កុដក្រៃលោកាចារ្យ
ផ្ចាញ់ពួកនិគ្រន្ថដោយបាដិហារ្យ ឈ្មោះល្បីអស្ចារ្យគ្មាននរណាដល់ ។
ទី៧ កាលអង្គព្រះទសពល គង់លើមណ្ឌលថ្មព្រះឥន្ទ្រា
ទ្រង់បានសម្ដែងនូវព្រះធម្មា ប្រាកដនាមថាធម៌អភិធម្ម ។
ទី៨ កាលអង្គព្រះសាស្ដា ផ្ទំក្រោមដើមសាលព្រឹក្សទាំងគូ
ពេលនោះឯងហើយព្រះសព្វញ្ញូ ព្រះអង្គជាគ្រូយាងចូលនិព្វាន ។
ឋានធំ ៨កន្លែងនេះមាន ប្រតិស្ឋានជម្ពូទ្វីបា
ជាទីដែលមនុស្សនិងពួកទេវតា មានចិត្តជ្រះថ្លាឆ្ពោះទៅយោគយល់ ។
ខ្ញុំសូមឱនកាយបង្គំឆ្ពោះដល់ ឋានធំនិមល ៨កន្លែង
សូមសុខចម្រើនកើតយូរអង្វែង ទុក្ខទោសចំបែងកុំកើតមានឡើយ ។

## មរណទុក្ខ

ទី៤ឈ្មោះថាមរណទុក្ខ លំបាកក្រៀមមុខទាំងចាស់ក្មេង
ទៀបពេលនឹងស្លាប់ច្រើនវង្វេង វិបរិតផ្សេងៗគ្មានស្ងប់ស្ងាត់ ។
ញ័រអស់ខ្លួនប្រាណសព្វជើងដៃ ស្បែកសាច់សរសៃថ្លើមប្រមាត់
បើធមិទាំងបីចេញផុតបាត់ កាយបីកំណាត់ដេកស្ដូកស្ដឹង ។
ពួកមិត្តសម្លាញ់ផងនានា យំស្ដាយគ្រប់គ្នាលាន់ទ្រហឹង
រូបអ្នកដែលស្លាប់គ្មានបានដឹង ដល់ថ្នាក់ត្រឹមហ្នឹងហៅថែកឋាន

សង្ឃឹមបងប្អូនកូនប្រពន្ធ ស្វាមីទ្រព្យធនទាំងប៉ុន្មាន
មាតាបិតាញាតិសន្តាន ជូនទៅពុំបានសឹងប្រាសព្រាត់ ។
សូម្បីតែលុយឬកាសប្រាក់ ដែលបានបង់ដាក់ចូលក្នុងមាត់
យកទៅពុំបានដោយទៀងទាត់ ចោលនៅរាយរាត់លើពសុធា ។
ធំស្រេចនឹងស្តេចមច្ចុរាជ សឹងមានអំណាចអាចពុះពារ
ផ្តិលផ្តាច់ជីវិតសត្វនានា ឥតមានរួញរាថាប្រុសស្រី ។
ត្រូវការមិនដែលឱ្យដំណឹង អ្នកផងបានដឹងហេតុសេចក្តី
ចូលផ្តាច់ជីវិតឥតមេត្រី គ្មានត្រាប្រណីប្រុសស្រីណា ។
បើទុកជាមានបុណ្យស័ក្តិធំ ប្រហែលឥន្ទ្រព្រហ្មនិងទេវតា
មច្ចុសង្គ្រាមគ្មានមេត្តា តែងតែប្រាថ្នាយកមិនសល់ ។
លើកលែងតែឋានព្រះនិព្វាន មច្ចុមិនហ៊ានចូលទៅដល់
ព្រោះឋាននោះឯកសុខថ្កើងថ្កល់ កើតដោយកុសលធំមហិមា
បើយើងចង់រត់ឱ្យផុតស្លាប់ ឱ្យបានរួចឆាប់ទាំងអស់គ្នា
ត្រូវខំសាងទាន សីលភាវនា ឱ្យរាល់វេលាបានគ្រប់គ្រាន់ ។
អាចចូលទៅកាន់និព្វានបាន ពូជស្លាប់ប៉ុន្មានតាមមិនទាន់
កំឆោតដោយកាមនាំបំភាន់ គួរគិតរួសរាន់គ្រាឥឡូវ ។
កុំអាងអាចារ្យឱ្យពុទ្ធោ ជិតស្លាប់ក្រែងលោថាមិនត្រូវ
កម្លាំងថយតិចគេចខុសផ្លូវ សង្ឃឹមម៉ែឪណាជួយបាន ។
កម្មខ្លួនអាក្រក់ទប់មិននឹង តែដាច់ខ្យល់ភឹងរៀបចែកឋាន
បើមិននរក គង់តិរច្ឆាន ឬប្រេតសាមាន្យ អសុរកាយ ។[៥៣]

## ទំនួញជីវីព្រះឆត្ទន្ត

ឱ!សព្ទទ្រាអើយគួរស្នេហា ម្ដេចចងវេរាពុំស្រាកស្រាន្ត
ប្រើព្រានកំណាចកាចសាមាន្យ បាញ់បងធ្លុះប្រាណបានវេទនា។
បើចង់បានភ្លុកបងថាថ្វី បាច់អីប្រើព្រានមកប្រហារ
ឱ្យបងចុកចាប់ឈឺខ្លោចផ្សា វេទនាណាស់ណាសព្ទទ្រាអើយ។
ថ្វីនាងមិនគិតកាលកម្សត់ ឯមេដំរីរត្នទឹមកក្បៀកកើយ
បងឥតឃោរឃៅនឹងប្អូនឡើយ ញុះព្រានប្រងើយឱ្យបាញ់បង ។
ល្ហើយចុះបងផ្ដាំ នឹងនាយព្រាន ឱ្យអូនស្រីបានភ្លុកបងហើយ
នៅឱ្យសុខសាន្តព្រលឹងអើយ បងលាសិនហើយស្លាប់ឥឡូវ។
ឱ!ព្រានសណ្ដូរចរលីលា ប្រាំពីរថ្ងៃណាឱ្យដល់ពៅ
ហើយប្រាប់បណ្ដាំការរាក់ជ្រៅ ទុក្ខទោសសត្រូវយើងគ្មានទេ។
តែយើងឱ្យភ្លុកដល់ប្អូនស្រី ស៊ូកាត់អាល័យណាមាសស្នេហ៍
ថ្វីថាបងស្លាប់ចុះមិនស្ដាយទេ ឱ្យតែបានត្រាស់ជាព្រះពុទ្ធហោង។

## ទំនួញនាងសព្ទទ្រា

សព្ទទ្រាគ្រាឃើញភ្លុកកាលណា ឱរាចុកណែនសែនអួលក្ដៅ
ឱរាសែនទុក្ខមុខសោកសៅ ឱ!អ្នកប្រុសពៅប្ដីសម្លាញ់។
ប្អូននឹកអ្នកណាស់ម្ចាស់ប្ដីអើយ ប្អូនមិនដឹងឡើយទេម្ចាស់បង
មកប្រាប់ដំណឹងឱ្យនួនល្អង ប្អូនសូមក្ស័យផងម្ចាស់បងអើយ។
ប្អូនបានឃើញភ្លុកទុក្ខឥតស្បើយ ឱ!ម្ចាស់ប្ដីអើយប្អូនសូមទោស
ប្អូនមិនដឹងប្ដីពិតដូច្នោះ ខ្លួនប្អូនសូមទោសនឹងបងហើយ។

ពេលនេះប្អូនសូមក្ស័យជាមួយ លំបាកទុក្ខព្រួយជាមួយគ្នា
សូមផ្សងសច្ចាជាតិនានា ប្អូនសូមជួបគ្នាគ្រាអវសាន ។
នាងអត់ដង្ហើមក្ស័យជន្មា ឱ្យបានជួបគ្នាជានិរន្តន៍
ជួបអង្គសាស្តាព្រះភគវន្ត ឱ្យទាន់សាសនាព្រះពុទ្ធហោង ។

## បទុមកាច់ផ្កាថ្វាយ

| | | |
|---|---|---|
| បទុមក្រពុំរីក | មានចិត្តត្រេក | កាច់មកថ្វាយ |
| បទុមក្រពុំថ្វាយ | បង្អាច់កាយ | កបកេសរ |
| លុតលើកទាំងទសករ | ប្រណម្យដាក់ | លើសិរិសា |
| ខ្ញុំក្រាបក្រោមព្រះបាទ | អភិវាទ | វិវវន្ទា |
| ថ្វាត់ថ្វាយព្រះជិនស្រី | រតនត្រ័យ | ស្រីក្រឡា |
| រុងរឿងបល្ល័ង្កពេជ្រ | វិចិត្រស្រេច | ក្បាច់រចនា |
| ថ្វាត់ថ្វាយបង្គំវន្ទា | សូមបានសុខ | ឋាននិព្វានហោង ។ |

**បញ្ជាក់ ៖ បទុម** ជាពាក្យត្រឹមត្រូវ ។ **បុទុម** ជាពាក្យសូត្រតាមធ្លាប់ ។

# បទកាច់បាយស្រី (បាយសី)

កាច់បាយសីទាំងប្រាំជាន់ ប្រដាប់គ្រប់គ្រាន់សឹងគ្រប់គ្រឿង
ជាន់ក្រោមក្បាច់ជានិទានរឿង កាលព្រះចោមមឿងទ្រង់សាសនា។
សោយរាជ្យសម្បត្តិបុរីរម្យ សម្រាន្តសុខសមទើបទេយ្យា
ជាមួយនឹងសម្តេចព្រះពិម្ពា ជាចោមជាយាអគ្គមហេសី។
អស់ទាំងស្រីស្នំកំណាន់នៃ បម្រើសព្វថ្ងៃជាប្រក្រតី
ដេញដំប្រគំតូរ្យតន្ត្រី ព្រលែងចក្រីខត្តិយា។
លុះព្រះជន្មវស្សាក៏បានធួន ម្ភៃប្រាំបួនព្រះវស្សា
កើតខ្ពើមសម្បត្តិក្នុងលោកា ទើបស្តេចយាត្រាចេញសាងព្រឹទ្ធ។
ទ្រង់គង់អស្វៈបវរស្អាត មានឆន្នាមាត្រមកជាមិត្ត
តោងកន្ទុយសេះដ៏ជាប់ជិត សេះបោលដោយឫទ្ធិអាសូរយាន។
ព្រះចតុលោកបាលទាំងបួន សុទ្ធសឹងតែងខ្លួនហើយតែងប្រាណ
ហោះចុះស្នួយជើងអាសូរយាន មិនបានឱ្យព្រួយរាជមនោម័យ។
ព្រះអង្គទ្រង់សីលសាងឫទ្ធី ព្រះព្រហ្មមុនីស្តេចបានត្រៃ
អស់ទេពអប្សរសួគាល័យ សឹងអរឱ្យជ័យគ្រប់ឥន្ទ្រិយ។
ជាន់ក្រោមកាច់កាលក្រុងរាមា ឃរាំងមាគាព្រះភូមិ
កុំឱ្យព្រះអង្គស្តេចចរលី សាងអភនីហារក្រមក្រឹត្យ។
ព្រះពោធិវង្សមិនទ្រង់តាម នៃពាក្យរាមាចោរទុច្ចរិត
ក្រុងមារកើតថ្នាក់អាក់អន់ចិត្ត ថយគិតរិះរេរកឱកាស។
ជាន់បីកាច់កាលទៅដល់ស្ទឹង អនោត្តនទីប្រាកដច្បាស់

ព្រះអង្គចុះចាករាជគន្ធស្ស ទ្រង់ផ្លាស់គ្រឿងយសសម្រេចបាន ។
ទ្រង់កាត់កេសីនៃព្រះអង្គ ឧទ្ទិសបោះត្រង់អាកាសដ្ឋាន
កាលនោះទេវិន្ទភគវន្ត ហោះស្ទួយទៅកាន់ត្រៃត្រិង្សា ។
ក៏ជាព្រះស្តូបព្រះចេតិយ បញ្ចុះកេសីព្រះសាស្តា
មាននាមប្រែកណ្ណកៈហៅចូឡា មុនីរតនានៅសព្វថ្ងៃ ។
ព្រះពោធិវង្សទ្រង់ព្រះផ្នួស ជាភេទអ្នកបួសនៅសព្វថ្ងៃ
ប្រើឆន្នាមាត្រឱ្យវិលវៃ នាំគ្រឿងនៅសព្វបុរីស្ថាន ។

មែនពិតសាធុជនចិត្តល្អ គេមើលទៅឃើញមានការដូច ផ្លែដូង ឯអ្នកដទៃទៀត គេមើលឃើញដូចផ្លែពុទ្រាមាន សំបកក្រៅរលោងស្រិលគួរជាទីពេញចិត្ត ។

ទស្សនៈ ភិក្ខុ ប៉ាង ខាត់ វីរិយបណ្ឌិតោ

# សម្រាប់ស្មូត្រគោរពធនង់សាសនា

សូមថ្វាយបង្គំព្រះសម្ពុទ្ធ ប្រសើរបំផុតក្នុងលោកា
ជាគ្រូនៃមនុស្សនិងទេព្តា ទ្រង់ត្រាស់ទេសនាប្រដៅសត្វ ។
ចង្អុលឱ្យដើរផ្លូវកណ្តាល មាគ៌ាត្រកាលអាចកម្ចាត់
ទុក្ខភ័យចង្រៃឱ្យខ្ចាយបាត់ អាចកាត់សង្សារទុក្ខបាន ។
សាសនាព្រះអង្គនៅសព្វថ្ងៃ សត្វមាននិស្ស័យពីបូរាណ
ប្រឹងរៀនប្រឹងស្តាប់ចេះចាំបាន កាន់តាមលម្អានបានក្តីសុខ ។
ឥតមានសុខណាស្មើក្តីស្ងប់ បញ្ចប់ត្រឹមសុខឃ្លាតចាកទុក្ខ
តាំងពីលោកនេះតទៅមុខ ក្តីសុខនឹងមានព្រោះធម៌ស្ងប់ ។
ខ្ញុំសូមបង្គំឆ្ពោះព្រះធម៌ ព្រះសង្ឃបវរទាំងគ្រប់សព្វ
រួមជាត្រៃរតន៍គួរគោរព ជាម្លប់ត្រជាក់នៃលោកា ។
ព្រះរូបព្រះធាតុនៃព្រះពុទ្ធ វិសុទ្ធទាំងអង្គព្រះសាស្តា
សូមគុណត្រៃរតន៍ជួយខេមរា ឱ្យបានសុខាតរៀងទៅ ។

## រស្មីប្រាំមួយពណ៌

ជាតិយើងអ្នកកាន់សាសនា ត្រូវដឹងច្បាស់ថាព្រះពុទ្ធជិនស្រី
ទ្រង់មានឆព្វណ្ណរង្សី គឺព្រះរស្មីទាំងប្រាំមួយពណ៌ ។
ផ្សាយចេញពីព្រះកាយទ្រង់ រុងរឿងរីទ្ធិវង្គប្រសើរបវរ
ឆ្វៀលឆ្វាត់កាយឆើតឆាយល្អ ទាំងប្រាំមួយពណ៌ស្រស់ល្អសោភា ។
កំណើតនៃព្រះរស្មី កើតដោយបារមីនៃព្រះភគវា
ធ្វើទានឥតមានរួញរា កាលដែលនៅជាព្រះពោធិសត្វ ។

រស្មីពណ៌ខៀវនោះណា កាលឆ្កៀលនេត្រាទ្រង់ដោយចិត្តកាត់
ឱ្យទានដល់ឥន្ទព្រាហ្មណ៍បាត់ កាលនៅជាក្សត្រនាមស្រីភិរាស្ត្រ ។
រស្មីពណ៌លឿងភ្លឺថ្លា កាលដែលទ្រង់អារសាច់ផៃធ្វើមាស
បិទពុទ្ធរូបភ្លឺឱភាស ព្រះឥន្ទជាងមាសទ្រង់វៃបណ្ឌិត ។
រស្មីក្រហមនោះណា កាលដែលមាតាពស់ខាំស្លាប់ពិត
បទុមសុំប្តូរជីវិត អារបេះដូងបិទធ្វើថ្នាំមាតា ។
រស្មីពណ៌សសុទ្ធសាធ កាលជាព្រះបាទវេស្សន្តរក្សត្រា
ឱ្យដំរីសល្អសោភា ដល់ព្រាហ្មណ៍ប្រាថ្នាយកពោធិញ្ញាណ ។
រស្មីពណ៌ដូចជើងហង្ស កាលមាតាទ្រង់យក្សចាប់យកបាន
ពិទ្យាធរអារសាច់ប្រាណ ឱ្យយក្សសាមាន្យស៊ីប្តូរជីវិត ។
រស្មីពណ៌ផ្លេកពណ្ណរាយ កាលជាទន្សាយឈ្មោះសោមបណ្ឌិត
ឱ្យទានសាច់ឈាមជីវិត ដល់ឥន្ទព្រាហ្មណ៍ពិតថាអត់អាហារ ។
រស្មីខៀវលឿងក្រហម ស-ហង្សបាទព្រមទាំងភ្លឺផ្លេកអស្ចារ្យ
ត្រូវជាប្រាំមួយប្រការ ក្មេងចាស់កុមារចូរចាំទុកអើយ ។

## កូនសូមអារាធនា

កូនសូមឱនកាយថ្វាយវន្ទីយ៍ លើកហត្ថទាំងពីរបន្ទន់ប្រាណ
បង្គំបាទាព្រះក្សេមក្សាន្ត ទោសខុសប៉ុន្មានសូមប្រណី ។
ម្ចាស់អើយកូនសូមអារាធនា ទាំងពីរអង្គាសូមថ្នមបី
សូមព្រះមេមានគុណលោកអភ័យ ដល់កូនប្រុសស្រីគ្រប់ៗប្រាណ ។
ពេលនេះកូនសូមដង្ហែព្រះ ហែចេញពីផ្ទះកាន់បុស្បុក
កម្រាលពិសេសកូនក្រាលទុក ជូនលោកឪពុក និងអ្នកម្តាយ ។

## ងូតទឹកជូនមាតាបិតា

សុគន្ធវារីមានក្លិនក្រអូប ដៃកូនលើកមកសូមជម្រះ
បំបាត់អសោចមន្ទិលព្រះ លើកហត្ថសំពះសុំខមាទោស ។
រីឯបាបកម្មដែលកូនមាន បានធ្វើបំពានមានប្រាកដ
ដោយបុញ្ញកម្មនេះតាមបទ កូនសូមសន្ទតស្មាលាបាប ។
សុភន្តោទេវសង្ឃាយោ ទេវតាចុះមកជុំត្រៀបត្រា
ប្រកាសអញ្ជើញអស់ទេវតា មានព្រះឥន្ទ្រាជាប្រធាន ។
សូមលោកប្រទាននូវពរជ័យ មង្គលសួស្តីគ្រប់ប្រការ
កើតមានប្រាកដគ្រប់វេលា ទាំងពីរអង្គាជាបុព្វការី ។

## ផ្លាស់សម្លៀកបំពាក់

មានទាំងកន្សែងថ្មីបារីស្លាម្លូ ដៃកូនទាំងគូលើកជូនដាក់
សូមលោកទទួលដោយស្មោះស្ម័គ្រ ខ្ញុំសូមបញ្ជាក់បុណ្យខែភ្លឺ ។
បុណ្យនេះឃើញជាក់ឥតសង្ស័យ កូនប្រុសកូនស្រីជុំត្រៀបត្រា
សំពះគោរពគ្រប់៧គ្នា មាតាបិតាទទួលពិត ។
រួចហើយកូនប្រុសនិងកូនស្រី សូមលើករបស់ថ្មីផ្លាស់ជូនលោក
សំពត់ខោអាវកូនលើកមក តាក់តែងជូនលោកអ្នកមានគុណ ។

## ហែចូលរោងបុណ្យ

ប្រោះព្រំរួចស្រេចកូនសូមហែ នូវអង្គព្រះមេទាំងពីរប្រាណ
លើកម្រាលថ្មីយ៉ាងសមសាន្ត ចូលរោងបុណ្យនេះកូនតបគុណ ។
កូនប្រុសលើកក្លស់បាំងថ្វាយព្រះ កូនស្រីសំពះហែអមជិត
ជូនដំណើរលោកមានគុណពិត ចិត្តកូនរិះគិតរំភើបក្រៃ ។[៥៤]

## សុវណ្ណសាម

ឱះឱ!អ្នកណាអើយមកបាញ់ខ្ញុំ
ខ្ញុំដើរតម្រង់ទៅដងទឹក
ដៃកណ្ដៀតក្អមជាមួយម្រឹគ
លាន់ស្នូរគគ្រឹកតាមមាគ៌ា។
រឿងហេតុពីអ្វីមកបាញ់ខ្ញុំ
លោកអើយធ្វើកម្មអ្វីម្ល៉េះណា
មកបាញ់ធ្លុះប្រាណអង្គអាត្មា
ឈាមដាបកាយាអស់ទៅហើយ។
បើស្លាប់ខ្ញុំហើយគ្មាននរណា
បម្រើមាតាបិតាខ្ញុំឡើយ
ស្លាប់ដល់បីនាក់ព្រះគុណអើយ
ពេលនេះឯងហើយត្រូវមរណា។
ឱះឱ! ព្រះមេមានគុណធ្ងន់
កូនបានក្ដីទុក្ខយ៉ាងនេះហើយ
មកជួយកូនផងព្រះមេអើយ
កូនស្លាប់ឥឡូវហើយណាព្រះមេ។
ធ្វើម្ដេចបានឃើញនូវមុខម៉ែ
កូនលាអ្នកម៉ែថ្ងៃនេះហើយ
កូនច្បាស់ជាស្លាប់ណាម្ចាស់អើយ
ថ្ងៃនេះឯងហើយណាព្រះមេ។
ខ្ញុំសូមឧទ្ទិសដល់ទេវតា
សូមប្រាប់មាតាបិតាខ្ញុំផង
អ្នកណាបាញ់ខ្ញុំឈឺកន្លង
សូមទេវតាផងប្រាប់ជាដំណឹង។

ភាពជាបុគ្គលមានចិត្តបរិសុទ្ធ ភាពជាបុគ្គលមានចិត្តចង់ឱ្យទាន ភាពជាបុគ្គលមានចិត្តអង់អាច ភាពជាបុគ្គលមានចិត្តស្មើគ្រាមាន សុខទុក្ខ ភាពជាបុគ្គលមានចិត្តមេត្តា ករុណា ភាពជាបុគ្គលមានចិត្ត ស្រឡាញ់រាប់អាន ភាពជាបុគ្គលមានចិត្តទៀងត្រង់ ទាំងអស់នេះ ជាគុណសម្បត្តិនៃមិត្ត។

ទស្សនៈ ភិក្ខុ ប៉ាង ខាត់ វីរិយបណ្ឌិតោ

៥៤-ប្រជុំធម្មសង្វេគ ទំព័រ៦០-៦១-៧៤-៧៦-១០៦-១០៧-១០៩-១២៩ ចម្លងឡើងវិញដោយ ភិក្ខុ ពេជ្រ សំណាង គ.ស.២០០៨។

# ប្រេតយំភ្ជុំបិណ្ឌ

បពិត្រអស់លោកសប្បុរស ក្មេងចាស់ទាំងអស់ទាំងស្រីប្រុស
ខែភ្ជុំបិណ្ឌ ដាក់បិណ្ឌក្នុងឆ្នាំថ្មី គួរតែលកលៃទៅវត្តវ៉ា ។
កុំនៅសម្ងំតែក្នុងផ្ទះ ឬដើរលេងផ្ដេសផ្ដាសហ៊ឺហា
បុណ្យទានមិនឆ្ងាញ់ៗតែស្រា ដេរគេឡូឡាពាសពេញផ្លូវ ។
ណាស់ហើយឈប់ខានប៉ុណ្ណឹងហើយ កុំនៅកន្ដើយខិតខឹរិះរេ
តោះទៅបុណ្យរាប់បាត្រជាមួយគេ កុំនៅទំនេរឥតបានការ ។
ម៉ែឪនៅរស់ប្រឹងព្រោះកូន ដល់សូន្យជីវិតផុតសង្ខារ
មិនដឹងជាកើតនៅទីណា ជាមនុស្សទេវតា ឬជាប្រេត ។
បើកើតជាមនុស្សឬទេព្ដា ប្រសើរថ្លៃថ្លាព្រោះស្គាល់ហេតុ
ខ្លាចណាស់តែភ្លាត់ធ្លាក់ជាប្រេត បាក់ពោះក្រហេតអត់អាហារ
ស៊ីតែខ្ទុះឈាមនិងលាមក រូបកាយអាក្រក់គួរអនិច្ចា
វេទនាខ្លាំងណាស់ក្នុងសង្ខារ មិនដឹងថ្ងៃណានឹងស្រាកស្រាន្ត ។
នេះហើយព្រោះកម្មចិញ្ចឹមកូន អកុសលនាំខ្លួនឱ្យរំខាន
សោយទុក្ខពុំសុខក្នុងសន្ដាន អស់លោកគ្រប់ប្រាណខឹរិះរេ ។
ឥឡូវភទ្របទខែបិណ្ឌភ្ជុំ ប្រេតទួញស្រែកយំព្រោះនឹកកូន
យមបាលដោះលែងឱ្យរួចខ្លួន ទៅរកតាដូនកូនប្រពន្ធ ។
អនិច្ចាអើយវ៉ាអាសូរពេក ប្រេតហូរទឹកភ្នែករងទុក្ខធ្ងន់
ទៅរកគ្រប់វត្តខំគយគន់ មិនឃើញប្រពន្ធកូនខ្លួនឡើយ ។

ឃើញតែញាតិគេអ្នកដទៃ បានខំលក់លៃម្ហូបអាហារ
បាយទឹកនំចំណីទុកជូនដូនតា បរិភោគកាលណាគេបានឆ្អែតគ្រប់គ្នា ។
ឈប់ស្លេះត្រឹមនេះមិននិយាយ ស្ដីពីពួកប្រេត ដែលកំព្រា
យំសោកបោកខ្លួនក្បែរវិហារ រងទុក្ខវេទនាជាអនេក ។
យកដៃគក់ទ្រូងទួញយំថា ឱអនិច្ចាអើយខ្លួនខ្ញុំពេក
កាលនៅជាមនុស្សខំទូលរែក យប់ថ្ងៃឥតដេកព្រោះតែកូន ។
ឥឡូវធ្លាក់ខ្លួនទៅជាប្រេត គេបានស៊ីឆ្អែតឥតនឹកនា
ឱខ្លួនខ្ញុំអើយសែនវេទនា កំព្រាខ្លោចផ្សាឈឺចុកចាប់ ។
ហេតុនេះគួរគិតសង្វេគ អាសូរប្រេតពេកដេកផ្ងាផ្ងាប់
ស្រេកឃ្លានខ្លាំងណាស់ស្ទើរនឹងស្លាប់ រៀបរាប់សារសព្ទស្រែកទួញថា ។
ឱកូនសម្លាញ់មាសឪពុក កូនឪសោយទុក្ខព្រោះកូនបា
ឥឡូវបាត់កូននៅទីណា មិនឃើញយាត្រាមកនឹងគេ ។
អ្នកដឹងឬទេថារូបឪពុក សោយទុក្ខពុំសុខព្រោះរូបកូន
បំបាត់ជីវិតសត្វឱ្យស្លាប់សូន្យ ឱ្យតែរូបកូនបានសុខសាន្ត ។
ឥឡូវកម្មតាមមកផ្ដល់ ផ្ដល់ឱ្យឪពុកពុំដែលក្សាន្ត
សោយទុក្ខពុំសុខក្នុងសន្ដាន គ្មានថ្ងៃស្រាកស្រាន្តម្ដងណា ។
កូនកើតជាមនុស្សស្គាល់ខុសត្រូវ កូនពៅគួរគិតដល់បិតា
ស្រេកឃ្លានខ្លាំងណាស់ព្រោះអត់អាហារ មិនដឹងថ្ងៃណានឹងបានហូបឡើយ ។
ឥឡូវជិតដល់គម្រប់ថ្ងៃយមបាល មកហៅឪពុកទៅហើយ

ឱកូនសម្លាញ់មាសឪពុកអើយ កូនអើយតើកូននៅទីណា ។
បើមុននឹងឪទៅសូមជួបកូន បានហូបមួយម៉ាត់រសអាហារ
ស៊ូស្លាប់ទៅចុះប្រុសជីវ៉ា ឪពុកឥតថាទេកូនអើយ ។
ឥឡូវដើររកគ្រប់តែវត្ត មិនឃើញមកសោះកូនពិសី
ឪអស់សង្ឃឹមនឹងបាននំចំណី ឱកូនប្រុសស្រី ឪពុកលាហើយ ។
តាំងពីព្រលឹមទល់ព្រលប់ហើយ ទ្រូងប្រេតថៃថប់ឥតល្ហែល្ហើយ
ម្ល៉េះសម្លាញ់អើយខានឃើញមុខកូននៅសុខចុះឪពុកលាហើយ ។
រឿងនេះឈប់ស្លេះប៉ុណ្ណេះចុះ អស់លោកស្រីប្រុសពិចារណា
ឃើញទេរឿងហ្នឹងព្រោះនរណា គឺព្រោះតែបុត្រីនិងបុត្រា ។
កម្មនេះនាំឱ្យឪពុកកើតជាប្រេត ដើមហេតុព្រោះតែនំចំណី
រកស៊ីចិញ្ចឹមកូនទាំងប្រុសស្រី ដល់ពេលក្សិណក្ស័យរងទុក្ខធ្ងន់ ។
បើសិនជាយើងកូនកតញ្ញូ ត្រូវតែគិតគូរពីរឿងគុណ
កុំយកតៀមស្រាធ្វើស្រែបុណ្យ ប្រយ័ត្នវាធ្ងន់ជាងខ្មោចឪ ។
ខែភ្ជុំដាក់បិណ្ឌមករាប់បាត្រ រៀបចំឱ្យស្អាតម្ហូបចំណី
បង្សុកូលឧទ្ទិសដល់តាយាយ ញាតិមិត្តប្រុសស្រីដែលចែកឋាន
ឱ្យគាត់បានហូបនូវចំណី ដែលធ្វើផ្ទាល់ដៃយ៉ាងចំណាន
ហូបហើយកាលណាឱ្យពរបាន សួស្តីសុខសាន្តដល់កូនចៅ ។
រឿងនេះបើសិនជាអស់លោកណា ដែលមានបញ្ញាបានបំពេញ
ផលនោះនឹងជូនដល់យើងវិញ សុខពាសពេញទៅមុខដល់និព្វានហោង ។
ឈប់ស្លេះសង្ខេបដោយវាចា ខ្ញុំពេជ្រសុខាសូមលើកដៃ
អភ័យអត់ទោសញាតិទាំងប្រុសស្រី សូមបញ្ចប់ខ្លីត្រឹមតែប៉ណ្ណេះ ។

**និពន្ធដោយ ពេជ្រ សុខា**

# ជីវិតឧត្តម

ជីវិតឧត្តមព្រោះតែមានសីល លះបង់មន្ទិលសព្វគ្រប់ប្រការ
ជីវិតឧត្តមព្រោះផុតស្នេហា លះបង់តណ្ហាឥតស្តាយក្រោយឡើយ ។
ជីវិតឧត្តមព្រោះមានសទ្ធា លះបង់វេរាឥតបីកន្តើយ
ជីវិតឧត្តមព្រោះស្គាល់កោះត្រើយ លះបង់អស់ហើយទាំងការជឿខុស ។
ជីវិតឧត្តមព្រោះមានចាគៈ លះបង់ឥតទាក់ឥតស្តាយស្រណោះ
ជីវិតឧត្តមព្រោះមិនទាស់ លះបង់យ៉ាងខ្ជោះអស់ពីសន្តាន ។
ជីវិតឧត្តមព្រោះការចេះស្តាប់ លះបង់ចិត្តស្លាប់អប្រិយសាមាន្យ
ជីវិតឧត្តមព្រោះស្តាប់ចំណាន លះបង់តិរច្ឆានគឺការស្តាប់ខុស ។
ជីវិតឧត្តមព្រោះមានបញ្ញា លះបង់វិជ្ជាដែលមិនសង្គ្រោះ
ជីវិតឧត្តមព្រោះបញ្ញានោះ លះបង់ដោយស្មោះនោះគឺវិមុត្តិ ។
ជីវិតឧត្តមព្រោះតែមានញាណ លះបង់ហោះធ្យានដោយចិត្តឥតស្លុត
ជីវិតឧត្តមព្រោះលែងស្រយុត លះបង់មោះមុតផុតចាកសង្សារ ។
ជីវិតឧត្តមព្រោះរួចចាគៈ លះបង់ហើយខ្ជាក់គ្មានទេប្រាថ្នា
ជីវិតឧត្តមព្រោះឥតស្នេហា លះបង់រាគានាភពលោកិយ ។
ជីវិតឧត្តមព្រោះគ្មានទោសា លះបង់ក្រោធាឥតបីរឹងរៃ
ជីវិតឧត្តមព្រោះឥតខឹងអ្វី លះបង់មិនខ្វីលែងខឹងទៀតហើយ ។
ជីវិតឧត្តមព្រោះឥតមោហា លះបង់ទាំងការវង្វេងទាំងឡាយ
ជីវិតឧត្តមព្រោះលែងងងឹតហើយ លះបង់រកត្រើយលុះចូលនិព្វាន ។

ជីវិតឧត្តមព្រោះគ្មានឥស្សា លះបង់ហិង្សារាប់រយសែនលាន
ជីវិតឧត្តមព្រោះតែចិត្តមាន លះបង់វិមានដែលមានជរា ។
ជីវិតឧត្តមព្រោះឥតព្យាបាទ លះបង់សង្ឃាតឈប់បៀតបៀនគ្នា
ជីវិតឧត្តមព្រោះសុខសោភា លះបង់គ្រប់គ្រាលុះគ្រាអវសាន ។

**ដោយ សាមណេរ ស៊ិន អក្ខរា**

## សីលអំប៊ីស៊ីអំបិល

សីលអំប៊ី ស៊ីអំបិល រងមន្ទិលគ្រប់វេលា
កើតជាប្រេតមានវេរា ជួបវេទនាគ្រប់កំណើត ។
សីលអំប៊ី ស៊ីអំបិល ម្តេចក៏ខ្ជិលធ្វើមិនកើត
ជឿជនពាលធ្លាក់លែងអើត យប់ឥតខ្មើតងងឹតណាស់ ។
សីលអំប៊ី ស៊ីអំបិល ចិត្តនោះខិលសែនផ្តេសផ្តាស
សម្លាប់សត្វសាងកម្មក្រាស់ មិនគិតខ្មាសជននានា ។
សីលអំប៊ី ស៊ីអំបិល រោគរបិលលួចទ្រព្យា
លួចម៉ែឪក្បត់គ្នីគ្នា នាំខ្លួនជាប្រេតទាំងស្រស់ ។
សីលអំប៊ី ស៊ីអំបិល ចិត្តកកិលរកទោមនស្ស
ក្បត់ប្រពន្ធឥតស្រណោះ យកអ្នកនោះមកសប្បាយ ។
សីលអំប៊ី ស៊ីអំបិល មាត់រអិលភរនាយអាយ

ភរផៅញាតិមិនគិតស្ដាយ សើចក្អាកក្អាយទាំងងងឹត ។
សីលអំបី ស៊ីអំបិល សាងមួយផ្ដិលឱ្យស្រាយចិត្ត
ទឹកស្រវឹងដាក់នៅជិត បើចិត្តគិតថែមមួយទៀត ។
តែកុំភ្លេចសីលអំបី នាំប្រុសស្រីឱ្យឃ្លៀងឃ្លាត
ទៅសួគ៌ាដោយខ្មីឃ្មាត រួចចាកប្រេតនាជាតិថ្មី ។
ពាក្យអំបិលគួរគិតណា ពិចារណាហើយកែច្នៃ
ទាំងដាំស្លគ្រូវការក្រៃ សូមលកលៃឱ្យបានឆាប់ ។
ប្រឡាក់ត្រីនៅច្រើនទៀត មានរសជាតិយ៉ាងគួរគាប់
យ៉ាងណាសីលមានឈ្មោះជាប់ មិនអភព្វគ្រប់វិស័យ ។
ទាំងក្មេងចាស់គ្រប់អង្គា កុំរួញរាត្រូវលាតដៃ
បញ្ជូចិត្តឱ្យថ្លាថ្លៃ សីលបារមីបាននិព្វានហោង ។

## សភាវមរណៈ

ទាំងចាស់ទាំងក្មេងត្រូវមានក្ដីស្លាប់ រស់យ៉ាងចុកចាប់គ្រប់ៗតែគ្នា
កើតចាស់ឈឺស្លាប់ឥតបីរួញរា នេះហើយគឺជាមតិកជីវិត ។
មនុស្សគ្រប់រូបតែងមានរឿងភ័យ រឿងសោកព្រោះក្ស័យរឿងឥតប្រឌិត
មានក្ដីវិយោគប្រលោមជុំជិត មាយាឧក្រិដ្ឋបញ្ឆោតមហាជន ។
មានរូបមានទុក្ខមិនទៀងសោះឡើយ រស់តាំងនៅហើយឱ្យមនុស្សទោរទន់
ជាប់នឹងរូបនោះដោយភាពមាំមួន ប្រកាន់ផ្គួនៗថារបស់អាត្មា ។
មិនយូរប៉ុន្មានរូបនេះត្រូវប្រែ ឥតអ្វីមកកែឱ្យមានខ្លឹមសារ

មិនអាចទៅរួចទាំងគ្មាននរណា ក្នុងវដ្តសង្សារត្រូវតែយ៉ាងហ្នឹង ។
វេទនាសញ្ញាសង្ខារវិញ្ញាណ គ្រប់ជាតិកោដិលានឥតបីរំពឹង
ថ្ងៃនេះតាំងនៅស្អែកនោះមិនដឹង វិនាសសូន្យឈឹងចោលអស់ប្រជា ។
សភាមរណៈមានសម្រាប់លោក រឿងការសោយសោកមករកគ្រប់គ្នា
ឥតអាចគេចរួចពីសំណាញ់មារ គឺចាស់គ្រាំគ្រានោះឯងឡើយណា ។
សភាមរណៈគ្មានអ្នកគ្រប់គ្រង មច្ចុយឺតយោងដាក់ទីប៉ាឆា
ដុតសល់តែឆ្អឹងគួរពិចារណា ដោយបញ្ញាថាលោកាគ្មានខ្លឹម ។
ការប្រជុំនេះសម្រាប់លោកិយ ឱ! អស់ប្រុសស្រីសូមកុំសង្ឃឹម
គ្មានអ្នកណាជួយសាងក្តីញញឹម ទាំងការសង្ឃឹមគឺគ្មានសំខាន់ ។
បើគ្រប់គ្នាដឹងគួរកុំប្រមាទ នាំគ្នាសង្វាតដោយការរួសរាន់
សាងទានសាងសីលឱ្យបានគ្រប់គ្រាន់ រកផ្លូវបន្ទាន់ដើរទៅយ៉ាងឆាប់ ។
បើមិនប្រញាប់ប្រយ័ត្នស្តាយក្រោយ បើមិនបណ្តោយរួចផុតបាបឆាប់
បានបុណ្យជាមិត្តរួចការយ៉ាកយ៉ាប់ រួចផុតពីច្បាប់នៃត្រៃលោកហើយ ។
សូមអស់បរិស័ទគិតឱ្យបានច្បាស់ ទាំងក្មេងទាំងចាស់ក្រឡាស់រកត្រើយ
ឆ្ពោះទៅនិព្វានបានការធូរស្បើយ ជីវិតលែងនឿយព្រោះចប់អស់កិច្ច ។

ដោយសាមណេរ ស៊ិន អក្ខរា

> មែនពិត មេត្រីចិត្តនៃបុគ្គលមានចិត្តបរិសុទ្ធ មានសភាពម៉្យាង ឯសំដីនៃបុគ្គលមានចិត្តអាក្រក់ខិលខូចមានសភាពម៉្យាងទៀត ។
>
> ទស្សនៈ ភិក្ខុ ប៉ាង ខាត់ វីរិយបណ្ឌិតោ

# ខ្លឹមសារកម្មវិធីពន្លឺនៃព្រះធម៌

អហ៊ើរខ្ញុំផ្គង់អញ្ជលី លើកហត្ថទាំងពីរនមស្ការ
នៃព្រះសម្ពុទ្ធជាសាស្តា ត្រួមនុស្សទេព្តាគ្រប់៣គ្នា ។
ព្រះអង្គបានត្រាស់ដឹងក្នុងលោក ប្រសើរជ័យជោគលើពសុធា
ប្រោសដល់មនុស្សសត្វមិនរួញរា ទោះក្តៅរងាយ៉ាងណាក្តី ។
សូមថ្វាយបង្គំឆ្ពោះព្រះធម៌ ធម្មាពិតល្អប្រោសប្រណី
៨៤000ធម្មក្ខន្ធនៃ របស់ជិនស្រីគ្រាន់បំភ្លឺ ។
សូមថ្វាយបង្គំឆ្ពោះព្រះសង្ឃ គ្រងចីវរស្បង់ទង់ជ័យភ្លឺ
គ្រប់មនុស្សប្រុសស្រីតែងដឹងឮ សែនល្បីរន្ទឺខ្ពស់ត្រដែត ។
ពេលនេះបានដល់កម្មវិធី នៅក្នុងស្ថានីយបុស្តិ៍ប៉ោយប៉ែត
វិទ្យុ៩៨.៣ច្បាស់ក្រឡែត អណ្តែតត្រសែតពន្លឺនៃព្រះធម៌ ។
ព្រះសង្ឃសម្តែងរៀងរាល់ថ្ងៃ ព្រះអង្គកែខៃច្រើនកុះករ
បែងចែកវេនទេសនាបន្ត ហើយថ្ងៃនេះក៏ត្រូវវត្តថ្មី ។
នាថ្ងៃព្រហស្បតិ៍រាល់សប្តាហ៍ ប្រធានបទទេសនា "កំណាព្យខ្លី"
រួមបទពិចារណាសព្វសេចក្តី ដែលមានអត្ថន័យអំពីបុណ្យ ។
កម្មវិធីនេះអាចដំណើរការ ប្រកបបញ្ញាវិសេសលន់
ផ្តើមដោយព្រះគ្រូអនុគណ ព្រះទ័យទោរទន់គ្រប់វេលា ។
យល់ថាកម្មវិធីមានប្រយោជន៍ ដូចទឹកស្រពស្រោចគ្រប់ជនា
ក្រោយពីបានស្តាប់នូវធម្មា កាត់ផ្តាច់អវិជ្ជាមានរស្មី ។
គ្រាន់ជាពន្លឺគ្រប់កន្លែង ប្រាជ្ញាថ្លាឈ្វេងប្រៀបពេជ្រថ្មី

ពន្លឺព្រះធម៌ល្អស៊ីមស្អែ អ្នកមាននិស្ស័យគង់ចូលចិត្ត ។
ទោះជនអ្នកស្តាប់ទីជិតឆ្ងាយ ចង់ឃ្លាតអបាយគួរនៃបនិត្យ
ផ្ទៀងសោតាស្តាប់ឱ្យបានជិត នោះប្រាកដពិតពីរោះជាក់ ។
ដ្បិតយើងជាតិនេះកើតជាមនុស្ស មានបុណ្យខ្ពង់ខ្ពស់ពីអតីតៈ
បច្ចុប្បន្នឱ្យផលផុតអបលក្ខណ៍ មិនទាញខ្លួនធ្លាក់ក្នុងអវិចី ។
ចុងក្រោយជីវិតជនគ្រប់គ្នា គ្រប់៧អង្គាទោះក្មេងខ្ចី
ទោះស្តេចអ្នកមានឬមន្ត្រី សេដ្ឋី គហបតីមានទ្រព្យធន ។
មិនអាចយកទៅបានតាមខ្លួន មានបងមានប្អូនកូនប្រពន្ធ
ដូច្នេះអ្នកអើយខំសាងបុណ្យ ទានសីលជាទុនសមបំណង ។
ដោយមានពន្លឺព្រះធម៌នេះ ទុកជាជំនិះជិះចម្លង
ឱ្យបានរួចចាកបាបកម្មផង ទាំងទុក្ខសៅហ្មងក្នុងអង្គប្រាណ ។
ទោះពេលបច្ចុប្បន្នអនាគត ខន្ធ៥រលត់ចាកចោលឋាន
សោយសម្បត្តិទិព្វបរិបូរបាន ដល់អមតស្ថានគឺនិព្វានហោង ។

**និពន្ធដោយ ភិក្ខុៈ ពេជ្រ សំណាង**

## បុណ្យមិនភ្លេចអ្នកតែអ្នកអាចភ្លេចបុណ្យ

ទ្រព្យបុណ្យយសស័ក្តិ មុខមាត់ឋានៈ និងម្ហូបអាហារ
យានយន្តទំនើប ដីស្រែចម្ការ លុយចាយហ៊ឺហា
មិនដែលមានខ្វះ ។
ជីវិតបានខ្ពស់ ប្រសើរដោយយស ពីក្មេងដល់ចាស់
មានតែជោគជ័យ គ្រប់វ័យល្អល្អះ បានសុខខ្លាំងណាស់

បុណ្យចាស់ឱ្យផល ។

គ្រប់រូបប្រុសស្រី កើតក្នុងលោកិយ ចូរគិតឱ្យដល់
តាំងចិត្តសាងល្អ សន្សំកុសល ទុកដូចជាថ្នល់
ក្នុងវដ្តសង្សារ ។

ម្យ៉ាងកុសលកម្ម ប្រុសស្រីត្រូវចាំ កុំភ្លេចឡើយណា
បានរស់ជួបជុំ ឥតមានប្រេះឆា បុណ្យពិតអស្ចារ្យ
ដោយសារអ្នកសាង ។

អាយុវែងពិត ព្រោះកម្មវិចិត្រ រស់នៅកុំអាង
លើទ្រព្យញាតិមិត្ត រស់នៅជិតខាង ហើយអួតក្អេងក្អាង
ថាខ្លួនមិនស្លាប់ ។

រស់ត្រូវសាងបុណ្យ បន្តធ្វើគុណ ហើយគោរពច្បាប់
ទោះជាក្រីក្រ លំបាកយ៉ាកយ៉ាប់ កុំឱ្យតែស្លាប់
ប្រាជ្ញាស្មារតី ។

បើគំនិតល្ងង់ ពិតជាត្រូវលង់ នរកលោកិយ
មិនមានក្តីសុខ ជួបតែព្រួយភ័យ មិនស្គាល់សិរី
ព្រោះមិនសាងទុក ។

បើរស់សប្បាយ រិះគិតខ្វល់ខ្វាយ ធ្វើបុណ្យទៅមុខ
បើសាងទុច្ចរិត រស់ដូចជាប់គុក រស់នៅជាទុក្ខ
វិលវល់ដូចផ្សែង ។

អស់លោកសប្បុរស ក្មេងចាស់ទាំងអស់ ចូរជួយខ្លួនឯង
រកទីពឹងពិត កុំឱ្យចំបែង ហើយខំប្រឹងប្រែង
ធ្វើបុណ្យចុះណា៎ ។

បើមិនដូច្នោះ បងប្អូនស្រីប្រុស ពិតជាសោកា
គឺនឹកស្ដាយក្រោយ ពេលជួបទុក្ខា ទុក្ខកើតដោយសារ
រស់ហើយភ្លេចបុណ្យ ។

## សំឡេងព្រះធម៌

សំឡេងបក្សីលម្អព្រឹក្សា សំឡេងទេសនាជួយដល់អ្នកស្ដាប់
ខិតខំពន្យល់បាលីសារសព្ទ ព្រះធម៌ជាច្បាប់គួរឱ្យសិក្សា ។
សំឡេងចម្រៀងអាចលង់អារម្មណ៍ ឯព្រះសទ្ធម្មនាំឱ្យជ្រះថ្លា
សំឡេងអ្នកម្ដាយពីរោះអស្ចារ្យ បំពេកាលណាកូនតែងត្រេកអរ ។
សំឡេងព្រះធម៌ព្រះពុទ្ធទេសនា មានហេតុអស្ចារ្យហៅសែនកម្រ
ពេលបានស្ដាប់ហើយគ្រប់សត្តនិករ តែងមានអំណររួចផុតទុក្ខា ។
ធម៌ព្រះសម្ពុទ្ធប្រសើរអនេក គួរមានចិត្តត្រេកស្ដាប់គិតពិចារណ៍
ធម៌ដូចយានធំឆ្លងផុតមរណា ដល់ទីថ្លៃថ្លានិព្វានប្រាកដ ។
ពាក្យថាព្រះធម៌មានតម្លៃណាស់ តូចធំក្មេងចាស់ស្ដាប់ឱ្យហ្មត់ចត់
ព្យាយាមរឿយៗត្រិះរិះអំណត់ ទោះកាយនឿយហត់កុំឆ្ងាយធម្មា ។
ធ្វើការស្រាលធ្ងន់ពិបាកកាយពិត កុំឱ្យតែចិត្តមានអវិជ្ជា
ទោះជីវិតអស់កាយត្រូវជរា ធ្វើចិត្តឱ្យជាអាស្រ័យធម៌ព្រះ ។

ដូច្នេះអស់លោកសប្បុរសប្រុសស្រី ចូរខំឃ្លាតខ្ចីអប់រំជម្រះ
លះកាត់ចិត្តបាបទិដ្ឋិមានះ ព្យាយាមយកឈ្នះកិលេសឱ្យបាន ។
ពេលនេះព្រះធម៌កំពុងរះហើយ ចូរកុំកន្តើយឆ្លៀតស្តាប់គ្រប់ប្រាណ
កុំឱ្យភាពល្ងង់ដឹកនាំសន្តាន អាចឱ្យវិលខានក្នុងវដ្តសង្សារ ។
សង្ខារទាំងឡាយកើតហើយវិនាស បើស្តាប់ធម៌ព្រះទើបមានប្រាជ្ញា
ប្រសិនជាខ្ជិលល្ងង់លុះមរណា បើសិនឧស្សាហ៍ជីវិតឧត្តម ។
ការស្តាប់ព្រះធម៌លំបាកមែនពិត លុះត្រារិះគិតប្រឹងប្រែងសន្សំ
ស្តាប់ហើយស្តាប់ទៀតកុំធ្វើបន្លំ តាំងខ្លួនឱ្យសមទទួលធម៌ថ្លៃ ។
សម័យឥឡូវមានធម៌គ្រប់ទី ចូរខំសំភីស្តាប់ឱ្យរាល់ថ្ងៃ
កុំខ្ជិលច្រអូសជាហេតុចង្រៃ គុណធម៌ក្សិណក្ស័យព្រោះខ្ជិលពាលា ។
ធម៌តាមវិទ្យុចូរខំស្តាប់ទៅ ឬអានសៀវភៅធម៌អាថ៌នានា
កុំពេលទំនេរនិយាយដើមគ្នា សិក្សាធម្មាទើបចិត្តបានសុខ ។
ពិតណាស់ប្រសិនចង់ឱ្យខ្លួនល្អ ចូរកុំត្រដររធ្វើបាបសព្វមុខ
បើសិនចង់ឱ្យខ្លួនផុតចាកទុក្ខ ចូរខំសម្រុកលះធម៌អបាយ ។
ប្រសិនជាចង់ជួបនូវសុខពិត ចូរខំរិះគិតស្តាប់ធម៌រាល់កាយ
ប្រសិនជាចង់ឱ្យខ្លួនសប្បាយ ចូរខំខ្វល់ខ្វាយសាងសុចរិតកម្ម ។
ដោយសារអាយុឥឡូវមានខ្លី ចូរប្រុងស្មារតីភាវនាប្រចាំ
ស្តាប់ធម៌ទេសនាព្រះពុទ្ធទ្រង់ផ្តាំ យើងត្រូវចងចាំធម៌មិនប្រមាទ ។
យប់ហើយនិងថ្ងៃពិតមិនយូរឡើយ ខ្ញុំសូមលាហើយដោយចិត្តល្អស្អាត
ពេលបានស្តាប់ហើយចូរខំសង្វាត ធ្វើបុណ្យដាក់បាត្រស្តាប់ធម៌ព្រះអើយ ។

៥៣-ប្រជុំធម្មសង្វេគ ទំព័រ៧-៨ ចម្លងឡើងវិញដោយ ភិក្ខុ ពេជ្រ សំណាង គ.ស.២០០៨។

# ស្រណោះវប្បធម៌ជាតិខ្ញុំខ្លាំងណាស់

សម័យឥឡូវជឿនលឿនខ្លាំងណាស់ ក្មេងធំជាងចាស់ប្អូនធំជាងបង
វាយទាត់កាប់ចាក់អ្នកណាចម្លង ច្រៀងរាំឆ្លើយឆ្លងគ្មានខ្មាសមេបា ។
បងតូចបងធំជួបគ្នាមិនបាន ចិត្តកាចសាមាន្យព្រោះជាតិសុរា
ពេលដែលស្រវឹងគ្មានខ្លាចនរណា ពេលដែលស្វាងស្រាថាមិនដឹងទេ ។
ទៅលេងជិតឆ្ងាយគេជិះម៉ូតូ ជិះហើយស្រែកហ៊ោមិនគិតខ្មាសគេ
ទៅលេងសួនហើយហួសទៅទន្លេ ជិះម៉ូតូជ្រេជិតធ្លាក់ខុសថ្នល់ ។
មើលទៅគេធ្វើឫកដូចសេដ្ឋី មិត្តភក្តិប្រុសស្រីគ្មានអ្នកណាដល់
ម្តាយខំរកលុយពួកនេះមិនខ្វល់ ចិត្តស្រាលជាងខ្យល់គំនិតពាលា ។
ឱ្យរកលុយបានឱ្យយកទៅរៀន ចិត្តខ្មៅដូចព្រានយកទៅលេងបៀ
បើមិនដូច្នោះស៊ីផឹកគ្នាវា គ្រួសារគ្រាំគ្រាព្រោះកូនអប្រិយ ។
សម្លៀកបំពាក់ស្ទើរឃើញស្ទើរបាត់ ដូចខ្វះក្រណាត់ម៉ូដទាន់សម័យ
ខើចមុខខើចក្រោយព្រោះគេកែច្នៃ ស្ទើងឃើញសរសៃព្រមទាំងសាច់ខ្ចី ។
ពីដើមគេស្លៀកបិទបាំងយ៉ាងជិត មិនបង្ហាញផ្ចិតព្រោះស្លៀកខើចខ្លី
ធ្វើអ្វីតែងគិតខ្លាចញាតិគេស្តី ខ្លួនឯងជាស្រីត្រូវស្តាប់មេបា ។
ក្មេងៗពីដើមធ្វើអ្វីស្តាប់ចាស់ ក្មេងឥឡូវផ្តាសគ្មានស្តាប់នរណា
ធ្វើតាមស្រេកឃ្លានឥតពិចារណា យល់ថាសង្ហាសប្បាយលេលា ។
ឱ្យតែមានបុណ្យជួបជុំគឹកកង ស្រីញីអូនបងដឹងធ្វើអីគ្នា
ដើរលេងដល់យប់ងប់ផឹកស្រាបៀរ គំនិតពាលាព្រោះខ្លួនមិនយល់ ។

ប្រសិនជារៀនគេចពីសាលា កុហកម៉ែថាគ្រូជាប់រវល់
ទៅលេងសួនស្នេហ៍ញ៉ាំនំគោជល់ កុំគិតអំពល់រៀនមិនអីទេ ។
ម្យ៉ាងទៀតមានការបុណ្យទានម្តងៗ បងប្អូនមឹងបងឃើញទៅមុនគេ
ដើរគ្មានចូលផ្ទះគ្មានគិតរិះរេ ឪពុកម្តាយជេរខឹងគាត់ខ្លាំងណាស់ ។
នេះហើយគេហៅសម័យលោតផ្លោះ បងប្អូនទាំងអស់ស្តាប់ឱ្យបានច្បាស់
វប្បធម៌បរទេសចូលមកច្រើនណាស់ ប្រសិនប្រែផ្លាស់ចូរគិតខ្មែរផង ។
ពេលខ្លះនិយាយសុទ្ធតែអង់គ្លេស រៀនខ្មែរមិនចេះនិយាយខុសឆ្គង
និយាយឯជើងន័យទៅឯត្បូង មិនត្រូវគន្លងពាក្យខ្មែរសោះឡើយ ។
សម័យទំនើបដូចជឿនលឿនណាស់ អ្វីៗប្រែផ្លាស់ខុសពីមុនហើយ
ទាំងការពោលស្តីសរសេរតោះតើយ មិនបានគិតឡើយឱ្យតែអានបាន ។
តាមពិតអក្សរលេខនព្វន្តខ្មែរ មិនចេះតែកែពិតមានមូលដ្ឋាន
ប្រសិនមិនច្បាស់កុំធ្វើស្មានៗ អស់ញាតិសន្តានស្រណោះខេមរា ។

## សិរីសួស្តីស្ថិតនៅឯណា?

បឋមវន្ទាសូមនមស្ការ គុណត្រ័យរតនាប្រសើរបី
ព្រះពុទ្ធព្រះធម៌ព្រះសង្ឃប្រពៃ ដែលមានគុណថ្លៃត្រារាប់ពុំបាន ។
បង្គំឆ្ពោះត្រង់អង្គព្រះសម្ពុទ្ធ ប្រាជ្ញាមោះមុតដឹងសព្វទីស្ថាន
ត្រាស់ដឹងក្នុងលោកពិតសុខក្សេមក្សាន្ត អាស្រ័យព្រះញាណទើបរួចវិបត្តិ ។
ព្រះធម៌ឧត្តមយានល្អកន្លង ដឹកនាំសត្វឆ្លងហើយអាចកម្ចាត់
មន្ទិលសង្ស័យបរមត្ថបញ្ញត្តិ ឱ្យពួកមនុស្សសត្វបានឃើញសច្ចៈ ។

បង្គំព្រះសង្ឃគួរឱ្យជ្រះថ្លា បួសហើយកាលណាប្រព្រឹត្តឥតអាក់
ជាស្រែបុណ្យល្អទាយកទុកដាក់ ធ្វើទានគ្រប់ថ្នាក់បន្តសាសនា ។
បង្គំរួចហើយខ្ញុំសូមលើកយក ព្រះសូត្រមួយមកទុកពិចារណា
សិក្សារួចហើយកើតក្តីអស្ចារ្យ ព្រះពុទ្ធត្រាស់ថាជាមង្គលសូត្រ ។
នៅសម័យមួយក្នុងជម្ពូទ្វីប មនុស្សគ្រប់ជន្មជីពរស់នៅស្លូតបូត
កើតក្តីសង្ស័យនៅឆ្ងល់រហូត អំពីព្រះសូត្រព្រោះតែមិនយល់ ។
ពេលប្រជុំគ្នាក៏បានសាកសួរ ថាអ្វីដែលគួរហៅថាមង្គល
រូបឬសំឡេងអារម្មណ៍វិលវល់ បើនរណាយល់សូមប្រាប់ផងណា៎ ។
កាលនោះទិដ្ឋមង្គិកៈ ជាបុរសម្នាក់បានពោលឡើងថា
គឺរូបហ្នឹងហើយឃើញគ្រប់នេត្រា ចាំរកឯណាយើងឃើញយ៉ាងច្បាស់ ។
ពេលព្រឹកព្រលឹមបុគ្គលឃើញហើយ សត្វស្លាបក្បៀកកើយហើរក្នុងអាកាស
ក្មេងខ្ចីកូនក្មេងរត់លេងផ្តេសផ្តាស ត្រីឆ្អិនល្អណាស់គោសេះគ្រប់ថ្នាក់ ។
ធម្មតាមើលឃើញស្រីមានផ្ទៃពោះ មេគោខ្ពស់ៗនេះគឺទស្សនៈ
ម្យ៉ាងគេសន្មតថាល្អឥតអាក់ សូមជនគ្រប់ថ្នាក់ជឿខ្ញុំចុះណា៎ ។
បុរសម្នាក់ទៀតខំឆ្លៀតស្តាប់ជាក់ ឮហើយគាត់ភ្ញាក់បដិសេធថា
អ្នកដ៏ចម្រើនពោលខុសសច្ចា ភ្នែកឃើញរូបាមិនល្អទាំងអស់ ។
គាប់ជួនពេលខ្លះល្អឥតទំនេរ សំឡេងនោះទេទើបល្អឥតទាស់
ឥឡូវស្តាប់ខ្ញុំរៀបរាប់សប្បុរស ចូរប្រុងស្តាប់ចុះគិតតាមប្រាជ្ញា ។
តាមពិតសំឡេងដែលឮនោះហើយ ចូរកុំភ្លេចឡើយលោកយាយលោកតា

ព្រោះក្នុងលោកនេះឮហើយកាលណា ទើបដឹងសាច់ការណ៍ជួបសុខសួស្តី ។

ឬក្សព្វឃោមល្អកម្រក្នុងលោក គឺមនុស្សបានមកពីការពោលស្តី
ព្ធថាចម្រើនគ្មានឡើយគ្រោះភ័យ ទើបខ្ញុំលកលៃពោលថាមង្គល ។
ពេលនោះមុតមង្គលិកៈ ស្តាប់ហើយស្ទើរស្ទាក់ថាពិតពុំយល់
គាត់ថាស្តាប់ហើយខ្វីតអំពល់ ព្រោះអ្នកពន្យល់ថាឮប្រពៃ ។
ប្រសិនសំឡេងដែលបានឮនោះ ស្តាប់ហើយចាក់ធ្លុះយល់អត្ថសេចក្តី
ខ្លះក៏ពីរោះខ្លះក៏គ្មានន័យ ថាជាសិរីដូចមិនសមសោះ ។
អារម្មណ៍មួយៗបុគ្គលបានដឹង ចូរស្តាប់ពាក្យហ្នឹងប្រឹងឱ្យបានអស់
តាមពិតក្លិនរសនោះទើបឥតខ្ចោះ ហិតទំពាអស់ទើបដឹងរសឆ្ងាញ់ ។
ក្លិនផ្កាបទុមចេញពីប្រឹថពី ភមរៈមូលមីរនៃបនិត្យស្រឡាញ់
នាំគ្នាក្រេបក្លិនយកឈ្មះយកចាញ់ ដេញជើងត្របាញ់ព្រោះឃើញសម្រស់ ។
ឯផោដ្ឋព្វៈម្នាក់ៗចង់ពាល់ ចាប់កាន់ឱ្យស្គាល់រសជាតិទាំងអស់
គឺខ្ញុំពោលនេះដោយចិត្តស្ម័គ្រស្មោះ លោកអ្នកទាំងអស់នេះហើយល្អជា ។
បុរសទាំងបីមិនយល់ព្រមសោះ អ្នកស្តាប់ទាំងអស់ជឿប្លែកពីគ្នា
ខ្លះប្រកាន់ថាឃើញរូបនានា ជឿស៊ប់តាមគ្នាទាំងខ្លួនមិនយល់ ។
ឯជនពួកខ្លះគំនិតរឹងត្អឹង ថាសំឡេងហ្នឹងទើបជាមង្គល
ខ្លះថាអារម្មណ៍ដែលខ្លួនបានយល់ រឿងនោះអំពល់ពេញទ្វីបហើយណា ។
នៅគ្រានោះឯងពួកមនុស្សទាំងឡាយ នាំគ្នាខ្វល់ខ្វាយព្រមទាំងទេវតា
ខំសាកសួរគ្នាក្រែងបានដឹងការណ៍ ដំណឹងនោះណារីតតែរាលដាល ។

មិនតែប៉ុណ្ណោះទោះមនុស្សទេវតា ចេះតែសង្កាអស់ម៉ឺនចក្រវាល
ចិត្តមិនបានស្ងប់សង្ស័យបណ្ដាល ពេលនោះដល់កាលត្រូវដឹងការពិត ។
កាលនោះទេវតាជាន់សុទ្ធាវាស ចិត្តលោកថ្លាជ្រះយល់ពីទឹកចិត្ត
របស់មនុស្សលោកមានទុក្ខរិបរិត ដប់ពីរឆ្នាំពិតព្រះពុទ្ធសម្ដែង ។
ពេលកន្លងមកដប់ពីរឆ្នាំហើយ លោកមិនភ្លេចឡើយនាំគ្នាប្រឹងប្រែង
នៅជាន់តាវត្តិង្សជុំអស់សម្ដែង ជួបជុំគ្នាឯងចូលគាល់សក្កៈ ។
ពេលនោះទេវរាជទ្រង់ត្រាស់សួរថា អស់លោកទេវតាច្រើនជាអនគ្ឃ
ដឹងរឿងរ៉ាវហើយយកចិត្តទុកដាក់ ទេវតាគ្រប់ថ្នាក់សួរព្រះរួសរាន់ ។
នៅគ្រានោះឯងគណៈទេវបុត្រ នាំគ្នាចុះផុតដល់វត្តជេតពន
ទេវតាមួយអង្គឱនកាយបន្ទន់ ទឹកចិត្តលោកធ្ងន់សាកសួរបញ្ហា ។
នាពេលអធ្រាត្រព្រះពុទ្ធជាម្ចាស់ ព្រះអង្គទ្រង់ត្រាស់ព្រះធម៌ទេសនា
ព្រះសូត្រសាមសិបប្រាំបីប្រការ ពីរោះពិស្ដារមានដូចតទៅ ។
មួយគឺមិនសេពគប់ពាលទាំងឡាយ នាំឱ្យខ្វល់ខ្វាយជួបរឿងអាស្រូវ
ពីរគប់បណ្ឌិតលោកតែងនាំទៅ ក្ដីសុខនោះកូវមានរាល់វេលា ។
ចំណែកទីបីត្រូវដឹងកុំខាន ញាតិគ្រប់សន្ដានត្រូវតែបូជា
មាតាបិតាសមណៈនានា ហេតុនោះហើយជាមង្គលឧត្ដម ។
រីឯទីបួនជួនទីកន្លែង ប្រទេសនោះឯងរស់នៅបានសម
ទីប្រាំខ្លួនបានធ្វើបុណ្យសន្សំ ប្រាំមួយខិតខំតម្កល់ខ្លួនល្អ ។
ប្រាំពីរបានស្ដាប់បានរៀនច្រើនមួយ អស់លោកមិនព្រួយពិតជាត្រេកអរ

ប្រាំបីសិប្បៈហត្ថកម្មកម្រ ចេះកែលម្អហើយច្នៃប្រឌិត ។
ប្រាំបួនវិន័យដែលអ្នកសិក្សា ខំពិចារណាទៅតាមការពិត
ដប់ពាក្យអ្នកពោលជាសុភាសិត ល្អិតល្អក្នុងចិត្តពិតជាសុខា ។
ដប់មួយល្អជាក់អ្នកស្តាប់ឱ្យច្បាស់ កុំប្រែក្រឡាស់បម្រើមាតា
លោកអ្នកមានគុណកុំភ្លេចឡើយណា ព្រះនោះហើយណាជាព្រះកន្លោង ។
ដប់ពីរបម្រើបិតាក្នុងផ្ទះ ហើយក្រាបសំពះគុណល្អឥតហ្មង
បបួលញាតិមិត្តមីងមាប្អូនបង កុំឱ្យសៅហ្មងស្លាប់ទើបម្នីម្នា ។
ដប់បីត្រូវតែប្រយ័ត្នបំផុត សង្គ្រោះដល់បុត្រព្រមទាំងភរិយា
ដប់បួនបន្តប្រកបការងារ មិនលាយឡំគ្នាច្របូកច្របល់ ។
ដប់ប្រាំធ្វើទានទោះតិចម្តេចម្តា កុំខានឡើយណាធ្វើទុកជាថ្នល់
ពេលដែលស្លាប់ទៅមិនមានខ្វាយខ្វល់ នឹកស្តាយទ្រព្យសល់ពិតជាវណ្ឌក ។
ដប់ប្រាំមួយការប្រព្រឹត្តធម៌ពិត រស់សាងសុចរិតស្រឡាញ់ធម៌ស
ពុំថាពាក្យបាបមិនដែលត្រេកអរ ហើយប្រព្រឹត្តល្អចៀសបាបឱ្យឆ្ងាយ ។
ដប់ប្រាំពីរអ្នកត្រូវធ្វើកុំលស់ គឺជួយសង្គ្រោះដល់ញាតិទាំងឡាយ
ឱ្យលោកបានសុខផ្លូវចិត្តរាងកាយ ជួបសុខសប្បាយទាំងស្រីទាំងប្រុស ។
ដប់ប្រាំបីទាក់ទងរាល់អាត្មា ត្រូវធ្វើកិច្ចការណាដែលមិនខុស
នឹងច្បាប់ហាមប្រាមត្រូវមានសន្តោស ការងារដូច្នោះជាសុខសួស្តី ។
ដប់ប្រាំបួនវៀរពីការធ្វើបាប ខិតខំបន្ទាបអធម៌ឱ្យខ្ចី
ម្ភៃវៀរចាកពីសុរាមេរ័យ អ្នកប្រុងស្មារតីកាន់យកឱ្យបាន ។

ថ្ងៃមួយរស់នៅកុំបីប្រមាទ ក្នុងធម៌ស្អាងស្អាតសោះតែនឹងខាន
ថ្ងៃពីររស់នៅគោរពសន្តាន ដោយការរាប់អានញាតិមិត្តស្រីប្រុស ។
ថ្ងៃបីរស់នៅបន្ទាបខ្លួនល្អ ថ្ងៃបួនមានក្រឱ្យចេះសន្តោស
ថ្ងៃប្រាំភារៈអ្នកដឹងត្រូវខុស មិនសាងកំហុសលើជនប្រុសស្រី ។
ថ្ងៃប្រាំមួយខំស្តាប់ធម៌តាមកាល មិនឱ្យបណ្តាលបាត់បង់ស្មារតី
ថ្ងៃប្រាំពីរអត់ធន់ត្រូវខន្តី ដុសខាត់អវិជ្ជីគឺក្រោធឱ្យឆ្ងាយ ។
ថ្ងៃប្រាំបីត្រូវតែដាក់មានះ អ្នកជួបប្រទះមិនសូវខ្វល់ខ្វាយ
គេប្រដៅងាយទាំងចិត្តទាំងកាយ អ្នកប្រាជ្ញទាំងឡាយមានរាល់វេលា ។
ថ្ងៃប្រាំបួនការបានជួបប្រទះ សមណៈប្រឹងលះកម្មាត់វេរា
សាមសិបគាប់ជួនបានសន្ទនា នូវកងធម្មាទៅមកតាមកាល ។
សាមសិបមួយគឺដុតបាបឱ្យអស់ ធម៌ខ្មៅឱ្យខ្ទេចខ្ទារកុំឱ្យរាលដាល
ម្យ៉ាងមិនពេញចិត្តឬត្រេកត្រអាល អធម៌បណ្តាលអាចមានទុក្ខព្រួយ ។
សាមសិបពីរប្រព្រឹត្តធម៌ប្រសើរ រស់នៅគ្រាន់បើបានជាជំនួយ
អប់រំកាយចិត្តឱ្យនឹងតែមួយ កុំឱ្យរលួយដោយអកុសល ។
សាមសិបបីឃើញអរិយសច្ច ដើម្បីកាត់ផ្តាច់វដ្តៈនាំខ្វល់
បានដល់ធម៌ពិតកម្ចាត់ចម្ងល់ ជាអកុសលកុំឱ្យកើតមាន ។
សាមសិបបួនបានធ្វើឱ្យជាក់ច្បាស់ នូវធម៌ល្អល្អះគឺព្រះនិព្វាន
ដែលជាមាគ៌ានៃព្រះទ្រង់ញាណ ព្រះអង្គទូន្មានជាគោលព្រះធម៌ ។
សាមសិបប្រាំចិត្តបុគ្គលណា ដែលលោកជ្រះថ្លាហើយមិនញាប់ញ័រ

សរសើរលាភយសសុខប្រៀបដូចជ័រ ឈ្មោះថាលោកធម៌មិនជាប់ជំពាក់ ។
សាមសិបប្រាំមួយអ្នកមិនសោយសោក ម្យ៉ាងមិនចាញ់បោកធម៌ជាអន្ទាក់
សាមសិបប្រាំពីរអ្នកគ្មានរាគៈ ជាអរិយៈផុតទុក្ខអស់ហើយ ។
សាមសិបប្រាំបីចិត្តអ្នកក្សេមក្សាន្ត លោកមិនរំខានដល់អ្នកផ្សេងឡើយ
លោកបានឆ្លងផុតឬបានដល់ត្រើយ ធម៌ទាំងនេះហើយជាសុខសួស្តី ។
ពេលដែលបានស្តាប់ធម៌ព្រះសម្តែង ភ្លឺច្បាស់ចិរំពែងដោយពាក្យបាលី
ពន្យល់ប្រាប់ដល់មនុស្សសត្វប្រុសស្រី អំពីអត្ថន័យមង្គលពិតហោង ។

> បុគ្គលមិនប្រឹងប្រែងរកទ្រព្យសម្បត្តិឈ្មោះថាប្រគល់ការសម្បូរ
> ទ្រព្យសម្បត្តិទៅលើដៃនរជនដែលមានសេចក្តីព្យាយាមដូចកង្កែប
> លោតចូលក្នុងអណ្តូងពេញប្រៀបដោយទឹកដូច្នេះ ។
>
> ទស្សនៈ ភិក្ខុ ប៉ាង ខាត់ វីរិយបណ្ឌិតោ

# ចាស់តែអាយុ

ធម្មតាឫស្សីរីងក្រៅរន្ធក្នុង ប្រៀបដូចផ្លែល្ហុងគ្រាន់តែនៅខ្ចី
ដល់ទុំរលួយធ្លាក់ចុះដល់ដី បានត្រឹមចំណីរូបធាតុទាំងឡាយ ។
រីងប៉េងប៉ោងគ្រាន់តែមានខ្យល់ រឿងមិនកង្វល់គ្រាន់នៅសប្បាយ
សាងទុច្ចរិតកម្មទុក្ខមិនរសាយ សង្ខារទាំងឡាយកើតហើយរលត់ ។
ស្តីពីគុណធមិអាស្រ័យប្រាជ្ញា ចង់បានសុខាធ្វើល្អមួយគត់
ចង់ល្អកុំស្មៀមប្រៀបដូចដង្កត់ ចង់លឿនត្រូវរត់ទើបដល់គោលដៅ ។
ចំណេះចេះដឹងបានព្រោះឧស្សាហ៍ រៀនសូត្រអក្ខរាទើបផុតល្ងង់ខ្លៅ
កុំអាងទ្រព្យធនឬមួយញាតិផៅ អាងកូនអាងចៅខុសក្បួនតម្រា ។
ប្រសិននៅល្ងង់គួរខំរៀនសូត្រ បើកាចត្រូវស្លូតកុំប្រើហិង្សា
បើសិនខ្លួនចាស់សូមចាស់ប្រាជ្ញា កុំឱ្យក្មេងថាយើងចាស់តែវ័យ ។
រុក្ខជាតិពេលខ្លះចេញផ្លែស្លាប់ខ្លួន មនុស្សមិនមាំមួនស្លាប់គ្មានអត្ថន័យ
រស់នៅយូរពិតមិនចេះលកលៃ សាងតែអប្រិយរស់ប្រៀបដូចស្លាប់ ។
ប្រសិនចង់សុខរស់មានតម្លៃ គួរតែកែច្នៃធ្វើខ្លួនតាមច្បាប់
កុំចាស់តែវ័យឱ្យក្មេងស្តីប្រាប់ គួរខំប្រញាប់សាងល្អទៅហោង ។

# កូនខុសហើយម៉ែ!

ពេលមានជីវិតកូនមិនបានគិត ដល់ម៉ែក្ស័យពិតទើបកូនភ្ញាក់ខ្លួន
បម្រើស្រាលធ្ងន់លើម៉ែនឹមនួន ក៏កូនមាសស្ងួនមិនបានធ្វើដែរ ។
ចំណីអាហារហូបចុកទាំងខ្វះ ខ្លួនម្ដាយសែនចាស់រស់នៅស្រុកស្រែ
កូនមិនដែលទៅសួរសុខទុក្ខម៉ែ គ្មានអ្នកមើលថែក៏កូនមិនខ្វល់ ។
ឱ!ព្រះម៉ែអើយកូនស្ដាយណាស់ ពីមុនល្ងង់ណាស់គ្មានដឹងខ្យល់
ពុកម៉ែនៅរស់មិនសាងមគ្គផល ព្រោះគិតមិនដល់គុណអ្នកម្ដាយថ្លៃ ។
នឹកឃើញគ្រាមួយកាលកូននៅតូច ម៉ែថៃប្រៀបដូចជាពេជ្រចរណៃ
យកសក់បាំងកូនយកខ្លួនបាំងថ្ងៃ កូនស្ថិតក្នុងដៃព្រះម៉ែថ្នមបី ។
ធ្វើការរកស៊ីមិនមានចន្លោះ ឆ្លៀតឱ្យបៅដោះមិនមានខ្មាសអី
នៅមុខមហាជនមានប្រុសមានស្រី ក៏ម៉ែធ្វើហីឱ្យតែកូនឆ្អែត ។
គុណធំយ៉ាងនេះរិះគិតមិនដឹង គុណល្អយ៉ាងហ្នឹងឃើញច្បាស់ក្រឡែត
គិតពីខែមគ្គថាចាំខែចេត្រ ធ្វើបុណ្យជាហេតុតបគុណម៉ែខ្លះ ។
មិនទាន់ដល់ផងម៉ែលាកូនហើយអ្នកម្ដាយត្រាណត្រើយកូនខុសខ្លាំងណាស់
ព្រោះមិនស្ដាប់គ្រូយល់តែផ្ដេសផ្ដាសមិនថែម្ដាយចាស់ឱ្យនៅម្នាក់ឯង ។
មើលចុះខ្ទមតូចស្ងៀមធ្វើមិនដឹង ខ្ញុំទុក្ខម៉ឺង១ចិត្តវិលដូចផ្សែង
ទឹកដីខ្ទមតូចដែលជាកន្លែង សូមជួយថ្លាថ្លែងរកម៉ែខ្ញុំផង ។
ឱ!ម្ដាយសំឡាញ់ជាទីស្នេហា ម៉ែនៅឯណាម្ដេចស្ងាត់តែម្ដង
ពីដើមមកជួបម៉ែស្ដីឆ្លើយឆ្លង ពេលនេះឯងហោងឃើញតែទីតាំង ។
ឃើញគ្រែកន្ទេលម៉ែធ្លាប់សម្រាន្ត កូនទប់មិនបានព្រោះកូនខុសខ្លាំង
ឃើញក្រមាចាស់ម៉ែធ្លាប់បិទបាំង ឱ!អ្នកសច្ចំជួយរកម៉ែខ្ញុំ ។

## អានិសង្ឃជួយបោះពុម្ពសៀវភៅធម៌ជាធម្មទាន១០ប្រការ

១-ធ្វើបាបពីជាតិមុន នឹងបានធូរស្រាល ព្រោះបានរស្មីនៃធម្មទាន

២-វត្ថុស័ក្តិសិទ្ធិទាំងពួងជួយថែរក្សាមិនឱ្យមានរោគភ័យអន្តរាយ

៣-ទោះបីសត្រូវក៏មានចិត្តត្រាប្រណីយើងដែរ

៤-ពួកបិសាចនិងមារមិនហ៊ាននៅជិត

៥-រួចផុតពីភ័យ សប្បាយចិត្ត មួយជីវិតជួបតែរឿងល្អ មានរាសីខ្ពស់

៦-ប្រាថ្នាអ្វីក៏សម្រេច ហើយគ្រួសារមានសុភមង្គល

៧-ធ្វើអ្វី និយាយអ្វី ក៏មានមនុស្សចូលចិត្ត សម្បូរដោយលាភ

៨-ជីវិតបរិបូណ៌ដោយក្តីសុខ មិនមានជំងឺ រាងកាយមាំមួន

៩-កើតមកមានបញ្ញា រូបស្អាត ចរិតល្អមានបុណ្យច្រើន

១០-មានសុភមង្គលក្នុងជីវិត កូនចៅកើតមកជាមនុស្សល្អ។

---

៩៥-អត្ថបទកំណាព្យ ចាប់ពីទំព័រ៣០៤-៣១៨ ជាអត្ថបទកំណាព្យក្រោមចំណងជើងថា "ខ្ញុំតែងជូនអ្នក" និពន្ធដោយ សាមណេរ

សា ចាន់រ៉ាត់។

# ផ្សាយមេត្តាចិត្តដល់សព្វសត្វ

សព្វេ បុរត្ថិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ
សព្វេ បុរត្ថិមាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ។
សព្វេ ទក្ខិណាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ
សព្វេ ទក្ខិណាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ។
សព្វេ បច្ឆិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ
សព្វេ បច្ឆិមាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ។
សព្វេ ឧត្តរាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ
សព្វេ ឧត្តរាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ។
សព្វេ ឧបរិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ
សព្វេ ឧបរិមាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ។
សព្វេ ហេដ្ឋិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ។
សព្វេ សត្តា អវេរា ហោន្តុ សុខិតា ហោន្តុ និទ្ទុក្ខា ហោន្តុ។
អព្យាបជ្ឈា ហោន្តុ អនីឃា ហោន្តុ ទីឃាយុកា ហោន្តុ អរោគា ហោន្តុ សម្បត្តីហិ សមិជ្ឈន្តុ សុខី អត្តានំ បរិហរន្តុ ទុក្ខប្បត្តា ច និទ្ទុក្ខា ភយប្បត្តា ច និព្ភយា សោកប្បត្តា ច និស្សោកា ហោន្តុ សព្វេបិ បាណិនោ។

# បរាភវសូត្រ

## បទបឋ្យាវត្ត

(ទេវតាទូលសួរព្រះសាស្ដាថា)

**បរាភវន្តំ បុរិសំ មយំ បុច្ឆាម គោតមំ**
**ភវន្តំ បុដ្ឋុមាគម្ម កឹ បរាភវតោ មុខំ៕**

យើងខ្ញុំទាំងឡាយ មកសូមទូលសួរ នូវហេតុដែលគួរ ចម្រើនវិនាស
ប្រុសស្រីក្នុងលោក-សន្និវាស ដែលនឹងវិនាស សាបសូន្យចាកគុណ។
ឆ្ពោះព្រះគោតម ព្រះអង្គមានបុណ្យ សូមទ្រង់និមន្ត សម្ដែងឱ្យទាន
ធម្មជាតិដូចម្ដេច ដែលជាប្រធាន នាំសត្វឱ្យមាន សេចក្ដីវិនាស។

(ព្រះសាស្ដា ឆ្លើយតបនឹងពួកទេព្ដាវិញថា)

**សុវិជានោ ភវំ ហោតិ សុវិជានោ បរាភវោ**
**ធម្មកាមោ ភវំ ហោតិ ធម្មទេស្សី បរាភវោ៕**

អ្នកដែលចម្រើន គេក៏អាចស្គាល់ងាយ អ្នកដែលអន្ដរាយ គេក៏អាចស្គាល់ពិត
អ្នកប្រាថ្នាធម៌ ល្អិតល្អក្នុងចិត្ត ហើយខំប្រព្រឹត្ត នឹងបានចម្រើន។
អ្នកដែលទ្រុស្ដធម៌ ស្អប់ធម៌ឥតកើត ឥតកើនចម្រើន វិនាសទៅមុខ។

**ឥតិ ហេតំ វិជានាម បឋមោ សោ បរាភវោ**
**ទុតិយំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ៕**

យើងខ្ញុំទាំងឡាយ បានដឹងជាក់ស្ដែង វិនាសនេះឯង ព្រោះហេតុដូច្នោះ
ក្ដីវិនាសនេះ បើរាប់សង្គ្រោះ វិនាសនោះឈ្មោះ ទី១ទាន់ហាន់។
បពិត្រព្រះអង្គ ព្រះនាមភគវន្ត សូមទ្រង់និមន្ត សម្ដែងឱ្យទាន
វិនាសទី២ អ្វីជាប្រធាន នាំសត្វឱ្យមាន សេចក្ដីវិនាស។

**អសន្តស្ស បិយា ហោន្តិ សន្តេន ក្ុរុតេ បិយំ**

**អសតំ ធម្មរោចេតិ តំ បរាភវតោ មុខំ។**

អ្នកដែលស្រឡាញ់ ពេញចិត្តស្នេហា តែនឹងមនុស្សណា អសប្បុរស

តែមិនស្រឡាញ់ ពេញចិត្តទាំងអស់ នឹងអ្នកសប្បុរស មកធ្វើជាមិត្រ។

សេចក្ដីស្រឡាញ់ ពេញចិត្តគំនិត ហើយទៅគប់មិត្រ អសប្បុរស

គាប់ចិត្តក្នុងធមិ ឬមួយរបស់ ហេតុនោះទាំងអស់ នាំឱ្យវិនាស។

**ឥតិ ហេតំ វិជានាម ទុតិយោ សោ បរាភវោ**

**តតិយំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ។**

យើងខ្ញុំទាំងឡាយ បានដឹងជាក់ស្ដែង វិនាសនេះឯង ព្រោះហេតុដូច្នោះ

ក្តីវិនាសនេះ បើរាប់សង្គ្រោះ វិនាសនោះឈ្មោះ ទី២ ទាន់ហន់។

បពិត្រព្រះអង្គ ព្រះនាមភគវន្ត សូមទ្រង់និមន្ត សម្ដែងឱ្យទាន

វិនាសទី៣ អ្វីជាប្រធាន នាំសត្វឱ្យមាន សេចក្ដីវិនាស។

**និទ្ទាសីលី សភាសីលី អនុដ្ឋាតា ជយោ នរោ**

**អលសោ កោធបញ្ញាណោ តំ បរាភវតោ មុខំ។**

អ្នកដេកច្រើន១ និយាយច្រើន១ និងអ្នកឥតព្រួយ ឥតគិតប្រឹងប្រែង

អ្នកខ្ជិលច្រអូស មិនមានខ្នះខ្នែង ខឹងច្រើនសម្ដែង ឱ្យគេឃើញបាន

ហេតុធមិទាំងនោះ មិនជាកល្យាណ នាំឱ្យរំខាន ខាតខូចប្រយោជន៍

មានជាប្រធាន តិចច្រើនដោយហោច នាំបង់ប្រយោជន៍ ហើយឱ្យវិនាស។

**ឥតិ ហេតំ វិជានាម តតិយោសោ បរាភវោ**

**ចតុត្ថំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ។**

យើងខ្ញុំទាំងឡាយ បានដឹងជាក់ស្តែង វិនាសនេះឯង ព្រោះហេតុដូច្នោះ

ក្តីវិនាសនេះ បើរាប់សង្គ្រោះ វិនាសនោះឈ្មោះ ទី៣ ទាន់ហន់។

បពិត្រព្រះអង្គ ព្រះនាមភគវន្ត សូមទ្រង់និមន្ត សម្តែងឱ្យទាន

វិនាសទី៤ អ្វីជាប្រធាន នាំសត្វឱ្យមាន សេចក្តីវិនាស។

**យោមាតរំ បិតរំវា ជិណ្ណកំវា គតយោព្វនំ**

**បហុសន្តោ ន ភរតិ តំ បរាភវតោ មុខំ។**

នរជនណា មានទ្រព្យធនធាន ហើយខ្លួនមិនបាន ចិញ្ចឹមរក្សា

មាតាបិតា ដែលចាស់ជរា ហេតុនោះទៅជា នាំឱ្យវិនាស។

**ឥតិ ហេតំ វិជានាម ចតុត្ថោ សោ បរាភវោ**

**បញ្ចមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ។**

យើងខ្ញុំទាំងឡាយ បានដឹងជាក់ស្តែង វិនាសនេះឯង ព្រោះហេតុដូច្នោះ

ក្តីវិនាសនេះ បើរាប់សង្គ្រោះ វិនាសនោះឈ្មោះ ទី៤ទាន់ហន់។

បពិត្រព្រះអង្គ ព្រះនាមភគវន្ត សូមទ្រង់និមន្ត សម្តែងឱ្យទាន

វិនាសទី៥ អ្វីជាប្រធាន នាំសត្វឱ្យមាន សេចក្តីវិនាស។

**យោ ព្រាហ្មណំ សមណំវា អញ្ញំវា បិវនិព្វកំ**

**មុសាវាទេន វញ្ចេតិ តំ បរាភវតោ មុខំ។**

ជនបញ្ឆោតព្រាហ្មណ៍ ឬពួកសមណៈ ពួកស្មូមឬ អ្នកដទៃ១

ដោយមុសាវាទ ឃ្លាតពាក្យប្រពៃ នោះប្រធាននៃ សេចក្តីវិនាស។

**ឥតិ ហេតំ វិជានាម បញ្ចមោ សោ បរាភវោ**

**ឆដ្ឋមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ។**

យើងខ្ញុំទាំងឡាយ បានដឹងជាក់ស្តែង វិនាសនេះឯង ព្រោះហេតុដូច្នោះ

ក្តីវិនាសនេះ បើរាប់សង្គ្រោះ វិនាសនោះឈ្មោះ ទី៥ទាន់ហន់។

បពិត្រព្រះអង្គ ព្រះនាមភគវន្ត សូមទ្រង់និមន្ត សម្តែងឱ្យទាន

វិនាសទី៦ អ្វីជាប្រធាន នាំសត្វឱ្យមាន សេចក្តីវិនាស។

**បហុតវិត្តោ បុរិសោ សហិរញ្ញោ សភោជនោ**

**ឯកោ ភុញ្ជតិ សាទូនិ តំ បរាភវតោ មុខំ។**

បុរសអ្នកមាន ទ្រព្យធនធានច្រើន មាសប្រាក់ចម្រើន និងគ្រឿងអាហារ

លបលាក់របស់ ដែលឆ្ងាញ់ពិសា ស៊ីម្នាក់ឯងជា ប្រធានវិនាស។

**ឥតិ ហេតំ វិជានាម ឆដ្ឋមោ សោ បរាភវោ**

**សត្តមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ។**

យើងខ្ញុំទាំងឡាយ បានដឹងជាក់ស្តែង វិនាសនេះឯង ព្រោះហេតុដូច្នោះ

ក្តីវិនាសនេះ បើរាប់សង្គ្រោះ វិនាសនោះឈ្មោះ ទី៦ទាន់ហន់។

បពិត្រព្រះអង្គ ព្រះនាមភគវន្ត សូមទ្រង់និមន្ត សម្តែងឱ្យទាន

វិនាសទី៧ អ្វីជាប្រធាន នាំសត្វឱ្យមាន សេចក្តីវិនាស។

**ជាតិត្ថទ្ធោ ធនត្ថទ្ធោ គោត្តត្ថទ្ធោ ច យោ នរោ**

**សញ្ញាតឹ អតិមញ្ញេតិ តំ បរាភវតោ មុខំ។**

អ្នកដែលប្រកាន់ ជាតិទ្រព្យត្រកូល ហើយមិនប្រមូល សាច់ញាតិសន្តាន

មើលងាយញាតិខ្លួន ដោយអាងខ្លួនមាន នោះជាប្រធាន សេចក្តីវិនាស។

**ឥតិ ហេតំ វិជានាម សត្តមោ សោ បរាភវោ**
**អដ្ឋមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។**

យើងខ្ញុំទាំងឡាយ បានដឹងជាក់ស្តែង វិនាសនេះឯង ព្រោះហេតុដូច្នោះ
ក្តីវិនាសនេះ បើរាប់សង្គ្រោះ វិនាសនោះឈ្មោះ ទី៧ទាន់ហន់ ។
បពិត្រព្រះអង្គ ព្រះនាមភគវន្ត សូមទ្រង់និមន្ត សម្តែងឱ្យទាន
វិនាសទី៨ អ្វីជាប្រធាន នាំសត្វឱ្យមាន សេចក្តីវិនាស ។

**ឥត្ថីធុត្តោ សុរាធុត្តោ អក្ខធុត្តោ ច យោ នរោ**
**លទ្ធំ លទ្ធំ វិនាសេតិ តំ បរាភវតោ មុខំ ។**

ជនអ្នកប្រព្រឹត្ត ល្បែងបីប្រការ ល្បែងស្រីល្បែងស្រា ល្បែងភ្នាល់ទាំងឡាយ
ធ្វើទ្រព្យខ្លួនមាន ឱ្យអន្តរាយ ការល្បែងទាំងឡាយ នោះនាំវិនាស ។

**ឥតិហេតំ វិជានាម អដ្ឋមោ សោ បរាភវោ**
**នវមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។**

យើងខ្ញុំទាំងឡាយ បានដឹងជាក់ស្តែង វិនាសនេះឯង ព្រោះហេតុដូច្នោះ
ក្តីវិនាសនេះ បើរាប់សង្គ្រោះ វិនាសនោះឈ្មោះ ទី៨ទាន់ហន់ ។
បពិត្រព្រះអង្គ ព្រះនាមភគវ័ន សូមទ្រង់និមន្ត សម្តែងឱ្យទាន
វិនាសទី៩ អ្វីជាប្រធាន នាំសត្វឱ្យមាន សេចក្តីវិនាស ។

**សេហិ ទារេហិ អសន្តុដ្ឋោ វេសិយាសុ បទុស្សតិ**
**ទុស្សតិ បរទារេសុ តំ បរាភវតោ មុខំ ។**

ប្រុសមិនត្រេកអរ នឹងប្រពន្ធខ្លួន ហើយទៅជាប់ជួន នឹងស្រីពេស្យា
ទ្រុស្តនឹងប្រពន្ធ កូនជននានា ហេតុនោះទៅជា នាំឱ្យវិនាស ។

**ឥតិហេតំ វិជានាម នវមោ សោ បរាភវោ**
**ទសមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។**

យើងខ្ញុំទាំងឡាយ បានដឹងជាក់ស្ដែង វិនាសនេះឯង ព្រោះហេតុដូច្នោះ
ក្ដីវិនាសនេះ បើរាប់សង្គ្រោះ វិនាសនោះឈ្មោះ ទី៩ទាន់ហាន់។
បពិត្រព្រះអង្គ ព្រះនាមភគវន្ត សូមទ្រង់និមន្ត សម្ដែងឱ្យទាន
វិនាសទី១០ អ្វីជាប្រធាន នាំសត្វឱ្យមាន សេចក្ដីវិនាស។

**អតីតយោព្វនោ ចោសោ អានេតិ តិម្ពរុត្ថនឹ**
**តស្សា ឥស្សា នសុបតិ តំ បរាភវតោ មុខំ**

បុរសមានវ័យ ដែលចាស់ហួសពេក ហើយមានតម្រេក ដោយក្ដីតណ្ហា
នាំយកស្រីក្មេង មកធ្វើភរិយា ហេតុនោះទៅជា នាំឱ្យវិនាស។

**ឥតិហេតំ វិជានាម ទសមោ សោ បរាភវោ**
**ឯកាទសមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ**

យើងខ្ញុំទាំងឡាយ បានដឹងជាក់ស្ដែង វិនាសនេះឯង ព្រោះហេតុដូច្នោះ
ក្ដីវិនាសនេះ បើរាប់សង្គ្រោះ វិនាសនោះឈ្មោះ ទី១០ទាន់ហាន់។
បពិត្រព្រះអង្គ ព្រះនាមភគវន្ត សូមទ្រង់និមន្ត សម្ដែងឱ្យទាន
វិនាសទី១១ អ្វីជាប្រធាន នាំសត្វឱ្យមាន សេចក្ដីវិនាស។

**ឥត្ថីសោណ្ឌី វិកិរណី បុរិសំ វាបិ តាទិសំ**
**ឥស្សរិយស្មឹ ឋបេតិ តំ បរាភវតោ មុខំ**

បុរសតាំងស្រី អ្នកលេងខ្ជះខ្ជាយ ឬស្រីទាំងឡាយ តាំងបុរសនោះ
ដែលជាអ្នកលេង ខ្ជះខ្ជាយដូច្នោះ អំពើទាំងនោះ នាំឱ្យវិនាស។

**ឥតិ ហេតំ វិជានាម ឯកាទសមោ សោ បរាភវោ**
**ទ្វាទសមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ**

យើងខ្ញុំទាំងឡាយ បានដឹងជាក់ស្ដែង វិនាសនេះឯង ព្រោះហេតុដូច្នោះ
ក្ដីវិនាសនេះ បើរាប់សង្គ្រោះ វិនាសនោះឈ្មោះ ទី១១ទាន់ហាន់។
បពិត្រព្រះអង្គ ព្រះនាមភគវន្ត សូមទ្រង់និមន្ត សម្ដែងឱ្យទាន
វិនាសទី១២ អ្វីជាប្រធាន នាំសត្វឱ្យមាន សេចក្ដីវិនាស។

**អប្បភោគោ មហាតណ្ហោ ខត្តិយេ ជាយតេ កុលេ**
**សោច រជ្ជំ បត្ថយតិ តំ បរាភវតោ មុខំ។**

ជនណាកើតក្នុង ត្រកូលជាក្សត្រ អ្នកខ្សត់សម្បត្តិ ហើយប្រាថ្នាធំ
ចង់បានជាស្តេច សោយរាជ្យស្តុកស្តម្ភ ហេតុនោះនឹងនាំ ឱ្យដល់វិនាស។

**ឯតេ បរាភវេ លោកេ បណ្ឌិតោ សមវេក្ខិយ**
**អរិយទស្សនសម្បន្នោ សលោកំ ភជតេ សិវំ។**

ជនជាបណ្ឌិត គំនិតប្រសើរ បានឃើញដំណើរ នៃហេតុវិនាស
ដល់សត្វក្នុងលោក- សន្និវាស រួចពីវិនាស គប់រកចម្រើន។

**បរាភវសុត្តំ និដ្ឋិតំ។**[៥៦]

៥៦-សែម-សូរ ប្រជុំភាណវារៈបាលី-ប្រែពិសេស ទំព័រ៣០០-៣០៧ ចម្លងដោយបណ្ណាគារត្រៃរតន៍ ព.ស. ២៥៤៣ គ.ស.១៩៩៩

# ធម៌ឱ្យពរជូនពរមនុស្សគ្រប់វ័យ

១-សាធុៗអ្នកម្ចាស់ទានមានសទ្ធាជ្រះថ្លាបាននាំយកបច្ច័យ មកចាប់កុសល សូមឱ្យជួបព្រះស្រីអារ្យមេត្រីស្រីពោធិសត្វ ព្រះអង្គទ្រង់លើកសាសនាចូរស្តាប់ធម៌ទេសនារបស់ព្រះអង្គបានសម្រេចតាំងពីសោតាបត្តិមគ្គសោតាបត្តិផល សកទា គាមិមគ្គ សកទាគាមិផល អានាគាមិមគ្គ អានាគាមិផល អរហត្តមគ្គអរហត្តផលរហូតដល់ព្រះនិព្វានកុំបីអាក់ខានឡើយ ។

អនុមោទនា!

២-សូមឱ្យអ្នកម្ចាស់ទាន មានតម្រិះដូចព្រះនាងអមរា មានបញ្ញាដូចព្រះមហោសថមានរឹទ្ធីបំផុតដូចព្រះមោគ្គល្លានពូកែចាំរកគ្មានដូចមហាអានន្ទបានសម្រេច ព្រះអរហន្តដូចអង្គុលិមាល ឈ្នះពៀរវេរាដូចខន្តីវាទីតាបស សូមមានចិត្តស្មោះដូចនាងមេទ្រីបាពិ រកស៊ីមានបានដូចអនាថបិណ្ឌិកសេដ្ឋី ចង់ប្រាថ្នាពុទ្ធពរណាសម្បត្តិអ្វី សូមបានសម្រេចឆាប់ៗរួសរាន់ទាន់ចិត្តកុំបីឃ្លាតឡើយ ។សូមអនុមោទនា!

៣-សូមអ្នកម្ចាស់ទានបានជួបពុទ្ធពរទាំងឡាយ៤ប្រការគឺទីមួយអាយុសូមមានអាយុវែងវណ្ណៈស្អាតធេងសព្វរូបាសុខៈក៏សូមឱ្យសុខតរៀងទៅមុខឥតគណនារីករាយប្រិមប្រិយសព្វវេលា ឈ្នះអស់ពួកមារសត្រូវផងពលៈនេះណាមានកម្លាំង និងសម្បត្តិទាំងឡាយ៣ប្រការ គឺៈសម្បត្តិមនុស្សសម្បូរសប្បាយសម្បត្តិទេព្តាល្អឆើតឆាយ សម្បត្តិព្រះនិព្វានគ្មានទុក្ខភ័យបើអ្នកម្ចាស់ទានប្រាថ្នាពុទ្ធពរនិងសម្បត្តិអ្វីៗ សូមសម្រេចដូចក្តីប៉ងប្រាថ្នាហោង ។

*សូមអនុមោទនា!*

៤-សូមអ្នកម្ចាស់ទានប្រាថ្នាតាមចិត្តស្ម័គ្រសាងបុណ្យពីអតីតៈ ចែដន្យទុក្ខៈ ទុក្ខវេទនានាំផលសម្រេចទាន់បច្ចុប្បន្នឱ្យបានគ្រប់គ្រាន់ទាន់វេលាចៀសផុត ទុក្ខសោកនិងរោគា សូមឱ្យក្លាយជាអហោសិកម្ម បើសត្រូវមកពីមុខក៏ សូមឱ្យរំលងបើសត្រូវមកពីខ្នងសូមឱ្យរលាយបើសត្រូវមកពីឆ្ងាយសូមឱ្យ ក្លាយមកជាមិត្ត បើសម្បត្តិណាក្រៗ សូមឱ្យងាយបើសម្បត្តិណាឆ្ងាយសូម មកជិតបើអ្វីៗដែលពិបាកគិត សូមកើតឯងៗពុទ្ធពរ៤ប្រការសម្បត្តិ៣ចូរ កើតមានដល់អ្នកកុំបីអាក់ខានឡើយ ។ *អនុមោទនា!*

៥-សូមឱ្យអ្នកម្ចាស់ទានជួបនូវពុទ្ធពរទាំងឡាយ៤ប្រការ គឺទីមួយអាយុក៏ សូមឱ្យមានអាយុវែងកុំស្លាប់នៅក្មេងសោះឡើយណា១០០ឆ្នាំពិតៗ គ្រប់ៗ គ្នាផលបុណ្យរក្សាកុំបីឃ្លាតទីពីរវណ្ណៈសម្បុរល្អល្អះឆើតឆាយឥតសៅហ្មង ទោះបីខ្មៅសល្អកន្លងឥតមានសៅហ្មងសមសោភាទីបីសុខៈសូមឱ្យបានសុខ តរៀងទៅមុខឥតគណនា រីករាយប្រិមប្រិយសព្វវេលា ឈ្នះអស់ពយកមារ សត្រូវផងទីបួនពលៈ គឺកម្លាំងសូមមានកម្លាំងខ្លាំងក្លាគ្រប់ៗប្រាណ ទាំង កាយទាំងចិត្តកុំបីខានគ្រប់រូបសព្វប្រាណកុំខានឡើយនិង សម្បត្តិ៤ប្រការគឺ រូបសម្បត្តិមិត្តសម្បត្តិបញ្ញាសម្បត្តិនិងភោគសម្បត្តិបើអ្នកម្ចាស់ទានប៉ុនប៉ង សម្បត្តិណាពរណានោះក៏សូមឱ្យសម្រេចឆាប់ៗ កុំបីក្លាយជាបការៈដទៃ ឡើយ ។ អនុមោទនា!

៦-សូមឱ្យប្អូនកុមារ សម្រេចសម្បត្តិគ្រប់យ៉ាង សូមរំលឹកដល់គុណកែវ ព្រះត្រ័យរត្ន គុណព្រះពុទ្ធជាអង្គម្ចាស់ដែលបានត្រាស់ទាំង៥ព្រះអង្គគុណ

ព្រះធមិទាំង៨៤០០០ព្រះធម្មក្ខន្ធ និងគុណព្រះអរិយសង្ឃ អង្គអក្ខរាលេខ គុណចែករៀនអក្សក៏ឆាប់ចាំចំណាំក៏ឆាប់បានប្រលងក៏ឆាប់ជាប់តាំងពីថ្នាក់ទី១ដល់ទី១០ ទីបញ្ចប់ ចូលមហាវិទ្យាល័យរៀនចេះចាំទាំងភាសាចិន កូរេ បារាំង អាល្លឺម៉ង់ អង់គ្លេស ទីបំផុតចូលធ្វើការនឹងគេ នៅក្នុងក្រុមហ៊ុន ឬក្នុងសមាគមកាកបាទ សង្វាតយក ប្រាក់ខែចាយវាយហូរហៃប្រើសម្ភារៈ ឱ្យទាន់សម័យមាន ទាំងទូរសព្ទដៃមានទាំងពីតេអូមានទាំងនាឡិកាម៉ាក រ៉ាដូ ម៉ូតូសេរី(០១០) ហុងដាពុទ្ធពរទាំងឡាយ៤ប្រការសម្បត្តិ៣ប្រការចូរ កើតមានដល់អ្នកកុំបីអាក់ខានឡើយ ។ អនុមោទនា!

៧-សូមកញ្ញាជាម្ចាស់ទាន សូមមានរាងល្អហ្មត់ហ្មង គន់មើលទៅខ្នងសម នឹងស្មាគន់មើលចង្កាសមនឹងមុខមុខនោះញញឹមប្រិមប្រិយដូចរស្មីនៃអំពិល អំពែកគន់មើលទៅកែវភ្នែកភ្លឺថ្លាបីដូចជាកញ្ចក់ គន់មើលទៅសក់ទន់ដូច សំឡី គន់មើលម្រាមដៃ បីដូចជាបន្ទាក្រូច ផ្កាល់ខ្លួចដូចអ្នកចម្រៀងខ្មែរ ដ៏ល្បី ស្រស់ សោភា បើអ្នកណាបានជាគ្នានោះ ពិតជាល្អសែនល្អទាំងឈ្មោះ ពីរោះទាំងវាចានិយាយសម្តីសំដៅទៅកាន់បុរសស្រីណា សែនពីរោះបីដូច សត្វសារិកា មានអ្នកចូលចិត្តអាណិតស្រលាញ់គ្រប់គ្នាម្យ៉ាងទៀតពុទ្ធពរ៤ ប្រការសម្បត្តិ៣ប្រការ ប្រសិនបើនាងកញ្ញាប្រាថ្នានូវសម្បត្តិណាពុទ្ធពរណា នោះសូមបានសម្រេចដូចសេចក្តីប្រាថ្នា ។អនុមោទនា!

៨-សាធុ១ អ្នកម្ចាស់ទានមានសទ្ធាជ្រះថ្លា ប្រមូលផ្តុំដោយចិត្ត ចំពោះ សាសនាហ្នឹង ជាអរិយទ្រព្យដ៏ប្រសើរសូមអានិសង្សដែលកើតពីសទ្ធាចិត្ត យ៉ាងនេះ សូមបួងសួងដល់វត្ថុស័ក្តិសិទ្ធិមានពិតលើលោកមានគុណព្រះរតន ត្រ័យទាំងបីទេវតាឆ្នាំចាស់ផ្លាស់ឆ្នាំថ្មីលើករាសីឱ្យខ្ពស់ត្រដែតរកស៊ីមានបាន

ត្រជាក់ត្រជំសុខដុមរមនា មូលមិត្តបងប្អូនជិតឆ្ងាយក្នុងក្រុមគ្រួសារគ្រប់វេលាឈ្នះអស់សត្រូវគ្រប់ទិសទីជយ័ជំនះឈ្នះអស់ភារកិច្ចដែលត្រូវបំពេញ ពុទ្ធពរទាំងឡាយ៤ប្រការនិងសម្បត្តិ៣ប្រការ ចូរមានដល់អ្នកដូចសេចក្តីប្រាថ្នា ។អនុមោទនា!

៩-សាធុៗបងប្រុសស្រីមានសទ្ធាជ្រះថ្លាក្នុងព្រះពុទ្ធសាសនាសូមអ្នកទាំងពីរបាន សេចក្តីសុខក្តីចម្រើនរកស៊ីមានបានមានតាំងពីផ្ទះថ្មសសរឥដ្ឋគ្រឿងបិទគ្រឿង ស្រឡៅក្រៅសាឡុង ក្នុងក្រឡាច់ជណ្តើរកាច់ស្រួលឡើងចុះបើគិតចេះតែខុសចុះមកថ្វាយបង្គំព្រះឈ្នះអស់សត្រូវគ្រប់ទិសទីរកស៊ីមានបានត្រជាក់ត្រជំ ដូចទឹកអង្គបំពង់ខ្ចីមានឡានវីឡា តូចធំមានខ្ញុំប្រុសស្រីចាប់ពីពេលនេះតទៅ *សូមអនុមោទនា!*

១០-សាធុៗ សូមអ្នកម្ចាស់ទានមានសទ្ធាញាណសម្បយុត្តជ្រះថ្លាចំពោះព្រះពុទ្ធសាសនាព្រមដោយសម្បត្តិ៣ប្រការសម្បត្តិមនុស្សល្អដូចផ្កាសម្បត្តិទេព្តាសម្បូរធនធានសម្បត្តិព្រះនិព្វានគ្មានទុក្ខភ័យ បើប្រាថ្នានូវ ពុទ្ធមាតាក្តីពុទ្ធបិតាក្តីអគ្គសាវ័កអគ្គសាវិកាណាក្តីសូមបានសម្រេចដូចសេចក្តីប្រាថ្នាទៅហោង។ *សូមអនុមោទនា !*

**នត្ថិ សន្តិ បរំ សុខំ**

ពុំមានសេចក្តីសុខដទៃណាស្មើនឹងសេចក្តីស្ងប់ឡើយ ។

*សូមអនុមោទនាធម្មទាន!*

# ក្បួនហោរាសាស្ត្រទស្សន៍ទាយ ជោគជតារាសីខ្ពស់ទាប

## ក្បួនសាមជាន់ ឬក្បួនអង្គរ រាប់ទិនាំង មនុស្សប្រុសនិងស្រី



របៀបរាប់អាយុសង្ខេបតាមខ្ទង់ឆ្នាំនីមួយៗ

| | |
|---|---|
| បើអាយុ១០ឆ្នាំឱ្យរាប់១០ | បើអាយុ៦០ឆ្នាំឱ្យរាប់១២ |
| បើអាយុ ២០ឆ្នាំឱ្យរាប់ ៨ | បើអាយុ៧០ឆ្នាំឱ្យរាប់១០ |
| បើអាយុ ៣០ឆ្នាំឱ្យរាប់ ៦ | បើអាយុ៨០ឆ្នាំឱ្យរាប់៨ |
| បើអាយុ ៤០ឆ្នាំឱ្យរាប់ ៤ | បើអាយុ៩០ឆ្នាំឱ្យរាប់៦ |
| បើអាយុ ៥០ឆ្នាំឱ្យរាប់ ២ | បើអាយុ១០០ឆ្នាំឱ្យរាប់៤។ |

**បញ្ជាក់:** ចំពោះទិសទាំងប្រាំបីនេះ គឺការរាប់ខុសគ្នាផ្នែកបុរសចាប់រាប់ពីទិសបស្ចិម-ឧត្តរ ចំណែកឯស្រីវិញ ចាប់រាប់ពី ទិស បូព៌-ទក្សិណ។ រាប់ម្តងគិត១០ឆ្នាំ ទាំងទីនាំងប្រុស-ស្រីដូចគ្នាទាំងអស់។

ឧទាហរណ៍ ឆ្នាំគោលគឺឆ្នាំសព្វថ្ងៃឆ្នាំខាល ចំណែកឯអ្នកទៅមើលប្រុសឆ្នាំថោះយើងដឹងថាគេអាយុ២៤ឆ្នាំក្នុងឆ្នាំខាលនេះ។ ដូច្នេះត្រូវរាប់ពីទិសបស្ចិមជាខ្ទង់ទី១កំណត់ថា១០-ឧត្តរ១០ស្មើ២០ឆ្នាំបន្ទាប់ពីខ្ទង់១០ត្រូវរាប់រាយរហូតដល់អាយុអ្នកនោះរួចទាយតាមទិសនីមួយៗ ដោយមានបរិវត្តគឺទី១ស្មើ៤ខែ ដូចនេះបរិវត្តស្មើ១២ខែគឺស្មើមួយឆ្នាំគត់ ។

ទី១ បួនខែហៅដើមឆ្នាំ-ទី២ បួនខែ ហៅកណ្តាលឆ្នាំ ទី៣បួនខែហៅចុងឆ្នាំ អ៊ីចឹងបុរសឆ្នាំថោះនោះអាយុ២៤គឺទំនាយចំទិសទក្សិណការទាយជាលំដាប់តាមសាច់រឿងជាក់ស្តែងដូចខាងក្រោមនេះ

**បូព៌**

ទី១បូពិព្រះចន្ទជាក់ក្នុងព្រះរាម ទ្រឿងទ្រង់លើកធ្នូសិល្ប៍ជ័យ បាននាងសេដាក្សត្រី ជាអគ្គមហេសីជាគូស្នេហា នឹងបានធនធាន បរិពានពីគ្រូអាចារ្យ មេបាចាស់ទុំផងទាំងឡាយ ។

( បានទ្រព្យឬបានគូ) ។

ទី២អាទិត្យកណ្ដាលមធ្យម កាលក្សត្រឧត្ដមចេញចាកបុរី បង់រាជ្យសេដាក្សត្រីក្រុងរាពណ៍អប្រិយលួចយកទៅបាន កុំឱ្យធ្វើដំណើរទៅទិសឦសានក្រែងលោកើតមានអំពល់ព្យាធិ ។

ទី៣ព្រះសុក្រជាន់ក្រៅទិសទី ព្រះរាមភូមីស្ដេចផ្ចាញ់លង្កា ផ្ចាញ់ក្រុងទសមុខ ក្រុងអសុរាបាននាងសេដាស្រីរត្នកល្យាណ ។

**អាគ្នេយ៍**

ទី១អាគ្នេយ៍អង្គារក្នុងស្ថានទំនាយនិទាន នៅភូមិសាលរាជាអភិសេកព្រះរាជបុត្រាឱ្យសោយរាជ្យក្នុងភូមិស្ថានកុំឱ្យទៅទិសអាគ្នេយ៍សម្បត្តិទ្រព្យនឹងបង់ប្រាណបង់ឋាន ។

ទី២ ព្រះចន្ទជាន់ក្នុងកណ្ដាលឋាន ប្រាសអស់រាជទាន នូវខ្ញុំប្រុសស្រី ។

ទី៣អាទិត្យជាន់ក្រៅរាសីព្រះបាទនរប្បតី លង់លក់មរណា**នឹង**មានជំងឺក្ដៅចិត្តខ្លោចផ្សា ឈឺអស់ជើងដៃ ។

*" **នឹង** " ក្នុងទីនេះជាកិរិយានុគ្រោះសម្រាប់និយាយនាំមុខកិរិយាសព្ទ សម្រាប់អនាគតកាលទៅខាងមុខ មានន័យថា **មុខជា** ឬ **ប្រាកដជា** ។*

**ទក្សិណ**

ទី១ទក្សិណពុធក្នុងល្អថ្ងៃព្រះលក្ខណ៍ស្ថិតអោយប្រាង្គប្រាសាទសមនឹងមាន មនុស្សម្នាឧត្តម នឹងមានអ្នកធំឱ្យលាភត្រកាល ។

ទី២អង្គារស្ថិតកណ្តាលព្រះលក្ខណ៍ភូបាលត្រូវម៉ូងក្រសាក់ទល់ទប់ពុំសុខ អាត្មា ទាសីទាសា នឹងបង់ពីប្រាណ ។

ទី៣ព្រះចន្ទជាន់ក្រៅឋាន កាលក្រុងហនុមានយកថ្នាំមកថ្វាយក្សត្រក្សាន្ត បានសុខសប្បាយបាត់ភ័យអន្តរាយស្តេចស្តែងទ្រឿងទ្រង់ ។

**និរតី**

ទី១និរតីព្រះសៅរ៍ជាន់ក្នុងកាលរាពណ៍ទ្រឿងទ្រង់សម្តែងរិទ្ធីកុំឱ្យទៅទិស និរតីអគ្នេយ៍រាសីនឹងកើតអន្តរាយ ។

ទី២ព្រះពុធស្ថិតកណ្តាលឋាន ទំនាយនិទានពីរាពណ៍ប្រែជាព្រាហ្មណ៍ ព្រឹទ្ធាចារ្យឆ្ពោះទៅទិសទក្សិណបានសេដាស្រីរត្នកល្យាណនាំមកនៅឧទ្យាន ចំណេរនៅមាន កើតទុក្ខវែងថ្ងាត់ ។

ទី៣អង្គារជាន់ក្រៅស្ថិតក្រុងរាពណ៍និម្មិតតាំងរិទ្ធី នឹងព្រះនរាយណ៍នរបតី ក្រុងរាពណ៍អប្រិយចេញព្រះរាជា ឱ្យប្រយ័ត្នភ្លើងឆេះគ្រឹហាបង់បុត្រ ភរិយានិងខ្ញុំប្រុសស្រី

**បស្ចិម**

ទី១បស្ចិមជាន់ក្នុងរាសី ព្រហស្បតិ៍សម្តីគឺនាងសេដា ឥសីឱ្យជាភរិយា ស្តេចរាមាសេពសមភិរម្យមេត្រី ថាបើស្វែងលាភទៅទិសនិរតី និងមាន ក្សត្រីពិតឱ្យលាភា។

ទី២ព្រះសៅរ៍ជាន់កណ្តាលពុំជាកាលនាងសេដាក្រុងរាពណ៍លួចបានព្រាត់ប្តី ស្វាមីកល្យាណស្រឡាញ់ពុំបាន មិត្តចូលស្នេហា នាងភ័យនាងភិតឥតឧបមា មានព្រះសវនីយ៍ថា អនិច្ចាក្នុងប្រាណ។

ទី៣ ពុធជាន់ក្រៅឋាន សេដាកល្យាណបានព្រះរាមវិញ ទោះទ្រព្យរបស់ស ម្លាញ់បាត់ហើយឃើញវិញជាលាភស្នេហា។

## ពាយព្យ

ទី១ ពាយព្យ ជាន់ក្នុងសេដាយុស និមិត្តនិងភូមី នឹងបានសម្លាញ់ភ្នាអប្រិយ បានហើយកើតក្តីនឹងបង់ទ្រព្យា ទោះជានាយគេក្តីណា នឹងត្រូវទោសា ហើយបង់ប្រាណ បង់ឋាន។

ទី២ព្រហស្បតិ៍ប្រទានសេដាយុសឱ្យសោយរាជ្យសម្បត្តិជាសុខសួស្តីពេក ក្តាត់នៅក្រែងព្រះមហាក្សត្រនឹងឱ្យរង្វាន់។

ទី៣ព្រះសៅរ៍ស្ថិតកៅក្រៅជាន់បក្សីរួសរាន់កើតទុក្ខទោសាត្រូវព្រះទម្រង់ រាជាលុះដល់មរណាក្សិណក្ស័យព្រះជន្ម។

## ឧត្តរ

ទី១ ឧត្តរសុក្រជាន់ក្នុងឋាន កាលក្រុងហនុមានសុគ្រិពនាំថ្វាយព្រះរាមឱ្យ ទានពណ្ណរាយ មន្ត្រីទាំងឡាយឱ្យទ្រព្យគាប់ចិត្ត។

ទី២ ព្រះរាមកណ្តាលឋាន ស្ថិតហនុមានមានរឹទ្ធិ ទៅកាច់ឧទ្យានឥន្ទជិត ថ្លែងសរ ចាប់បានសំពត់រុំប្រាណ យកភ្លើងដុតដាលឱ្យឆេះអស់អង្គរន្ទាលឱ្យក្រែងសព្វកាលប្រយ័ត្នភ្លើងឆេះហោង។

ទី៣ព្រះហស្បតិ៍សម្តីកាលក្រុងហនុមាន ទ្រឿងទ្រង់បានរាជលង្កាបានលាភទ្រព្យផង ជាស្តេចរាមាឱ្យលាភគាប់ចិត្ត។

## ឡៀសាន

ទី១ ឡៀសានជាន់ក្នុងអាទិត្យពិភេកគន់គិតពោលទាយក្សត្រា ក្រុងរាពណ៍ក្រេវក្រោធដោះសាបណ្តេញអនុជា រួសរត់ចាកឋានទៅពឹងព្រះរាមជាប្រធានប្រាសអស់ព្រះរាជទានអរឱ្យរង្វាន់ ខុសនឹងបងធ្វើទាន់រួសរាន់បង់ទ្រព្យធនធាន។

ទី២ព្រះសុក្រជាន់កណ្តាលឋានទំនាយនិទានពីពិភេកបានសោយរាជ្យសម្បត្តិជាសុខសួស្តីពេកក្តាត់ ក្សេមក្សាន្តមូលមិត្ត នឹងញាតិផៅផង។

ទី៣រាហូនិត្យនៅជាន់ក្រៅពិភេកកើតក្តៅលុះដល់មរណា នឹងមានជំងឺរោគាពីមុននាយណានឹងត្រូវក្តីក្តាំហើយបង់ទ្រព្យអ្វីៗ។

ទោសកើតថ្មីពីទិសឧត្តរ។

**(ចប់ក្បួនសាមជាន់ឬក្បួនអង្គរ)**

# អវសានកថា

យប់យន់អធ្រាត្រកាន់តែស្ងាត់អង្គុយសរសេរសៀវភៅម្នាក់ឯងដោយក្តីព្យាយាមខិតខំប្រឹងប្រែងឥតគណនា។ ទីបំផុតរូបខ្ញុំបានទទួលជោគជ័យនៃការចងក្រងរៀបរៀងសៀវភៅ ចំណេះដឹងនានាក្នុងពុទ្ធសាសនាខ្មែរ នៅវេលាម៉ោង១១.៣០នាទីយប់ដោយពិតប្រាកដ។ តាមការប្រមូលយកមកចងក្រងជាសៀវភៅនេះឡើង ខ្ញុំជឿជាក់ថាមិនបានគ្រប់សព្វនោះទេគ្រាន់តែជាការបង្ហាញខ្លះៗ ទាក់ទងទៅនឹងពិធីបុណ្យនីមួយៗ ដែលគេនិយមធ្វើជាហូរហែនាពេលបច្ចុប្បន្ន អមដោយពិធីការជាច្រើន ព្រមទាំងកំណាព្យអប់រំគ្រាន់ជាបទពិចារណាសម្រាប់ជាពន្លឺនៃការរស់នៅជាប្រចាំថ្ងៃ តើគួរធ្វើអ្វីខ្លះ? សម្រាប់សង្គមជាតិ និងសាសនាទុកជាប្រយោជន៏តទៅ ទោះបីការចងក្រងសៀវភៅនេះ ត្រូវចំណាយពេលវេលាជាយូរ មានការលំបាកយ៉ាងណាក្តី ក៏ប៉ុន្តែរូបខ្ញុំមានការរីករាយឥតឧបមា គឺសប្បាយនឹងទឹកចិត្តរបស់ព្រះករុណាគ្រប់ព្រះអង្គ រួមនឹងញាតិញោមពុទ្ធបរិស័ទ អ្នកមានសទ្ធាជ្រះថ្លាចំណាយបច្ច័យផ្ទាល់ខ្លួនគ្រប់ៗរូប ដើម្បីចូលរួមជាធម្មទាន តាំងពីចាប់ផ្តើម រហូតដល់បានសម្រេចនេះ។ សូមជនអ្នកមានសទ្ធាទាំងអស់សម្រេចជាបុណ្យ កុសលជាប្រយោជន៏តាមឧបនិស្ស័យរៀងៗខ្លួនចុះ។

ជាទីបញ្ចប់នេះខ្ញុំជឿជាក់ថា ការចងក្រងជាសៀវភៅនេះ ពិតជាមានខុសត្រង់ណាមួយមិនខាន។ ទោះបីមានការត្រួតពិនិត្យចេញពីស្ថាប័ន

ជំនាញភ្នំពេញក្តី ហេតុដូច្នេះហើយ បើសៀវភៅនេះមានកន្លែងត្រង់ណាខុសក្តីនោះ សូមអស់លោកអ្នកអានគ្រប់រូប មេត្តាខន្តី អភ័យទោស និងសូមជួយផ្តល់មតិរិះគន់ដើម្បីស្ថាបនាសារជាថ្មី ដើម្បីឱ្យស្នាដៃនេះកាន់តែល្អថែមទៀតនៅពេលបោះពុម្ពលើកទី២ និងបានកាន់តែល្អប្រសើរជាពុំខានឡើយ ។សូមព្រះករុណាគ្រប់ៗព្រះអង្គនិងញាតិញោមសប្បុរសជនគ្រប់ទិសទី សូមទទួលបានជោគជ័យ ឈ្នះអស់មារសត្រូវ គ្រប់បែបយ៉ាង និងបានពើបប្រទះជួប នូវពុទ្ធពរទាំងឡាយ៤ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

*សូមអរព្រះគុណ និងសូមអរគុណ !*

# ឯកសារយោង

-ជំនួយសតិ ភាគ ៥ ( អគ្គបណ្ឌិត ប៊ុត សាវង្ស)

-ឧបមាសុភាសិត ( អគ្គបណ្ឌិត ប៊ុត សាវង្ស)

-អភិធម្មត្ថសង្គហៈ ៩បរិច្ឆេទ ( ភិក្ខុ អគ្គធីរោ គង់ សុមិត្ត)

-គិហិបដិបត្តិ ពិស្តារពិសេស : ( កៅ ឈឺន)

-ដឹងគុណ តបគុណ និង និយមន័យកំណាព្យ ( សាមណេរ ឆិម ប៊ុនឆា)

-ខ្ញុំតែងជូនអ្នក ( សាមណេរ សា ចាន់ រ៉ាត់)

-ធម្មវិន័យ ត្រី-ទោ-ឯក ( ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ)

-អានិសង្សសាមសិប ( ការបោះពុម្ពផ្សាយតូបផ្សារអូរឬស្សី)

-សាមណេរវិន័យ ( ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ)

-ប្រជុំនានាធម្មសង្គហៈ ( កេរ្តិ៍មរតក ព្រះគ្រូធម្មាចារ្យ ចក់ កន)

-ព្រះរាជជីវប្រវត្តិសម្តេចព្រះសង្ឃរាជ ( ភិក្ខុ លឹម វាសនា វត្តអង្គប្រិយ )

-ទម្លាប់អាចារ្យ ( ញាណភឿន និង ម៉ម ឆៃ)

-ប្រជុំបុញ្ញប្រវត្តិ ( ឃិន វ៉ន់)

-មាឃបូជា-វិសាខបូជា-អភិសេក ( សម្តេចព្រះសង្ឃរាជ ជោតញ្ញាណោ ជួន ណាត )

-ប្រជុំភាណវារៈ ( សែម សូរ)

-រំដោះគ្រោះទាំង១២ឆ្នាំ ( ការបោះពុម្ពផ្សាយតូបផ្សារអូរឬស្សី)

-គហិប្បដិបត្តិឃរាវាស ( អាស្រមមហាឧត្តម)

-មគ្គុទ្ទេសក៍ជីវិត ( ឥន្ទបញ្ញោ ភិក្ខុ ហេង មណីចិន្តា)

-ប្រជុំធម៌បទ ( ការបោះពុម្ពផ្សាយតូបផ្សារអូរឫស្សី)

-អានិសង្ស១២៥ ( ភិក្ខុ ធម្មបាលោ សាន សប្បាយ)

-ព្រះធម្មបទ ៣០គាថា ( ភិក្ខុ វជិរប្បញ្ញោ សាន សុជា )

-មាគ៌ាជីវិតនៃព្រះពោធិសត្វ ( បណ្ឌិត កុល ផេង)

-ស្រីហិតោបទេស ( ភិក្ខុ ប៉ាង ខាត់ វីរិយបណ្ឌិតោ)

-ទស្សនៈ ឯណាទៅនរក-សួគ៌ ? ( រម្យវីរិយ រឿនមុនីរម្យ)

-វចនានុក្រមខ្មែរ ( សម្តេចព្រះសង្ឃរាជ ជួន ណាត ជោតញ្ញាណោ)